# របាយការណ៍សិទ្ធិមនុស្សឆ្នាំ ២០០៧ ដែលបានផ្សព្វផ្សាយដោយ ការិយាល័យនៃលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ ថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨

## អារម្ភកថា

ដូចដែលលោកប្រធានាធិបតី ប៊ូស មានប្រសាសន៍ថា "សេរីភាពអាចត្រូវបានប្រឆាំង និងសេរីភាពអាចត្រូវបានពន្យាពេល ប៉ុន្តែសេរីភាព មិនអាចត្រូវបានប្រកែកឡើង ។ " នៅថ្ងៃអនាគត ប្រជាពលរដ្ឋដែលបូជាដើម្បីសេក្តីថ្លៃថ្នូរ និងសិទ្ធិរបស់ខ្លួននឹងទទួលជោគជ័យ ខណៈពេលដែល Havels និង Mandelas បានធ្វើមុនពួកគេ ។ ដូចជាតស្ស៊ូរជនល្បីទាំងនោះ អ្នកការពារសិទ្ធិមនុស្សនៅ សព្វថ្ងៃនេះជាច្រើនរូបត្រូវបានគេរិះគន់ និងធ្វើទុក្ខបុកម្នេញ និងចោទថាជាជនក្បត់ និងជាគោលដៅនៃការគាបសង្កត់ដោយ រដ្ឋាភិបាលរបស់ខ្លួន ដោយគ្រាន់តែសុំទទូចចង់បានសេរីភាព ដែលត្រូវចែងនៅក្នុងសេក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តី ពីសិទ្ធិមនុស្ស ។ ជនស្នេហាជាតិដែលមានគ្មានភាពអត់ធ្មត់ទាំងនេះគឺកំលាំងជំរុញមួយសម្រាប់ប្រជាពលរដ្ឋរបស់ ខ្លួននិងបទដ្ឋាន ក៏រិតខ្ពស់ដែលពួកគេកំណត់ បន្តផ្តល់ក្តីសង្ឃឹមដល់ប្រជាជានគ្រប់ទីកន្លែង ដែលធ្វើការប្រកបដោយសន្តិវិធីដើម្បីសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់ខ្លួន ។

តម្លៃទាំងនេះគឺជាទាយជ្ជទានមូលដ្ឋានរបស់មនុស្សទាំងអស់ និងជាវិធីពិតប្រាកដបំផុតដើម្បីការពារ និងរក្សាតម្លៃទាំងនោះតាមរយៈអភិបាលកិច្ចប្រជាធិបតេយ្យ ស្របច្បាប់ និងមានប្រសិទ្ធភាព ។ ដើម្បីឱ្យមានភាពពិតប្រាកដនោះគ្មានជាតិណាមួយមានមាគ៌ាទៅកាន់លទ្ធិប្រជាធិបតេយ្យប្រកបរលូន ឬត្រង់ឡើយ ។ ត្រូវតែមានឧបសគ្គនិងការរារាំងនៅតាមផ្លូវ ។ ទោះបីជានៅក្រោម កាលៈទេសៈណាក៏ដោយវាមិនងាយស្រួលនឹងកែប្រែឧត្តមគតិប្រជាធិបតេយ្យឱ្យក្លាយទៅជាស្ថាប័នប្រជាធិបតេយ្យប្រកបដោយសិទ្ធភាពខ្ពស់ទេ ។ ការផ្លាស់ប្តូរទៅកាន់ប្រជាធិបតេយ្យអាចមានការរំខាន ហើយភាពរីកចំរើនអាចរអាក់រអួលដោយសារតែអស្ថិរភាព និង អសន្តិសុខ ភាពក្រីក្រ និងជំងឺ ។ រដ្ឋាភិបាលមានអំពើពុករលួយ ឬដោយគ្មានធនធានគ្រប់គ្រាន់ អាចខ្វះនូវការបំពេញនូវក្តីបំណងរបស់ប្រជាពលរដ្ឋ ដែលបណ្តាលឱ្យពួកគេបាត់បង់ជំនឿចិត្តលើការសន្យាថាមានជីវភាពល្អប្រសើរ ។ អ្នកដឹកនាំ ដែលមានការ តាំងចិត្តមិនបានគ្រប់គ្រាន់ក្នុងការកែប្រែ អាចមានទំលាប់យកលិទ្ធិផ្តាច់ការ ឬងាកចេញពីនីតិរដ្ឋប្រកបដោយគ្រោះមហន្តរាយ ។ រដ្ឋាភិបាលផ្សេងទៀតមិនបានចាត់វិធានការដំបូងដើម្បីធានានូវសិទ្ធិប្រជាពលរដ្ឋរបស់ខ្លួនទេ ។ បញ្ហាប្រឈមទាំងនេះចំពោះសិទ្ធិមនុស្ស និងបញ្ហាប្រឈមផ្សេងទៀតត្រូវកត់ត្រាយ៉ាងពេញលេញនៅក្នុងរបាយការណ៍ថ្នាក់ជាតិជាបន្តបន្ទាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ឯកសារនេះត្រូវប្រមូល និងសរសេរឡើងដោយមានជំនឿចិត្តថា គ្មានប្រទេសណាមួយនៅលើលោកនេះត្រូវបានថ្កោលទោសជានិច្ចកាលដោយសារតែការគាបសង្កត់នោះទេ ។ ការផ្លាស់ប្តូរត្រូវការពេលវេលា ប៉ុន្តែការផ្លាស់ប្តូរនឹងត្រូវតែកើតមាន ។ ដរាបណាប្រជាពលរដ្ឋជុំវិញពិភពលោកគាំទ្រតម្លៃជាសកលនៃសិទ្ធិមនុស្សតែងតែមានក្តីសង្ឃឹម ហើយយើងបន្តជឿថា វាគឺជាភារកិច្ចរបស់រដ្ឋាភិបាលដែលមានការទទួលខុសត្រូវគ្រប់ទីកន្លែងដើម្បីគាំទ្របុរសនិងស្ត្រីក្លាហាន ទាំងនេះ ។

នៅក្នុងន័យនេះ ខ្ញុំសូមផ្ញើ*របាយការណ៍ថ្នាក់ជាតិស្តីពីការអនុវត្តសិទ្ធិមនុស្ស ឆ្នាំ ២០០៧* របស់ក្រសួងការបរទេសជូនសភាសហរដ្ឋអាមេរិក ។

ខនដូលីហ្សារ៉ាយ

*រដ្ឋមន្ត្រីក្រសួងការបរទេស*

## សេចក្តីផ្តើម

ការគោរពសិទ្ធិមនុស្សនិង សេរីភាពជាមូលដ្ឋាន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្សគឺដូចទៅនឹងប្រសាសន៍របស់លោក ប៊ូស ដែលបានថ្លែងអំពី " មូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និង សន្តិភាពនៅលើពិភពលោក " ។ សព្វថ្ងៃនេះ គ្រប់ទ្វីបទាំងអស់ បុរសនិងស្ត្រី កំពុងធ្វើញឹកញាប់ដើម្បីជំនះលើរាល់បញ្ហាគ្រប់យ៉ាង និងប្រឈមមុខនឹងគ្រោះថ្នាក់ផងដែរ ដើម្បីទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ដើម្បីដើរតាម មនសិការរបស់ពួកគេ និងអាចបញ្ចេញ មតិដែលជាគំនិតរបស់ខ្លួនដោយគ្មានភាពភ័យខ្លាច ដើម្បីជ្រើសរើសអ្នកណាដែលអាចដឹកនាំពួកគេបានហើយធ្វើអោយអ្នកដឹកនាំ ទាំងនោះមានទំនួលខុសត្រូវ និងដើម្បីទទួលបាននូវយុត្តិធម៌ស្មើៗគ្នាក្នុងន័យច្បាប់ ។

លើសពីនេះទៅទៀត លិទ្ធិប្រជាធិបតេយ្យ ត្រូវបានគេចាត់ទុកថា ជាទំរង់នៃរដ្ឋាភិបាលដែលមានសមត្ថភាពក្នុងការធានាអោយមានសិទ្ធិទាំងឡាយ និងសេរីភាពជាមូលដ្ឋាន ។ គ្មានទំរង់រដ្ឋាភិបាលណាមួយ ដែលមិនមានកំហុសនោះទេ ។ លទ្ធិប្រជាធិបតេយ្យគឺជាប្រព័ន្ធមួយរបស់រដ្ឋាភិបាលដែលបង្កើតឡើងដោយប្រជាពលរដ្ឋ និងជារបស់ប្រជាពលរដ្ឋដែលផ្អែកទៅលើគោលការណ៍ដែលថាមនុស្សជាតិ មានសិទ្ធិ ក្នុងការកែប្រែនូវអនាគតរបស់ពួកគេផ្ទាល់  ប៉ុន្តែដោយសារពួកគេជាភាវៈធម្មជាតិដែល ប្រព្រឹត្តខុសហេតុដូច្នេះហើយត្រូវតែមានចំនុចត្រូវកែលំអ ។ ប្រជាពលរដ្ឋរបស់យើងលើកឡើងនូវប្រវត្តិសាស្ត្រដែលប្រកបដោយ មោទនភាពអំពីការតស៊ូនៅគ្រប់ជំនាន់ តាំងពីមានការកកើតឡើងនូវជាតិរបស់យើងមកម្លេះដើម្បីធ្វើឱ្យមានការអនុវត្តនៃលិទ្ធិប្រជាធិបតេយ្យ ដែលមានភាពជិតស្និទ្ធទៅនឹងគោលការណ៍ដែលយើងបានគោរព ទោះបីជាយើងត្រូវប្រឈមមុខទៅនឹងភាពអយុត្តិធម៌និងឧបសគ្គជាច្រើន ដែលកើតមាននៅក្នុងយុគសម័យកាលថ្មីក៏ដោយ ។

នៅពេលដែលយើងចេញផ្សាយនូវរបាយការណ៍នេះ ក្រសួងការបរទេសបានគិតពិចារណាចំពោះការរិះគន់ទាំងក្នុងស្រុកនិង ជាអន្តរជាតិទៅលើស្ថានភាពសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិក ។ រដ្ឋាភិបាលអាមេរិក នឹងបន្តធ្វើការទទួលយក ចំពោះការព្រួយបារម្ភទាំងឡាយអំពីការអនុវត្តរបស់យើង រួមមានសកម្មភាពដែលយើងបានប្រព្រឹត្តដើម្បីការពារជាតិ ពីការគំរាមកំហែងភេរវកម្មជាសកល ។ រាល់ច្បាប់, បទបញ្ជា, និងការអនុវត្ត ទាំងឡាយ របស់យើងបានប្រែលប្រួល យ៉ាងច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ហើយយើងក៏បន្តការប្រឹងប្រែង ការពារប្រជាពលរដ្ឋ អោយជៀសផុតពីការវាយប្រហារណាមួយ ដោយយើងផ្តល់ការយកចិត្តទុក ដាក់លើការប្តេជ្ញាគោរព សិទ្ធិមនុស្ស និងសារៈសំខាន់ នៃសេរីភាព ។ ដើម្បីជាផ្នែកមួយនៃការខិតខំប្រឹងប្រែងនេះ សហរដ្ឋអាមេរិកដាក់ជូនរបាយការណ៍ផ្សេងៗ ជូនដៃគូអង្គការអន្តរជាតិ ដើម្បីអោយស្របទៅតាមកាតព្វកិច្ចអាមេរិក ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងៗ ដែលអាមេរិកជាបក្សសម្ព័ន្ធ ។

យើងចាត់ទុករាល់ការប្តេជ្ញាចិត្តការពារ សិទ្ធមនុស្សយ៉ាងម៉ឹងម៉ាត់ ដោយយើងអោយតំលៃលើតួនាទីសំខាន់ នៃសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយផ្សាយឯករាជ្យ ដើម្បីបញ្ជាក់ពីការខិតខំយ៉ាងស្មោះត្រង់ របស់យើងលើការប្តេជ្ញាទាំងនោះ ។ យើងមិនចាត់ទុក

មតិយោបល់ បញ្ចេញដោយសហគមន៍អន្តរជាតិអំពីដំណើរការប្រព្រឹត្តរបស់យើងថាជាការជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងគេឡើយ ហើយរដ្ឋាភិបាលដទៃទៀត ក៏មិនគួរគិតថាមតិយោបល់លើដំនើរប្រព្រឹត្តទៅរបស់គេ ថាជាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងឡើយ ។ ជាការពិតណាស់ ក្រោមការប្រកាសជាសកលអំពីសិទ្ធិមនុស្ស វាជាសិទ្ធិ និងការទទួលខុសត្រូវ របស់មនុស្សគ្រប់រូបក្នុងសង្គមដើម្បីគាំទ្រ គោរពសិទ្ធិ និងសេរីភាពទាំងនេះ និងដើម្បីការពារ ភាពជាសកល និងការទទួលស្គាល់ និង ការអង្កេតមើលទៅតាមយុទ្ធនាការបន្តបន្ទាប់ ជាលក្ខណៈជាតិនិងអន្តរជាតិ ។

របាយការណ៏ដែលត្រូវបានកំនត់ដោយសភាអាមេរិកនេះ  រៀបរាប់អំពី ដំនើរការប្រព្រឹត្តទៅ នៃរដ្ឋាភិបាលទូទាំងពិភពលោកក្នុងការអនុវត្ត ការប្តេជ្ញាគាំពារសិទ្ធិមនុស្ស ជាអន្តរជាតិរបស់គេនាឆ្នាំ២០០៧ ។ របាយការណ៏នេះនឹងផ្តល់អោយរដ្ឋាភិបាលអាមេរិក សំរាប់ការបង្កើតច្បាប់ និងក៏អាចជាឯកសារយោងសំរាប់រដ្ឋាភិបាលដ៏ទៃទៀត, វិទ្យាស្ថានអន្តររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល មនុស្សទូទៅ, នឹងប្រព័ន្ធផ្សព្វផ្សាយ ។  របាយការណ៏ របស់ប្រទេសនីមួយ១ រៀបរាប់សំរាប់តែប្រទេសរបស់ខ្លួន ប៉ុណ្ណោះ ។ ដោយឡែក ការអង្កេតដកស្រង់មួយចំនួន អាចត្រូវបានទាញចេញ ពីរបាយការណ៏ រួមមាន វឌ្ឍនភាពនៃសិទ្ធិមនុស្ស និងគោលការណ៏ប្រជាធិបតេយ្យទូទាំងពិភពលោក ។ តួយ៉ាង ដូចប្រទេសមួយចំនួន ដែលយើងផ្តល់ខាងក្រោមនេះ គឺក្នុងន័យជួយបំភ្លឺ មិនមែនជាការមូលបង្កាច់ ឬការបន្ទុះបង្អាប់ទេ ។

ក្នុងឆ្នាំ ២០០៧ ប្រទេសទាំងឡាយ ដែលធ្លាប់មានបទពិសោធន៏ អាក្រក់ ក្នុងការអនុវត្តសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យបានចុះក្នុងទំព័រព័ត៌មានសំខាន់១ ។ ប្រទេសមួយចំនួន បានបង្កើន ក៏រិតប្រសើរធំសំបើម បើទោះបីជា នៅមានការប្រណាំងប្រជែងគ្នាដ៏ធ្ងន់ធ្ងរ តែប្រទេសមួយចំនួន បានតស៊ូយ៉ាងស្វិតស្វាញ នៅក្នុងចន្លោះនេះ ដែលបង្កើននូវដំនើរការប្រព្រឹត្តទៅ នឹងរងគ្រោះពីឧបសគ្គរាំងស្ទះមួយចំនួន ។ យើងដកស្រង់កថាខណ្ឌ ខាងក្រោម ដើម្បីបំភ្លឺះ

ក្នុងពិធីចូលកាន់តំណែងជាប្រធានាធិបតីក្នុងប្រទេស ម៉ូរីតានី កាលខែមេសា ក្រោមការបោះឆ្នោតដែលត្រូវបានសហគមន៏អន្តរជាតិយល់ស្របទាំង ស្រុងថា ជាការ បោះឆ្នោតដោយសេរី និង យុត្តិធម៌ បានសំគាល់នូវបំលាស់ប្តូរ ទៅរកសិទ្ធិប្រជាធិបតេយ្យជាលើកដំបូង ក្នុងរយៈ ពេល ៥០ឆ្នាំនៃឯករាជ្យប្រទេសនេះ ។ សំលេងឆ្នោតទាំងនេះ រួមជាមួយការបោះឆ្នោតសភានាខែ វិច្ឆិកា ២០០៦ បានបង្កើតនូវ បរិយាកាសសមស្របមួយដែលការចូលរួមក្នុងនយោបាយមានភាពទូលំទូលាយ និងនៅតែមានការរាប់បញ្ចូល ។ រដ្ឋាភិបាលថ្មី បានដឹកនាំ ដើម្បីផ្តោតការយកចិត្តទុកដាក់លើការដោះស្រាយ ជាមួយនឹងបញ្ហាសិទ្ធិមនុស្សផ្សេង១ ដូចជាការសេសសល់នៃវណ្ណៈទាសករ ភាពមិនស្មើគ្នានៃសិទ្ធិនយោបាយ និងសង្គមរវាងជនជាតិស្បែកខ្មៅអំបូរ មួរ (Moors) និងជនជាតិ អាហ្វ្រូបម៉ូរីតានី និងការបញ្ជូនជនភៀសខ្លួន ម៉ូរីតានី ដែលកំពុងរស់នៅក្នុងប្រទេស សេណេហ្កាល់ ទៅកាន់ប្រទេសកំណើតរបស់ខ្លួនវិញ ។ ប្រទេស ហ្កាណា បានប្រារព្ធពិធីខួបទី៥០ នៃ រដ្ឋឯករាជ្យរបស់ប្រទេសនេះក្នុងឆ្នាំ២០០៧ ។ កាលពី១៥ មុននេះ គេបានឃើញការបោះឆ្នោតដោយសេរី បែបប្រជាធិបតេយ្យជាបន្តបន្ទាប់, ការកើតឡើងនូវសង្គមស៊ីវិល ប្រកបដោយសកម្មភាព និងថាមពល និងការប្តេជ្ញាស្វែងរក កំនែទំរង់យូរអង្វែងតាមរដ្ឋាភិបាលដែល មានការទទួលខុសត្រូវចំពោះផ្នែកផ្សេង ១ របស់រដ្ឋាភិបាល ។  ក្រោមការដឹកនាំរបស់ប្រធានាធិបតី Kufuor ដែលត្រូវបានហាមឃាត់ដោយរដ្ឋធម្មនុញ្ញមិនអោយឈរឈ្មោះសំរាប់អណ្តត្តិទីបី ហើយដែលបានបំរើជាប្រធានសហព័ន្ធជនជាតិអាហ្វ្រិក (African Union Chairman)  រហូតមក

ដល់ពេលថ្មីៗនេះ ។ ប្រទេសហ្គាណា ក៏មានមុខនាទីយ៉ាងសំខាន់មួយទៀត ក្នុងការគាំទ្រផ្សព្វផ្សាយ និងសិទ្ធិប្រជាធិបតេយ្យ និងសន្តិសុខ នៅក្នុងបញ្ហាប្រទេសអាហ្វ្រិកផ្សេងៗ ទៀតដែរ ។

ជាផ្នែកមួយនៃដំនើរកំនែរទំរង់យ៉ាងទូលំទូលាយ នៅក្នុងប្រទេស ម៉ារុក (Morocco) ការបោះឆ្នោតសភា ខែកញ្ញាគឺមាន តំឡាភាព និងរួមជាមួយនូវការកើនឡើងនៃឥទ្ធពលពីគណៈកម្មការក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ បើទោះបីជាអ្នកអង្កេតការបាន សង្កេតឃើញមាន បញ្ហាមួយចំនួន ក្នុងពេលយុទ្ធនាការ បោះឆ្នោត និងមានរបាយការណ៏ ពីការទិញសន្លឹកឆ្នោត រួមទាំងមានការបង្ខិតបង្ខំនានា ក៏រដ្ឋាភិបាលបានបោះពុម្ពផ្សាយនូវស្ថិតិចូលរួម និងលទ្ធផលសំឡេងឆ្នោតខ្ពស់មានប្រជាប្រិយភាព តាមស្រុកក្នុងរយះពេល ៤៨ម៉ោង ហើយគណបក្សទាំងអស់យល់ស្របថា លទ្ធផលចុងក្រោយគឺត្រឹមត្រូវ ។ កំនែទំរង់ ពន្ធធនាគារខ្លះៗ ដោយរាប់បញ្ចូលទាំងការភ្ជាប់ជាមួយអង្គការក្រៅរដ្ឋាភិបាល ត្រូវបានដាក់ទោសតាមការប្តេជ្ញាជាសាធារណៈ ដើម្បីជំរុញការអនុវត្តវប្បធម៌សិទ្ធិមនុស្ស ។ យ៉ាងណាក៏ដោយ បញ្ហាសិទ្ធិមនុស្សនៅតែកើតមាន ជាបន្ត ដូចជាការហាមឃាត់ដាក់កំហិតលើសេរីភាពសារពត៌មាន និង របាយការណ៏ស្តីអំពីការបំពានសិទ្ធិមនុស្ស ក្នុងតំបន់វាលខ្សាច់សាហារ៉ា បែកខាងជើងប្រទេសម៉ារ៉ុក ។

ប្រទេសហាយទី បានធ្វើការបោះឆ្នោតបីដងក្នុងឆ្នាំ២០០៦ រួមមានការបោះឆ្នោតជ្រើសរើសសភា និងប្រធានាធិបតីថ្មី ។ ដោយឡែក ក្នុងឆ្នាំ២០០៧ ប្រទេសហាយទី បរាជ័យក្នុងការ ធ្វើការបោះឆ្នេត ជ្រើសរើសព្រឹទ្ធសភា ។

រដ្ឋាភិបាលបណ្តោះអាសន្នក្នុងប្រទេសនេប៉ាល់ បានពន្យារពេលចំនួនពីរដង ដើម្បីបង្កើតសភាពេញលេញមួយ បន្ទាប់ពីកិច្ចព្រមព្រៀង សន្តិភាព នាខែវិច្ឆិកា ២០០៦ បានបញ្ចប់ការប្រឆាំងរដ្ឋាភិបាល អស់រយៈពេលជាច្រើនទសវត្សមក ។

ខណៈពេលដែលការរំលោភដោយកងកម្លាំងសន្តិសុខ បានកាត់បន្ថយយ៉ាងច្រើន សមាជិកនៃអ្នកកាន់លទ្ធិម៉ៅនិយម និងសម្ព័ន្ធកុម្មុយនិស្តនៅក្មេងខ្ចីបានចូលរួមចលនាលទ្ធិម៉ៅនិយម ក៏ដូចក្រុមតូចៗ ដទៃទៀតផងដែរ ជារឿយៗ ក៏មានក្រុមប្រដាប់អាវុធដែលប្រកាន់ខ្ជាប់សីលធម៌ចូលរួមចលនានេះផងដែរ បានរំលោភសិទ្ធិមនុស្ស ដ៏ធ្ងន់ធ្ងរមួយចំនួន និងជាប់ទាក់ទងក្នុងការវាយប្រហារ ប្រឆាំងនឹងជនស៊ីវិល មន្ត្រីរដ្ឋាភិបាល សមាជិកក្រុមជនជាតិភាគតិចមួយចំនួន វាយប្រហារគ្នាទៅវិញទៅមក ឬក្រុមអ្នកប្រកាន់លទ្ធិម៉ៅនិយមជាអ្នកវាយប្រហារ ។ ដោយសារកង្វះការគាំទ្រផ្នែកនយោបាយ ជារឿយៗមន្ត្រីប៉ូលីសស្ទាក់ស្ទើរក្នុងការធ្វើអន្តរាគមន៍ក្នុងការវាយប្រហារនេះ ជាពិសេសក្នុងការប្រឆាំងនឹងក្រុមអ្នកប្រកាន់លទ្ធិម៉ៅនិយម ។ រដ្ឋាភិបាល បានចាត់វិធានការដ៏មានប្រសិទ្ធភាពមួយ ដោយបានតែងតាំងអភិបាលខេត្តឱ្យធ្វើការជាដៃគូជាមួយ ស្ថងការទទួលខុសត្រូវសិទ្ធិមនុស្សថ្នាក់ជាតិ (NHRC) នៅក្នុងខែកញ្ញា ប៉ុន្តែរដ្ឋាភិបាល មិនបានដោះលែងមនុស្សដែលបានបាត់ខ្លួនចំនួនប្រហែលជា ៧០០នាក់ ដែលបានបញ្ជាក់អត្តសញ្ញាណ ដោយអង្គការសហប្រជាជាតិ និងស្ថងការទទួលខុសត្រូវសិទ្ធិមនុស្សថ្នាក់ជាតិ នៅក្នុងឆ្នាំ ២០០៦ នោះទេ ។ ការលើកលែងទោសដល់អ្នករំលោភសិទ្ធិមនុស្ស ការគម្រាមកំហែងប្រឆាំងសារព័ត៌មានការចាប់មនុស្សតាម តែអំពើចិត្ត និងការដាក់ឃុំឃាំងមនុស្សមុនការកាត់សេចក្តីរយៈពេលយូរ ទាំងអស់នេះ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរ ។

នៅក្នុងប្រទេសហ្សកហ្ស៊ី ជំហានដំបូងនៃសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ មិនស្មើគ្នាទេ កំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋាភិបាល បាន

ធ្វើឱ្យប្រសើរឡើង នៅក្នុងតំបន់ខ្លះ នៅអំឡុងពេលប៉ុន្មានឆ្នាំនេះ ។ រដ្ឋាភិបាល បានបើកមហាវិទ្យាល័យយុត្តិធម៌ ដើម្បីបណ្តុះបណ្តាលចៅក្រម និងសភាដែលអនុម័តច្បាប់ ដែលបានហាមប្រាមមិនឱ្យមានទំនាក់ទំនងរវាងចៅក្រម និងបណ្តាភាគីដែលជាប់ទាក់ទងនឹងករណីនៅខាងក្រៅបន្ទប់តុលាការ និងបណ្តុះបណ្តាលក្រមសីលធម៌របស់ចៅក្រម ។ មានការគោរពសេរីភាពក្នុងការបញ្ចេញមតិ សារព័ត៌មាន និងការប្រជុំ ទោះបីយ៉ាងណាក៏ដោយ ក៏មានការទទួលរងនូវវិបត្តិនយោបាយដែរ នៅពេលដែលប៉ូលីស និងអ្នកតវ៉ា បានប៉ះទង្គិចគ្នា ហើយរដ្ឋាភិបាល បានប្រើកំលាំងហួសហេតុ ដើម្បីបង្ក្រាបក្រុមបាតុកម្ម រដ្ឋាភិបាល បានផ្អាកជាបណ្តោះអាសន្នស្ទើរតែគ្រប់ការចាក់ផ្សាយទាំងអស់របស់ស្ថានីយ៍ទូរទស្សន៍ ព្រមទាំងផ្អាកស្ថានីយ៍ពីរផ្សេងទៀត និងបានប្រកាសរដ្ឋមានអាសន្នជាបណ្តោះអាសន្ន ។ នៅពេលដឹងថា មានវិបត្តិនយោបាយ ប្រធានាធិបតី Saakashvili បានលាលែងពីដំណែង ហើយបានអំពាវនាវឱ្យប្រញាប់មានការបោះឆ្នោតជ្រើសរើសប្រធានាធិបតីសារជាថ្មី ។

ទោះបីជា កំណត់ត្រាសិទ្ធិមនុស្ស និងប្រជាធិបតេយ្យរបស់ប្រទេស គៀហ្ស៊ីស្ថាន បានធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ នៅបន្ទាប់ពីការបោះឆ្នោតជ្រើសរើសប្រធានាធិបតី នៅឆ្នាំ ២០០៥ក៏ដោយ ក៏នៅឆ្នាំ ២០០៧ ឃើញមានការបន្តស្ថានភាពពីឆ្នាំ ២០០៦ ដែលបានបញ្ជាក់យ៉ាងច្បាស់ ដោយសារការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីដាក់កម្រិតលើការប្រមូលផ្តុំគ្នា ដោយសន្តិភាព ការឃុំឃាំងអ្នករៀបចំគម្រោង និងបានប្រញាប់ផ្លាស់ប្តូរធម្មនុញ្ញ ច្បាប់បោះឆ្នោត និងការរៀបចំរដ្ឋាភិបាល ។ ខណៈពេលដែលរដ្ឋាភិបាល បានគោរពសេរីភាពខាងការបញ្ចេញមតិជាទូទៅ បែរជាមានសម្ពាធលើប្រព័ន្ធសារព័ត៌មានឯករាជ្យ បានកើនឡើងទៅវិញ ។ អង្គការសំរាប់សន្តិសុខ និងសហប្រតិបត្តិការនៅក្នុងអឺរ៉ុប (OSCE) និងអ្នកសង្កេតការណ៍បោះឆ្នោតលោកខាងលិច និងអ្នកពិនិត្យមើលក្នុងស្រុកឯករាជ្យ បានរាយការណ៍ថា មានការរំលោភបានរាលដាលដ៏ធ្ងន់ធ្ងរ នៅក្នុងប្រជាមតិធម្មនុញ្ញខែតុលា ខណៈពេលដែលមានការបោះឆ្នោតសភាទូទាំងប្រទេស នៅក្នុងខែធ្នូ ដែលមិនបានបំពេញតាមបទដ្ឋានអន្តរជាតិ ។

នៅក្នុងប្រទេសរុស្ស៊ី មានអំណាចវិមជ្ឈការនៅក្នុងផ្នែកនីតិប្រតិបត្តិ អនុលោមតាមសភា Duma អំពើពុករលួយ និងសកម្មភាពជ្រើសរើស នៅក្នុងការពង្រឹងច្បាប់ តម្រូវការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលឱ្យបានច្រើន ។ មានការរុកគួនដល់អង្គការមួយចំនួន និងការដាក់កម្រិតលើប្រព័ន្ធសារព័ត៌មាន បានបន្តកាត់បន្ថយការទទួលខុសត្រូវរបស់រដ្ឋាភិបាល ចំពោះពលរដ្ឋរបស់ខ្លួន ។ ដោយមានកន្លែងចែកចាយសារព័ត៌មានផ្ទាល់ខ្លួន ធ្វើឱ្យមានការជះឥទ្ធិពលដល់ម្ចាស់ហាងដែលលក់សារព័ត៌មាន និងមានការរុកគួន និងមានការគម្រាមកំហែងដល់អ្នកសារព័ត៌មាន ចំពោះការតិទៀន រដ្ឋាភិបាលបានបន្តរឿបសង្កត់សេរីភាពខាងសារព័ត៌មាននៅប្រទេសរុស្ស៊ី ។ ការស្លាប់របស់អ្នកសារព័ត៌មាន នៅតែពុំទាន់មានដំណោះស្រាយ ។ ច្បាប់ស្តីពីអ្នកនិយមជ្រុល ត្រូវបានប្រើប្រាស់ ដើម្បីកំណត់សេរីភាពខាងសារព័ត៌មាន និងការបង្កើតសមាគម ។ រដ្ឋាភិបាល បានដាក់កម្រិតយ៉ាងធ្ងន់ធ្ងរលើលទ្ធភាពរបស់គណបក្សប្រឆាំងនយោបាយ និងបេក្ខជន ដែលចង់ចូលរួមដំណើរការនយោបាយនេះ ។ ការបោះឆ្នោតរបស់សភា Duma នៅខែធ្នូធ្វើឱ្យមានបញ្ហាគួរឱ្យកត់សម្គាល់ នៅអំឡុងពេលធ្វើយុទ្ធនាការបោះឆ្នោត ដែលរួមមានការរំលោភផ្នែកធនធានរដ្ឋបាល ហើយមានភាពលំអៀងខាងគណបក្សបង្រួបបង្រួមរុស្ស៊ី ដែលគាំទ្រដោយលោកប្រធានាធិបតេយ្យ Putin មានការរុកគួនគណបក្សប្រឆាំង មិនមានឱកាសស្មើគ្នាសំរាប់គណបក្សប្រឆាំងក្នុងការចុះបញ្ជី និងដំណើរការធ្វើយុទ្ធនាការ និងមានការបន្លំសន្លឹកឆ្នោត ។ អ្នកសង្កេតការអន្តរជាតិ បានធ្វើសេចក្តីថ្លែងការណ៍ថា ការបោះឆ្នោត មិនមានភាពយុត្តិធម៌ និងមិនបានបំពេញតាមបទដ្ឋាននៃការ

បោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យទេ ។ កំណត់ត្រាសិទ្ធិមនុស្ស នៅតែមានភាពខ្សោយ នៅក្នុងសាធារណរដ្ឋឆេកឈិន និងមានភាពដុនដាបគួរឱ្យកត់សម្គាល់នៅក្នុង សាធារណរដ្ឋ Ingushetiya ដែលជាកន្លែងមានអំពើហឹង្សាកើនឡើង និងការរំលោភច្បាប់ ដែលប្រព្រឹត្តដោយកំលាំងសន្តិសុខ ។

ទោះបីជា មានការប្តេជ្ញាចិត្តរបស់លោកប្រធានាធិបតេយ្យ Musharraf ចំពោះអន្តរកាលលទ្ធិប្រជាធិបតេយ្យក៏ដោយ ក៏ស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេស ប៉ាគីស្ថាន បានធ្លាក់ដុនដាប នៅអំឡុងខែមីនា ឆ្នាំ ២០០៧ ។ បន្ទាប់ពី លោកប្រធានាធិបតេយ្យ Musharraf បានព្យួរតំណែងជាប្រធានក្រសួងយុត្តិធម៌ នៅក្នុងខែ មីនា ក្រុមមេធាវី និងសង្គមស៊ីវិល បានឆ្លើយតបទៅនឹងការរីករាលដាលការតវ៉ា នៅក្នុងការគាំទ្រតុលាការឯករាជ្យ បណ្តាលឱ្យមានការឃុំឃាំងខ្លួនដ៏ធំ ។ បញ្ហានេះ បណ្តាលឱ្យក្រុមមេធាវីបន្តធ្វើកូដកម្ម ។ នៅក្នុងខែ វិច្ឆិកា លោកប្រធានាធិបតេយ្យ Musharraf បានប្រកាស រដ្ឋមានអាសន្ន មុនពេលតុលាការកំពូលចេញសាលក្រម ថាតើ គាត់មានលទ្ធភាពឈរជាបេក្ខជនប្រធានាធិបតេយ្យ ឬអត់នៅការបោះឆ្នោតម្តងទៀត ។ អំឡុងពេលរដ្ឋមានអាសន្ន លោកប្រធានាធិបតេយ្យ Musharraf បានព្យួររដ្ឋធម្មនុញ្ញ និងការបណ្តេញចោល និងបានចាប់ខ្លួនសមាជិកតុលាការកំពូលចំនួនប្រាំបីរូប រួមមានប្រធានក្រសួងយុត្តិធម៌ និងចៅក្រមតុលាការខេត្តជាន់ខ្ពស់ចំនួន ៤0រូប ។ ក្នុងករណីមានអាសន្នអាជ្ញាធរប្រទេស ប៉ាគីស្ថាន បានចាប់ខ្លួនសកម្មជនគណបក្សនយោបាយប្រឆាំងប្រហែលជា ៦.000 រូប  ព្រមទាំង អ្នកគាំទ្រសិទ្ធិមនុស្ស មេធាវី និងចៅក្រម ។ នៅចុងឆ្នាំ ២០០៧  មានចៅក្រមចំនួន ១១រូបត្រូវបានព្យួរ និងមេធាវីចំនួន ៣រូប ស្ថិតក្នុងការឃុំខ្លួននៅក្នុងផ្ទះ និងកន្លែងចែកចាយលក់សារព័ត៌មាន ត្រូវតម្រូវឱ្យចុះហត្ថលេខាលើច្បាប់ទូន្មានស្តីពីការហាមប្រាមក្នុងការរិះគន់រដ្ឋាភិបាលដើម្បីប្រតិបត្តិបាន ។ ចំណែកឯចំណុចវិជ្ជមានវិញ លោកប្រធានាធិបតេយ្យ Musharraf បានលាលែងតំណែងជាអគ្គមេបញ្ជាការ នៅចុងខែវិច្ឆិកា លោកប្រធានាធិបតេយ្យ Musharraf បានធ្វើសច្ចាប្រណិធានកាន់ តំណែងជាប្រធានាធិបតីឡើងវិញក្នុងនាមជាជនស៊ីវិលមួយរូប និងបានលើកការប្រកាសរដ្ឋមានអាសន្នចេញនៅខែធ្នូ ។ មេដឹកនាំគណបក្សនយោបាយប្រឆាំងសំខាន់ចំនួន ២រូប បានធ្វើមាតុភូមិនិវត្តន៍ និងមានការកំណត់ពេលវេលាការបោះឆ្នោតសភា ។ បន្ទាប់មកទៀត ការបោះឆ្នោតសភា ត្រូវបានពន្យារពេល បន្ទាប់ពីមានការធ្វើឃាតលោក  Benazir Bhutto ។

ការគ្រប់គ្រងឯកសារស្តីពីសិទ្ធិមនុស្សរបស់ប្រទេសបង់ក្លាសដេសកាន់តែអន់ឡើង មួយផ្នែកដោយសារតែស្ថានភាពអាសន្ន និងការពន្យាពេលការបោះឆ្នោត ។ ច្បាប់ស្តីពីអំណាចពេលគ្រាអាសន្ន (Emergency Powers Rules) នៅឆ្នាំ ២០០៧ ដែលដាក់ចេញដោយរដ្ឋាភិបាលនៅខែមករា ហើយមានប្រសិទ្ធិភាពពេញមួយឆ្នាំ បានព្យួរទុកនូវសិទ្ធិ និងសេរីភាពជាមូលដ្ឋានជាច្រើនដោយរួមមានសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិធានានៅក្រៅឃុំ ។ កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ ដែលផ្តួចផ្តើមដោយរដ្ឋាភិបាល បានលើកឡើងនូវក្តីបារម្ភអំពីដំណើរការត្រឹមត្រូវ ខណៈពេលដែលត្រូវទទួលស្វាគមន៍ដោយមានការគាំទ្រពីប្រជាពលរដ្ឋ ។ ភាគច្រើនក្នុងឆ្នាំនោះ រដ្ឋាភិបាលដាក់បំរាមលើសកម្មភាពនយោបាយជាច្រើន បើទោះបីជាគោលនយោបាយនេះត្រូវគេពង្រឹងមិនត្រឹមត្រូវក៏ដោយ ។ នៅពេលដែលមានការធ្លាក់ចុះច្រើននូវចំនួនការសម្លាប់ក្រៅតុលាការដោយកម្លាំងសន្តិសុខ កម្លាំងទាំងនេះត្រូវបានចោទប្រកាន់ពីបទការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដោយរួមមាន ការស្លាប់នៅមន្ទីរឃុំឃាំងការឃាត់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត ហើយនិងការរំខានពីអ្នកកាសែត ។

នៅក្នុងប្រទេសស្រីលង្កា ការគោរពរបស់រដ្ឋាភិបាលចំពោះសិទ្ធិមនុស្សបានបន្តធ្លាក់ចុះ ខណៈពេលដែលជម្លោះដោយប្រដាប់អាវុធបានបង្កើតនូវអំពើហិង្សាកាន់ខ្លាំងឡើងចំពោះភាគីសងខងនៃជម្លោះនេះ ។ របាយការណ៍គួរទុកចិត្តមួយបានលើកឡើងអំពីការ សម្លាប់មនុស្សដោយខុសច្បាប់ដោយមន្ត្រីរដ្ឋាភិបាល ការធ្វើឃាតដោយជនល្មើសមិនស្គាល់មុខ ការសម្លាប់ដោយមូលហេតុនយោបាយ និងការជ្រើសរើសទាហានកូនក្មេងដោយកម្លាំងកងទ័ព សហការជាមួយនឹងរដ្ឋាភិបាល ការបាត់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត និងការរំលោភបំពានធ្ងន់ធ្ងរជាច្រើនករណី ។ ការសម្លាប់ក្រៅប្រព័ន្ធតុលាការលើឧបទ្វីប Jaffna ដែលគ្រប់គ្រងដោយរដ្ឋាភិបាល បានកើនឡើង ។ មានរបាយការណ៍ជាច្រើនបានឱ្យដឹងថា កងទ័ព ប៉ូលីស និងក្រុមយោធាគាំទ្ររដ្ឋាភិបាល បានចូលរួមនៅក្នុងការវាយប្រហារដោយប្រដាប់អាវុធប្រឆាំងនឹងជនស៊ីវិល និងធ្វើទារុណកម្ម ការចាប់ជម្រិតចាប់ចំណាប់ខ្មាំង និងការគំរាមគំហែងដោយគ្មានទទួលទោសអ្វីសោះឡើយ ។ ក្រុម  Liberation Tigers of Tamil Eelam ដែលគេស្គាល់ថាជាអង្គការភេរវកម្ម បានគ្រប់គ្រងមួយផ្នែកធំនៅប៉ែកខាងជើងបានបន្តចូលរួមការវាយប្រហារលើជនស៊ីវិល និងធ្វើទារុណកម្ម ការឃាត់ខ្លួន និងការឃុំខ្លួនដោយទំនើងចិត្ត និងការរំលោភបំពានផ្សេងទៀត ។

នៅឆ្នាំ ២០០៧ អសន្តិសុខដោយសារតែជម្លោះផ្ទៃក្នុង/ជម្លោះឆ្លងដែនបានបន្តគំរាមគំហែង ឬធ្វើឱ្យខាតបង់គុណប្រយោជន៍ផ្នែកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ។ ជាមួយគ្នានេះដែរ ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសន្តិសុខ បានបង្កើតលក្ខខណ្ឌ ដែលអំណោយផលដល់ការរីកចំរើននៅក្នុងតំបន់ទាំងនេះ ។

ជំហានរបស់រដ្ឋាភិបាលកូឡុំបៀក្នុងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស និងសន្តិសុខ បានបង្ហាញនូវលទ្ធផលគួរកត់សម្គាល់ ។ ច្បាប់ស្តីពីយុត្តិធម៌ និងសន្តិភាពបានជួយស្រាយបំភ្លឺបទឧក្រិដ្ឋជាង ៣ ០០០ ករណី និងបណ្តាលឱ្យមានការគាស់ចេញនូវផ្នូរខ្មោចជាច្រើន ការសម្របសម្រួលកំណត់អត្តសញ្ញាណនៃផ្នូរដែលនៅសល់ជាងមួយពាន់ ។ ការស៊ើបអង្កេតរបស់តុលាការកំពូល និងអគ្គព្រះអាជ្ញាលើទំនាក់ទំនងរវាងអ្នកនយោបាយ និងក្រុមយោធា បានធ្វើឱ្យមានការពាក់ពន្ធ័ដល់អ្នកដឹកនាំមួយចំនួន ដែលឈ្នះឆ្នោត ដែលភាគច្រើនត្រូវជាប់គុកនៅចុងឆ្នាំនេះ ។ សេចក្តីណែនាំរបស់ក្រសួងការពារជាតិ បានបណ្តាលឱ្យមានករណីសិទ្ធិមនុស្សប្រហែល ជា ៦០០ករណីពីប្រព័ន្ធតុលាការយោធាទៅកាន់តុលាការស៊ីវិល ។

នៅប្រទេសអ៊ីរ៉ាក់ រដ្ឋធម្មនុញ្ញ និងច្បាប់ផ្តល់នូវគ្របខណ្ឌសម្រាប់អនុវត្តដោយសេរីលើសិទ្ធិមនុស្ស និងប្រជាពលរដ្ឋជាច្រើនបានរួមចំណែកដល់កិច្ចប្រឹងប្រែងដើម្បីជួយកសាងស្ថាប័នទាំងស៊ីវិល និងសន្តិសុខ ដើម្បីការពារសិទ្ធិទាំងនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ អំពើហិង្សាដោយក្រុមនិកាយសាសនា ជនជាតិភាគតិច និងពួកជ្រុលនិយម គួបផ្សំជាមួយនឹងសមត្ថភាពទន់ខ្សោយរបស់រដ្ឋាភិបាល ក្នុងការលើកកំពស់និតិរដ្ឋ ដែលជាហេតុបណ្តាលឱ្យមានការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងរាលដាល និងការបង្កើតឱ្យមានជនភាសខ្លួន និងអ្នកគ្មានទីលំនៅមួយចំនួនធំ ។ ឆ្នាំនេះបានចាប់ផ្តើមដោយមានសង្គ្រាមរយៈពេល ៦ខែ ក្រោយពីការកាត់បន្ថយយ៉ាងច្រើននូវការស្លាប់របស់ជនស៊ីវិលនៅពាក់កណ្តាលទីពីរនៃឆ្នាំនេះ នៅពេលដែលយុទ្ធសាស្ត្រថ្មីបានទទួលជោគជ័យ ។ ដោយមានជំនួយពីកងកម្លាំងយោធាថ្មី ។ អំពើហិង្សាថយចុះ ពេលដែលបទឈប់បាញ់មួយដោយកងជីពល Shila មួយចំនួនបានកាន់កាប់និងក្រុមឃ្លាំមើលប្រជាពលរដ្ឋក្នុងមូលដ្ឋានតទល់នឹងពួកជ្រុលនិយម ។ អំឡុងពេលសង្គ្រាមស្ថាប័ន រដ្ឋាភិបាលមានការព្រួយបារម្ភជាខ្លាំង និងបានប្រឈមមុខនឹងការលំបាកក្នុងការឆ្លើយតបប្រកបដោយជោគជ័យទៅនឹងបញ្ហា ប្រឈមដែល

ចោទឡើងដោយសារតែការរំលោភបំពានសិទ្ធិមនុស្សយ៉ាងរាលដាល និងការវាយប្រហារដោយអាល់កៃដារនៅក្នុង ក្រុមភេរវករ និងជ្រុលនិយមនៅអ៊ីរ៉ាក់ ។ ក្រុមភេរវករបានបន្តវាយប្រហារលើជនស៊ីវិល និងកម្លាំងសន្តិសុខ ។

បើទោះបីជាមានការរីកចំរើនជាច្រើនចាប់តាំងពីការធ្លាក់ចុះរបស់ក្រុមតាលីបង់នៅឆ្នាំ ២០០៦ក៏ដោយ ឯកសារស្តីពីសិទ្ធិមនុស្សរបស់ប្រទេសអាហ្វហ្គានីស្ថាននៅតែអន់ដដែលដោយសារតែមានការបះបោរប្រកបដោយគ្រោះថ្នាក់ ស្ថាប័នពីដើម និងស្ថាប័នរដ្ឋាភិបាលមានភាពទន់ខ្សោយ អំពើពុករលួយ និងការជួយដូរគ្រឿងញៀន និងជម្លោះអស់ពីរទសវត្សកន្លះក្នុងផ្ទៃប្រទេស ។ នៅពេលដែលរដ្ឋាភិបាលពង្រឹងអំណោចខ្លួននៅក្នុងទីប្រជុំជនខេត្ត ក្រុមតាលីបង់ ឬក្រុមបំបែកខ្លួន ដែលកំពុងតែធ្វើការនៅខាងក្រៅការគ្រប់គ្រងរបស់រដ្ឋាភិបាលបានគ្រប់គ្រងតំបន់មួយចំនួន ។ នៅអំឡុងឆ្នាំនេះ មនុស្សជាង ៦ ៥០០នាក់បានស្លាប់ដោយសារតែការបះបោល ដោយរួមមានការវាយ ប្រហារធ្វើអត្តឃាត ការដាក់គ្រាប់បែកតាមផ្លូវ និងអំពើហិង្សាដែលពាក់ព័ន្ធនឹងការប្រយុទ្ធ ហើយការកើនឡើងយ៉ាងខ្លាំងកាលពីឆ្នាំ ទៅ ។ ការរំលោភបំពានដោយកម្លាំងសន្តិសុខបានបន្ត ដោយរួមមានការសម្លាប់ក្រៅតុលាការ ការឃាត់ខ្លួន និងការឃុំខ្លួនដោយទំនើង ចិត្ត ភាពគ្មានទោសជាផ្លូវការ និងការធ្វើទារុណកម្ម ។ បើទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានធ្វើការពង្រឹងវិជ្ជាជីវៈរបស់កម្លាំងកងទ័ព និងប៉ូលីស ។ ការធ្វើប្រហែសច្រើនដោយប៉ូលីសទៅលើការតាមដានខាងក្នុង និងខាងក្រៅ បានជួយបង្ការការរំលោភបំពាន ហើយនិងការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សបានក្លាយជាសមាសធាតុមួយយ៉ាងទៀងទាត់សម្រាប់ប៉ូលីស និងកងកម្លាំងទ័ព ។

ការរីកចំរើនផ្នែកលិទ្ធប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅប្រទេសលីបង់ បានបន្តប្រឈមមុខនឹងការជំទោប្រឆាំងក្នុងរូបភាពជាយុទ្ធនាការប្រឆាំងនឹងអំពើហិង្សា និងការធ្វើឃាត ហើយនិងកម្លាំងដែលគាំទ្រដោយបទេសដើម្បីការពារដំណើរការរបស់រដ្ឋាភិបាល ។ ក្រុមសកម្មប្រយុទ្ធបានបន្តកិច្ចខិតខំប្រឹងប្រែងធ្វើភេរវកម្មលើសាធារណៈជន និងឥស្សរជននយោបាយ ដោយរួមមានតាម រយៈការដាក់គ្រាប់បែកក្នុងរថយន្តជាបន្តបន្ទាប់ និងធ្វើឃាតនៅក្នុងអំឡុងឆ្នាំនេះ ។ ជម្លោះ Nahral-Barid ពីខែឧសភា ដល់ខែកញ្ញា រវាងកងកម្លាំងប្រដាប់អាវុធលីបង់ (LAF) និងក្រុមភេរវករ ហ្វាតា អាល់ អ៊ិស្លាម បានបណ្តាលឱ្យមានការស្លាប់ទាហានរបស់កងកម្លាំងប្រដាប់អាវុធលីបង់ចំនួន ១៦៨ នាក់ ហើយនិងជនស៊ីវិលប្រមាណជាង ៤២ នាក់ និងធ្វើឱ្យជនភាសខ្លួនប៉ាលីស្ទីនប្រហែលជា ៣០ ០០០ នាក់គ្មានផ្ទះ សម្បែងរស់នៅប្រទេសរបស់ខ្លួន ។ ការជំទោសប្រឆាំងរបស់ជនជាតិលីបង់ដែលគាំទ្រដោយកម្លាំងខាងក្រៅបានបន្តរាំងដល់ការបោះឆ្នោតជ្រើសរើសប្រធាធិបតេយ្យដោយធ្វើការបដិសេធមិនអនុញ្ញាតឱ្យមានកោះប្រជុំសភា ។ បើទោះបីជាយ៉ាងណាក៏ ដោយ គណៈរដ្ឋមន្ត្រីលីបង់ ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី Fouad Siniora បានបន្តធ្វើការយ៉ាងខ្លាំងក្លាដើម្បីធានាទូវដំណើរ ការប្រព្រឹត្តិទៅរបស់រដ្ឋាភិបាល ។

នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គូ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងប្រធាននាធិតេយ្យ ដែលមានលក្ខណៈជាប្រជាធិ តេយ្យជាប្រវត្តិសាស្ត្រ ។ វា បានកើតឡើងនៅឆ្នាំ ២០០៦ ដោយធ្វើការសន្និដ្ឋានថា ដំណើរការអន្តរកាល ត្រូវបានចាប់ផ្តើមនៅឆ្នាំ ២០០២ ដែលបានបញ្ចប់សង្គ្រាមស៊ីវិលដែលបំផ្លិចបំផ្លាញ និងជម្លោះនៅក្នុងតំបន់ ។ បើទោះបីជាមានព្រិត្តិការណ៍ជាប្រវត្តិសាស្ត្រ នេះក៏ដោយ បញ្ហាសិទ្ធិមនុស្សជាច្រើននៅតែកើតមានឡើង ។ ឯកសារស្តីពីសិទ្ធិមនុស្សរបស់រដ្ឋាភិបាលនៅតែអន់នៅឆ្នាំ ២០០៧ សិទ្ធិ សេរីភាពសាព័តិមានបានធ្លាក់ចុះ ហើយនិងអំពីពុករលួយរបស់មន្ត្រីនៅតែរាលដាល ។ ជម្លោះប្រដាប់អាវុធ

ផ្ទៃក្នុងបានបន្តនៅ ក្នុងតំបន់មួយចំនួន សំបូររ៉ែនៅប៉ែកខាងកើត ដែលជាកន្លែងដែលកងកម្លាំងសន្តិសុខ និងកងប្រដាប់អាវុធ បានធ្វើសកម្មភាពដោយរួចផុតពី ទោសពេញមួយឆ្នាំ ដែលកំពុងធ្វើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរជាច្រើន ដោយរួមមានការសម្លាប់ជនស៊ីវិលដោយខុសច្បាប់ អំពើហិង្សាផ្លូវភេទយ៉ាងធ្ងន់ធ្ងរ ការជ្រើសរើស និងការប្រើប្រាស់ទាហានកូនក្មេង និងការរំខានពីអ្នកឃ្លាំមើលសិទ្ធិមនុស្ស របស់ អង្គការប្រសហប្រជាជាតិ ។ នៅខែ វិច្ឆិការ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលកុងហ្គូបានឈានទៅដល់ការព្រមព្រៀងជាមួយ នឹងរដ្ឋាភិបាលរ៉្វាន់ដាទៅលើវិធីសាស្ត្រសំរាប់ទាក់ទងជាមួយក្រុមប្រដាប់អាវុធនៅប៉ែកខាងកើត នៃប្រទេសកុងហ្គូ ដោយរួមមានកម្លាំងដើម្បីការរំដោះជាតិប្រជាធិបតេយ្យនៃប្រទេសរ៉្វាន់ដា ។

ជាមួយនឹងជំនួយរបស់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ សណ្តាប់ធ្នាប់ត្រូវរៀបចំឡើងវិញនៅប្រទេសទីម័រ ឡេសក្រោយពីកើតមានអំពើហិង្សាឆ្នាំ ២០០៦ ហើយនិងប្រទេសនេះបានធ្វើការបោះឆ្នោតប្រជាធិតេយ្យពីរលើកប្រកបដោយជោគជ័យគឺៈ ការបោះឆ្នោតជ្រើសរើសប្រធានាធិតេយ្យនៅខែមេសា និងខែឧសភា និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅមិថុនា ។ រដ្ឋាភិបាលនេះបានធ្វើការកំណែទម្រង់ ដោយរួមមាន ការរៀបចំសម្ព័ន្ធឡើងវិញនូវនគរបាលជាតិ ប៉ុន្តែបន្តពឹងផ្អែកយ៉ាងខ្លាំងទៅលើកម្លាំងសន្តិសុខបរទេស តែមិនមែននៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួនទេ ។ បើទោះបីជាប្រព័ន្ធយុត្តិធមិមានការរីកចំរើនខ្លះចំពោះកំណែទម្រង់ក៏ដោយ វានៅតែពឹងផ្អែកទាំងស្រុងទៅលើកងកម្លាំង និងជំនួយអន្តរជាតិ ។ ថ្វីត្បិតជាមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ បញ្ហាប្រកួតប្រជែងផ្ទៃកនយោបាយផ្ទាល់ខ្លួន និងនៅក្នុងតំបន់ទៅលើឬសគល់នៃចលាចល របស់ប្រទេសនេះក៏ដោយវត្តមានជា បន្តបន្ទាប់នៅចុងឆ្នាំនេះ ដែលមានជនក្បត់ប្រដាប់អាវុធ បានបន្តការគំរាមគំហែង ជាច្រើនចំពោះការអភិវឌ្ឍន៍ប្រជាធិបតេយ្យ របស់ប្រទេសទីម័រឡេស ។

ក្តីសង្ឃឹមជាច្រើនបានកើតមានបន្ទាប់ពីការចុះហត្ថលេខានៅ ខែមីនាទៅលើកិច្ចព្រមព្រៀងនយោបាយ Quangadougou សំរាប់ Cote D'lvoire ដែលបានធ្វើឡើងដោយប្រធានាធិបតី Burkina Faso ឈ្មោះ Compaore ។ ប្រធានាធិបតី អ៊ីវ៉ររី ឈ្មោះ Gbagbo និងអតីតៈអ្នកដឹកនាំកម្លាំងថ្មីក្រុមឧទ្ទាមឈ្មោះ Guillaume Soro ចាត់វិធានការយ៉ាងឆាប់រហ័សដើម្បីបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ប៉ុន្តែទិដ្ឋភាពសំខាន់នៃដំណើរការសន្តិភាពមានដូចជា ដកហូតអាវុធពីក្រុមផ្តាច់ខ្លួនប្រដាប់អាវុធការបង្រួបបង្រួមប្រទេស ការកំណត់សញ្ជាតិរបស់ប្រជាពលរដ្ឋ ដែលខ្វះឯកសារ និងការរៀបចំការបោះឆ្នោតដើម្បីរើសជ្រើសប្រធានាធិបតីថ្មី នេះបានដំណើរការយ៉ាងយឺត និងមិនទៀងទាត់នៅក្នុងបរិយាកាសមួយដែលមានឆន្ទៈនយោបាយទន់ខ្សោយ ។ នៅក្នុងប្រទេសអ៊ុយហ្គានដា ស្ថានភាពសន្តិសុខនិងសិទ្ធិមនុស្សបានកែលម្អយ៉ាងច្រើនតាំងពីកងកម្លាំងយោធាបណ្តេញកងទ័ពតស៊ូរបស់មេដឹកនាំក្រុមឧទ្ទាម (LRA) ចេញពីតំបន់ប៉ែកខាងជើងនៃប្រទេសនៅឆ្នាំ ២០០៥ និងចាប់ផ្តើមកិច្ចចរចារសន្តិភាព ដែលធ្វើឡើង ដោយរដ្ឋាភិបាលស៊ូដង់នៅប៉ែកខាងត្បូងនៅឆ្នាំ ២០០៦ ។ គ្មានរបាយការណ៍ណាមួយស្តីពីការវាយប្រហាររបស់កងទ័ពតស៊ូរបស់មេដឹកនាំក្រុមឧទ្ទាមនៅអំឡុងឆ្នាំ ២០០៧ ។ ជនជាតិអ៊ុយហ្គានដាប្រហែលជា ៤០០ ០០០ នាក់ដែលគ្មានផ្ទះ បានវិលត្រឡប់ទៅស្រុករបស់គេវិញ ឬនៅក្បែរស្រុកគេនៅឆ្នាំ ២០០៦ និង ២០០៧ ដោយមានការត្រឡប់មកវិញរបស់ប្រជាជននេះ ជាច្រើន ប្រសិនជាបទឈប់បាញ់ទទួលជោគជ័យ ។ សន្តិសុខល្អប្រសើរនៅប៉ែកខាងជើងស្ទើរតែបញ្ចប់នូវការអនុវត្តមួយ ដែលគេដឹងថាជា "ការធ្វើដំណើរនៅពេលយប់ " ខណៈពេលដែលកូនក្មេងបានធ្វើដំណើរពីតំបន់មានជម្លោះ ឬជំរុំរបស់ប្រជាជន ដែលគ្មាន

ផ្ទះសម្បែងនៅក្នុងប្រទេសរបស់ខ្លួន ជារៀងរាល់យប់ទៅកាន់ទីប្រជុំជនក្នុងក្រុងដើម្បីជៀសវាងនូវការចាប់ជម្រិតរបស់កងទ័ពតស៊ូរបស់មេដឹកនាំក្រុមឧទ្ទាម ។

ប្រទេសជាច្រើនដែលអំណាចស្ថិតនៅក្រោមដៃរបស់អ្នកដឹកនាំដែលគ្មានការទទួលខុសត្រូវ នៅតែជាអ្នករំលោភបំពានសិទ្ធិមនុស្សជាច្រើននៅលើលោកនេះ ។

របបគ្រប់គ្រងប្រទេសកូរ៉េខាងជើងដែលពោពេញដោយការគាប់សង្កត់នោះ បានបន្តគ្របដណ្តប់ស្ទើរតែគ្រប់ទិដ្ឋភាព នៃការរស់នៅរបស់ប្រជាពលរដ្ឋ ដោយមិន ព្រមផ្តល់នូវសិទ្ធិសេរីភាពក្នុងការនិយាយស្តី សារព័ត៌មាន ការប្រជុំ និងការបង្កើតសមាគម ហើយនិងការបំបិទសេរីភាពក្នុងការ ដើរហើរ និង សិទ្ធិរបស់កម្មករ ។ របាយការណ៍ជាច្រើនអំពីការសម្លាប់ក្រៅតុលាការ ការបាត់ខ្លួននិងការឃុំខ្លួនតាមទំនើងចិត្ត ដោយរួមមានការឃុំខ្លួនអ្នកទោសនយោបាយជាដើម បានបន្តកើតមានពីប្រទេស ដែលឯកោពីគេនេះ ។ គេនិយាយថា ជនភាសខ្លួន មួយចំនួនដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ទាំងបង្ខំបានទទួលរងនូវទារុណកម្មយ៉ាងធ្ងន់ធ្ងរ និងអាចមានការធ្វើទារុណកម្ម ។ របាយការណ៍ជាច្រើនអំពីការប្រហារជីវិតជាសាធារណៈក៏បានបន្តលេចឡើងដែរ ។

ឯកសារស្តីពីសិទ្ធិយ៉ាងអាក្រក់របស់ប្រទេសភូមានៅតែបន្តធ្ងន់ធ្ងរឡើង ។ រយៈពេលពេញមួយឆ្នាំ របបនេះបានបន្តធ្វើការសម្លាប់មនុស្សនៅក្រៅប្រព័ន្ធតុលាការ និងបានទទួលខុសត្រូវចំពោះការបាត់ខ្លួន ការឃុំខ្លួនតាមទំនើងចិត្ត និងគ្មានកំណត់ពេលវេលាជាក់លាក់ការរំលោភផ្លូវភេទ និងការធ្វើទារុណកម្ម ។ នៅខែកញ្ញា កម្លាំងសន្តិសុខបានសម្លាប់បាតុករយ៉ាងហោចណាស់ ៣០នាក់ និងឃុំខ្លួនបាតុករផ្សេងទៀតជាង ៣ ០០០ នាក់ នៅពេលធ្វើការបង្ក្រាបយ៉ាងព្រៃផ្សៃទៅលើក្រុមបាតុករដែលធ្វើបាតុកម្មដោយសន្តិវិធី ដោយរួមមានព្រះសង្ឃ និងអ្នកគាំទ្រលិទ្ធិប្រជាធិបតេយ្យ ។ បើទោះបីជាមានការសន្យាថាមានកិច្ចចរចារក៏ដោយ របបនេះ មិនបានគោរពនូវការសន្យារបស់ខ្លួន ក្នុងការចាប់ផ្តើមកិច្ចពិភាក្សាពិតប្រាកដមួយ ជាមួយក្រុមប្រឆាំងប្រជាធិបតេយ្យ និងក្រុម ជនជាតិភាគតិច ។ ដោយបំពានទៅលើការអំពាវអំនាវពីក្រុមប្រឹក្សាសន្តិសុខអង្គការប្រជាជាតិ និងសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ដើម្បីសុំការដោះលែងអ្នកទោស នយោបាយទាំងអស់ភ្លាម១ របបនេះបានបន្តចាប់អ្នកដឹកនាំគណៈបក្សប្រឆាំដាក់ពន្ធនាគារ ដោយរួមមានអ្នកទទួលជ័យលាភីរង្វាន់សន្តិភាពណូបែលគឺលោកស្រី អង់ សាន ស៊ូជី ដែលនៅតែត្រូវបានឃុំខ្លួននៅវេសនដ្ឋាន ។

របបអ៊ីរ៉ង់ បានរំលោភលើសេរីភាពខាងការនិយាយស្តី និងការប្រជុំ មានការបង្ក្រាបដ៏ខ្លាំងក្លារបស់របបនេះ ប្រឆាំងនឹងអ្នកប្រឆាំង អ្នកសារព័ត៌មាន សកម្មជនការពារសិទ្ធិរបស់ស្ត្រី សកម្មជនការងារ និងអ្នកដែលប្រឆាំងនឹងរបបនេះ នឹងទទួលរងនូវការចាប់ និងឃុំឃាំងខ្លួនដ៏ឃោរឃៅ មានការធ្វើទារុណកម្ម មានការចាប់ពង្រត់ មានការប្រើកំលាំងហួសហេតុ និងមានការរីករាលដាលការប្រឆាំងចំពោះការកាត់ក្តីដោយយុត្តិធម៌ចំពោះសាធារណជន ។ របបនេះ បានបន្តឃុំឃាំងមនុស្ស និងរំលោភលើសេរីភាពខាងប្រតិបត្តិសាសនា និងជនជាតិភាគតិច ។ អាជ្ញាធរ បានប្រើដុំថ្មជាវិធីក្នុងការប្រហារជីវិត និងជាវិធីកាត់សេចក្តី ចំពោះករណីផិតក្បត់ចិត្ត ទោះបីជា មានការហាមប្រាមរបស់រដ្ឋាភិបាល នៅក្នុងការអនុវត្តន៍បំរាមឆ្នាំ ២០០២ ក៏ដោយ ។ របបនេះ បានបន្តគាំទ្រដល់ចលនាភេរវករ និងក្រុមជ្រុលនិយមដែលប្រើអំពើហឹង្សា នៅប្រទេសស៊ីរី ប្រទេសអ៊ីរ៉ាក់ និងប្រទេសលីបង់ និងបានអំពាវ

នាវឱ្យមានការធ្វើវិនាសកម្មចំពោះរដ្ឋដែលជាសមាជិកអង្គការសហប្រជាជាតិ ។

កំណត់ត្រាសិទ្ធិមនុស្សរបស់ប្រទេសស៊ីរី បានធ្លាក់ដុនដាបនៅឆ្នាំនេះ និងរបបនេះ បានបន្តប្រព្រឹត្តការរំលោភដ៏ធ្ងន់ធ្ងរដូចជា មានការឃុំឃាំងសកម្មជនកាន់តែច្រើនឡើង រួមមានអ្នករៀបចំសង្គមស៊ីវិល និងអ្នករិះគន់របបនេះដទៃទៀត ។ របបនេះ បានកាត់ទោសសមាជិកសហគមន៍ការពារសិទ្ធិមនុស្សដែលមានឈ្មោះល្បីមួយចំនួនធំ ឱ្យជាប់គុក រួមមាន មេដឹកនាំក្រុមប្រឹក្សាជាតិសំរាប់សេចក្តីប្រកាស Damascus មួយចំនួន នៅក្នុងខែធ្នូ ។ របបនេះ បានបន្តកាត់ទោសអ្នកទោសនយោបាយមួយចំនួន នៅក្នុងតុលាការឧក្រិដ្ឋកម្ម ។ ឧទាហរណ៍ដូចជាករណី នៅខែមេសា និងខែឧសភា អាជ្ញាធរ បានកាត់ទោសលោក Anwar al-Bunni និងលោក Michel Kilo ដែលជាសកម្មជនសិទ្ធិមនុស្ស នៅក្នុងតុលាការឧក្រិដ្ឋកម្ម ពីបទ "ធ្វើឱ្យចុះខ្សោយចំពោះមនោសញ្ចេតនាស្នេហាជាតិ នៅអំឡុងពេលសម័យសង្គ្រាម ។ របបស៊ីរី នឹងបន្តគាំទ្រដល់ក្រុមភេរវកម្មអន្តរជាតិ និងក្រុមជ្រុលនិយមដែលប្រើអំពើហឹង្សា នឹងធ្វើឱ្យមានអស្ថេរភាពតាមរយៈសកម្មភាពរបស់ពួកគេ និងមានការរំលោភសិទ្ធិមនុស្ស នៅក្នុងប្រទេសលីបង់ ដែនដីប៉ាលេស្ទីន និងកន្លែងដទៃទៀត ។

ឆ្នាំ ២០០៧ ជាឆ្នាំដែលមិនទាន់អាក្រក់បំផុតនៅឡើយទេ សំរាប់អ្នកការពារសិទ្ធិមនុស្ស នៅក្នុងប្រទេសហ្ស៊ីមបាបវេ ។ ទោះបីជា អ្នកដឹកនាំតាមតំបន់ បានខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ដើម្បីដោះស្រាយវិបត្តិដែលកំពង់តែបន្តក៏ដោយ ក៏នៅតែមានការវាយប្រហារប្រឆាំងនឹងសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដោយរដ្ឋាភិបាល បានកើនឡើងគួរឱ្យកត់សម្គាល់ ។ របបមូហ្គាបេ បានពន្លឿនយុទ្ធនាការរបស់ខ្លួន ដើម្បីកម្រិតការប្រឆាំងផ្នែកនយោបាយ ។ អំពើពុករលួយ និងការលើកលែងទោសរបស់មន្ត្រី នៅតែរីករាលដាល ។ កំលាំងសន្តិសុខ បានរុកគួន វាយ និងចាប់ខ្លួនអ្នករិះគន់ និងអ្នកគាំទ្រគណបក្សប្រឆាំងតាមតែអំពើចិត្ត ដែលពួកគេធ្វើការឱ្យអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស ប្រព័ន្ធព័ត៌មាន និងបានរៀបចំការងារ ព្រមទាំងបានធ្វើទុក្ខបុកម្នេញដល់ប្រជាពលរដ្ឋសាមញ្ញផងដែរ ។ មានរបាយការណ៍ មកពីអង្គការឯករាជ្យ ដែលប្រតិបត្តិនៅក្នុងប្រទេសហ្ស៊ីមបាបវេ បានលើកឡើងថា មានពាក្យបណ្តឹងជាង ៨.០០០ករណី ស្តីពីការរំលោភសិទ្ធិមនុស្ស នៅក្នុងឆ្នាំ ២០០៧ រួមមានការវាយប្រហារប្រហែលជាចំនួន ១.៤០០លើក ប្រឆាំងនឹងក្រុមនិស្សិតតែមួយគត់ និងយ៉ាងហោចណាស់មាន ១.៦០០ករណី ស្តីពីការចាប់ និងឃុំឃាំងខ្លួនដោយខុសច្បាប់ ។ ក្រុមសិទ្ធិមនុស្ស បានរាយការណ៍ថា មានការធ្វើទារុណកម្មទាំងកាយ ទាំងចិត្ត ដែលប្រព្រឹត្តដោយភ្នាក់ងារសន្តិសុខ និងអ្នកគាំទ្ររដ្ឋាភិបាល បានកើនឡើងនៅអំឡុងឆ្នាំ ២០០៧ នេះ ។ ជនរងគ្រោះ បានរាយការណ៍ថា ពួកគាត់ត្រូវបានវាយដោយខ្សែតី ខ្សែភ្លើង និងដំបងឆក់ ដើម្បីបង្ខំឱ្យឆ្លើយសារភាព ។

ប្រទេសគុយបា នៅតែស្ថិតក្រោមការត្រួតត្រានៃលទ្ធិផ្តាច់ការ ក្រោមការដឹកនាំរបស់ប្រធានាធិបតីស្តីទី Raul Castro និងអគ្គលេខាបក្សកុម្មុយនិស្ត Fidel Casro ។ របបនេះ បានបន្តប្រឆាំងនឹងប្រជាពលរដ្ឋដែលចង់បានសិទ្ធិជាមូលដ្ឋាន និងសេរីភាពខាងលទ្ធិប្រជាធិបតេយ្យ រួមមានសិទ្ធិក្នុងការផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួន សិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ សិទ្ធិក្នុងការនិយាយស្តី សារព័ត៌មាន ការប្រជុំ ការធ្វើដំណើរ និងសិទ្ធិខាងការបង្កើតសមាគម ។ ទោះបីជា មានការប៉ាន់ស្មានថា មានចំនួនអ្នកទោសបានថយចុះ ពីចំនួន ២៨៣ ដល់ ២៤០ បានរាយការណ៍កាលពី ឆ្នាំកន្លងទៅក៏ដោយ ក៏ស្ថានភាពអ្នកទោស នៅតែមានភាពយង់ឃ្នង និងមានការគម្រាមកំហែងដល់ជីវិតទៀតផង និងអាជ្ញាធរ បានវាយ រុកគួន និងគម្រាមសម្លាប់ទាំងអ្នក

ប្រឆាំង នៅក្នុងគុក និងអ្នកប្រឆាំងនៅក្រៅគុក ។ ក្នុងចំណោមសកម្មជនដែលស្រឡាញ់សន្តិភាពចំនួន ៧៥រូប រួមមានអ្នកសារព័ត៌មាន អ្នកបង្កើតសហព័ន្ធ និងសកម្មជនគណបក្សប្រឆាំង បានចាប់ខ្លួន និងបានកាត់ទោស នៅក្នុងឆ្នាំ ២០០៣ មានសកម្មជនចំនួន ៥៩ រូប ត្រូវបានជាប់ឃុំឃាំង ។ ការវាយប្រហារហ្វូងមនុស្សឥតសណ្ដាប់ធ្នាប់ដែលដឹកនាំដោយរដ្ឋាភិបាលប្រឆាំងនឹងអ្នកប្រឆាំងដែលមានឈ្មោះល្បី មានចំនួនថយចុះ បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ប៉ុន្តែអត្រាការចាប់ និងឃុំខ្លួនរយៈពេលខ្លីចំពោះប្រជាពលរដ្ឋសាមញ្ញដែលសំដែងការប្រឆាំងនឹងរបបនេះ ទំនងជាកើនឡើង ។

នៅក្នុងប្រទេសបេឡារុស្ស រដ្ឋាភិបាលផ្តាច់ការ Lukashenko បានដាក់កម្រិតលើសេរីភាពខាងសារព័ត៌មាន ការនិយាយស្តី ការប្រជុំ ការបង្កើតសមាគម និងសិទ្ធិខាងប្រតិបត្តិសាសនា ។ សកម្មជន និងអ្នកគាំទ្រលទ្ធិប្រជាធិបតេយ្យមួយចំនួន ត្រូវបានចាប់ខ្លួន និងបានកាត់ទោសពីបទជាប់ទាក់ទងនឹងបុព្វហេតុនយោបាយ ។ ម្នាក់ក្នុងចំណោមគូបដិបក្សរបស់រដ្ឋាភិបាលផ្តាច់ការ Lukashenko នៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្នាំ ២០០៦ គឺលោក Alexander Kozulin ដែលនៅជាអ្នកទោសនយោបាយនៅឡើយ ។ នៅក្នុងខែមករា លោក Lukashenko បានពង្រឹងការគ្រប់គ្រងរបស់គាត់បន្ថែមទៀត តាមរយៈការបោះឆ្នោត តាមតំបន់ ដែលមិនបានបំពេញតាមបទដ្ឋានអន្តរជាតិ ។ មហាសន្និបាតអង្គការសហប្រជាជាតិ សំរាប់ឆ្នាំទី ២ បានអនុម័តដំណោះស្រាយមួយក្នុងការថ្កោលទោសស្ថានភាពសិទ្ធិមនុស្ស នៅក្នុងប្រទេសបេឡារុស្ស និងបានអំពាវនាវជាបន្ទាន់ឱ្យមានការដោះលែងអ្នកទោសនយោបាយ និងអ្នកជាប់ឃុំដទៃទៀតដោយគ្មានលក្ខខណ្ឌ សំរាប់ការអនុវត្ត ឬសំរាប់ការលើកកម្ពស់សិទ្ធិមនុស្ស ។

ប្រធានាធិបតីផ្តាច់ការ Karimov និងផ្នែកនីតិប្រតិបត្តិរបស់រដ្ឋាភិបាល បានគ្រប់គ្រងជោគវាសនានយោបាយរបស់ប្រទេសអ៊ុយបេគីស្ថាន និងបានអនុវត្តការគ្រប់គ្រងលើផ្នែកដទៃទៀតស្ទើរតែទាំងស្រុង ។ កំលាំងសន្តិសុខ បានធ្វើទារុណកម្ម បានវាយជាប្រចាំ ហើយបើមិនដូច្នេះទេ បានធ្វើទុក្ខទោសសួរចម្លើយអ្នកជាប់ឃុំ ឱ្យទទួលសារភាព ឬព័ត៌មានដែលទាក់ទងនឹងបទឧក្រិដ្ឋកម្ម និងមានអ្នកទោសស្លាប់នៅក្នុងមន្ទីរឃុំឃាំងមួយចំនួន ដោយចោទប្រកាន់ថាជាសមាជិកអង្គការ ដែលបានបញ្ជាក់ដោយរបបនេះ ថាជាការគម្រាមកំហែង ។ នៅក្នុងខែវិច្ឆិកា គណៈកម្មាការអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម បានសន្និដ្ឋានថា ការធ្វើទារុណកម្ម និងការរំលោភ ជាដំណើរការស៊ើបអង្កេតតាមរយៈប្រព័ន្ធ ។ រដ្ឋាភិបាល បានព្យាយាមក្នុងការគ្រប់គ្រងទាំងស្រុងនូវសកម្មភាពប្រតិបត្តិសាសនា និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ។

កំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋាភិបាល អេរីទ្រី នៅតែខ្សោយ ។ មានការដាក់កម្រិតដ៏ធ្ងន់ធ្ងរ ចំពោះសេរីភាពខាងការនិយាយស្តី សារព័ត៌មាន ការប្រជុំ ការបង្កើតសមាគម និងសាសនា ជាពិសេសសំរាប់ក្រុមប្រតិបត្តិសាសនា ដែលមិន

ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាល ។ អាជ្ញាធរបានបន្តធ្វើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរជាច្រើន ដោយរួមមានការបំបិទសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួនតាមរយៈដំណើរការប្រជាធិបតេយ្យ ការសម្លាប់មនុស្សដោយខុសច្បាប់ដោយកងកម្លាំងសន្តិសុខ ធ្វើទារុណកម្ម និងវាយដំអ្នកទោស ដែលបណ្តាលឱ្យអ្នកទោសខ្លះបានស្លាប់ ការឃាត់ខ្លួន និងធ្វើទារុណកម្ម លើអ្នកគេចវេសបំរើជាតិ ដែលគេរាយការណ៍ថា មួយចំនួនបានស្លាប់ដោយសារតែបុព្វហេតុមិនច្បាស់លាស់ ខណៈ

ពេលដែលកំពុង ជាប់ឃុំឃាំង លក្ខខណ្ឌដ៏អាក្រក់ និងគំរាមគំហែងដល់ជីវិត ការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត ការចាប់ខ្លួនសមាជិក គ្រួសាររបស់អ្នកគេចវេសបំរើជាតិ ការធ្វើអន្តរាគមន៍នីតិប្រតិបត្តិនៅក្នុងប្រព័ន្ធតុលាការ ហើយនិងការប្រើប្រាស់ប្រព័ន្ធតុលាការពិសេសមួយដើម្បីកំណត់ដំណើរការត្រឹមត្រូវ ។

ឯកសារកំណត់ត្រាសិទ្ធិមនុស្សរបស់ប្រទេសស៊ូដង់នៅតែគួរឱ្យរន្ធត់ ដោយមានរបាយការណ៍ជាបន្តបន្ទាប់អំពីការសម្លាប់មនុស្សនៅក្រៅប្រព័ន្ធតុលាការ ការធ្វើទារុណកម្ម ការវាយដំ និងការរំលោភដោយកម្លាំងសន្តិសុខរដ្ឋាភិបាល និងកងឈ្លបតំណាងរបស់ពួកគេនៅតំបន់ដាហ្វួ ។ បើទោះបីជាការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពដាហ្វួនៅឆ្នាំ ២០០៦ អំពើហិង្សាបានកើនឡើងនៅឆ្នាំ ២០០៧ ហើយនិងតំបន់នេះធ្លាក់ចុះសភាពរឹកររំថែមទៀត នៅពេលដែលរដ្ឋាភិបាលបានបន្តការទម្លាក់គ្រាប់បែកលើភូមិពីលើអាកាស ក្រុមឧទ្ទាមបានបែកបាក់ និងបង្កើនការវាយប្រហារ ហើយនិងសង្គ្រាមរវាងកុលសម្ព័ន្ធកាន់តែខ្លាំងឡើង ។ ចាប់តាំងពីឆ្នាំ ២០០៣ គេជឿថា យ៉ាងហោចណាស់មនុស្ស ២០០ ០០០ នាក់បានស្លាប់ដោយសារអំពើហិង្សា ការអត់ឃ្លាន និងជម្ងឺ ។ រដ្ឋាភិបាលអាមេរិកបាន ហៅជម្លោះនេះថាជាប្រល័យពូជសាសន៍ និងជនស៊ីវិលស្លូតត្រង់ជាច្រើន បានបន្តទទួលរងគ្រោះដោយសារតែឥទ្ធិពលនេះនៅឆ្នាំនោះ ។ នៅចុងឆ្នាំ ជម្លោះអូសបន្លាយពេលបានធ្វើឱ្យមនុស្សជាងពីរលាននាក់គ្មានផ្ទះរស់នៅ និង ២៣១ ០០០ នាក់ទៀតឆ្លងកាត់ព្រំដែននៅ ក្នុងប្រទេសឆាត ជាទីដែលពួកគេបានស្វែងរកជំរក ។ រដ្ឋាភិបាលបានបន្ទុចបង្អាក់កិច្ចខិតខំប្រឹងប្រែងអន្តរជាតិក្នុងការដាក់ពង្រាយកម្លាំង រក្សាសន្តិភាពរបស់អូស្ត្រាលី និងអង្គការសហប្រជាជាតិនៅទីនោះ ហើយកម្លាំងសន្តិសុខរដ្ឋាភិបាលបានរារាំង ដល់ជំនួយមនុស្សធម៌ជួយសង្គ្រោះមនុស្ស ។ អ្នកធ្វើការមនុស្សធម៌យល់ឃើញថា ខ្លួនឯងជាគោលដៅនៃអំពើហិង្សា ។ ដោយយោងទៅតាមអង្គការសហប្រជាជាតិបានឱ្យដឹងថា អ្នកធ្វើការសិទ្ធិមនុស្ស ១៣ នាក់ត្រូវបានសម្លាប់ ៥៩ នាក់ ត្រូវបានវាយប្រហារ ៦១នាក់ត្រូវបានចាប់ខ្លួន និងឃុំ ខ្លួន ហើយ ១៤៧ នាក់ ត្រូវបានចាប់ជំរិតនៅអំឡុងឆ្នាំនេះ ។

ប្រទេសប្រើអំណាចផ្តាច់ការមួយចំនួន ដែលកំពុងធ្វើកំណែទម្រង់សេដ្ឋកិច្ច បានទទួលរងនូវការផ្លាស់ប្តូរសង្គមយ៉ាងឆាប់រហ័ស ប៉ុន្តែមិនបានធ្វើការកំណែទម្រង់នយោបាយប្រជាធិបតេយ្យទេ ហើយនៅតែមិនយល់ព្រមផ្តល់សិទ្ធិមនុស្ស និងសិទ្ធសេរីភាពជាមូលដ្ឋានដល់ប្រជាពល់រដ្ឋដដែល ។

ឧទាហរណ៍ ឯកសារកត់ត្រាសិទ្ធិមនុស្សរបស់ប្រទេសចិននៅតែមានភាពទន់ខ្សោយនៅឆ្នាំ ២០០៧ ។ ការគ្រប់គ្រង ត្រូវបានពង្រឹងទៅលើសិទ្ធិសេរីភាព ជំនឿសាសនានៅតំបន់ទីបេ និងតំបន់ស្វ័យយ័តស៊ីន ជៀង និងការប្រព្រឹត្តិទៅលើអ្នកបណ្តឹងទាមទារនៅក្នុងទីក្រុងប៉េជីងកាន់តែអាក្រក់ ។ រដ្ឋាភិបាលក៏បានបន្តតាមដាន រំខាន ឃាត់ខ្លួន ចាប់ខ្លួន និងដាក់គុកសកម្មជន អ្នកនិពន្ធ អ្នកកាសែត មេធាវីការពារក្តី និងក្រុមគ្រួសាររបស់ពួកគេ ដែលភាគច្រើនពួកគេ កំពុងព្យាយាមប្រើប្រាស់សិទ្ធិរបស់ខ្លួននៅក្រោមច្បាប់ ។ បើទោះបីជារដ្ឋាភិបាលបានបន្តកំណែទម្រង់សំខាន់ៗមួយចំនួន ដូចជា តុលាការកំពូលប្រជាមានិត្យបន្តអំណាចត្រួតពិនិត្យលើទោសប្រហារជីវិតនៅក្នុងករណីជាច្រើន ដែលត្រូវតម្រូវឱ្យធ្វើការប្រហារជីវិតភ្លាមៗ កិច្ចប្រឹងប្រែងដើម្បីកែប្រែ ឬលុបបំបាត់ចោលប្រព័ន្ធការអប់រំឡើងវិញតាមរយៈ ពលកម្ម នៅតែទទួលបរាជ័យ ។ បទបញ្ញត្តិបណ្តោះអាសន្នថ្មីៗ បានធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការរាយការណ៍ទាំងមូលសម្រាប់ អ្នកកាសែតបរទេស ប៉ុន្តែការពង្រឹងការអនុវត្តបទបញ្ញត្តិទាំងនេះមិនប្រែប្រួលទេ ដែលធ្វើឱ្យរារាំងដល់ការងាររបស់អ្នកកាសែត បរទេសមួយចំនួន ។ នៅឆ្នាំ ២០០៧ មានការកើនឡើង កិច្ចខិតខំប្រឹងប្រែង ដើម្បីត្រួតពិនិត្យ និងតិទៀនទៅលើអ៊ិនធឺណិត និងរដ្ឋាភិបាលពង្រឹងការរឹតបន្តឹង លើសិទ្ធិសេរីភាព ក្នុងការនិយាយ

ស្តី និងសារព័ត៌មានក្នុងស្រុក ។ រដ្ឋាភិបាលបានបន្តតាមដាន រារាំង ឃុំឃាំង ចាប់ខ្លួន និងដាក់គុកអ្នកកាសែត អ្នកនិពន្ធតាម ប្រព័ន្ធអ៊ិនធឺណិត និងអ្នកបង្កើតវេបសាយ ។ អង្គការសហប្រជាជាតិបានរាយការណ៍ថា អ្នកកាសែត ២៩ នាក់ អ្នកដែលបានធ្វើការប្រឆាំងតាមប្រព័ន្ធអ៊ិនធឺណិត និងអ្នកប្រើប្រាស់អ៊ិនធឺណិត នៅតែជាប់គុកនៅចុងឆ្នាំ ។ មានការកើនឡើង ២០ ភាគរយនៅឆ្នាំ ២០០៦ ក្នុងការដាក់ទោសលើប្រជាពលរដ្ឋនៅក្រោមច្បាប់សន្តិសុខរដ្ឋដ៏ទូលំទូលាយរបស់ប្រទេសចិន ដែលជាញឹកញាប់ ត្រូវបានប្រើប្រាស់ដើម្បីបំបិទមាត់អ្នករិះគន់រដ្ឋាភិបាល ។ នៅខែធ្នូ សកម្មជនសិទ្ធិមនុស្សល្បីឈ្មោះគឺលោក ហ៊ូ ជៀ ត្រូវបានចាប់ខ្លួននៅផ្ទះរបស់លោក និងឃុំខ្លួនពីបទសង្ស័យ "ការញុះញង់ធ្វើវិទ្ធង្សនានាអំណាចរដ្ឋ" ។ បើតាមការរាយការណ៍បានឱ្យដឹង ប្រពន្ធ និងកូនស្រីនៅវ័យក្មេងរបស់លោក ក៏ត្រូវបានឃាត់ខ្លួននៅវេសនដ្ឋាននៅពេលជាមួយគ្នានេះដែរ ។ អង្គការក្រៅរដ្ឋាភិបាល ទាំងក្នុងស្រុក និងក្រៅស្រុក បានប្រឈមមុខនឹងការពិនិត្យពិច័យ និងការរឹតបណ្ដឹងជាខ្លាំង ។

សមាសធាតុបីដែលពង្រឹងទៅវិញទៅមក និងមានសារៈសំខាន់ត្រូវមានវត្តមានដើម្បីមានការរីកចំរើន និងទ្រទ្រង់លិទ្ធប្រជាធិបតេយ្យណាមួយ:

សមាសធាតុទី ១: ដំណើរការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ ការបោះឆ្នោតប្រជាធិបតេយ្យគឺជាព្រឹត្តិការណ៍សំខាន់ ស្តីពីដំណើរនៃប្រជាធិបតេយ្យនីយកម្ម ។ ការបោះឆ្នោតទាំងនេះអាចជួយតំរែតំរង់ប្រទេសឱ្យនៅលើមាគ៌ាកំណែទម្រង់ ចាក់គ្រឹះក្នុងការបង្កើត ស្ថាប័នការពារសិទ្ធិមនុស្ស និងអភិបាលកិច្ចល្អ និងលំហនយោបាយបើកចំហសម្រាប់សង្គមស៊ីវិល ។ ប៉ុន្តែការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ពាក់ព័ន្ធនឹងការទៅបោះឆ្នោត និងការរាប់សន្លឹកឆ្នោតយ៉ាងត្រឹមត្រូវនៅថ្ងៃបោះឆ្នោត ។ នៅពេលឈានមកដល់ពេលបោះឆ្នោត ត្រូវឱ្យមាន ការប្រកួតប្រជែងពិតប្រាកដោយកម្លាំងសន្តិភាព ដែលប្រឆាំងនឹងរដ្ឋាភិបាលកំពុងកាន់អំណាច និងការគោរពពេញលេញចំពោះសិទ្ធិជាមូលដ្ឋាន ក្នុងការបញ្ចេញមតិយោបល់ ការប្រជុំប្រកបដោយសន្តិវិធី និងការបង្កើតសមាគម ។ នេះបានសេចក្តីថា គណបក្សនយោបាយត្រូវតែ ត្រូវបានគេអនុញ្ញាតធ្វើការរៀបចំ និងដាក់ស្នើនូវចក្ខុវិស័យដែលពួកគេផ្តល់តាមរយៈសារព័ត៌មានសេរី ការប្រជុំ និងការនិយាយស្តី ។

សមាសធាតុទី ២: ស្ថាប័នតំណាងមានការទទួលខុសត្រូវរបស់រដ្ឋាភិបាលនៅក្រោមនិតិរដ្ឋ ។ ហួសពីដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌ លិទ្ធប្រជាធិបតេយ្យទាំងឡាយត្រូវមានស្ថាប័នតំណាងមានការទទួលខុសត្រូវ និងមានតម្លាភាពរបស់រដ្ឋាភិបាលដោយរួមមាន គណបក្សនយោបាយធ្វើឡើងដោយផ្អែកលើមតិយោបល់ មិនមែនបុគ្គលិកលក្ខណៈ ឬអត្តសញ្ញាណកម្មកុលសម្ព័ន្ធ ឬជនជាតិភាគតិចអង្គនីតិបញ្ញត្តិ និងប្រព័ន្ធតុលាការមានឯករាជ្យភាព ដែលអាចធ្វើសកម្មភាពដើម្បីធានាថា អ្នកដឹកនាំដែលឈ្នះឆ្នោតតាមបែបលទ្ធិ ប្រជាធិបតេយ្យ ត្រូវគ្រប់គ្រងតាមបែបលិទ្ធិប្រជាធិបតេយ្យ នៅពេលពួកគេកាន់អំណាច ។ នីតិរដ្ឋដែលបង្កើតឡើងដោយតំណាងរាស្ត្រដែលត្រូវបានជ្រើសរើសតាមបែបលិទ្ធិប្រជាធិបតេយ្យ ត្រូវតែជំនួសនូវវប្បធម៌ពុករលួយ ។ លិទ្ធប្រជាធិបតេយ្យអាចបញ្ជាក់ថា មានភាពទន់ខ្សោយនៅក្នុងប្រទេស ដែលស្ថាប័នរបស់រដ្ឋាភិបាលមានភាពទន់ខ្សោយ ឬគ្មានការត្រួតពិនិត្យ អំពើពុករលួយបានរាលដាល ហើយការផ្សះផ្សាមិនបានកើតឡើងនៅក្នុងចំណោមពួកជនជាតិភាគតិច ឬក្រុមកុលសម្ព័ន្ធ ឬវាំងវរជនគ្មានសិទ្ធអំណាច និងមានគំនិតរឹងរូសទេ ។ ប្រទេសក្រីក្រ ដែលប្រកាន់យកគោលនយោបាយ អភិបាលកិច្ចល្អដែលជួយជំរុញការរីកចំរើន និងវិនិយោគទុនប្រជាជនរបស់ខ្លួន គឺទំនងជានឹងប្រើប្រាស់ជំនួយអភិវឌ្ឍរបស់ខ្លួន យ៉ាងឆ្លាតវៃ និងសម្រេចនូវគោលបំណងអភិវឌ្ឍរបស់ខ្លួន ធ្វើឱ្យទទួលបានទំនុកចិត្ត និងការគាំទ្រប្រជាពលរដ្ឋរបស់ខ្លួន ។ ប្រទេសមួយ ដែល

មិនមានរដ្ឋាភិបាលជាអ្នកតំណាង និងទទួលខុសត្រូវ ដែលផ្តល់នូវការការពារស្មើគ្នានៅក្រោមច្បាប់ គឺជាប្រទេសមួយដែលអ្នកជ្រុលនិយមប្រើហិង្សា ហើយទំនងជាមិនសូវជារីកចំរើនទេ ។

សមាសធាតុទី ៣៖ សង្គមស៊ីវិលឯករាជ្យ និងសកម្ម ដោយរួមមានគណបក្សនយោបាយឯករាជ្យ អង្គការក្រៅរដ្ឋភិបាល និងប្រព័ន្ធផ្សព្វផ្សាយដោយសេរី ។ សង្គមស៊ីវិលបើកចហ និងរឹងមាំ ជួយរក្សាការបោះឆ្នោត និងការបោះឆ្នោតទាំងនោះ បានជ្រើសរើសការសាងលិទ្ធប្រជា ធិបតេយ្យស្មោះត្រង់ និងប្រជាពលរដ្ឋដែលបានរួមចំណែកដល់ជោគជ័យរបស់ប្រទេសរបស់ខ្លួន ។

នៅប្រទេសវ៉េណេហ្ស៊ូអេឡា កិច្ចប្រឹងប្រែងរបស់អ្នកដឹកនាំដែលជ្រើសរើស ដោយប្រជាធិបតេយ្យ ដើម្បីបំផ្លាញស្ថាប័នប្រជាធិបតេយ្យ និងបំភិតបំភ័យសង្គមស៊ីវិល គឺពោរពេញដោយការតស៊ូយ៉ាងខ្លាំងក្លា ។ ប្រធានាធិបតេយ្យឆាវេស្សបានបន្តកិច្ចប្រឹងប្រែងនៅឆ្នាំ ២០០៧ ដែលរៀបចំឡើងដើម្បីពង្រឹងអំណាចនៅផ្នែកនិតិប្រតិបត្តិ និងធ្វើឱ្យខ្សោយនូវស្ថាប័នប្រជាធិបតេយ្យប្រព័ន្ធឃោសឯករាជ្យ និងសង្គមស៊ីវិល ។ លោកបានប្រើប្រាស់ច្បាប់ ដែលអនុញ្ញាតឱ្យមានការផ្អាកការផ្សព្វផ្សាយទូរគមនាគមន៍ ហើយនិងនៅខែឧសភារដ្ឋាភិបាលបដិសេធមិនព្រមបន្តអាជ្ញាប័ណផ្សព្វផ្សាយទូរទស្សន៍ និងវិទ្យុ Caracas ដោយបង្ខំឱ្យបណ្តាញឯករាជ្យមួយនៅចំណោម  បណ្តាលឯករាជ្យជាច្រើនដែលមានទស្សនិកជន និងអ្នកស្តាប់ក្នុងប្រទេសមិនបានធ្វើការចេញផ្សាយ ។ ប្រធានធិបតេយ្យឆាវេស្សក៏បានស្នើសុំឱ្យមានការផ្លាស់ប្តូរ រដ្ឋធម្មនុញ្ញ ដែលនឹងពន្យារយៈពេលអណត្តិប្រធានាធិបតី និងលុបបំបាត់ការកំណត់ចំនួនអាណត្តិប្រធានាធិបតីមិនរាប់បញ្ចូលនូវមន្ត្រីផ្សេងទៀត ដែលជ្រើសរើសដោយការបោះឆ្នោត ដោយផ្តល់ឱ្យប្រធានាធិបតីនូវអំណាចគ្រប់គ្រងសេដ្ឋកិច្ច និងកំណត់ការផ្តល់ហិរញ្ញវត្ថុបរទេសសម្រាប់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ។ ប្រជាពលរដ្ឋរាប់ម៉ឺននាក់បានជួបជុំគ្នានៅក្នុងបាតុកម្មសាធារណៈដែលជួនកាលមានអំពើហិង្សា  ដែលគាំទ្រ និងប្រឆាំងនឹងការកែប្រែដែលបានស្នើ ។ អ្នកគាំទ្ររដ្ឋាភិបាលជាច្រើនវាយខាន និងព្យាយាមបំភិតបំភ័យពួកប្រឆាំង ពិសេសជានិស្សិត ដោយបាញ់ប្រហារទៅលើក្រុមចូលរួមបាតុកម្ម និងធ្វើឱ្យរបួសមនុស្សមិនស្គាល់មុខជាច្រើន ។  ជាចុងក្រោយ នៅក្នុងប្រជាមតិនៅខែធ្នូការផ្លាស់ប្តូរដែលបានស្នើនោះត្រូវបានបដិសេធ ហើយជាលទ្ធផល ដែលត្រូវបានទទួលយកដោយប្រធានាធិបតី ឆាវេស្ស ។

ចំពោះលទ្ធផលចុងក្រោយនៃការបោះឆ្នោតដែលខុសឆ្គងយ៉ាងធ្ងន់ធ្ងរនៅខែមេសា មានសញ្ញាវិជ្ជមានបង្ហាញថា លទ្ធិប្រជាធិបតេយ្យទន់ខ្សោយរបស់ប្រទេសនីហ្សេរីយ៉ាមិនត្រូវបានធ្វើឱ្យខូចដោយការបន្លំដ៏រាលដាល និងករណីអំពើហិង្សា ដែលកំណត់ការបោះឆ្នោតនៅខែមេសាសម្រាប់តំណែងប្រជាធិបតេយ្យ និតិបញ្ញត្តិ និងតំណែងរដ្ឋមន្ត្រី ។ នៅក្នុងសាលាក្តី ដែលបានបង្កើតឡើងដើម្បីកាត់ក្តីបណ្តឹងចំនួនជាង ១ ២០០ ករណី ដែលប្រឆាំងនឹងលទ្ធផលការបោះឆ្នោតនៅគ្រប់កំរិតប្រព័ន្ធតុលាការបានធានាអះអាងនូវឯករាជ្យភាពរបស់ខ្លួន ដោយបណ្តាលឱ្យមានការចាត់ទុកជាមោឃៈនូវលទ្ធផលមួយចំនួនអំពីការបោះឆ្នោត ជ្រើសរើសចៅហ្វាយខេត្រ និងព្រឹទ្ធសភា ។ ដោយឆ្លើយតបទៅនឹងសម្ពាធយ៉ាងខ្លាំង រដ្ឋាភិបាលបានបង្កើតគណៈកម្មការមួយ ដើម្បីណែនាំអំពីកំណែទម្រង់ នៃគណៈកម្មការរៀបចំការបោះឆ្នោតជាតិឯករាជ្យ ដែលការរៀបចំដ៏យឺតយ៉ាវរបស់ខ្លួនបានធ្វើឱ្យខូចនូវទំនុកចិត្តលើការបោះឆ្នោតយ៉ាងខ្លាំង ។ គណៈកម្មការទទួលបន្ទុកបទឧក្រិដ្ឋសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបន្តការងាររបស់ខ្លួន ដើម្បីស៊ើបអង្កេតលើករណី ចោទប្រកាន់ពីបទអំពើពុករលួយនៅកំរិតរបស់រដ្ឋាភិបាល ប៉ុន្តែការចាត់តាំងឡើងវិញនៅចុងឆ្នាំនេះរបស់ប្រធានត្រូវបានគេយល់ ឃើញថាជាការវាយប្រហារមួយចំពោះកិច្ចប្រឹងប្រែងប្រឆាំងនឹងអំពើពុករលួយ ។

នៅខែសីហា រដ្ឋាភិបាលបណ្តោះអាសន្ននៅក្នុងប្រទេសថៃ បានធ្វើប្រជាមតិមួយស្តីពីរដ្ឋធម្មនុញ្ញថ្មី ដែលជាបទដ្ឋានសំខាន់មួយនៅការវិលត្រឡប់របស់ថៃទៅកាន់លិទ្ធប្រជាធិបតេយ្យ បន្ទាប់ពីការរដ្ឋប្រហារនៅឆ្នាំ ២០០៦ ។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រត្រូវបានធ្វើឡើងនៅខែធ្នូ និងជាទូទៅត្រូវបានចាត់ទុកថាសេរី និងយុត្តិធម៌ បើទោះបីជាការចោទប្រកាន់ពីការទិញសន្លឹកឆ្នោត ការបំភិត បំភ័យ និងភាពក្រិក្រតីមួយចំនួនតូច ។ លទ្ធផលបោះឆ្នោតក្រៅផ្លូវការបានបង្ហាញថា គណបក្សអំណាចបជាជនបានទទួលនូវអសនះជាច្រើនកន្លែង ។ ការដឹកនាំរបស់គណបក្សអំណាចប្រជាជនមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងអតីតៈនាយករដ្ឋមន្ត្រី ថាក់ស៊ីនស៊ីនណាវ៉ាត់ត្រា ។ នៅចុងឆ្នាំនេះ បញ្ហាប្រឈមធំបំផុតររបស់ប្រទេសនេះនៅតែជាការពង្រឹងការវិលត្រឡប់របស់ខ្លួនទៅកាន់រដ្ឋាបាល ដែលជ្រើសរើសដោយការបោះឆ្នោត និងដោះស្រាយនូវបុព្វហេតុចម្បងនៃរដ្ឋប្រហារតាមរយៈការពង្រឹងការគ្រប់គ្រងលើកងទ័ពការពង្រឹងស្ថាប័នប្រជាធិបតេយ្យ ការលើកកំពស់ការគោរពសេរីភាពក្នុងការនិយាយស្តី និងសារព័តិមានការធ្វើឱ្យមានការរីកចំរើនចំពោះការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្ស ដោយរួមមានការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ និងការបាត់ខ្លួននៅអំឡុងពេលធ្វើយុទ្ធនាការប្រឆាំនឹងការបះបោរ និងប្រឆាំងណាកូទីន ហើយការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយរបស់មន្ត្រី ។

លទ្ធផលចុងក្រោយដោយអំពើហិង្សានៃការបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលមូលដ្ឋាន តំណាងរាស្ត្រ និងប្រធានាធិបតេយ្យរបស់ប្រទេសកែនយ៉ានៅខែធ្នូ បានបង្ហាញនូវចំណុចខ្សោយជាច្រើននៅក្នុងស្ថាប័នប្រជាធិបតេ្យរបស់ប្រទេសកែនយ៉ា ដូចជាការផ្តោតទៅលើអំណាចនៅក្នុងតំណែងប្រធានាធិបតេយ្យ និងតំរូវការដែលទទួលស្គាល់នូវកំណែទម្រង់រដ្ឋធម្មនុញ្ញ ។ អ្នកសង្កេតការណ៍បោះឆ្នោតជាច្រើនបានសន្និដ្ឋានថា នៅពេលដែលដំណើការការបោះឆ្នោត និងរាប់សន្លឹកឆ្នោតជាទូទៅបានបំពេញនូវបទដ្ឋានប្រជាធិបតេយ្យមានភាពប្រក្រតីធ្ងន់ធ្ងរជាច្រើនក្នុងការបូកលទ្ធផល ។ ក្រុមតវ៉ា និងកំលាំងប៉ូលីសបានសម្លាប់ជនមិនស្គាល់មុខមួយចំនួនមានប្រវត្តិជាជនជាតិភាគតិចនានា និងរាប់ម៉ឺននាក់គ្មានផ្ទះសម្បែងរស់នៅនៅខែធ្នូ ដោយសារតែអំពើហិង្សាក្រោពីការបោះឆ្នោត ។

ចំពោះសង្គមស៊ីវិល និងប្រព័ន្ធឃោសនាឯករាជ្យ សេរីភាពក្នុងការសម្តែងមតិយោបល់ ការបង្កើតសមាគម មិងការប្រជុំដោយសន្តិវិធីគឺជាខ្យល់អុកស៊ីសែន ។ ដោយគ្មានសេរីភាពជាមូលដ្ឋានទាំងនេះហើយ លទ្ធិប្រជាធិបតេយ្យត្រូវបានដកហូតចេញពីដង្ហើមនៃវីជីត ។ ដោយភាពគួរឱ្យស្តោកស្តាយនៅឆ្នាំ ២០០៧ រដ្ឋាភិបាលនៅគ្រប់តំបន់បានប្រើអំណាចរបស់ខ្លួនក្នុងផ្លូវខុស និងប្រើច្បាប់ក្នុងផ្លូវខុសប្រឆាំងនឹងអង្គការក្រៅរដ្ឋាភិបាល អ្នកកាសែត និងសកម្មជនសង្គមស៊ីវិលផ្សេងទៀត ។ ដោយបន្ថែមទៅលើការដាក់កំរិតទៅលើ និងការគាបសង្កត់លើសង្គមស៊ីវិល និងប្រព័នឃោសនាឯករាជ្យ ដែលត្រូវលើកឡើងពីមុននៅក្នុងសេក្តីផ្តើមនេះ យើងក៏លើកឡើងនូវការបកស្រាយដូចតទៅ:

នៅប្រទេសអេហ្ស៊ីប សមកម្មជននយោបាយគណៈបក្សប្រឆាំង អ្នកកាសែត និងអង្គការក្រៅរដ្ឋាភិបាល បានបន្តការតស៊ូមិតដើម្បីកំណែទម្រង់ និងរិះគន់រដ្ឋាភិបាល បើទោះបីជាការប៉ុនប៉ងរបស់រដ្ឋាភិបាលក្នុងកាច់បំបាក់ពួកគេ ។ រដ្ឋាភិបាលបានបន្តឃុំខ្លួនអតីតៈបេក្ខជនប្រធានាធិបតេយ្យ អាយម៉ែន ណួរ ជាអ្នកទោសនយោបាយ ចោទប្រកាន់អ្នកកាសែតពីបទបរិហារកេ្តិ៍ ឃុំខ្លួនអ្នកបង្អាក់

ដំណើរការអ៊ីនធឺណែត និងជាពិសេស បំបិទសេរីភាពក្នុងការបង្កើតសមាគម ។ នៅខែកញ្ញា អ្នកនិពន្ធនាគយកកាសែតឯករាជ្យ ចំនួន ៧ ត្រូវបានកាត់ទោសពីបទចោទប្រកាន់ផ្សេងៗចាប់ពីការដកស្រង់សម្តីខុសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ទៅការបរិហារកេរ្តិ៍ ប្រធានាធិបតេយ្យ និងមន្ត្រីជាន់ខ្ពស់នៃគណបក្សប្រជាធិបតេយ្យជាតិដែលកំពុងតែកាន់អំណាច ។ នៅអំឡុងឆ្នាំនេះ ប៉ូលីស បានឃុំឃាំងអ្នកបង្ហាក់ដំណើរអ៊ីនធឺណែតសកម្មមួយចំនួនអស់រយៈពេលជាច្រើនថ្ងៃ។ នៅខែកញ្ញា រដ្ឋាភិបាលបានបញ្ជាការ បិទសមាគមដើម្បីជំនួយផ្នែកច្បាប់សិទ្ធិមនុស្ស ដែលជាអង្គការក្រៅរដ្ឋាភិបាល ដែលទទួលបានមូលនិធិពីម្ចាស់ជំនួយបរទេស ដោយគ្មានការគាំទ្រពីរដ្ឋាភិបាល ។ អង្គការនេះបានដើរតួនៅក្នុងបំបែករឿងក្តីជារឿងទាក់ទិននទារុណកម្មដោយបុគ្គលិកសន្តិសុខ ។

នៅអំឡុងឆ្នាំនេះ ទំហំនៃសេរីភាពសារព័ត៌មាននៅក្នុងប្រទេសអាហ្សែបាយជែនកាន់តែអន់ ។ អ្នកសង្កេតការណ៍បានពិចារណាការ កាត់ទោស និងការដាក់គុកអ្នកកាសែតប្រាំបីនាក់នៅអំឡុងឆ្នាំនោះ ហើយនិងការកាត់ទោសអ្នកកាសែតម្នាក់នៅតែជាប់គុកចាប់ពី ឆ្នាំ ២០០៦ ដោយមានការពាក់ព័ន្ធនឹងមូលហេតុនយោបាយ ។ (អ្នកកាសែតប្រាំពីរនាក់ត្រូវបានគេដោះលែងជាបន្តបន្ទាប់នៅឆ្នាំ ២០០៧ ។ អ្នកកាសែតពីរនាក់ផ្សេងទៀតនៅតែជាប់គុកដដែល ។) អ្នកកាសែតម្នាក់ទៀត ដែលការចាប់ខ្លួនគាត់ត្រូវបាន គេចាត់ទុកថាមានការពាក់ព័ន្ធនឹងមូលហេតុនយោបាយនៅតែឃុំឃាំងមុនធ្វើការជំនុំជម្រះ ។ កាសែតពីរដែលរដ្ឋាភិបាលបាន បញ្ឈប់ជាបណ្តោះអាសន្ននៅខែឧសភាបានបញ្ចប់ហើយនៅចុងឆ្នាំ ។ ចំនួនពាក្យប្តឹងបរិហារកេរ្តិ៍ ដែលគំរាមគំហែងដល់លទ្ធភាព ហិរញ្ញវត្ថុនៃសារមានព័ត៌មានបានកើនឡើង ។ អ្នកកាសែតជាច្រើននៅតែទទួលរងនូវការរំខានយាយី ការគំរាមគំហែង និងទង្វើអំពើហឹង្សារាងកាយ ដែលទំនងជាមានការទាក់ទិននឹងការរិះគន់របស់ពួកគេទៅលើមន្ត្រីរដ្ឋាភិបាល ឬមន្ត្រីមុខងារ សាធារណៈណាមួយ ។

នៅប្រទេសរ៉្វាន់ដា សេរីភាពសារព័ត៌មានបានធ្លាក់ចុះ នៅពេលដែលរដ្ឋាភិបលបានពង្រឹងច្បាប់ដែលកំណត់ឡើងយ៉ាងទូលំទូលាយ ពេក និងស្រពិចស្រពិល ។ មានការកើនឡើងករណីជាច្រើន ដែលនៅក្នុងនោះរដ្ឋាភិបាលបានរំខាន កាត់ទោស ដាក់ពិន័យ និងបំភិតបំភ័យអ្នកកាសែតឯករាជ្យ ដែលបានសម្តែងមិតយោបល់ដែលត្រូវបានចាត់ទុកថា ជាមានការរិះគន់លើរដ្ឋាភិបាលអំពី ប្រធានបទរសើប ឬអ្នកណាត្រូវបានគេជឿថាបានបំពាន់ច្បាប់ ឬបទដ្ឋានសារព័ត៌មាន ដែលត្រូវតាមដានដោយក្រុមប្រឹក្សា ច្បាប់សារព័ត៌មានឯករាជ្យពាក់កណ្តាល ។ អ្នកកាសែតជាច្រើនធ្វើការរិះគន់ដោយខ្លួនឯង ។

នៅក្នុងប្រទេសវៀតណាម សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលនៅតែមានកំណត់ ពីព្រោះរដ្ឋាភិបាលតាមដាន យ៉ាងជិតដល់ ទៅលើអង្គការទាំងនេះ ។ សង្គមស៊ីវិលត្រូវបានរឹតបណ្តឹងដោយការបង្ក្រាបជាបន្តបន្ទាប់របស់រដ្ឋាភិបាលទៅលើពួកប្រឆាំង ដែលបណ្តាលឱ្យមានការចាប់ខ្លួនអ្នកសកម្មជនសិទ្ធិមនុស្ស និងប្រជាធិបតេយ្យមួយចំនួន និងការរារាំងដល់អង្គការប្រឆាំង ដែលទើបងើបឡើង ដែលបណ្តាលឱ្យអ្នកប្រឆាំងជាច្រើនរត់គេចពីប្រទេស ។ រដ្ឋាភិបាល និងអង្គការជាច្រើនដែលគ្រប់គ្រប់ដោយ គណៈបក្សកុម្មុយនិស្តនិយមបានកាន់កាប់ផ្តាច់មុខសារព័ត៌មានបោះពុម្ព ផ្សព្វផ្សាយ និងសារព័ត៌មានអេឡិចត្រូនិក និងបិទវេបសាយជាច្រើនអំពីព័ត៌មានអន្តរជាតិ និងសិទ្ធិមនុស្ស ។ បើទោះបីជាយ៉ាងណាក៏ដោយ អង្គការសារព័ត៌មានមួយ ចំនួនបានជំរុញអោយកើតចំពោះការហាមប្រាម។

នៅប្រទេសតុយនីស្យេ ពេញមួយឆ្នាំ រដ្ឋាភិបាលបានបន្តបំភិតបំភ័យ រំខាន ចាប់ខ្លួន ដាក់គុក និងធ្វើវាយប្រហាររាយកាយលើអ្នកកាសែត អ្នកដឹកនាំសហជីពកម្មករ និងអ្នកដែលកំពុងធ្វើការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ។ រដ្ឋាភិបាលក៏បានបន្តដាក់កំហិតលើការផ្តល់មូលនិធិបរទេសទៅអង្គការទាំងឡាយ ដែលមិនត្រូវបានទទួលការយល់ព្រមពីរដ្ឋាភិបាល ។ អ្នកនិពន្ធ និងមេធាវី មហាមេត អេបប៊ូ ដែលត្រូវបានចាប់ដាក់គុកនៅឆ្នាំ ២០០៥ ពីបទចុះផ្សាយអត្ថបទតាមអ៊ីនធឺណែត ដែលធ្វើការរិះគន់ប្រធានាធិបតេយ្យ បែនអាលី ត្រូវបានដោះលែងហើយ ប៉ុន្តែលោកមិនត្រូវបានអនុញ្ញាតធ្វើដំណើរនៅក្រៅប្រទេសទេ ។

បណ្តាញសារព័ត៌មានដែលផ្តោតលើការប្រឆាំងនៅក្នុងប្រទេសកាហ្សាស្ថែន បានបន្តប្រឈមនឹងការរំខានពីរដ្ឋាភិបាល ដោយរួមមានការស៊ើបអង្កេតលើបទញ្ញត្តិ និងពន្ធដា សម្ពាធយ៉ាងខ្លាំងលើក្រុមទៅលើក្រុមហ៊ុនបោះពុម្ពកាសែត និងចោទប្រកាន់ថាមានការបិទវេបសាយ ។ នៅខែធ្នូ រដ្ឋាភិបាលសន្យាជាសាធារណៈថានឹងកែទម្រង់ច្បាប់បោះឆ្នោតរបស់ខ្លួនដោយមានជំនួយពីអង្គការ OSCE បន្ធូរលក្ខខណ្ឌចុះឈ្មោះគណបក្ស នយោបាយ និងកែតម្រូវច្បាប់សាព័ត៌មាន ដោយធ្វើការពិចារណាលើអនុសាសន៍របស់ អង្គការ OSCE ដើម្បីកាត់បន្ថយការទទួលខុសត្រូវ បទឧក្រិដ្ឋចំពោះការបរិហារកេរ្តិ៍នៅក្នុងបណ្តាញសារព័ត៌មាន និងបន្ធូរនីតិវិធីចុះឈ្មោះសម្រាប់បណ្តាញសារព័ត៌មាន ។

នៅពេលដែលបញ្ហាប្រឈមនៅតែគួរឱ្យភ័យខ្លាច ឆ្នាំ ២០០៧ គេឃើញមានកិច្ចប្រឹងប្រែងរួមជាអន្តរជាតិនៅកំរិតថ្នាក់ជាតិ និងតំបន់ក្នុងការគាំទ្រសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ។

សេចក្តីសម្រេចចំពោះប្រទេស ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ បានថ្កោលទោសលើស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកូរ៉េខាងជើង ប៉េឡារូស អ៊ីរ៉ង់ និងភូមា និងកាតួកិច្ចរបស់រដ្ឋាភិបាលដើម្បីការពារ និងថែរក្សាសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពប្រជាធិបតេយ្យនៅតែជាបញ្ហាសំខាន់មួយនៅក្នុងគណៈកម្មការទីបីរបស់មហាសន្និបាតអង្គការសហប្រជា ជាតិ ។

ការបង្ក្រាបយ៉ាងព្រៃផ្សៃរបស់របបភូមាទៅលើបាតុកម្មសន្តិវិធីដោយព្រះសង្ឃ និងអ្នកគាំទ្រប្រជាធិបតេយ្យបានជំរុញឱ្យមានការបើកប្រជុំពិសេសរបសលក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលជាហេតុធ្វើឱ្យមានគុណវិបត្តិជាច្រើន និងធ្វើឱ្យខូចប្រយោជន៍ និងការអនុម័តនៅខែតុលាដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទៅលើសេចក្តីថ្លែងការណ៍របស់ប្រធានាធិបតី ដែលអំពាវអំនាវឱ្យមានការដោះលែងភ្លាមៗអ្នកទោសនយោបាយទាំងអស់ ការបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ការពិភាក្សាពិតប្រាកដ ជាមួយលោកស្រី អង់សានស៊ូជី ក្រុមកុលសម្ព័ន្ធ និង ដៃគូដែលពាក់ព័ន្ធរួមទាំងយុទ្ធនាការនានាដែលមានសារៈ សំខាន់ដើម្បី ដោះស្រាយបញ្ហានយោបាយ សេដ្ឋកិច្ច មនុស្សជាតិ និង សិទ្ធិមនុស្ស ដែលជាការព្រួយបារម្ភរបស់ប្រជាជន។

ការប្រកួតប្រជែងដើម្បីការពារ និងលើកកំពស់គោលការណ៍សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ ទូទាំងពិភពលោកតំរូវអោយមានយុទ្ធសាស្រ្តច្នៃប្រឌិត។

មូលនិធិ ប្រជាធិបតេយ្យ របស់ អង្គការសហប្រជាជាតិ ដែលត្រូវបានស្នើ ទៅកាន់សភា ក្នុងឆ្នាំ ២០០៤ ដោយលោកប្រធានាធិបតី ប៊ូស ក្នុងពេលថ្លែងសន្ទរកថា របស់លោក បានបន្តលូតលាស់ជាជំហាន។ ទៅមុខជានិច្ច ។ គិតត្រឹមចុងឆ្នាំ២០០៧ មូលនិធិមានតំលៃសរុប ៣៦លាន ដុល្លា ហើយគំរោងផ្សេង។ ត្រូវបានកំពុងធ្វើ កំនត់សំគាល់ជាលើកទីពីរ សំរាប់ការផ្តល់ជំនួយ ។ ចំនួននៃការស្នើសុំទាំងឡាយ ដែលបានដាក់សុំ មានការកើនឡើងពី១.៣០០ សំណើរក្នុងឆ្នាំ២០០៦ ទៅ ១.៨០០ សំណើរក្នុងឆ្នាំ២០០៧ ។ ភាពជាអតិភាព គឺកំពុងនឹងផ្តល់មូលនិធិដល់គំរោងនានា ដែលគាំទ្រការខិតខំប្រឹងប្រែង របស់អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ ដែលជំរុញអោយមានលទ្ធិប្រជាធិបតេយ្យ ដូចជាមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដំណើរការផ្លាស់ប្តូរទៅរក លទ្ធិប្រជាធិបតេយ្យ របស់ប្រទេស ខុនងារយ និងដើម្បីគាំទ្រ សំរាប់ការចូលរួមរបស់ជនស៊ីវិលក្នុងតំបន់បូព៌ា និង គំរោងអភិវឌ្ឍ អាហ្រ្វិកខាងជើង ( Middle East and North Africa) ។

ការប្រជុំរដ្ឋមន្រ្តីលើកទី៤ ដើម្បី សហគមន៍ លិទ្ធិប្រជាធិបតេយ្យ ពិភពលោក បានប្រារព្ធធ្វើឡើង ក្នុងទីក្រុង បាម៉ាកូ (Bamako) ប្រទេស ម៉ាលី កាលពីខែវិច្ឆិកា និង បាន ពិភាក្សាដើម្បីរកអោយឃើញ នូវទំនាក់ទំនងទូទៅរវាង លិទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍ ។ ក្រុមរដ្ឋមន្ត្រីទាំងអស់ បានសំរេចបង្កើតការិយាល័យលេខាធិការអចិន្រ្តៃយ៍ (Permanent Secretarial) និងបានដាក់ចេញ នូវសេចក្តីប្រកាស បាម៉ាកូមួយ ដែលបង្ហាញ នូវតួនាទីសំខាន់។ របស់សង្គមស៊ីវិល ក្នុងការលើកកំពស់ លទ្ធិប្រជាធិបតេយ្យ ។

អង្គការនានា ក្នុងតំបន់ ក៏បានបង្កើនការលើកកំពស់ សិទ្ធិមនុស្ស ព្រមទាំង ពង្រឹងលទ្ធភាពស្ថាប័នរបស់ខ្លួន  ដើម្បីសំរេចបានការយកចិត្តទុកដាក់លើសិទ្ធិមនុស្សអោយកាន់តែមានប្រសិទ្ធភាពថែមទៀត ។

អង្គការ របស់សហរដ្ឋអាមេរិក ហៅកាត់ថា (OAS) បានចាប់ផ្តើមបង្កើតប្រព័ន្ធមួយ ចំពោះអ្នកអនុវត្តលិទ្ធិប្រជាធិបតេយ្យចំនួន ១០០ នាក់ ដែលមានដោយជំនាញច្បាស់លាស់លើផ្នែក ច្បាប តុលាការ ការបោះឆ្នោត និងកំណែទំរង់លើការចូលរួមរបស់ប្រជាជន ។ ប្រព័ន្ធនេះ នឹងជួយសំរួលដល់ រដ្ឋាភិបាលដែលជាប់ឆ្នោតតាមតំបន់ទាំងឡាយ អោយឆ្លើយតបនឹងការប្រកួតប្រជែងផ្សេង។ នៃអភិបាលកិច្ច លទ្ធិប្រជាធិបតេយ្យ ។

សហគមន៍អាប្រិក (AU) បានបន្តអភិវឌ្ឍស្ថាប័ន នានារបស់ខ្លួន និង យន្តការផ្សេង។ ឆ្ពោះទៅកាន់ គំរោងការពារសិទ្ធិមនុស្ស និង លិទ្ធិប្រជាធិបតេយ្យ របស់ខ្លួន ដោយរួមមាន ការទទួលយកធម្មនុញ្ញអាហ្រ្វិកលើលិទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងអភិបាលកិច្ច ។ ធម្មនុញ្ញនេះ តំកល់បង្ហាញអោយឃើញនូវ ការប្តេជ្ញារបស់រដ្ឋាភិបាលអាហ្រ្វិកទាំងឡាយ ទៅកាន់ការអនុវត្តពហុនយោបាយ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងការគោរពបញ្ញត្តិនៃច្បាប់ ព្រមទាំងមានអភិបាលកិច្ចល្អ ។

ដោយមានការបំផុសគំនិត  ពី សហគមន៍ប្រជាធិបតេយ្យ OAS និង AU បានប្រជុំគ្នា នៅទីក្រុងវ៉ាស៊ីនតោន ដើម្បីបង្កើតចំនងមិត្តភាពប្រជាធិបតេយ្យ OAS-AU កាលពីខែ កក្កដា ។ តាមរយៈ ចំនងមិត្តភាពនេះ OAS-AU អាចនឹងចែករំលែកការ

អនុវត្ត និងបទពិសោធន៍ល្អៗជាមួយគ្នា ដើម្បីដឹកនាំ ធម្មនុញ្ញប្រជាធិបតេយ្យអោយមានភាពប្រសើរឡើងខ្លួន និងធ្វើការពង្រឹង ស្ថាប័នប្រជាធិបតេយ្យទាំងឡាយ ក្នុងតំបន់ទាំងពីរ ។

ក្នុងអង្គប្រជុំនៅប្រទេសសិង្ហបុរី កាលពីខែវិច្ឆិកា, មេដឹកនាំប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ទាំងអស់បានអនុម័តធម្មនុញ្ញថ្មីមួយស្ដីអំពី ការបង្កើតស្ថាប័នសិទ្ធិមនុស្សមួយ និងផ្ដល់សិទ្ធិអោយទៅឱ្យ មន្ត្រីការបរទេសអាស៊ាន (ASEAN) កំណត់បទបញ្ជាផ្សេងៗសំរាប់ស្ថាប័ននេះ ។

នៅតំបន់បូព៌ាកណ្ដាល និង អាហ្វ្រិកខាងជើង ក្រុមសកម្មជនក្រៅរដ្ឋាភិបាលទាំងឡាយ នៅតែបន្តសកម្មភាពផ្សេងៗរបស់ពួកគេ ដែលពាក់ព័ន្ធជាមួយនឹង វេទិកា សំរាប់ អនាគត ដែលជាជំហានឈានទៅរក វេទិកាសង្គមស៊ីវិលមានសិទ្ធិស្មើគ្នា ក្នុងទីក្រុង សាណា (Sanaa) នៃប្រទេស យេម៉ែន (Yemen) នាខែ ធ្នូ ។ ជំនួបនេះ បានប្រមូលផ្ដុំមេដឹកនាំសង្គមស៊ីវិលជាង៣០០រូប ពីបណ្ដាប្រទេសទូទាំងតំបន់ ។ អ្នកចូលរួមវេទិកានេះ បានលើកឡើងនូវរបាយការណ៍មួយ បញ្ជាក់ពីសារៈសំខាន់ស្ដីពីការកែទំរង់សារជាថ្មី និងការបង្កើតគំរោងសំខាន់ៗ សំរាប់ឆ្នាំ២០០៨ ដើម្បីដោះស្រាយបញ្ហាចំបងៗ នៃសេរីភាពបញ្ចេញមតិ និងសេរីភាពក្នុងការបង្ហាញនូវការអនុញ្ញាតអោយមានការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ ។

OSCE ដែលជាស្ថាប័នដំបូងក្នុងតំបន់ ក្នុងការបង្កើតស្តង់ដារ និងការបង្កើតស្ថាប័នផ្នែកសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ បានយ៉ាងលំបាកលំបិន លើការខំប្រឹងប្រែងផ្សេងៗ ចំពោះរដ្ឋាភិបាលដែលចូលរួមមួយចំនួន ដែលចង់អោយការអង្កេតការបោះឆ្នោត ធ្វើឡើងដោយការិយាល័យនៃស្ថាប័ន ប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស មិនមានតំលៃ ។ កាលពីខែធ្នូ OSCE បានការពារខ្លួន លើគោលការណ៍ សង្កេតការណ៍បោះឆ្នោត យ៉ាងច្បាស់លាស់ ដែលធ្វើឡើងដោយ ស្ថាប័នឯករាជ្យ គ្មានការហាមឃាត់ពីអជ្ញាធរ បន្ទាប់ពីមានការសំរេចយកការច្រានចោលចំពោះ ការអញ្ជើញដោយមានល័ក្ខខ័ណ្ឌយ៉ាងធ្ងន់ធ្ងររបស់រដ្ឋាភិបាលប្រទេសរុស្ស៊ី លើការអង្កេតការបោះឆ្នោតសភា ។

---

កិច្ចខំប្រឹងប្រែង ជំរុញសេរីភាពស្ដីអំពីសិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យជុំវិញពិភពលោក របស់សហរដ្ឋអាមេរិក ដែលឆ្លុះបញ្ចាំង អំពីគុណតំលៃស្នូល របស់ប្រជាជនអាមេរិក ។ កិច្ចខំប្រឹងប្រែងនេះ បណ្ដុះអោយមានចំណាប់អារម្មណ៍រួម ដូចដែលប្រធានាធិបតី ប៊ូស  បានមានប្រសាសន៍ថា សេរីភាពគឺជាសិទ្ធិដែលមិនអាចកាត់ថ្លៃបានសំរាប់បុរស ស្ត្រី និង កុមារ គ្រប់រូប រួមទាំងមាគ៌ាឈានទៅកាន់ សន្តិភាពទូទាំងពិភពលោកយើងនោះគឺ សេរីភាព ។

យើងបង្រួបបង្រួមតម្លៃ និងផលប្រយោជន៍របស់យើងទាំងអស់គ្នា នៅពេលដែលយើងធ្វើការជាដៃគូជាមួយនឹងលទ្ធិប្រជាធិបតេយ្យ និងជាមួយអ្នកការពារសិទ្ធិមនុស្ស ដើម្បីបង្កើតប្រព័ន្ធប្រជាធិបតេយ្យ និងបង្ហាញពីការរំលោភសិទ្ធិមនុស្ស ដើម្បីលើកកម្ពស់ភាពអត់ធ្មត់ និងការពារសិទ្ធិរបស់ជនជាតិភាគតិច និងជនជាតិដែលប្រតិបត្តិសាសនា និងសិទ្ធិរបស់កម្មករ ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពរបស់ស្ត្រីឱ្យស្មើនឹងបុរស  និងបញ្ឈប់ការជួញដូរមនុស្ស ។ តម្លៃ និងផលប្រយោជន៍របស់យើង មិនដែលមានបន្ថែមទេ នៅក្នុងសមកាលភាព នៅពេលដែលយើងគាំទ្រការអភិវឌ្ឍន៍ឱ្យ សង្គ្រាមស៊ីវិលមានឯករាជ្យ និងមានសក្តានុពល ព្រមទាំងធ្វើកិច្ចការដើម្បីធានា ឱ្យមានការបោះឆ្នោះដោយសេរី និងយុត្តិធម៌ និងពង្រឹងលទ្ធិប្រជាធិបតេយ្យ ដែលមានច្បាប់ជាមូលដ្ឋាន ។

នៅពេលណាក៏ដោយ ដែលអ្នកការពារសិទ្ធិមនុស្ស ជាគោលដៅក្នុងការបង្រ្កាប នោះតម្លៃ និងផលប្រយោជន៍រយៈពេលវែងរបស់យើងនៅតែជាការបម្រើដ៏ល្អបំផុត នៅពេលដែលយើង បង្ហាញតាមរយៈការប្រើពាក្យសំដី និងទង្វើរបស់យើងក្នុងគោលដៅបង្រួបបង្រួមគ្នាជានិច្ច ជាមួយនឹងអ្នកការពារសិទ្ធិមនុស្ស ។

## ប្រទេសកម្ពុជា

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ រួមជាមួយរដ្ឋាភិបាលដែលបង្កើតឡើងដោយប្រជាពលរដ្ឋខ្មែរជាអ្នកបោះឆ្នោតឱ្យ និងមានប្រជាជនសរុបប្រហែលជា ១៤ លាននាក់ ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ ២០០៣មក គណបក្សប្រជាជនកម្ពុជា (CPP) ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សហ៊្វុនស៊ិនប៉ិច (FUNCINPEC) ដែលដឹកនាំដោយ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានបង្កើតរដ្ឋាភិបាលចម្រុះមួយ នៅក្នុងឆ្នាំ ២០០៤ ។ គណបក្សប្រជាជនកម្ពុជា បានបន្តគ្រប់គ្រងអំណាចទាំងបី របស់រដ្ឋាភិបាល និងស្ថាប័នជាតិដទៃទៀត រួមជាមួយនឹងអំណាចជាច្រើនទៀត គឺស្ថិតក្នុងកណ្តាប់ដៃរបស់រដ្ឋាភិបាល ។ ទោះបីជា អជ្ញាធរស៊ីវិល បានគ្រប់គ្រងកំលាំងសន្តិសុខដោយមានតែឈ្មោះក៏ដោយ ក៏ក្នុងការអនុវត្តន៍ផ្នែកកំលាំងសន្តិសុខ ត្រូវឆ្លើយតបទៅនឹងការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាដែរ ។ កំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋាភិបាលនៅតែខ្សោយ ទោះបីជា មិនមានរបាយការណ៍ថា រដ្ឋាភិបាល ឬភ្នាក់ងាររបស់រដ្ឋាភិបាល បានសម្លាប់មនុស្សដោយបុព្វហេតុនយោបាយក៏ដោយ ក៏មានកំលាំងសន្តិសុខមួយចំនួនបានសម្លាប់មនុស្ស ហើយមិនដែលចាប់ខ្លួនអ្នកសម្លាប់នោះឡើងតុលាការទេ និងបានលើកលែងទោសកំលាំងសន្តិសុខដែលបានសម្លាប់មនុស្ស ។ អជ្ញាធរ រដ្ឋាភិបាលមានឆន្ទៈនយោបាយតិចតួចក្នុងការប្រកាន់ខ្ជាប់នីតិរដ្ឋ ។ អ្នកជាប់ឃុំជាញឹកញាប់ត្រូវទទួលរងអំពើហឹង្សា ដើម្បីឱ្យ សារភាព និងស្ថានភាពក្នុងគុក មានភាពអាក្រក់ ។ អ្នកសង្កេតការណ៍សិទ្ធិមនុស្ស បានរាយការណ៍ថា មានការចាប់ខ្លួនតាមតែអំពើចិត្ត និងបានពន្យារពេលការឃុំខ្លួនមុនពេលកាត់ទោស នេះបង្ហាញពីភាពខ្សោយរបស់តុលាការ និងមានបំណងប្រឆាំងនឹងសិទ្ធិក្នុងការ ទទួលបានការកាត់ទោសដោយយុត្តិធម៌ ។ ជាញឹកញាប់ អំពើហឹង្សាលើជម្លោះដីធ្លីនៅកើតមានបន្ត ហើយមានការបង្ខំឱ្យប្រជាជនចេញពីលំនៅដ្ឋាន ។ រដ្ឋាភិបាល បានដាក់កម្រិតលើសេរីភាពខាងការនិយាយស្តី និងសារព័ត៌មាន តាមរយៈការដាក់ពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ និងព័ត៌មានមិនពិត រដ្ឋាភិបាលបានគ្រប់គ្រង ឬមានឥទ្ធិពលលើការចាក់ផ្សាយតាមវិទ្យុនិងទូរទស្សន៍ ហើយនៅពេលនោះក៏មាន ការរំលោភលើសិទ្ធិសេរីភាពខាងការប្រជុំដែរ ។ អំពើពុករលួយ បានកើតមាននិងបានរីករាលដាលគ្រប់ផ្នែករបស់សង្គមទាំងអស់ រួមមានអំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការរបស់រដ្ឋាភិបាល ។ អំពើហឹង្សាក្នុងគ្រួសារ និងការរំលោភសិទ្ធិលើកុមារបានកើតមានឡើង កុមារទទួលការអប់រំមិនបានគ្រប់គ្រាន់ និងការជួញដូរស្ត្រី និងកុមារនៅតែកើតមានឡើង ។ រដ្ឋាភិបាល បានជួយជនពិការតិចតួច ។ សកម្មភាពរួបរួមប្រឆាំងរបស់នយោជក និងភាពទន់ខ្សោយក្នុងការពង្រឹងច្បាប់ការងារ នៅតែបន្តមាន និងការរំលោភលើពលកម្មរបស់កុមារនៅតែជាបញ្ហា ។

មានរបត់ជាវិជ្ជមានមួយ គឺនៅថ្ងៃទី ១២ ខែមិថុនា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំរាប់ការកាត់ទោសបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យបានអនុម័តច្បាប់ផ្ទៃក្នុងរបស់ខ្លួន ដើម្បីកាត់ទោសមេដឹកនាំរបបខ្មែរក្រហមកំពូលៗ និងអ្នកដែលទទួលខុសត្រូវសំរាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ។ នៅថ្ងៃទី ៣១ ខែកក្កដា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចោទប្រកាន់ លោក កាំង ហ្គិច អ៊ាវ ដែលគេស្គាល់ថា ឌុច ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

និងបានចោទប្រកាន់មន្ត្រីជាន់ខ្ពស់បួនរូបទៀតជាបន្តបន្ទាប់នៅចុងឆ្នាំ ។ អ្នកទាំងអស់នេះបានជាប់ឃុំឃាំង ដើម្បីរង់ចាំការកាត់ទោស ។ លើសពីនេះទៅទៀត រដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការប្រារព្ធទិវាសិទ្ធិមនុស្ស នៅថ្ងៃ១០ធ្នូ ដោយអនុញ្ញាតអោយមានការដង្ហែជាក្បួនទូវសកម្មជនសិទ្ធិមនុស្សចំនួន ៥០០នាក់ ព្រមទាំងមានព្រះសង្ឃនិងប្រជាពលរដ្ឋដទៃទៀត ហើយមានការប្រជុំមួយដោយមានអ្នកចូលរួមសរុបប្រមាណជា ២.៥០០នាក់ នៅទីក្រុងភ្នំពេញ ។

# ការគោរពសិទ្ធិមនុស្ស

## ជំពូក ១ ការគោរពសេចក្តីសុច្ចរិតរបស់មនុស្ស រួមមានសេរីភាពពីការៈ

### ក. ការផ្តាច់ជីវិតដោយបំពាននិងមិនស្របច្បាប់

មិនមានរបាយការណ៍ថា រដ្ឋាភិបាល ឬក៏ភ្នាក់ងាររបស់រដ្ឋាភិបាល បានសម្លាប់មនុស្សដោយបុព្វហេតុនយោបាយនោះទេ ។ ទោះបីយ៉ាងណាក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាលការពារសិទ្ធិមនុស្ស បានរាយការណ៍ថា នៅតែមានករណីសម្លាប់មនុស្សកើតមានឡើង ហើយមិនដែលចាប់ខ្លួនអ្នកសម្លាប់នោះឡើងតុលាការទេ ។

-សមាគមអភិវឌ្ឍន៍ និងការពារសិទ្ធិមនុស្សនៅកម្ពុជា (ADHOC) កត់ត្រាបាន ៥៣ករណី ស្តីពីការសម្លាប់មនុស្ស ហើយមិនដែលចាប់ខ្លួនអ្នកសម្លាប់នោះ ឡើងតុលាការទេ មាន ១៤នាក់ក្នុងចំណោចអ្នកស្លាប់ទាំងនោះ ប៉ូលីសជាអ្នកសម្លាប់មាន ៩នាក់ ទាហានជាអ្នកសម្លាប់មាន ៦នាក់ មន្ត្រីជលផលជាអ្នកសម្លាប់ និង២៤នាក់ទៀតកំលាំងរបស់រដ្ឋាភិបាលដែលមិនស្គាល់អត្តសញ្ញាណជាអ្នកសម្លាប់ ។ មន្ត្រីប៉ូលីសចាប់ឧក្រិដ្ឋជនបានបួនករណី ។

សកម្មជននយោបាយនៅតែជាជនរងគ្រោះក្នុងការសម្លាប់ ។ នៅថ្ងៃទី២៧ ខែកុម្ភៈ ព្រះសង្ឃព្រះនាម អៀង សុខ ធឿន ជាព្រះសង្ឃខ្មែរកម្ពុជាក្រោម គេបានប្រទះឃើញសាកសពដោយគេកាត់បំពង់កនៅក្នុងវត្តទ្រទុំ ច្រើង ក្នុងខេត្តកណ្តាល សកម្មជននយោបាយនៅតែបន្តជាជនរងគ្រោះនៃការតាមសម្លាប់ ។ នៅថ្ងៃទី ២៧ កុម្ភៈ គេប្រទះឃើញសាកសពរបស់ បព្វជិត អៀង សុខធឹម នៅក្នុងវត្តទ្រទុំច្រើង ខេត្តកណ្តាល ដែលស្លាប់ដោយការអារបំពង់ក ។ មរណៈភាពរបស់ ព្រះអង្គត្រូវបានគេដឹងនៅពេលព្រឹកបន្ទាប់ពីព្រះអង្គបានចូលរួមក្រុមបាតុកម្ម នៅមុខស្ថានទូតវៀតណាមនៅក្នុងទីក្រុងភ្នំពេញ ដើម្បីទាមទារសិទ្ធិដល់ប្រជាជនខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅក្នុងប្រទេសវៀតណាម ។ ខាងប៉ូលីសបានអះអាងយ៉ាងប្រញាប់ថា នេះជាអំពើធ្វើអត្តឃាតខ្លួនឯង ហើយបានរៀបចំបូជាសព្វដោយគ្មានបន្តការស៊ើបអង្កេតតទៅមុខទៀត ។ ប៉ុន្តែក្រុមអង្គការ និងក្រុមខ្មែរកម្ពុជាក្រោមមួយចំនួនសង្ស័យថា នេះជាអំពើឃាទគំរាមខាងនយោបាយ ។

សមាជិកសកម្មនៃគណបក្សនយោបាយមួយចំនួនត្រូវបានសម្លាប់នៅក្នុងកំឡុងឆ្នាំនោះ ប៉ុន្តែខាងអង្គការ និងប៉ូលីសមិនអាចអះអាងបានថា នេះជាអំពើឃាទគំរាមក្នុងនយោបាយនោះទេ ។ កាលពីថ្ងៃទី ១៤ កុម្ភៈ មានជនដែលមិនត្រូវបានស្គាល់អត្តសញ្ញាណច្បាស់លាស់ បានលបសម្លាប់លោក ជា សូវីន ដែលជាបេក្ខជនខាងគណបក្សសមរង្ស៊ី សំរាប់ការបោះឆ្នោតទីប្រឹក្សាឃុំ ក្នុងខែមេសា នៅខេត្តបាត់ដំបង ។ នៅថ្ងៃទី ២៧ កក្កដា ក៏មានជនដែលមិនត្រូវបានស្គាល់អត្តសញ្ញាណច្បាស់លាស់ បានសម្លាប់លោក ក្លិប អ៊ុន ដែលជាអនុប្រធានឃុំ និងនៅខាងគណបក្សសមរង្ស៊ី នៅខេត្តបន្ទាយមានជ័យ ។ មេបញ្ជាការប៉ូលីសប្រចាំតំបន់បានរាយការថា ឧក្រិដ្ឋជនបានរត់គេចខ្លួនដោយមិនបានប្លន់យករបស់ទ្រព្យអ្វីពីជនរងគ្រោះ និងកន្លែងកើតហេតុនោះ

ទេ ។ ប៉ូលីសបានចាប់ជនសង្ស័យម្នាក់ដែលទាក់ទងនឹងករណីនេះ ប៉ុន្តែដោះលែងវិញបន្ទាប់ពីបានសួរចម្លើយរួច ។ សម្រាប់ករណីឃាតកម្មទាំងពីរនេះ ប៉ូលីសបញ្ជាក់ថា កំពុងបន្តការស៊ើបអង្កេតនៅឡើយ ។

នៅថ្ងៃទី ៤ មេសា មន្ត្រីប៉ូលីស ស៊ីវ សឿន បាននិយាយដោយព្រងើយថា ខ្លួនបាញ់សម្លាប់ជនរងគ្រោះ ដោយគាត់បានចូលទៅនេសាទខុសច្បាប់ក្នុងតំបន់ឯកជនមួយនៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ គ្រួសារជនរងគ្រោះបានដាក់ពាក្យបណ្តឹងប្តឹងមន្ត្រីប៉ូលីសរូបនេះ ប៉ុន្តែគាត់បានដកពាក្យបណ្តឹងវិញ បន្ទាប់ពីលោក ស៊ីវ សឿនបានសងជម្ងឺចិត្តដល់គ្រួសារនោះចំនួន ៣.០០០ ដុល្លា ស.រ.អ (១២ លានរៀល) ។ នៅចុងឆ្នាំ លោក ស៊ីវ សឿន មិនបានទទួលការចោទប្រកាន់ ឬចាប់ឃុំខ្លួននោះទេ ។

នៅថ្ងៃទី ១៥ វិច្ឆិកា នៅក្នុងកំឡុងពេលដែលធ្វើការបណ្តេញជនរស់នៅខុសច្បាប់លើដីរបស់រដ្ឋ នៅក្នុងឃុំចោមស្តាន ខេត្តព្រះវិហារ គឺមានកងកម្លាំងរដ្ឋាភិបាលដែលមិនត្រូវបានស្គាល់អត្តសញ្ញាណច្បាស់លាស់ បានសម្លាប់អ្នកភូមិពីរនាក់ ដែលបានតវ៉ានឹងការបណ្តេញនេះ ។ មានប៉ូលីស កងរាជអាវុធហត្ថ និង ទាហាន ប្រមាណជា ១៥០ នាក់ បានធ្វើការបណ្តេញ ៣១៧ គ្រួសារ ។ គ្មានការស៊ើបអង្កេតជាផ្លូវការណាមួយលើការសម្លាប់នេះទេ ។ ប៉ូលីសបានចាប់ជនរស់នៅខុសច្បាប់ទាំងនោះចំនួន ១៨ នាក់ ក្នុងនោះក៏មានអភិបាលខេត្តរងផងដែរ ដែលជាពួកគាត់ជាអ្នកទទួលខុសត្រូវក្នុងការរំលោភលើដីរដ្ឋ ។ អ្នកភូមិទាំង ១៨ នាក់នោះបានដោះលែងអោយនៅក្រៅការឃុំខ្លួន ហើយរង់ចាំការកាត់ទោសនៅចុងឆ្នាំ ។

នៅក្នុងខែមិថុនា តុលាការខេត្តព្រៃវែងបានធ្វើការកាត់ទោសជនសង្ស័យម្នាក់ ឈ្មោះ ម៉ែន មិត្ត អោយជាប់ពន្ធនាគារ រយៈពេល ១០ ឆ្នាំ ពីបទសម្លាប់សកម្មជន របស់គណបក្សសមរង្ស៊ី កាលពីខែ វិច្ឆិកា ឆ្នាំ២០០៦ ហើយអ្នករួមគំនិតពីរនាក់ទៀត ក្នុងការសម្លាប់នេះ ត្រូវជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ ។

នៅថ្ងៃទី ១៨ កក្កដា តុលាការក្រុងភ្នំពេញបានកាត់ទោស ហេង ពៅ ដែលជាមេប៉ូលីសប្រចាំទីក្រុងភ្នំពេញ និងជាអនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ អោយជាប់ពន្ធនាគារបន្ថែមរយៈពេល ២២ ឆ្នាំកន្លះ ពីបទល្មើសក្នុងឆ្នាំ២០០៥ ដូចជា ការឃុំខ្លួនមនុស្សខុសច្បាប់ ការប្រើប្រាស់អាវុធខុសច្បាប់ និងមានលុយក្លែងក្លាយ ។ ហេង ពៅ ត្រូវបានកាត់ទោសរួចទៅហើយអោយជាប់ពន្ធនាគាររយៈពេល ១៨ ឆ្នាំ ពីបទធ្វើឃាតលោកចៅក្រម សុខ ស៊ីថាមុន្នី ក្នុងឆ្នាំ២០០៣ ការធ្វើឃាតដោយមានចេតនាជាច្រើនដងរាប់មិនអស់ និងការចូលរួមការចាប់ និងឃុំខ្លួនមនុស្សខុសច្បាប់ ។ នៅក្នុងពេលធ្វើការកាត់ទោស ហេង ពៅ បានបញ្ជាក់ថា ប៊ិន សំណាង និង សុខ សំអឿន ដែលជាជនសង្ស័យពីរនាក់ ដែលគាត់បានបញ្ជារអោយចាប់ខ្លួន នៅក្នុងឆ្នាំ ២០០៥ ហើយបន្ទាប់មកត្រូវបានចោទពីបទសម្លាប់ លោក ជា វិជ្ជា ដែលជាសកម្មជនក្នុងសហគម គឺគ្មានទាក់ទងនឹងអំពើ ឃាទកម្មនោះទេ ។ នៅថ្ងៃទី ១២ មេសា តុលាការឧទ្ធរណ៍ បានកាត់ទោស លោក ប៊ិន សំណាង និង សុខ សំអឿន អោយជាប់ពន្ធនាគារក្នុងម្នាក់រយៈពេល ២០ ឆ្នាំ ។ មេធាវីរបស់ពួកគាត់ទាំងពីរ ក៏បានដាក់ស្នើសារទុក្ខទៅតុលាការកំពូល ហើយពួកគាត់រង់ចាំសកម្មភាពរបស់តុលាការកំពូលនៅចុងឆ្នាំ ។

គ្មានការរីកចំរើនទូវការស៊ើបអង្កេត  សំរាប់ករណីឃាតកម្ម នៅក្នុងឆ្នាំ ២០០៦ លើ គីន ជួន និង ធឿង ធា ដែលជាសកម្មជនរបស់គណបក្សសមរង្ស៊ី ដែលត្រូវបានសម្លាប់នៅក្នុងខេត្តព្រះវិហារ និងបន្ទាប់មកទៀតនៅខេត្តកំពង់ចាម ។ ដូចគ្នានេះដែរក៏គ្មានការរីកចំរើនលើករណី ពៅ រុំ និង ខាត ធឿន ដែលបានស្លាប់នៅក្នុងមន្ទីឃុំឃាំងប៉ូលីសក្នុងខេត្តកណ្តាល កាលពីឆ្នាំ ២០០៦ ឬករណីប៉ុនប៉ងធ្វើការហែកគុករត់នៅក្នុងខេតកំពង់ធំ និងបាត់ដំបង កាលពីឆ្នាំ ២០០៦នេះដែរ ដែលក្នុងពេលនោះធ្វើអោយអ្នកទោស ១០ នាក់បាត់បង់ជីវិត ។ សំរាប់ករណីរបស់ នង សំ ដែលត្រូវបានរាយការថាស្លាប់កាលពីខែ មិថុនា ឆ្នាំ ២០០៦ នៅក្នុងមន្ទីរពេទ្យខេត្តសៀមរាប ដោយសាររបួសក្បាលដែលវាយដោយក្រុមប៉ូលីស ប៉ុន្តែតុលាការខេត្តបានកាត់ទោសបិទរឿងក្តីនេះដោយអះអាងថា នង សំ ស្លាប់ដោយការសម្លាប់ខ្លួន ។

គ្មានការរីកចំរើនក្នុងការស៊ើបអង្កេតពីការសម្លាប់ក្នុងឆ្នាំ ២០០៥ ទៅលើសកម្មជនប្រាំនាក់របស់គណបក្សសមរង្ស៊ី ឬករណីប៉ុនប៉ងរត់ចេញពីគុកត្រពាំងថ្លុង ដែលក្នុងពេលនោះមានអ្នកទោស ១៩នាក់ និងអ្នកគ្រប់គ្រងគុកត្រូវបានសម្លាប់  ។ តុលាការឧទ្ធរណ៍ក៏មិនមានសកម្មភាពអ្វីទៅលើការស្លាប់របស់អ្នកភូមិប្រាំនាក់ និងអ្នករបួសផ្សេងទៀត ដោយកងកម្លាំងសន្តិសុខ រដ្ឋាភិបាលក្នុងកំឡុងពេលធ្វើការបណ្តេញអ្នកភូមិចេញពីដីជម្លោះនៅក្នុងភូមិក្បាលស្ពានខេត្តបន្ទាយមានជ័យ ។

នៅថ្ងៃទី ៨ កុម្ភៈ លោក ប៊ុន សំភា សួស ប៊ុនថាត និង ហៃ ជីវីន ដែលជាមេបញ្ជាការរងប៉ូលីសប្រចាំស្រុក និងឃុំនៅក្នុងខេត្តព្រៃវែង ត្រូវបានធ្វើការកាត់ទោសពីបទអំពើមនុស្សឃាតក្នុងឆ្នាំ ២០០០ ប៉ុន្តែពួកគាត់មិនបានមកកាន់តុលាការ ដោយរាយការថាពួកគាត់ កំពុងរវល់ខ្លាំងណាស់ ។ តុលាការក៏លើកការកាត់ទោសនេះទៅខែ មិថុនា ប៉ុន្តែក៏ត្រូវបាន ពន្យាពេលម្តងទៀត ដោយខាងតុលាការមានការរវល់ខ្លាំង មិនអាចមកធ្វើការកាត់ទោសនៅក្នុងខែមិថុនាបាននោះទេ ។ ការកំណត់ថ្ងៃកាត់ទោសសារជាថ្មីក៏មិនទទ់បានធ្វើនៅឡើយ ។

គ្រាប់មីនដែលបន្សល់ទុក កាលពីជំនាន់ខ្មែរក្រហម និងវិបត្តិក្នុងតំបន់ ឥណ្ឌូចិន នៅតែបន្តគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស។ យោងទៅតាមប្រព័ន្ធពតិមានកម្ពុជាអំពីជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ មិនទាន់ផ្ទុះបានអោយដឹងថា ក្នុងអំឡុងពេលមួយឆ្នាំ គ្រាប់មិននិងគ្រាប់មិនទាន់ផ្ទុះបានបំផ្លាញជីវិតមនុស្សប្រមាណ៦៣នាក់ដែល បង្កអោយមានជនពិការប្រមាណ៥៦នាក់ និងរងរបួសប្រមាណ២២២នាក់។

អ្នកអប្បមាទយុត្តិធមិ និងការសំលាប់ដោយហ្វូងមនុស្សឥតសណ្តាប់ធ្នាប់ នៅតែកើតមាន។ អង្គការអាដហុក (ADHOC) បានរាយការណ៏អោយដឹងថា ក្រុមហ្វូងមនុស្សឥតសណ្តាប់ធ្នាប់ទាំងនោះបានសំលាប់មនុស្ស ចំនួន ៩នាក់ក្នុងឆ្នាំនេះ។ ជនជាប់សង្ស័យមួយចំនួនត្រូវបានចាប់ខ្លួន។ ក្នុងហេតុការណ៏មួយចំនួន អាជ្ញាធរមិនអាចការពារជនសង្ស័យពីក្រុមហ្វូងមនុស្សឥតសណ្តាប់ធ្នាប់ទាំងនោះបានឡើយ។ អង្គការក្រៅរដ្ឋាភិបាលបានសំគាល់ថា ភាគច្រើននៃការសំលាប់ដោយក្រុមហ្វូងមនុស្ស  គឺជាប់ពាក់ព័ន្ធទៅនឹងអំពើចោរកម្មដូចជា លួច ប្លន់ រឺសង្ស័យលើអំពើធ្មប់ ជាដើម ។កាលពីថ្ងៃទី៩ ខែសីហា អ្នកភូមិ "យក ជ័រ" (Yos Chor) បានសំលាប់មនុស្សម្នាក់ដោយសារតែការលួចមាន់របស់អ្នកជិតខាង។ កាលពីថ្ងៃទី២១ ខែសីហា ឧក្រិដ្ឋជនម្នាក់

បានសំលាប់គ្រូសិល្បៈបុរាណខ្មែរម្នាក់នៅក្នុងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ដោយពួកគេមានការសង្ស័យថាបុរសម្នាក់នេះជាចេះអាគមន៍អូមអាម ។ សមត្ថកិច្ច មិនបានធ្វើការចាប់ខ្លួនឧក្រិដ្ឋជនម្នាក់នោះ ក្នុងករណីនេះឡើយ ។

កាលពីថ្ងៃទី២៧ ខែសីហា តុលាការខេត្តក្រចេះ បានកាត់ទោសមនុស្សចំនួន ៦នាក់អោយជាប់ពន្ធនាគារ ចាប់ពី៧ ទៅ ១០ខែ ក្នុងឆ្នាំ ២០០៦ ពីបទធ្វើឃាត លោក សាម សារឿន ។ តុលាការបានកាត់ទោសពួកគេដោយចោទប្រកាន់លើការបង្កររបួសស្នាម នៅពេលការអង្កេតបទល្មើសឃាតកម្មត្រូវបានលើកចោល ។ ពុំមានការរីកចំរើនណាមួយក្នុងករណីវាយដំ និងសំលាប់មនុស្សដែលប៉ុនប៉ង ធ្វើចេញពីអំពើធ្មប់ឡើយកាលពីខែកុម្ភៈ ឆ្នាំ២០០៦ ។

**ខ. ការបាត់ខ្លួន**

ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយអង្គនាម ទីម សាខន (Tim Sakhorn) ជាព្រះសង្ឃរាជវត្ត អស់រយៈកាលជាង១០ព្រះវស្សា នៅក្នុងស្រុក គីរីវង្ស ខេត្តតាកែវ បានបាត់ព្រះកាយកាលពីថ្ងៃទី៣០ ខែសីហា ។ មុនបាត់ព្រះកាយព្រះអង្គ មានព្រះសង្ឃមកពីទីក្រុងភ្នំពេញ បានផ្សឹកព្រះអង្គទៅតាមសង្ឃដិការបស់សម្តេចសង្ឃរាជ ទេព វង្ស ហើយបន្ទាប់មកមានមនុស្សមិនស្គាល់អត្តសញ្ញាណមួយក្រុមដែលត្រូវបានគេជឿជាក់ថាមានការជាប់ទាក់ទងនឹងក្រសួងមហាផ្ទៃ (MOI) បានចាប់ព្រះអង្គចូលក្នុងរថយន្តរួចបើកចេញទៅបាត់ ។ សង្ឃដិកានៃការផ្សឹកបញ្ជាក់ថា សង្ឃ ទីម សាខន បានបំបែកបំបាក់សាមគ្គីភាពរវាងកម្ពុជា និងវៀតណាម ដោយប្រើ ប្រាស់ទីអារាមសំរាប់ប្រមូលផ្តុំ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់កិត្តិសព្ទដ៏ប្រណិតរបស់ព្រះពុទ្ធសាសនា ។ នៅទីកន្លែងនោះ ព្រះអង្គត្រូវបានគេកត់សំគាល់ថាបានផ្តល់អាហារ និងទីជំរកសំរាប់ខ្មែរកម្ពុជាក្រោម ។ MOI បានបញ្ជាក់ថា ទីម សាខន បានសំរេចចិត្ត ទៅរស់នៅប្រទេសវៀតណាមបន្ទាប់ពីបានសឹករួចដែលមានមន្ត្រីក្រសួងផ្សេងៗ រៀបចំឯកសារសំរាប់បំណងនេះ ។ បើទោះបីជា មានហត្ថលេខារបស់ ទីម សាខន ហើយក៏ដោយ ក៏ឯកសារសរសេរដោយដៃនេះមិនមែនជាអក្សររបស់លោកទេ ។ ថ្ងៃទី២ ខែសីហា លោក ទីម សាខន បានបង្ហាញខ្លួនសារជាថ្មីម្តងទៀតក្នុងមន្ទីរឃុំឃាំងប្រទេសវៀតណាមដែលត្រូវបានចោទពីបទបំផ្លិចបំផ្លាញ សាមគ្គីភាព នយោបាយ ។ នៅខែកញ្ញា ក្រសួងព័ត៌មានបានបញ្ជាក់អោយដឹងថា ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសវៀតណាម ក្រុងហូជីមិញ (HO CHI MING) កំពុងតែធ្វើការស៊ើបអង្កេតពីស្ថានភាព របស់លោក ទីម សាខន នៅក្នុងមន្ទីរឃុំឃាំង ។ ថ្ងៃទី៨ ខែវិច្ឆិកា កាសែតវៀតណាម បានរាយការណ៍ថា តុលាការនៅក្នុងប្រទេសវៀតណាមសំរេចកាត់ទោសលោក ទីម សាខនអោយជាប់ពន្ធនាគាររយៈ ពេល មួយឆ្នាំពីបទបំផ្លាញសាមគ្គីភាពរវាងប្រទេសកម្ពុជានិងវៀតណាម ។

នៅថ្ងៃទី១០ ខែសីហា នាយទាហានប្រចាំអង្គភាពការពារព្រំដែន អ៊ឹម ប៊ុនធី បានបាត់ខ្លួននៅទីក្រុងប៉ៃលិន ។ បើយោងតាមសាក្សីបានអោយដឹងថា កាលពីយប់ថ្ងៃនោះមានទាហាន ៤នាក់ ដែលនៅអង្គភាពជាមួយគាត់ បានអញ្ជើញគាត់ទៅចំការកៅស៊ូរបស់មេបញ្ជាការអង្គភាពរបស់ពួកគេ គឺលោកសេនីយ៍ ប៉ុល ស៊ីនួន ។ នៅពេលដែលលោក អ៊ឹម ប៊ុនធី មកដល់ស្រាប់តែទាហានទាំង៤រូបនេះ វាយដំរូបលោក ហើយចោទប្រកាន់លោកពីបទលួចកាំភ្លើងមួយដើម ។ តាមរបាយការណ៍របស់សាក្សីដែលសុំលាក់ឈ្មោះ បានអោយដឹងថា អ៊ឹម ប៊ុនធី ត្រូវបានស្លាប់បន្ទាប់ពីការវាយដំ និង ត្រូវបានបញ្ចុះសាកសពដោយទាហាន ទាំង៤ នាក់ ។ មកដល់ចុងឆ្នាំ លោក អ៊ឹម ប៊ុនធីនៅតែបាត់ខ្លួន យោងតាមរបាយការណ៍សិទ្ធិមនុស្សមួយបានបង្ហើបថា សមត្ថកិច្ចបានបញ្ចប់ការស៊ើបអង្កេត ហើយបានបញ្ជូនលទ្ធផលទៅអោយតុលាការរួចហើយ ។ តុលាការមិនបានមានវិធានការ ណាមួយនោះទេ ហើយទាហានទាំងបួនរូបនៅតែធ្វើការដូចធម្មតា ។

**គ. ការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ និងការដាក់ទណ្ឌកម្មឬការប្រព្រឹត្តមិនត្រឹមត្រូវ**

សកម្មភាពប្រឆាំងនឹងរដ្ឋធម្មនុញ្ញដូចជា ការវាយដំ និងការធ្វើបាបលើរាងកាយពីសំណាក់សមត្ថកិច្ច រួមទាំងជនជាប់ឃុំខ្លួនអ្នកជាប់ពន្ធនាគារនៅតែបន្តជាបញ្ហាធ្ងន់ធ្ងរមួយ ។

មានរបាយការណ៍ដែលអាចជឿបានថា មន្ត្រីប៉ូលីស ស៊ីវិល និងយោធា បានធ្វើទារុណ្ឌកម្មទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយព្រមទាំងវាយដំយ៉ាងធ្ងន់ធ្ងរ ទៅលើជនជាប់ឃុំឃាំងជាពិសេសនៅពេលសួរចម្លើយ ។ ផ្អែកទៅលើបទសំភាសជាមួយអ្នកទោសចំនួន ១.២៩៣ នាក់មកពី ពន្ធនាគារចំនួន ១៨កន្លែង ក្នុងចំនោមពន្ធនាគារចំនួន ២៦កន្លែងនៅក្នុងប្រទេស តាមរយៈសមាគមន៏បង្ការនិងលើកស្ទួយសិទ្ធិ មនុស្សកម្ពុជា (LICADO) បង្ហាញថា ក្នុងមួយឆ្នាំនេះ អាជ្ញាធរបានធ្វើទារុណកម្មអ្នកទោសចំនួន ១៥៥ នាក់ ដែល ១២៥នាក់ ត្រូវបានធ្វើឡើងនៅក្នុងមន្ទីរឃុំឃាំងរបស់ប៉ូលីស និង៣០នាក់ផ្សេងទៀតនៅក្នុងពន្ធនាគារ ។ ការទាត់ធាក់ វាយដំ និងការគំរាមដោយចុងកាំភ្លើង គឺជាវិធីសាស្ត្រធម្មតានៃការធ្វើទារុណកម្មលើរាងកាយ នៅមានវិធីធ្វើទារុណកម្ម ផ្សេងទៀតដូចជា ការឆក់ ប្រព័ន្ធអគ្គិសនី បង្អត់ដង្ហើម និង ការវាយនឹងដំបង ខ្សែភ្លើង ។ អង្គការមិនមែនរដ្ឋាភិបាល រាយការណ៏ថាវាជាការធម្មតាទៅហើយដែលប៉ូលិសធ្វើទារុណកម្ម លើជនសង្ស័យដែលជាប់ឃាត់ខ្លួន រហូតទាល់តែពួកគេសារភាពថាបានប្រព្រឹត្ត បទឧក្រិដ្ឋណា មួយ ។ តុលាការ ប្រើប្រាស់កម្លាំងបង្ខិតបង្ខំឱ្យសារភាព ក្នុងការកាត់ក្តី បើទោះបីជាមានការហាមឃាត់ក៏ដោយ ។

អង្គការមិនមែនរដ្ឋាភិបាលបានកត់សំគាល់ថា អំឡុងឆ្នាំនេះ មានការធ្វើទារុណកម្មលើរាងកាយចំនួន ១៨០ករណី ធ្វើឡើងដោយ អជ្ញាធរក្នុងតំបន់ ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សឯកជន បើប្រៀបជាមួយឆ្នាំ២០០៦ មាន ១៦៤ករណី និង ១៥៤ករណីទៀតក្នុងឆ្នាំ ២០០៥ ។

នៅថ្ងៃទី២៧ ខែឧសភា មន្ត្រីប៉ូលិសយោធិន ឈ្មោះ ប្រាក់ វុត្ថា នៅស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ ត្រូវបានរាយការណ៏ថា គាត់បានចាប់ខ្លួនលោក សុខ សឿន អស់រយៈពេលមួយយប់ដោយគ្មានដីកាចាប់ខ្លួនពីតុលាការឡើយ ថែមទាំងវាយដំបុរសម្នាក់នេះរហូតទាល់តែសន្លប់ បន្ទាប់ពីមានជំម្លោះទាស់ទែងគ្នាក្នុងភោជនីយដ្ឋានមួយ ។ តាមរយៈអង្គការអាដហុក បានអោយដឹងថាក្រុមគ្រួសារលោក សុខ សឿន បានអោយស្រាបៀរចំនួន ២កេស ដើម្បីសុំអោយដោះលែងលោក សុខ សឿន ត្រលប់មកវិញ ។ បន្ទាប់មកលោក សុខ សឿន បានដាក់ពាក្យបណ្តឹងទៅកាន់ប៉ូលិសក្នុងតំបន់ ប៉ុន្តែប៉ូលិសមិនទទួលយកពាក្យបណ្តឹងនោះឡើយ ។ មិនមានការស៊ើបអង្កេតលើករណីនេះ ឬសកម្មភាពស្របច្បាប់ណាមួយប្រឆាំងនឹងលោក ប្រាក់ វុត្ថា នៅឡើយទេ ។ សកម្មភាពស្របច្បាប់អនុវត្តប្រឆាំងការប្រព្រឹត្តរបស់ប៉ូលិសពីររូបប្រចាំអង្គភាពការពារព្រំដែនលេខ៧០១ លើការវាយដំកុមារាអាយុ១៣ឆ្នាំម្នាក់ កាលពីខែកុម្ភៈ ឆ្នាំ២០០៦នោះទេ ។ ដូចគ្នានេះដែរ មិនទាន់មានការប្តឹងទៅលើមន្ត្រីមួយចំនួន ព្រមទាំងគ្មានការរីកចំរើនក្នុងការស៊ើបអង្កេតពីសំណាក់ សមត្ថកិច្ច លើករណីមួយកាលពីខែមេសា ឆ្នាំ២០០៦ ដែលពាក់ព័ន្ធនឹងក្រុមប៉ូលិសបេសកកម្មឈ្មោះ ទីម សេងគ្រាម (Team SangKriem) ក្នុងខេត្តព្រះវិហារ រួមជាមួយភ្នាក់ងារប៉ូលិសដទៃ ៣នាក់ទៀតដែលជាប់ពាក់ព័ន្ធលើការចាប់ខ្លួន និងវាយដំលោក គង់ សាឡាដ៏ ដោយគ្មានដីកា ។ មិនទាន់មានវិន័យ ឬសកម្មភាពស្របច្បាប់ណាមួយត្រូវបានប្រើប្រាស់ប្រឆាំងតវ៉ា នឹងការរំលោភបំពានច្បាប់របស់មន្ត្រីមួយចំនួន ដូចជាលើករណីវាយដំអ្នកជិះម៉ូតូម្នាក់ពី

សំណាក់រាជអាវុធហត្ថខេត្តបាត់ដំបង ក្នុងខែមេសា ឆ្នាំ២០០៦។ រួមជាមួយករណី លោក ទូស ស្តឹងដែលត្រូវបានរាជអាវុធហត្ថ២នាក់ ធ្វើទារុណកម្មរហូតដល់ស្លាប់ កាលពីខែធ្នូ ឆ្នាំ២០០៦ ហើយត្រូវបានតុលាការខេត្ត បញ្ឈប់ការស៊ើបអង្កេតកាល ពីដើមឆ្នាំ និងបញ្ជូន ទៅអោយចៅក្រមស៊ើបអង្កេត។ ការស៊ើបអង្កេត របស់តុលាការ បានបន្ត ហើយ ឧក្រិដ្ឋជនទាំងពីររូបនៅតែបន្តតំណែងជា រាជអាវុធហត្ថដដែល។

**ស្ថានភាពមន្ទីរឃុំឃាំង និង ពន្ធនាគារ**

ស្ថានភាពពន្ធនាគារ មិនបានស្របតាមស្តង់ដារអន្តរជាតិទេ។ ស្ថានភាពមួយចំនួននៅតែមានភាពលំបាក និងមានការគំរាមកំហែងដល់អាយុជីវិតដដែល។ ការខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីជំរុញអោយមានភាពប្រសើរក្នុងពន្ធនាគារ មានការរាំងស្ទះដោយខ្វះជំនួយ និងភាពកំសោយក្នុងការអនុវត្តច្បាប់។ អង្គការសិទ្ធិមនុស្សមួយចំនួន បានលើកឡើងនូវបញ្ហា ធ្ងន់ធ្ងរ រួមមាន បញ្ហាលើសចំនុះមនុស្សច្រើនហួសហេតុ អនាម័យនិង សុខាភិបាល កង្វះអាហារ និងទឹក កង្វះអាហារឧបត្ថម្ភ និងភាពទន់ខ្សោយនៃសុវត្ថិភាព។ យោងទៅតាមអង្គការ លីកាដូ បានត្រួតពិនិត្រមើលមន្ទីរឃុំឃាំង១៨កន្លែង អាចដាក់មនុស្ស ប្រមាណជា៦.៤៤០នាក់ប៉ុណ្ណោះ ប៉ុន្តែចំនួនអ្នកជាប់ពន្ធនាគារ ទាំងអស់សរុប ៩.៥៨២នាក់។

មានរបាយការណ៍ថា មន្ទីរឃុំឃាំងមួយចំនួន ដែលមានបន្ទប់ទំហំ ៤០ x ២០ ហ្វីត បានដាក់អ្នកទោសរហូតដល់១១០នាក់។ នៅឯពន្ធនាគារ CC1 បន្ទប់ឃុំឃាំងទំហំ26 x 26 ហ្វីតអាច ដាក់អ្នកទោសជាមធ្យម៥០នាក់។ នៅតាមពន្ធនាគារមួយចំនួនអាជ្ញាធរប្រើខ្នោះដៃ និងឃុំអ្នកទោសក្នុងបន្ទប់ឃុំឃាំងតូចងងឹតសំរាប់ជាការដាក់ទោសក៏រិតធ្ងន់។

អង្គការ លើកាដូ បានរាយការណ៍ថា អ្នកទោសចំនួន ៥៦ នាក់ នៅក្នុងពន្ធនាគារចំនួន ១៨ ក្នុងប្រទេស បានស្លាប់ក្នុងអំឡុងពេលមួយឆ្នាំ។

របបថវិការរបស់រដ្ឋសំរាប់ទិញអាហារសំរាប់អ្នកជាប់ពន្ធនាគារនៅតែមិនសមរម្យ ដែលនាំអោយមានជំងឺ និងកង្វះជីវជាតិ។ អង្គការមិនមែនរដ្ឋាភិបាលមួយ បានអះអាងថា ក្នុងករណីខ្លះ មន្ត្រីអាជ្ញាធរបានលក់អាហារបន្ថែមរបស់អង្គការដែលផ្តល់អោយអ្នកជាប់ពន្ធនាគារប៉ុណ្ណោះ។ បើយោងតាមអង្គការសិទ្ធិមនុស្សមួយចំនួនបានអោយដឹងថា ក្រុមគ្រួសារអ្នកទោសត្រូវសូកប៉ាន់មន្ត្រីពន្ធនាគារ ដើម្បីចូលសួរសុខទុក្ខ រឺផ្តល់អាហារ និងរបស់របរផ្សេងៗ ដល់អ្នកទោស។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ដែលថា អ្នកទោសដែលមានក្រុមគ្រួសារសូកប៉ាន់មន្ត្រីពន្ធនាគារ គឺទទួលបាន ការយកចិត្តទុកដាក់ខ្ពស់ រួមមានការជួបជាមួយអ្នកមកសួរសុខទុក្ខ ការប្តូទៅបន្ទប់ឃុំឃាំងល្អជាងមុន និងមានឱកាសអាចចេញពីបន្ទប់ឃុំឃាំងនាពេលថ្ងៃ។

មានរបាយការណ៍ថា មន្ត្រីមួយចំនួនទាមទារសំណូកមុននឹងអនុញ្ញាតអោយអ្នកទោសឡើងតុលាការ ឬដាក់ពាក្យបណ្តឹងមុន នឹងដោះលែងអ្នកទោសដែលដល់ពេលត្រូវចេញពីគុក។

ក្នុងពន្ធនាគារមួយចំនួនគ្មានការដាក់បែងចែករវាងអ្នកទោសវ័យចាស់ និងវ័យជំទង់ ភេទប្រុស និងភេទស្រី ឬអ្នកទោសកំរិតធ្ងន់ ឬកំរិតស្រាលនោះទេ ។ ជនជាប់ឃុំមិនទទ់បានកាត់ទោសជានិច្ចជាកាលដាក់លាយឡំជាមួយជនបានកាត់ទោសរួចហើយ ។ អង្គការលីកាដូ បានរាយការណ៍ថាមានជនជាប់ឃុំនៅក្នុងពន្ធនាគារជាកុមារ អាយុពី១៣ ទៅ ១៧ឆ្នាំ ចំនួយ ៦២២នាក់ដែលភាគច្រើន ត្រូវបានឃុំនៅក្នុងពន្ធនាគារដែលមិនមានសំភារៈគ្រប់គ្រាន់ សំរាប់ដាក់ចែកអ្នកទោសពេញវ័យ ។

ជាទូទៅ រដ្ឋាភិបាលបានអនុញ្ញតអោយក្រុមសិទ្ធិមនុស្សទាំងក្នុង និងក្រៅស្រុក រួមទាំងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ចុះទៅក្នុងពន្ធនាគារនានា និងផ្តល់ការបណ្តុះបណ្តាលការអប់រំផ្នែកសិទ្ធិមនុស្សទៅដល់ឆ្មាំយាមមន្ទីរឃុំឃាំង ។ តែទោះជាយ៉ាងណាក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ពេលនេះកិច្ចសហប្រតិបត្តិការពីអាជ្ញាធរក្នុងស្រុកនៅមានកំណត់នៅឡើយ ។ ដោយឡែក អាជ្ញាធរបានកាត់បន្ថយ ការធ្វើជំនួបជាមួយអ្នកទោសដែលមិនទាន់ធ្វើការកាត់ក្តី ។ ក្រសួងមហាផ្ទៃបន្តអោយមេធាវី អ្នកឃ្លាំមើលសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខទាំងអស់ សុំការអនុញ្ញតមុនពេលចូលជួបអ្នកទោស ។ ក្រសួងមហាផ្ទៃ មិនផ្តល់ការអនុញ្ញតទៅលើករណីពាក់ព័ន្ធនឹងនយោបាយ មួយចំនួន ។ អង្គការមិនមែនរដ្ឋាភិបាល ក៏មិនត្រូវបានអនុញ្ញាត អោយធ្វើការសំភាសន៍អ្នកជាប់ឃុំឃាំងជាលក្ខណៈឯកជននោះទេ ។

ឃ. <u>ការឃុំឃាំង ឬចាប់ខ្លួនតាមអំពើចិត្ត</u>

ច្បាប់ហាមឃាត់ការចាប់ ឬឃុំខ្លួនដែលគ្មានដីកាពីតុលាការ ប៉ុន្តែនាពេលបច្ចុប្បន្ន រដ្ឋាភិបាលមិនបានគោរពតាមការហាមឃាត់ទាំងនេះទេ ។ សភាជាតិបានអនុម័តក្រមនីតិវិធីព្រហ្មទ័ណ្ឌ កាលពីថ្ងៃទី ០៧ ខែមិថុនា ហើយកាលពីខែសីហាព្រះករុណាបានឡាយព្រះហស្ថលេខាដាក់អោយអនុវត្តច្បាប់ផ្លូវការ ។ ច្បាប់ថ្មីនេះបានអនុញ្ញាតពន្យារការឃុំខ្លួនមុនពេលកាត់ទោសឡើងរហូតដល់ ៦ខែ សំរាប់បទ ល្មើសមជ្ឈិម និង១៨ខែ សំរាប់បទឧក្រិដ្ឋ ។ មុនពេលការអនុម័តច្បាប់នេះ មានការឃុំខ្លួនមុនពេលកាត់ទោសរយៈពេលអតិបរមា សំរាប់មនុស្សពេញវ័យ គឺមានរយៈពេល ៦ខែ ស្ថិតក្រោមច្បាប់ UNTAC ទោះបីជា រដ្ឋាភិបាលមានពេលខ្លះបានឃុំឃាំងអ្នក ទោសមុនពេលកាត់ទោសមានរយៈពេលវែងជាងនេះក៏ដោយ ។ ADHOC បានរាយការណ៍ថា យ៉ាងហោចណាស់មានមនុស្ស ចំនួន ១០០នាក់ ត្រូវបានចាប់ខ្លួន និងឃុំឃាំងដោយខុសច្បាប់នៅអំឡុងឆ្នាំនេះ ។ ADHOC បានចេញសេចក្តីថ្លែងការណ៍ថា មានមនុស្ស៣២នាក់ក្នុងចំណោម១០០នាក់ ដែលត្រូវបានឃុំឃាំងដោយខុសច្បាប់ ត្រូវបានដោះលែងឱ្យមានសេរីភាពជាបន្តបន្ទាប់ ក្រោយពេលអ្នកជាប់ឃុំឃាំងបានដាក់ពាក្យបណ្តឹង ព្រមទាំងមានអន្តរាគមន៍របស់អង្គការមិនមែនរដ្ឋាភិបាលផ្នែកការពារសិទ្ធិមនុស្ស ឬមានការសូកប៉ាន់ ។ ADHOC ជឿជាក់ថា ចំនួនពិតប្រាកដនៃការចាប់ខ្លួន និងឃុំខ្លួនតាមតែអំពើចិត្តមានកើនឡើងបន្តិចបន្តួច ពីព្រោះមានជនរងគ្រោះមួយចំនួននៅតាមតំបន់ជនបទ មិនបានដាក់ពាក្យបណ្តឹងដោយសារមានភាពលំបាក់ក្នុងការធ្វើដំណើរមកការិយាល័យរបស់អង្គការមិនមែនរដ្ឋាភិបាលផ្នែកការពារសិទ្ធិមនុស្ស ឬមានការភ័យខ្លាចចំពោះសន្តិសុខក្រុមគ្រួសាររបស់ពួកគេ ។ ដោយយោងតាម ADHOC មិនមានច្បាប់ ឬមិនបានចាត់វិធានការសមស្របដើម្បីប្រឆាំងនឹងមនុស្សដែលទទួលខុសត្រូវលើសកម្មភាពខុសច្បាប់ ។

**តួនាទីផ្នែករចនាសម្ព័ន្ធរបស់ប៉ូលីស និងសន្តិសុខ**

នាយកដ្ឋាននគរបាល ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ហើយនាយកដ្ឋាននគរបាលជាអ្នកគ្រប់គ្រងគ្រប់អង្គភាពប៉ូលិសស៊ីវិលទាំងអស់ ។ កំលាំងប៉ូលិសបានបែងចែកជា ប៉ូលិសមានអំណាចក្នុងការចាប់ខ្លួន ប៉ូលិសគ្មានអំណាចក្នុងការចាប់ខ្លួន និងប៉ូលីសតុលាការ ។ កងរាជអាវុធហត្ថមានសិទ្ធិក្នុងការចាប់ខ្លួនជនស៊ីវិល ដែលរស់នៅលើអចលនទ្រព្យរបស់យោធា ឬនៅពេលមានការផ្តល់អំណាចឱ្យកងរាជអាវុធហត្ថ ដោយក្រុមជួររដ្ឋាភិបាលតាមស្រុកមូលដ្ឋាន។

មន្ត្រីប៉ូលិសខ្លះ បានដោះលែងអ្នកទោស និងក្នុងករណីជាច្រើនទៀត រដ្ឋាភិបាលបានចាត់វិធានការតិចតួច ឬមិនមានវិធានការសោះ ។ មានរបាយការណ៍ជាច្រើនថា ប៉ូលិស ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងប្រធានចៅក្រម បានទទួលសំណូកពីម្ចាស់ពាណិជ្ជករខុសច្បាប់ ។

ច្បាប់ តម្រូវឱ្យប៉ូលិស ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ រួមមាន ពាក្យបណ្តឹងប្រឆាំងការរំលោភរបស់ប៉ូលិស ទោះបីយ៉ាងណាក៏ដោយ ក្នុងការអនុវត្តន៍វិញ ចៅក្រម និងព្រះរាជអាជ្ញាកម្រនឹងស៊ើបអង្កេតដោយឯករាជ្យណាស់ មុនពេលកាត់សេចក្តីជាសាធារណៈ ។ ប្រធានចៅក្រម បានចេញសាលក្រមដោយផ្អែកទៅលើរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់ប៉ូលិស និងកសិណសាក្សីតែប៉ុណ្ណោះ ។ ជាទូទៅ ប៉ូលិសបានទទួលតិចតួចផ្នែកការបណ្តុះបណ្តាលជាលក្ខណៈវិជ្ជាជីវៈរបស់ប៉ូលិស ។ ប៉ូលិសដែលមិនបានការពារ ឬមិនបានទទួលខុសត្រូវចំពោះការប្រើអំពើហឹង្សានៅក្នុងសង្គម គឺកម្រដាក់វិន័យណាស់ ។ មិនមានការរីកចំរើនទេ ក្នុងករណីខែមេសា ឆ្នាំ២០០៦ ស្តីពីវិធានការប្រឆាំងនឹងថ្នាំញៀន និងមន្ត្រីរាជអាវុធហត្ថ ដែលបានបាញ់ឱ្យរបួសកញ្ញា សុវណ្ណសុជាតា ដែលជាអ្នកចម្រៀងដ៏ល្បីមួយរូប ។ មិនបានចាត់វិធានការតាមផ្លូវច្បាប់ទេ ក្នុងករណីនៅខែមេសា ឆ្នាំ ២០០៦ ស្តីពីករណីមានកងពលតូចពីរក្រុមដែលមានមន្ត្រីអង្គភាពយោធាចំនួន ៧០នាក់ បានបាញ់ឱ្យរបួសមនុស្សម្នាក់នៅក្នុងក្រុងភ្នំពេញ ។ មិនមានការរីកចំរើនទេ ក្នុងករណីនៅខែមិថុនា ឆ្នាំ ២០០៦ ដែលមន្ត្រីយោធាបានបាញ់ឱ្យរបួសកម្មកររោងចក្រកាត់ដេរមួយរូប ។ នៅខែកុម្ភៈ មានចៅក្រមស៊ើបអង្កេតមួយរូបនៅក្នុងខេត្តសៀមរាប បានចេញដីកាចាប់ខ្លួនមន្ត្រីប៉ូលិសបីរូបតាមការចោទប្រកាន់ពីបទ បានចាប់រំលោភក្មេងស្រីអាយុ១២ឆ្នាំមួយរូបនៅខែវិច្ឆិកា ឆ្នាំ ២០០៦ ទោះបីជាយ៉ាងណាក៏ដោយក៏ជនជាប់សង្ស័យនៅតែស្ថិតនៅក្រៅឃុំឃាំងនៅឡើយ។ មិនមានការរីកចម្រើនទេ ករណីការអំពាវនាវមិនបានសម្រេចឱ្យរួចទោសពីការចោទប្រកាន់ ចៅក្រមបីរូប ព្រះរាជអាជ្ញារងពីររូប និងក្រឡាបញ្ជីពីររូប ពីបទមានអំពើពុករលួយ និងការរួមគំនិតដែលទាក់ទងនឹងអំពើពុករលួយនៅខែមេសា ឆ្នាំ ២០០៦ បន្ទាប់មកបានកាត់ទោសម្តងទៀតបន្ទាប់ពីមានការអំពាវនាវសុំឱ្យមានការលើកលែងទោស ។

**ការចាប់ និងឃុំខ្លួន**

ច្បាប់តម្រូវឱ្យប៉ូលិសទទួលដីកាពីចៅក្រមស៊ើបអង្កេតជាមុនសិន មុនពេលធ្វើការចាប់ខ្លួន ប៉ុន្តែប៉ូលិសអាចចាប់ខ្លួននរណាម្នាក់បានដោយគ្មានដីកាក្នុងករណីប្រព្រឹត្តបទឧក្រិដ្ឋកម្ម ។ ច្បាប់អនុញ្ញាតឱ្យប៉ូលិសចាប់ជនជាប់ចោទដាក់គុក និងធ្វើការស៊ើបអង្កេតរយៈពេល ៤៨ ម៉ោង រួមទាំងថ្ងៃចុងសប្តាហ៍ និងថ្ងៃបុណ្យជាតិ ហើយមុនពេលចោទប្រកាន់ត្រូវដាក់ពាក្យបណ្តឹង ។ ក្នុងករណី

បទឧក្រិដ្ឋជាករណីលើកលែងដោយបានចេញបញ្ញត្តិដោយច្បាប់ គឺប៉ូលីសអាចឃុំខ្លួនជនជាប់សង្ស័យបានរយៈពេល ២៤ ម៉ោង បន្ថែមទៀតដោយមានការយល់ព្រមពីព្រះរាជអជ្ញា ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អាជ្ញាធរបានពន្យារការឃុំខ្លួនជនជាប់សង្ស័យជាប្រចាំមុនពេលធ្វើការចោទប្រកាន់ ។ មានអ្នកជាប់ឃុំឃាំងជាច្រើន ជាពិសេសអ្នកជាប់ឃុំឃាំងដោយគ្មានមេធាវី គឺពួកគេ គ្មានឱកាសបង់ប្រាក់ធានាខ្លួន ដើម្បីនៅក្រៅឃុំ ។ ស្ថិតក្រោមច្បាប់នីតិវិធីថ្មីប្រឆាំងនឹងឧក្រិដ្ឋកម្ម ជនជាប់ចោទអាចត្រូវចាប់ ខ្លួន និងឃុំខ្លួនបានឡើងទៅដល់ ២៤ ម៉ោង មុនពេលជួបជាមួយមេធាវី ប៉ុន្តែអ្នកជាប់ឃុំឃាំង ត្រូវឃុំខ្លួនរយៈពេលជាច្រើនថ្ងៃជាទម្លាប់ មុនពេលអនុញ្ញាតឱ្យមេធាវី ឬក្រុមគ្រួសារទៅជួប ។ យោងទៅតាមមន្ត្រីរដ្ឋាភិបាលការពន្យារពេលការឃុំខ្លួនដ៏វែងបែបនេះ គឺបណ្តាលមកពីសមត្ថភាពប្រព័ន្ធតុលាការមានកំណត់ ។

LICADHO បានរាយការណ៍ថា នៅពាក់កណ្តាលឆ្នាំយ៉ាងហោចណាស់មានអ្នកជាប់ឃុំមុនពេលកាត់ទោសចំនួន ១០១រូប ត្រូវបានឃុំខ្លួនលើសពី ៦ ខែ ដែលហួសពីការកំណត់ក្នុងច្បាប់ ។ ស្ថិតក្រោម ច្បាប់ថ្មីនេះ បញ្ជាក់យ៉ាងច្បាស់ថា អាចអនុញ្ញាតឱ្យមានការពន្យារពេលការឃុំខ្លួនមុនពេលកាត់ទោស នៅចុងឆ្នាំ យ៉ាងហោចណាស់ មានអ្នកទោស ៣៤ រូប ស្ថិតនៅក្នុងករណីបែបនេះ ។ នៅថ្ងៃទី១៩ ខែឧសភា មានមន្ត្រីអាវុធហត្ថ ២ រូប នៅខេត្តបន្ទាយមានជ័យ បានឃុំខ្លួនលោក គីម ហ៊ាង អស់រយៈពេលបីថ្ងៃ បន្ទាប់ពីលោក គីម ហ៊ាង មានជម្លោះជាមួយអ្នកជិតខាងរបស់គាត់ គឺមន្ត្រីយោធាភូមិភាគមួយរូប ។ មានមន្ត្រីពីររូប បានធ្វើការចាប់ខ្លួន ដោយគ្មានដីកាបង្គាប់ ។ បន្ទាប់មក មានអង្គការមិនមែនរដ្ឋាភិបាលមួយ បានធ្វើអន្តរាគមន៍ ពេលនោះមេបញ្ជាការរបស់មន្ត្រីទាំងពីរនោះ បានបញ្ជាឱ្យដោះលែងវិញ ។មិនមានវិធានការផ្នែកច្បាប់ ឬផ្នែករដ្ឋបាលណាមួយ ប្រឆាំងនឹងមន្ត្រីទាំងនោះទេ ។ នៅថ្ងៃទី២៥ ខែឧសភា មានយុវជនជនជាតិភាគតិច ចារ៉ាយមួយរូប ដែលមានអាយុ ១៣ ឆ្នាំ បានកាត់ទោសនៅក្នុងតុលាការខេត្តរតនៈគីរី ឱ្យជាប់គុកប្រាំបីខែ និង១០ថ្ងៃ ពីបទលួចឃ្មោះទង់ដែង ។ យុវជននេះ មានអាយុ ១២ ឆ្នាំ នៅពេលចាប់ខ្លួន ដែលស្ថិតក្រោមអាយុអប្បបរមាមិនអាចដាក់គុកបាន ប៉ុន្តែផ្ទុយទៅវិញ យុវជននេះ ត្រូវបានឃុំខ្លួនមុនពេលកាត់ទោសរហូតទៅដល់ជាងប្រាំបីខែ ។ ដោយយោងទៅតាម ADHOC នៅថ្ងៃទី២៥ ខែឧសភា មានព្រះរាជអាជ្ញាមួយរូប បានដាក់ពាក្យបណ្តឹងនេះ ទៅតុលាការកំពូល ប៉ុន្តែនៅចុងឆ្នាំ យុវជននេះ ស្ថិតនៅក្នុងគុកដដែល ។

នៅថ្ងៃទី៩ ខែសីហា តុលាការក្រុងភ្នំពេញ បានកាត់ទោសមនុស្សប្រាំមួយរូប និងបានដោះលែងមនុស្សពីររូបទៀត ដែលបានចោទប្រកាន់ពីបទរៀបចំផែនការណ៍ដាក់គ្រាប់បែកឱ្យផ្ទុះ នៅឯពិធីបុណ្យអុំទូកក្នុងខែវិច្ឆិកា ឆ្នាំ ២០០៦ ។ ក្នុងចំណោមមនុស្សប្រាំមួយរូបនោះមានពីររូបត្រូវ បានកាត់ទោសដោយកំបាំងមុខ ឱ្យជាប់គុករយៈពេល ១២ ឆ្នាំ ។ មនុស្សបួនរូបទៀតត្រូវបានកាត់ឱ្យជាប់គុករយៈពេល ៦ ឆ្នាំ ។ មេធាវី និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានអះអាងថា ប៉ូលីស មិនដែលបង្ហាញដីកាបង្គាប់ចាប់ខ្លួនទេ ឬមិនប្រាប់ជនជាប់សង្ស័យពីបទចោទប្រកាន់របស់ពួកគេទេ ។

### ង. ការច្រានចោលស្តីពីការកាត់ទោសជាសាធារណៈដោយយុត្តិធម៌

រដ្ឋធម្មនុញ្ញ បានចែងឱ្យមានតុលាការឯករាជ្យ ប៉ុន្តែរដ្ឋាភិបាល មិនបានគោរពឯករាជ្យភាពរបស់ខ្លួនទេ ។ អំណាចនីតិប្រតិបត្តិនៅតែមានឥទ្ធិពល និងជ្រៀតជ្រែកដល់អំណាចតុលាការ និងមានអំពើពុករលួយរីករាលដាល ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។

ប្រព័ន្ធតុលាការ មានដូចជា សាលាជំរះក្តី តុលាការឧទ្ធរណ៍ និងតុលាការកំពូល ។ រដ្ឋធម្មនុញ្ញ កំណត់ផងដែរនូវអាណត្តិរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ព្រមទាំងបានផ្តល់សិទ្ធិឱ្យក្រុមប្រឹក្សានេះ ដើម្បីពិនិត្យមើលច្បាប់រដ្ឋធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការតែងតាំង ពិនិត្យមើល និងដាក់វិន័យលើចៅក្រម ។ សមាសភាពនៃក្រុមប្រឹក្សាទាំងពីរនេះ មានទិន្នាការទៅខាងគណបក្សប្រជាជនកម្ពុជាទាំងស្រុង ។

មានប្រព័ន្ធតុលាការយោធាដាច់ដោយឡែកមួយ ដែលទទួលរងនូវភាពទន់ខ្សោយ ដែលស្រដៀងគ្នានឹងភាពទន់ខ្សោយរបស់ប្រព័ន្ធតុលាការស៊ីវិល ។ ក្នុងករណីមួយចំនួនមានភាពខុសប្លែកគ្នាផ្នែកច្បាប់ រវាងតុលាការយោធា និងតុលាការស៊ីវិល ជួនកាលព្រងើយកន្តើយក្នុងការអនុវត្តច្បាប់ ខណៈពេលដែលជនស៊ីវិល មានរឿងក្តីនៅសាលាក្តីតុលាការយោធា ។ ជនស៊ីវិលត្រូវបានធ្វើការសួរចម្លើយដោយតុលាការយោធា ទោះបីតុលាការនេះគ្មានសមត្ថកិច្ចខាងផ្លូវច្បាប់ នៅក្នុងករណីរឿងក្តីរបស់ជនស៊ីវិលក៏ដោយ ។

នៅថ្ងៃទី១២ ខែមិថុនា អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួន ដើម្បីចាប់ផ្តើមកាត់ទោសឧក្រិដ្ឋកម្មដ៏យង់ឃ្នងនៃរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ នៅថ្ងៃទី៣១ ខែកក្កដា មានសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានចោទប្រកាន់លោក កាំង ហ្គិច អ៊ាវ (ដែលស្គាល់ថា ឌុច) ដែលជាអតីតប្រធានគុកធ្វើទារុណកម្ម S-21 របស់ខ្មែរក្រហម ឬគុកទួលស្លែង សំរាប់ប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបានដាក់ ឌុច នៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះនៅក្នុងតុលាការកម្ពុជាជាបណ្តោះអាសន្ន ។ ក្រោយមកទៀត អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានចាប់ និងឃុំខ្លួនមេដឹកនាំខ្មែរក្រហមបួនរូបបន្ថែមទៀត និងបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមៈ រួមមានលោក នួន ជា (ដែលស្គាល់ថាជា "បងធំទី ២") លោក ខៀវ សំផន លោក អៀង សារី និងលោក អៀង ធីរិទ្ធ ដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចគ្នា ។ នៅខែសីហា មេធាវីរបស់ ឌុច បានប្តឹងទៅឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនជាបណ្តោះអាសន្នរបស់ ឌុច ។ នៅថ្ងៃទី៣ ខែធ្នូ ការឃុំខ្លួនមុនពេលកាត់ទោសនៅមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះនៅក្នុងតុលាការកម្ពុជា បានសម្រេចចិត្តជាឯកច្ឆន្ទ បន្តការឃុំខ្លួន និងច្រានចោលសេចក្តីសម្រេចរបស់ឧទ្ធរណ៍ ។

**នីតិវិធីក្នុងការកាត់ក្តី**

ការជំរះក្តីធ្វើជាសាធារណៈ ។ មិនមានការប្រើក្រុមប្រឹក្សាតុលាការ ហើយចៅក្រមជំនុំជំរះមានសិទ្ធិក្នុងការចេញសាលក្រម ។ ចុងចោទ មានសិទ្ធិក្នុង ការបង្ហាញខ្លួន និងពិគ្រោះយោបល់ជាមួយនឹងមេធាវី ព្រមទាំងប្រឈមមុខ នឹងសួរសាក្សីពីសំនួរដែលប្រឆាំងនឹងពួកគេ និងបង្ហាញសាក្សី និងភស្តុតាងដោយផ្ទាល់ខ្លួន ។ ប្រសិនបើចុងចោទ មិនអាចលៃលករកមេធាវីបាននោះ តុលាការត្រូវផ្តល់អ្នកតំណាងច្បាប់ឱ្យចុងចោទដោយឥតគិតថ្លៃ ទោះបីជាយ៉ាងណាក៏ដោយ ក៏តុលាការមានការខ្វះខាតធនធានផ្នែកអ្នកប្រឹក្សាច្បាប់ ដើម្បីផ្តល់ឱ្យចុងចោទ ហើយចុងចោទភាគច្រើន បានស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬបានឡើងតុលាការដោយគ្មានអ្នកតំណាងច្បាប់ ។ ជាធម្មតា ការកាត់ក្តីធ្វើឡើងដោយមានការប្តូរគ្នាត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងធ្វើឡើងគ្រាន់តែជាការគោរពប៉ុណ្ណោះ ប៉ុន្តែជាធម្មតា លទ្ធផលពិតមិនកើតមានឡើងទេ ។ ចុងចោទ និងមេធាវីរបស់ចុងចោទមានសិទ្ធិក្នុង

ការត្រួតពិនិត្យភស្តុតាងរបស់រដ្ឋាភិបាល ដែលទាក់ទងនឹងករណីរបស់ពួកគេ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅពេលនោះ មានមានភាពលំបាក់ សំរាប់ពួកគេ ដើម្បីទទួលបានសិទ្ធិបែបនេះ ជាពិសេស ប្រសិនបើ ករណីបែបនេះ ជាករណីរឿងនយោបាយ ឬទាក់ទងនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ឬសមាជិកវរជនដែលទាក់ទងយ៉ាងជិតស្និតនឹងរដ្ឋាភិបាល ។ ច្បាប់ បានចែងថា បើមិនរកឃើញថាមានកំហុសទេ នោះចុងចោទនៅតែជាមនុស្សគ្មានទោស និងមានសិទ្ធិឡើងទៅឧទ្ធរណ៍ ប៉ុន្តែដោយសារអំពើពុករលួយ មានភាពសុះសាយ  ទើបចុងចោទជាញឹកញាប់បានរំពឹងទៅលើការសូកចៅក្រម ដើម្បីឱ្យរួចពីសាលក្រម ។ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការឡើងឧទ្ធរណ៍ ជួនកាលមានភាពលំបាកក្នុងការផ្ទេរអ្នកទោសពីមន្ទីរឃុំឃាំងខេត្តទៅតុលាការឧទ្ធរណ៍ នៅក្នុងទីក្រុងភ្នំពេញ ។ ដូច្នេះហើយ ទើបមានការជំរះសេចក្តីនៅសាលាឧទ្ធរណ៍ក្នុងករណីជាច្រើនដោយកំបាំងមុខចុងចោទ ។

ដោយសារកង្វះធនធាន ប្រាក់បៀវវត្សរ៍នៅទាប និងការបណ្តុះបណ្តាលនៅខ្សោយ ទើបបណ្តាលឱ្យអំពើពុករលួយ និងភាពមិនសម្រេចបានផល មានកម្រិតខ្ពស់ នៅក្នុងប្រព័ន្ធអំណាចតុលាការ និងរដ្ឋាភិបាល មិនបានធានាដំណើរកាត់ទោសឱ្យបានត្រឹមត្រូវ ។ ពីខែមករាដល់ខែកញ្ញា មជ្ឈមណ្ឌលសំរាប់ការអភិវឌ្ឍន៍សង្គ្រម បានពិនិត្យឃើញមានបទឧក្រិដ្ឋ ១.៤២០ករណី និងមានសវនាការបទល្មើសមជ្ឈឹម ២.៤៣៧ករណី និងបានពិនិត្យឃើញមានការរំលោភបំពាននៅពេលកាត់ក្តី នៅក្នុងតុលាការកំពូល តុលាការឧទ្ធរណ៍ និងសាលាជំរះក្តីចំនួនបួនទៀត ។ នៅក្នុងរបាយការណ៍មួយស្តីពីការកាត់ក្តីដែលបានសង្កេតពីខែមករាដល់ខែមីនាថា មជ្ឈមណ្ឌលសំរាប់ការអភិវឌ្ឍន៍សង្គ្រម បានចេញសេចក្តីថ្លែងការណ៍ថា តុលាការ បានកាត់ទោសកំបាំងមុខ ៣៤ភាគរយក្នុងចំណោមមនុស្ស ៧៤០នាក់ ។ នៅតុលាការឧទ្ធរណ៍ មានចុងចោទ ៦៩ភាគរយនៃករណី មិនបានបង្ហាញមុខអំឡុងពេលកាត់ក្តី ។ មាន ៣៧ភាគរយនៃចំណោមចុងចោទទាំងអស់ ដែលត្រូវបានចោទប្រកាន់បទឧក្រិដ្ឋ មានអ្នកតំណាងច្បាប់ បើប្រៀបធៀបទៅនឹងបទល្មើសមជ្ឈឹមមានត្រឹមតែ ៧ភាគរយប៉ុណ្ណោះ ។

មន្ត្រី បានរាយការណ៍ថា មានពាក្យបណ្តឹងជាច្រើននៅមិនទាន់ដោះស្រាយរួច ដោយសារកង្វះចៅក្រម និងបន្ទប់សវនាការ ។ អង្គការ មិនមែនរដ្ឋាភិបាល បានរិះគន់ដំណើរការយឺតយ៉ាវនេះ មកពីមន្ត្រីតុលាការដោះស្រាយតែករណីដែលពួកគេ អាចទទួលបានលាបសក្ការៈច្រើន ។

នៅមានការខ្វះខាតច្រើនផ្នែកមេធាវីដែលបានបណ្តុះបណ្តាល ជាពិសេសនៅក្រៅភ្នំពេញ ។ អ្នកដែលគ្មានមធ្យោបាយធ្វើដំណើរដើម្បីទៅជួបអ្នកផ្តល់ប្រឹក្សា ជានិច្ចកាលមិនមានឱកាសទទួលបានសិទ្ធិក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌នោះទេ ។ យោងទៅតាមគណៈមេធាវី មានមេធាវីប្រហែលជា ៣០ភាគរយក្នុងចំណោមមេធាវី៥៧៣រូបនៅទូទាំងប្រទេស  ដែលបានផ្តល់ប្រឹក្សាផ្នែកច្បាប់ទៅឱ្យជនក្រីក្រ ចំនួននេះ គឺមិនគ្រប់គ្រាន់ទេដើម្បីឱ្យគ្របដណ្តប់លើសិទ្ធិសេរីភាពផ្នែកច្បាប់ជាមូលដ្ឋានរបស់អ្នកក្រីក្រនៅក្នុងប្រទេសក្រីក្រមួយនេះ ។

មានរបាយការណ៍ជាលាយលក្ខណ៍អក្សរព្រមទាំងមានការស្បថរបស់សាក្សី និងជាធម្មតាចុងចោទ ត្រូវតែបង្ហាញភស្តុតាងរនៅសាលាក្តី ។ ជួនកាល សេចក្តីថ្លែងរបស់ចុងចោទ មានការបង្ខិតបង្ខំ តាមរយៈការវាយដំ ឬការគម្រាមកំហែង និងជាញឹកញាប់ ចុងចោទជាអក្ខរជន មិនបានផ្តល់ព័ត៌មានត្រឹមត្រូវតាមការសារភាពជាលាយលក្ខណ៍អក្សរដែលគេបង្ខំឱ្យចុះហត្ថលេខា ។ក្នុងករណីខ្លះ

មានការទាក់ទងនឹងបុគ្គលិកយោធា ហើយជាញឹកញាប់ មន្ត្រីយោធា បានដាក់សម្ពាធលើចៅក្រមផ្នែកតុលាការឧក្រិដ្ឋកម្មស៊ីវិល ឱ្យដោះលែងចុងចោទដោយគ្មានការកាត់ក្តី ។

ការពន្យារពេលរបស់តុលាការ ឬអំពើពុករលួយរបស់តុលាការ ជាញឹកញាប់ បានអនុញ្ញាតឱ្យចុងចោទរួចផុតពីការកាត់ទោស ។ មន្ត្រីរដ្ឋាភិបាល ឬសមាជិកក្រុមគ្រួសាររបស់មន្ត្រីរដ្ឋាភិបាល ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាញឹញាប់ទទួលបានការលើកលែងទោស ។

ទោះបីជា តុលាការ បានកាត់ទោសសមាជិកមួយចំនួនរបស់កំលាំងសន្តិសុខពីបទរំលោភសិទ្ធិមនុស្សក៏ដោយ ក៏នៅតែមានការលើកលែងទោសដដែល សំរាប់អ្នកប្រព្រឹត្តអំពើរំលោភទាំងនេះ ។ ក្នុងករណីបទឧក្រិដ្ឋជាច្រើនទៀត ចុងចោទដែលជាបុគ្គលអ្នកមាន ឬជាអ្នកមានអំណាច ជាធម្មតា បានបង់លុយឱ្យជនរងគ្រោះ និងឱ្យអាជ្ញាធរ ដើម្បីឱ្យរួចផុតពីការចោទប្រកាន់បទឧក្រិដ្ឋ ។ គេបានដឹងយ៉ាច្បាប់ថា អាជ្ញាធរ ជាអ្នកជំរុញឱ្យជនរងគ្រោះ ឬក្រុមគ្រួសាររបស់ជនរងគ្រោះទទួលប្រាក់សងជម្ងឺចិត្តជាថ្នូរ សំរាប់ការរួចផុតពីការចោទប្រកាន់បទឧក្រិដ្ឋ ។

លោក ប៊ិន សំណាង និងលោក សុខ សំអឿន ស្ថិតក្នុងមន្ទីរឃុំឃាំងនៅឡើយពីបទធ្វើឃាដលោក ជា វិជ្ជា។ នៅថ្ងៃទី១២ខែមេសា សវនាការរបស់តុលាការឧទ្ធរណ៍ បានយល់ព្រមជាឯកច្ឆន្ទនឹងសេចក្តីសម្រេចរបស់តុលាការក្រុងភ្នំពេញ ក្នុងការកាត់ទោសឱ្យលោក ប៊ិន សំណាង និងលោក សុខ សំអឿន ឱ្យជាប់ពន្ធាគារម្នាក់ ២០ ឆ្នាំ ទោះបីជាមានភស្តុតាងថ្មី៧បញ្ជាក់ថាគេគ្មានទោសក៏ដោយ ។ នៅថ្ងៃទី៧ ខែមិថុនា ក្រុមមេធាវី បានដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការកំពូល និងបានរង់ចាំការកាត់សេចក្តីរហូតដល់ចុងឆ្នាំ ។

នៅថ្ងៃទី៧ ខែមិថុនា សភាជាតិ បានអនុម័តក្រមនីតិវិធីព្រហ្មទ័ណ្ឌ និងនៅខែសីហា ព្រះករុណា បានឡាយព្រះហស្តលេខាលើក្រមនេះអោយចូលជាធរមានដើម្បីអនុវត្តន៍ ។ នៅពេលដែលច្បាប់គោលនៃច្បាប់ជាតិ បានយកមកប្រើនៅសាលាក្តីខ្មែរក្រហម ច្បាប់ថ្មីនេះ គឺផ្អែកលើការពិគ្រោះយោបល់តាមលក្ខណៈអន្តរជាតិ និងចាត់ទុកថា បានបំពេញតាមបទដ្ឋានអន្តរជាតិ ដែលសមស្របសំរាប់ចៅក្រមកាត់ក្តី នៅសាលាក្តី ។

**អ្នកជាប់ឃុំ និងអ្នកទោសនយោបាយ**

មិនមានរបាយការណ៍ស្តីពីអ្នកជាប់ឃុំ និងអ្នកទោសនយោបាយទេ ។

**វិធី និងនីតិវិធីតុលាការស៊ីវិល**

ប្រទេសត្រូវមានតុលាការមួយក្នុងការដោះស្រាយរឿងបណ្តឹងស៊ីវិល ហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បី ទាមទារប្រាក់សំណងពីបទរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងវិធីតុលាការ និងវិធីរដ្ឋាភិបាល ។ ទោះបីជាយ៉ាណាក៏ដោយ ក៏គេចាត់ទុកថាតុលាការប្រព្រឹត្តអំពើពុករលួយ នៅខ្សោយ និងលំអៀងផ្អែកនយោបាយ ហើយជនរងគ្រោះ កម្រនឹងដាក់ពាក្យបណ្តឹង

ណាស់ ពីព្រោះគេមិនជឿជាក់ប្រព័ន្ធតុលាការ ។ ជាពិសេស មហាជន ទំនងជាមិនទុកចិត្តលើ វិធីរបស់តុលាការថាមានតម្លាភាព នោះទេនៅពេលករណី មានជម្លោះជាមួយនឹងរដ្ឋាភិបាល ។ ការពង្រើងសណ្តាប់ធ្នាប់របស់តុលាការ ជាញឹកញាប់ នៅតែជាមញ្ហា ចំពោះ ករណីស៊ីវិល និងករណីឧក្រិដ្ឋកម្ម ។ ជួនកាល ជនរងគ្រោះ ប្រែក្លាយទៅជាអ្នកស្វែងរកយុត្តិធម៌ដោយខ្លួន ឯងទៅវិញ ។

**ច. មានការជ្រៀតជ្រែកតាមតែអំពើចិត្តទាក់ទងនឹងសិទ្ធិឯកជនដូចជា ផ្ទៃក្នុងគ្រួសារ លំនៅដ្ឋាន ឬឆ្លើយឆ្លងតាមសំបុត្រ**

ច្បាប់នេះផ្តល់នូវភាពឯកជននៃលំនៅដ្ឋាន និងការឆ្លើយឆ្លងព័ត៌មាន និងហាមឃាត់នូវការឆែកឆេដោយខុសច្បាប់ ។ ទោះបីជា យ៉ាងក៏ដោយ ប៉ូលីស ធ្វើការឆែកឆេ និងចាប់ខ្លួនដោតគ្មានដីការបស់តុលាការ ។

មានរបាយការណ៍ពីអាជ្ញាធរ ដែលចូលកាន់កាប់ទ្រពសម្បត្តិឯកជនដោយមិនបានទទួលការអនុញ្ញាតិពីតុលាការឱ្យសមស្រប ។ ដោយសារតែសហមូហនីយកម្មទាំងបង្ខំនៅអំឡុងរបបខ្មែរក្រហម និងការវិលត្រឡប់មកវិញរបស់ជនភៀសខ្លួនរាប់ពាន់នាក់ក៏ ដោយ ក៏ការកាន់កាប់ដីធ្លីជាញឹកញាប់មានភាពមិនច្បាស់លាស់ ហើយនិងម្ចាស់ដីធ្លីភាគច្រើនពុំមានឯកសារជាផ្លូវការគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីកម្មសិទ្ធិ ។ ច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងថា បុគ្គលណា ដែលបានកាប់កាន់ទ្រព្យសម្បត្តិឯកជនដោយសន្តិវិធី ដោយគ្មានវិវាទរយៈពេលប្រាំឆ្នាំមុននឹងការប្រកាសឱ្យប្រើប្រាស់ច្បាប់ភូមិបាលនៅ ២០០១ មានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិទ្រព្យ សម្បត្តិនោះយ៉ាងជាក់លាក់ ។ ការរកស៊ីដីធ្លីដែលកំពុងតែរាលដាលបានបង្កើតឱ្យមានទូវជម្លោះ និងកើនឡើងនូវភាពតានតឹងរវាង សហគមន៍ជនបទក្រីក្រ និងអ្នករកស៊ី ។ គណៈកម្មការសុរិយាដី ដែលមានភារកិច្ចរបស់ខ្លួនក្នុងការបន្តការដោះស្រាយជម្លោះដីធ្លី ដែលមិនមានចុះបញ្ជី ឬកន្លែងណាដែលម្ចាស់ដីធ្លីមិនមានលិខិតបញ្ជាក់ដីធ្លីគឺមានសភាពយ៉ាងយឺតយ៉ាវ ។ តុលាការនៅតែទទួល ខុសត្រូវចំពោះការដោះស្រាយជម្លោះទាំងឡាយក្នុងករណីដែលដីធ្លីដែលមានចុះបញ្ជី ឬអ្នកជម្លោះនោះមានប័ណ្ណកម្មសិទ្ធិដីធ្លី ។ អាជ្ញារជាតិដោះស្រាយជម្លោះដីធ្លី ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដើម្បីវិនិច្ឆ័យរឿងក្តីជម្លោះដីធ្លី មិនមានប្រសិទ្ធភាព ទេ ។ បញ្ហារបស់អ្នករស់នៅ ដែលត្រូវបង្ខំឱ្យផ្លាស់ទីលំនៅ បន្តកើតមានឡើង នៅពេលដែលមន្ត្រី អ្នកជំនួញឃុបឃិតជាមួយនឹង អាជ្ញាធរក្នុងស្រុក ។ មនុស្សមួយចំនួនក៏បានប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីបំភិតបំភ័យប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ឱ្យផ្ទេរផ្លូវដីធ្លីរបស់ខ្លួនដើម្បីទទួលសំណងដែលមានតម្លៃទីផ្សារទាប ។ អង្គការ Adhoc បានរាយការណ៍ថាបានទទួលបានករណី ជម្លោះដីធ្លី ៣៨២ករណី ដែលជះឥទ្ធិពលលើគ្រួសារចំនួន ១៩ ៣២៩ គ្រួសារ នៅអំឡុងឆ្នាំនោះ ។ នៅអំឡុងឆ្នាំដដែលនោះ អង្គការ LICADHO ទទួលបានករណីដីធ្លីចំនួន ៩៨ករណីនៅទីក្រុងភ្នំពេញ និងខេត្តផ្សេងទៀតចំនួន ១៣ខេត្ត ដែលបានធ្វើប៉ះ ពាល់ដល់មនុស្សសរុបចំនួន ៦ ០៤៨នាក់ ។ ប្រជាជនក្រីក្រជាញឹកញាប់គ្មានឯកសារច្បាប់ដើម្បីគាំទ្រការទាមទារ ដីធ្លី របស់ខ្លួន ទេ និងខ្វះទំនុកចិត្តលើប្រព័ន្ធតុលាការ ។ ប្រជាជនមួយចំនួននៅក្នុងចំណោមប្រជាជន ដែលត្រូវបណ្តេញដោយជាស្ថាពរបាន តវ៉ា នឹងសកម្មភាពទាំងនោះក្នុងតុលាការ ប៉ុន្តែមនុស្សភាគច្រើនបានចាញ់រឿងក្តីរបស់ខ្លួន ។

នៅថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០០០ អ្នកភូមិជនជាតិភាគតិចចារាយនៅខេត្តរតនគិរី បានធ្វើពាក្យបណ្តឹងទៅនឹងតុលាការខេត្ត និង ពាក្យបណ្តឹងបទឧក្រិដ្ឋទៅនឹងព្រះរាជអាជ្ញារខេត្តប្តឹងលោកស្រី គាត កល្យណី ដែលជាបុគ្គលមានខ្នងច្រើន ពីបទរឹបអូសយក ដីធ្លីរបស់ប្រជាជនទំហំ ១ ១១២អា នៅឆ្នាំ ២០០៤ ។ អ្នកភូមិជាច្រើនបានបដិសេធចំពោះសំណើរផ្តល់ទីតាំងថ្មីរបស់លោកស្រី ។ នៅថ្ងៃទី ១៩ ខែមិថុនា លោកស្រី គាត កុល្យណីបានផ្ញើលិខិតមួយទៅកាន់គណៈមេធាវីកម្ពុជា ដោយចោទប្រកាន់ថា មេធាវី

របស់អង្គការមិនមែនរដ្ឋាភិបាលជំនួយផ្នែកច្បាប់ ដែលបានតំណាងឱ្យអ្នកភូមិនោះបានបង្ហាត់អ្នកភូមិឱ្យនិយាយរឿង មិនពិតទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ និងស្នើសុំឱ្យគណៈមេធាវីនេះស៊ើបអង្កេតលើមេធាវីទាំងនោះ ។ នៅថ្ងៃទី ២១ ខែមិថុនា លោកស្រី គាត កល្យាណី បានដាក់ពាក្យបណ្តឹងបទឧក្រិដ្ឋ ដោយចោទប្រកាន់អ្នកភូមិពីបទឆបោក និងមេធាវីពីបទញុះញង់អ្នកភូមិឱ្យធ្វើការបន្លំឆបោក ។ នៅខែកក្កដា អ្នកភូមិ ៤២ នាក់នៅក្នុងចំណោមអ្នកភូមិ ២០០នាក់បានដកសំដីពីមុនរបស់គេវិញ និងនិយាយ ថាពួកគេព្រមលក់ដីទាំងនោះឱ្យលោកស្រី គាត កល្យាណី ។ នៅចុងឆ្នាំ ការស៊ើបអង្កេតរបស់តុលាការខេត្តបានបន្តទៀត ។

នៅថ្ងៃទី ២០ ខែមេសា កងរាជអាវុធហត្ថប្រហែលជា ១៥០នាក់ និងភ្នាក់ងារប៉ូលីសដែលប្រដាប់ដោយអាវុធ ដំបងអគ្គិសនី និងឧស្ម័នផ្សែង បានបណ្តេញគ្រួសារ ចំនួន ១១៧គ្រួសារមកពីស្រុកមិត្តភាពនៅក្នុងក្រុងព្រះសីហនុទាំងបង្ខំ។ អ្នកភូមិជាច្រើនត្រូវបានរងរបួសនិងផ្ទះសម្បែងរបស់គេត្រូវបំផ្លាញខ្ទេចទីអស់ ។

នៅថ្ងៃទី ៤ ខែឧសភា អ្នកភូមិស្រុក ល្វា អែម នៅក្នុងខេត្តកណ្តាលបានទាក់ទងនឹងរដ្ឋសភាជាតិដើម្បីធ្វើអន្តរាគមន៍នៅក្នុងរឿងសម្បទានដីធ្លីសេដ្ឋកិច្ច ។ គ្រួសារសហគមន៍ជាច្រើនបានកំពុងតែធ្វើស្រែចំការ និងរស់នៅលើដីធ្លីជម្លោះ ១ ៧៣០អារ។ នៅថ្ងៃទី ២៥ ខែមេសា ក្រុមហ៊ុនចិនមួយបានចាប់ផ្តើមជីកគាស់កាយដីធ្លីនេះ ដោយធ្វើសកម្មភាពលើដីសម្បទានសេដ្ឋកិច្ច ដែលរដ្ឋាភិបាលបានប្រគល់អោយនៅឆ្នាំ២០០៦ដើម្បីធ្វើការអភិវឌ្ឍន៍ ។ ក្រុមហ៊ុននេះត្រូវបានគេរាយការណ៍ថាបានផ្អាកសកម្មភាពដំណើរការដោយសារតែការតវ៉ារបស់អ្នកភូមិ ។

នៅថ្ងៃទី ២៩ ខែឧសភា ទាហាន ៤០នាក់មកពីទីបញ្ជាការរថក្រោះ ACO នៅខេត្តកំពង់ស្ពឺបានប្រើប្រាស់យានយន្តពាសដែកដើម្បីបំផ្លាញដំណាំ និងរបងនៅដីធ្លីទំហំ ៦០អា ដែលកាន់កាប់ដោយក្រុមគ្រួសារស្រុកភ្នំស្រួចចំនួន ២៥ គ្រួសារ ។ មន្ត្រីយោធាបានបញ្ជាក់ថា ដីធ្លីនេះជាដីមួយផ្នែកនៃកន្លែងសម្រាប់បរបាញ់ និងអ្នកភូមិបានចូលកាន់កាប់ដីធ្លីនេះដោយខុសច្បាប់ ។ នៅឆ្នាំ ២០០២ អ្នកភូមិបានស្វះស្វែងរកប័ណ្ណកម្មសិទ្ធិដីធ្លីជាមួយនឹងគណៈកម្មការសុរិយោដី ហើយនៅឆ្នាំ ២០០៦ ពួកគេបានប្តឹងទៅកាន់អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី ដោយបញ្ជាក់ថា ពួកគេបានរស់នៅលើដីនេះតាំងពីឆ្នាំ ១៩៧៩ ។ នៅចុងឆ្នាំ សំណើទាំងនេះមិនបានទទួលលទ្ធផលណាមួយឡើយ ។

សេចក្តីជូនដំណឹងនៃការបណ្តេញចេញនេះត្រូវបានប្រើប្រាស់ដោយមិនបានទទួលការ អនុញ្ញាតិពីតុលាកាឱ្យបានសមស្របទេ ។ នៅថ្ងៃទី៣១ ខែកក្កដា សាលាក្រុងព្រះសីហនុបានចេញនូវសេចក្តីជូនដំណឹងនៃការ បណ្តេញចេញដោយបញ្ជាឱ្យជាង ១០០ គ្រួសារចេញពីខ័ណ្ឌមិត្តភាពនៅក្នុងក្រុងនេះ ។ ដោយឆ្លើយតបទៅនឹងសំណូមពររបស់អ្នកភូមិដែលសុំអន្តរាគមន៍ នាយករដ្ឋមន្ត្រីបានបញ្ជាអភិបាលក្រុងព្រះសីហនុធ្វើការពិនិត្យរឿងក្តីនេះឡើងវិញ ។ នៅថ្ងៃទី ៨ ខែឧសភា តំណាងឱ្យក្រុមគ្រួសារ ១៤៦ គ្រួសារ នៅតំបន់ក្រុមទី ៧៨ទន្លេបាសាក ភ្នំពេញ បានប្រកាសជាផ្លូវការនូវផែនការអភិវឌ្ឍន៍តំបន់នេះ ។ ផែនការនេះបានឆ្លើយតបទៅនឹងសេចក្តីជូនដឹងរបស់សាលាក្រុងនៅខែមិថុនា ឆ្នាំ ២០០៦ ដោយបញ្ជាក់ថាដីនេះនឹងធ្វើការអភិវឌ្ឍន៍ដើម្បី កែលំអសោភ័ណភាពទីក្រុង ។ ក្រុមគ្រួសារជាច្រើនបានរស់នៅលើដីនេះតាំងពីទសវត្សឆ្នាំ ១៩៨០ និងទាមទារកម្មសិទ្ធិនៅក្រោមច្បាប់ភូមិបាលឆ្នាំ ២០០១ ។ សមាជិកសហគមន៍ក្រុមទី ៧៨ នេះបានបញ្ជាក់ថា សាលាក្រុងបានផ្តល់ប្រាក់សំណង ដែលប្រហាក់

ប្រហែលស្មើនឹង២ ភាគរយនៃតម្លៃទីផ្សារដែលបានកំណត់ដោយឯករាជ្យ រួមជាមួយនឹងដីមួយកន្លែងនៅលើទីតាំង ថ្មីនៅក្រុងភ្នំពេញក្នុងមួយគ្រួសារ ។ នៅចុងឆ្នាំនេះគ្មានសេចក្តីសម្រេចណាមួយអំពីការបណ្តេញចេញទាំងនោះទេ ។

នៅថ្ងៃទី ៣ ខែមិនា គណៈកម្មការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជាបានផ្តល់អំណាចផ្តាច់មុខឱ្យនាយករដ្ឋមន្ត្រីដើម្បីដោះស្រាយជម្លោះដីធ្លី ដែលពាក់ព័ន្ធនឹងមន្ត្រីគណបក្សប្រជាជនកម្ពុជា ។ នាយករដ្ឋមន្ត្រីនៅពេលនោះបានប្រកាសសង្គ្រាមប្រឆាំងនឹងអ្នករំលោភដីធ្លីខុសច្បាប់ ដោយធ្វើការព្រមានមន្ត្រីគណបក្សប្រជាជនឱ្យប្រគល់ដីដែលទទួលបានដោយខុសច្បាប់ បើពុំនោះទេនឹងប្រឈមមុខនឹងការដកហូតតំណែង ។ ជាលទ្ធផល រដ្ឋាភិបាលបានប្រកាសអះអាងថា លោក ចៅ ភិរុន អគ្គនាយកនៃមន្ទីរសម្ភារ និងបច្ចេកទេសយោធា បានប្រគល់ដីជាង ៨៩៥អា និងមន្ត្រីគណៈបក្សប្រជាជនមិនស្គាល់ឈ្មោះបានដកខ្លួនចេញពីជម្លោះដីធ្លីនៅខេត្តកណ្តាល ។ គ្មានមន្ត្រីណាម្នាក់បានប្រឈមមុខនឹងការស្តីបន្ទោសទេ ។ នៅថ្ងៃទី ១០ ខែមិនា អាជ្ញាធរបានចាប់ខ្លួនសមាជិកគណៈបក្សប្រជាជន និងវរសេនីយឯកយោធា តែ ហាំងពីបទពាក់ព័ន្ធនឹងជម្លោះដីធ្លី ២ ៥០០អា នៅខេត្តបន្ទាយមានជ័យ ។ នៅចុងឆ្នាំ តែ ហាំងកំពុងតែរង់ចាំការវិនិច្ឆ័យទោស ។ នៅខែវិច្ឆិកា តាន សេង ហាក់ ជាអតីតៈទីប្រឹក្សាប្រធានគណៈបក្សប្រជាជនកម្ពុជា លោក ជា ស៊ីម ត្រូវបានកាត់ទោសពីបទក្លែងបន្លំឯកសារ និងផ្តល់ចម្លើយក្លែងក្លាយដែលពាក់ព័ន្ធនឹងកិច្ចប្រឹងប្រែងកាន់កាប់ដីជាង ៧៤០អានៅទីក្រុងភ្នំពេញ ។ គាត់ត្រូវកាត់ទោសឱ្យជាប់គុក ៥ឆ្នាំ និង៨ ខែ ។ គ្មានការវិវត្តន៍ណាមួយអំពីផែនការខែមិនា ឆ្នាំ ២០០៦របស់នាយករដ្ឋមន្ត្រីក្នុងការចែកជូនដីធ្លី ៤៩៤ ២១០អាទៅឱ្យកសិករ ៥០ ០០០នាក់នៅក្នុងក្រុងសីហនុទេ។

លក្ខខណ្ឌរស់នៅកាន់តែលំបាកនៅទីតាំងលំនៅដ្ឋានពីរសម្រាប់អតីតអ្នករស់នៅសហគមន៍ភ្នំពេញក្នុងតំបន់ទន្លេបាសាក់ សំបុកចាប និងមន្ទីរពេទ្យព្រះមុន្នីវង្ស ដែលមានក្រុមគ្រួសារ ១២០ ០០ និង១៦៨គ្រួសារត្រូវបានបណ្តេញដោយឡែកពីគ្នានៅឆ្នាំ ២០០៦ ដោយគេរាយការណ៍ថាតាមរយៈដំណើរការមិនមានតម្លាភាពមួយ ដែលមិនមានការអនុញ្ញាតពីតុលាការឱ្យបានត្រឹមត្រូវ ។ អាជ្ញាធរបានផ្តល់ឱ្យប្រជាពលរដ្ឋទាំងនោះនូវដីតាំងលំនៅដ្ឋានថ្មី ប៉ុន្តែដីនៅតាំងលំនៅដ្ឋានថ្មីពីរកន្លែងត្រូវបានគេចាត់ថាជាសំណងមិនគ្រប់គ្រាន់ ។ ទីតាំងនេះខ្វះសម្ភារអនាម័យឱ្យបានគ្រប់គ្រាន់ អគ្គិសនី ទឹកស្អាត មន្ទីរពេទ្យ សាលារៀន និងផ្សារ និងឆ្ងាយពីមជ្ឈមណ្ឌលភ្នំពេញ កន្លែងដែលប្រជាពលរដ្ឋទាំងនោះអាចរកចំណូលបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិត ។

តុលាការឧទ្ធរណ៍មិនបានចាត់វិធានការលើពាក្យបណ្តឹងនៅខែកុម្ភៈ ឆ្នាំ២០០៦ដោយតំណាងរាស្ត្រគណៈបក្សប្រឆាំងសម រង្ស៊ី ស៊ុន ឆៃ ដែលត្រូវបានបង្គាប់ដោយតុលាការខេត្តសៀម រាបឱ្យលក់ដី ៧.៨ អា របស់លោកទៅឱ្យទីភ្នាក់ងាររដ្ឋាភិបាលនៅតម្លៃមួយទាបជាងតម្លៃទីផ្សារ ។ តុលាការឧទ្ធរណ៍នេះមិនបានចាត់វិធានការណាមួយលើករណីបណ្តឹងឆ្នាំ ២០០៦របស់ប្រជាពលរដ្ឋ ១០នាក់ដែលត្រូវបានកាត់ទោសពាក់ព័ន្ធទៅនឹងការប្រឈមមុខនៅខេត្តកំពតរវាងអ្នកតាំងទីលំនៅអណាធិបតេយ្យ ២០០០នាក់ និងប៉ូលីសមូលដ្ឋានអំពីសិទ្ធិរបស់អ្នកតាំងទីលំនៅអណាធិបតេយ្យដើម្បីរស់នៅលើដីរដ្ឋទេ ។ នៅក្នុងករណីបណ្តេញចេញ នៅឆ្នាំ ២០០៦ នៅស្រុកពាម រ ខេត្តព្រៃវែង ដែលបានបណ្តាលឱ្យមនុស្សមួយនាក់ស្លាប់ និងបួននាក់រងរបួស ប៉ូលីសដែលបានជាប់ពាក់ព័ន្ធនឹងនៅក្នុងការសម្លាប់នេះ បានធ្វើការចោទប្រកាន់អ្នកភូមិមួយចំនួនពីបទប្លន់ ដែលអង្គការមិនមែនរដ្ឋាភិបាលមានប្រសាសន៍ថាគឺជាការប៉ុនប៉ងបំភិតបំភ័យអ្នកភូមិ ។ នៅថ្ងៃទី ១ ខែវិច្ឆិកា តុលាការខេត្តបានសាកសួរអ្នកភូមិ ៧នាក់អំពីការ

ចោទប្រកាន់ពីបទប្លន់ និងការស៊ើបអង្កេតរបស់តុលាការបានបន្តនៅចុងឆ្នាំនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានការវិវឌ្ឍន៍ថ្មីណាមួយចំពោះការស៊ើបអង្កេតលើករណីការសម្លាប់ និងរបួសដោយសារការបណ្តេញចេញ ។ គ្មានការវិវឌ្ឍន៍ថ្មីណាមួយ ចំពោះករណីជម្លោះដីធ្លីរបស់តុលាការខេត្តកោះកុងនៅខែសីហា ឆ្នាំ ២០០៦ ដែលក្រសួងកសិកម្មបានផ្តល់ដីសម្បទានជាប់គ្នាពីរកន្លែងទៅឱ្យពាណិជ្ជករ និងសមាជិកព្រឹទ្ធសភា លី យ៉ុង ផាត់ ក្នុងប្រឆាំងនឹងបទដ្ឋានច្បាប់ទេ ។

គ្មានការវិវឌ្ឍន៍ថ្មីណាមួយចំពោះជម្លោះដីធ្លីឆ្នាំ ២០០៥ ដែលពាក់ព័ន្ធនឹងសមាជិកកុលសម្ព័ន្ធព្នង និងក្រុមហ៊ុនចិនមួយនៅខេត្តរតនគិរី នោះទេ។

**ផ្នែកទី ២ គោរពចំពោះសិទ្ធិសេរីភាពស៊ីវិល ដោយរួមមាន៖**
**ក- សេរីភាពក្នុងបញ្ចេញមតិ និងសារព័ត៌មាន**

រដ្ឋធម្មនុញ្ញបានផ្តល់នូវសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។ ទោះបីយ៉ាងណាក៏ដោយ សិទ្ធិទាំងនេះមិនត្រូវបានគេគោរព ដើម្បីយកទៅអនុវត្តនោះទេ ។

រដ្ឋធម្មនុញ្ញកំណត់នូវសេរីភាពក្នុងការនិយាយស្តីដោយតំរូវមិនឱ្យមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ។ រដ្ឋធម្មនុញ្ញក៏ប្រកាសថា ព្រះមហាក្សត្រជាបុគ្គលមិនអាចប៉ះពាល់បាន ។ នៅខែធ្នូ ក្រសួងព័ត៌មានបានចេញសេចក្តីណែនាំមួយ ដែលបញ្ជាក់ពីដែនកំណត់ទាំងនេះ និងហាមឃាត់ចាងហ្វាង និងនាយកនិពន្ធមិនឱ្យផ្សព្វផ្សាយអត្ថបទព័ត៌មាន ដែលជេរប្រមាថ ឬបង្ខូចកេរ្តិ៍ឈ្មោះថ្នាក់ដឹកនាំរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាល ។

ច្បាប់សារព័ត៌មាននៅឆ្នាំ ១៩៩៥ហាមឃាត់ការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ ឬការចាប់ដាក់គុកដោយសារការសម្តែងមតិយោបល់ ។ ទោះបីជាយ៉ាងក៏ដោយ រដ្ឋាភិបាលបានបន្តប្រើប្រាស់ច្បាប់អ៊ុនតាក់ចាស់ដើម្បីកាត់ទោសអ្នកកាសែត និងអ្នកផ្សេងទៀតពីបទបរិហារកេរ្តិ៍ និងផ្តល់ព័ត៌មានមិនពិត ។ នៅឆ្នាំ ២០០៦ រដ្ឋសភាបានធ្វើវិសោធនកម្មលើច្បាប់អ៊ុនតាក់ ដោយលុបបំបាត់ចោលនូវការដាក់គុកពីបទបរិហារកេរ្តិ៍ និងប៉ុន្តែមិនមែនបទផ្សព្វផ្សាយព័ត៌មានមិនពិត ដែលមានការជាប់គុករហូតដល់បីឆ្នាំ ។ នៅក្នុងករណីទាំងពីរនេះ ចៅក្រមអាចបញ្ជាឱ្យមានការផាកពិន័យ ដូចជាការដាក់គុកជាដើម ប្រសិនជាមិនបានបង់ប្រាក់ពិន័យ ។

រដ្ឋាភិបាល និងបុគ្គលមានឥទ្ធិពលបានប្រើប្រាស់ប្រព័ន្ធតុលាការទន់ខ្សោយ និងលំអៀងផ្នែកនយោបាយដើម្បីធ្វើពាក្យបណ្តឹងបរិហារកេរ្តិ៍ និងផ្តល់ព័ត៌មានមិនពិត ក្នុងរឿងស៊ីវិល និងព្រហ្មទណ្ឌ នៅក្នុងកិច្ចប្រឹងប្រែងដើម្បីបំបិទមាត់អ្នករិះគន់ ។ ខែកុម្ភៈ តុលាការក្រុងភ្នំពេញបានធ្វើចោទប្រកាន់កាសែតស្រឡាញ់ខ្មែរពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងជេរប្រមាថប្រធានតុលាការ ជីវ កេង ។ ជាមួយគ្នានេះដែរ នៅខែកុម្ភៈ អភិបាលក្រុងព្រះសីហនុ សាយ ហាក់ បានធ្វើពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ប្រឆាំង

កាសែតគាំទ្រគណៈបក្សនរោត្តមបូណរិទ្ធិគឺ សំលេងយុវជនខ្មែរទៅលើអត្ថបទព័ត៌មានដែលធ្វើឱ្យលោកពាក់ព័ន្ធនឹងការរំលោភដីធ្លី ។ នៅខែកក្កដា លោក សៅ រ៉ានី អគ្គលេខាធិការរងគណៈបក្សនរោត្តមបូណរិទ្ធិ បានធ្វើពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ប្រឆាំងកាសែតស្រឡាញ់ខ្មែរដោយសារបោះពុម្ពផ្សាយរបាយការណ៍មួយ ដែលអះអាងថា កូនស្រីរបស់លោកសាហាយស្មន់ជាមួយនឹងព្រះអង្គម្ចាស់នរោត្តមរាណារិទ្ធិ ។ នៅវិច្ឆិកា ឧត្តមសេនីយ អ៊ុន ដែន បានធ្វើពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ និងព័ត៌មានមិនពិតប្រឆាំងនឹងថាច់ កេត ជាចាងហ្វាយបោះពុម្ពកាសែតស្រឡាញ់ខ្មែរ ដោយសារតែបោះពុម្ពផ្សាយអត្ថបទព័ត៌មានដែលចោទប្រកាន់ឧត្តមសេនីយ៍ពីបទរត់ពន្ធយានយន្តឆ្លងកាត់ព្រំដែនពីប្រទេសថៃ ។ នៅចុងឆ្នាំ មិនមានការសម្រេចចិត្តជាផ្លូវការ នៅក្នុងករណីទាំងនេះទេ ។

នៅខែកក្កដា កែប ជុតិមាអភិបាលក្រុងភ្នំពេញបានធ្វើពាក្យបណ្តឹងពីបទផ្សព្វផ្សាយព័ត៌មានមិនពិតប្រឆាំងនឹងនិពន្ធនាយកកាសែតសំលេងយុវជនខ្មែរដោយតែចុះផ្សាយអត្ថបទព័ត៌មាន ដែលចោទប្រកាន់ថាអភិបាលក្រុងនេះបានលក់សាលាក្រុងឱ្យក្រុមហ៊ុនអភិវឌ្ឍន៏ឯកជនមួយ ។ នៅខែវិច្ឆិកា អ្នកនិពន្ធនាយកបានបង់ប្រាក់ធានាចំនួន ៥០០ដុល្លារ (ពីរលានរៀល) និងនៅចុងឆ្នាំ បណ្តឹងនេះមិនទាន់សម្រេចដោយតុលាការទេ ។

រដ្ឋធម្មនុញ្ញបានចែងថា ប្រទេសមួយមិនត្រូវរំលោភលើប្រទេសណាមួយ ឬជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសផ្សេងទៀតដោយផ្ទាល់ ឬដោយមិនផ្ទាល់ ។ ការធ្វើសេចក្តីថ្លែងការណ៍ដែលប្រឆាំងនឹងខបញ្ញត្តិរដ្ឋធម្មនុញ្ញនេះត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ ។ នៅក្នុងករណីដែលយ៉ាងហោចណាស់សកម្មជនខ្មែរកម្ពុជាក្រោមម្នាក់ ដីការចាប់ខ្លួនត្រូវបានធ្វើឡើងដោយសារសេចក្តីថ្លែងការណ៍របស់ខ្លួនពីអ្វីដែលរដ្ឋាភិបាលចាត់ទុកជាទឹកដីរបស់ប្រទេសវៀតណាម ។

មានមនុស្សជាច្រើនបកស្រាយថា ច្បាប់ដែលបានអនុម័តនៅឆ្នាំ ២០០៦ ជាការកំណត់សិទ្ធិរបស់សមាជិករដ្ឋសភាក្នុងនិយាយដោយសេរី ។ ច្បាប់នេះបានប្រកាសថា សមាជិករដ្ឋសភាមិនអាចប្រើប្រាស់អភ័យឯកសិទ្ធិរដ្ឋសភារបស់ខ្លួនដើម្បីរំលោភសន្តិសុខជាតិទំនៀមទំលាប់សង្គម ឬកិត្តិយសរបស់បុគ្គលណាមួយឡើយ ។ លើសពីនេះទៅទៀត ច្បាប់នេះអនុញ្ញាតសមាជិករដ្ឋសភាត្រូវចាប់ខ្លួន ចោទប្រកាន់ និងឃុំឃាំង មុននឹងដកអភ័យឯកសិទ្ធិ ។ នៅចុងឆ្នាំនេះ គ្មានសមាជិករដ្ឋសភាត្រូវបានចោទប្រកាន់នៅក្រោមច្បាប់នេះទេ ។

គណៈបក្សនយោបាយធំៗទាំងអស់មានសិទ្ធិប្រើប្រាស់សារព័ត៌មានបោះពុម្ពដោយសមហេតុសមផល និងទៀងទាត់ ។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់សារព័ត៌មានមិនបានអនុញ្ញាតឱ្យកាសែតណាមួយ ទទួលការគាំទ្រហិរញ្ញវត្ថុពី គណៈបក្ស នយោបាយឡើយ ។ កាសែតជាភាសាខ្មែរធំៗទាំងអស់បានទទួលការគាំទ្របែបនេះ និងមានមានពាក់ព័ន្ធនឹងនយោបាយ ។ មានកាសែតសរសេរជាភាសាខ្មែរប្រមាណជាង ២០ បានបោះពុម្ពផ្សាយយ៉ាងទៀតទាត់ ។ កាសែតជាងពាក់កណ្តាលត្រូវបានចាត់ទុកថាគាំទ្រគណៈបក្សប្រជាជន និងយ៉ាងហោចណាស់កាសែតពីរត្រូវបានចាត់ទុកថាមានការគាំទ្រ គណបក្សនយោបាយធំៗគឺ គណបក្សហ៊្វុនស៊ីនប៉ិច គណៈបក្សសម រង្ស៊ី និងគណបក្សនរោត្តមបូណរិទ្ធិ ។ ទោះបីជាកាសែតចេញផ្សាយមានចំនួនច្រើនជាងគេ ដែលចាត់ទុកថាជាកាសែត គាំទ្រគណបក្សប្រជាជនក៏ដោយ ក៏មានកាសែតភាគច្រើនបានរិះគន់រដ្ឋាភិបាល ជាពិសេសអំពើពុករលួយ

និងការរំលោភដីធ្លី ។ នាយករដ្ឋមន្ត្រី ព្រះអង្គម្ចាស់នរោត្តមបុណរិទ្ធិ ជាប្រធានគណបក្សនរោត្តមរាណាឬទ្ធិ និងថ្នាក់ដឹកនាំគណ
បក្សហ៊្វុនស៊ីនប៉ិច និងលោក សម រង្ស៊ី ជាប្រធានគណបក្សប្រឆាំងជាញឹកញាប់ត្រូវទទួលរងការរិះគន់ ។

រដ្ឋាភិបាល កម្លាំងយោធា  និងគណបក្សនយោបាយកាន់អំណាចបានបន្តគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និងជះឥទ្ធិពលលើអត្ថន័យនៃ
ការផ្សព្វផ្សាយ  ។ មានប្រហែលជា ៥០ស្ថានីយ៍វិទ្យុ និងស្ថានីយ៍ទូរទស្សន៍ចំនួន ៧ ។ ភាគច្រើនត្រូវបានគ្រប់គ្រង ឬត្រូវជះឥទ្ធិពល
យ៉ាងខ្លាំងដោយគណៈបក្សប្រជាជន បើទោះបីជាមានឯករាជ្យបន្តិចបន្តួច ឬប្រកាន់គណៈបក្សនយោបាយផ្សេងទៀតក៏ដោយ  ។
នៅខែសីហា ក្រសួងព័ត៌មានបានចេញអាជ្ញាប័ណ្ណផ្សព្វផ្សាយទៅឱ្យមន្ត្រីរដ្ឋបាលគណបក្សប្រជាជនអោយបើកស្ថានីយ៍វិទ្យុនៅ
ភ្នំពេញ បន្ទាប់ពីការបដិសេធសំណើរស្រដៀងគ្នាតាំងពីឆ្នាំ ២០០៣ពីគណបក្សសម រង្ស៊ី និងអង្គការគាំទ្រសិទ្ធិមនុស្សឯករាជ្យ  ។
នៅខែកញ្ញា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សំលេងប្រជាធិបតេយ្យបានស្នើសុំអាជ្ញាប័ណ្ណម្តងទៀត ប៉ុន្តែក្រសួងបានបដិសេធ
ការដាក់ពាក្យនេះ ដោយបញ្ជាក់ពីការទាមទារពីមុនថា ទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានពេញណែនហើយ  ។ នៅខែកុម្ភៈ
ក្រសួងព័ត៌មានបានបញ្ជាឱ្យស្ថានីយ៍ទូរទស្សន៍ និងវិទ្យុទាំងអស់មិនឱ្យផ្ទេរ ឬលក់អាជ្ញាប័ណ្ណ ប្រសិនជាមិនអាចបន្តដំណើរការ និង
វិលត្រឡប់ទៅសុំអាជ្ញាប័ណ្ណពីក្រសួងវិញ ។

បើទោះបីជាមិនអាចទទួលបានអាជ្ញាប័ណ្ណផ្សព្វផ្សាយ កម្មវិធីវិទ្យុសំលេងប្រជាធិបតេយ្យ ដែលរួមមានទស្សនៈប្រឆាំងរដ្ឋាភិបាល
និងឯករាជ្យ នៅតែមានប្រជាប្រិយភាព និងបន្តចាក់ផ្សាយកម្មវិធីរបស់ខ្លួនតាមស្ថានីយ៍វិទ្យុជាច្រើន ដោយរួមមានស្ថានីយវិទ្យុ
លំអៀងទៅគណៈបក្សសម រង្ស៊ី FM 93.5  ។ នៅខែកក្កដា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានប្រកាសថា ខ្លួនបានផ្ទេរការ
គ្រប់គ្រងសំលេងប្រជាធិបតេយ្យទៅឱ្យមជ្ឈមណ្ឌលព័ត៌មានឯករាជ្យកម្ពុជាដែលទើបតែបង្កើតឡើងនាថ្មីៗនេះ ។ កម្មវិធីថតទុក
ជាខ្មែរអាត់ពីវិទ្យុសំលេងវីអូអេ និងវិទ្យុអាស៊ីសេរី ដែលជាសេវាកម្មជាភាសាខ្មែរ ក៏ត្រូវបានចាក់ផ្សាយយ៉ាងទៀងទាត់តាម
ស្ថានីយ៍វិទ្យុសំបុកឃ្មុំ FM 105 ស្ថានីយ៍វិទ្យុមជ្ឈមណ្ឌលព័ត៌មានស្ត្រី FM 102 និងស្ថានីយ៍វិទ្យុ រដ្ឋា អង្គរ FM 95.5 នៅខេត្ត
សៀម រាប  ។ គណៈបក្សនយោបាយបួនកំពុងតែចាក់ផ្សាយកម្មវិធីរយៈពេលមួយម៉ោងជារៀងរាល់ថ្ងៃតាមស្ថានីយ៍វិទ្យុ FM105
។

អ្នកកាសែត ចាងហ្វាងកាសែត និងអ្នកចែកចាយកាសែតបានទទួលរងនូវការរំខាន និងបំភិតបំភ័យតាមរូបភាពផ្សេងៗ ដោយរួម
មានការគំរាមគំហែងសម្លាប់  ។ នៅខែមិថុនា ក្រសួងព័ត៌មានបានចេញបញ្ជាធ្វើការរឹបអូសច្បាប់ចម្លងដែលបានបោះពុម្ពអំពី
របាយការណ៍មួយរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ Global Witness ដែលបានធ្វើការចោទប្រកាន់ទៅលើនាយក
រដ្ឋមន្ត្រី និងញាតិមិត្តជិតស្និទ្ធ និងបក្សពួកដែលមានការពាក់ព័ន្ធនឹងការព្រៃឈើខុសច្បាប់  ។ របាយការណ៍នេះអាចរកបានដោយ
ឥតគិតថ្លៃតាមប្រព័ន្ធអ៊ិនធឺណិតនិងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកក៏អាចផ្តល់ឯកសារយោងអំពីរបាយការណ៍នេះបានដែរ  ។ លិខិតចុះ
នៅថ្ងៃទី៨ ខែមិថុនា ដែលត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន ខៀវ កញ្ញារិទ្ធិ ទៅឱ្យកាសែតស្រឡាញ់ខ្មែរ ដែល
ទាមទារឱ្យកាសែតនេះបញ្ឈប់ការបោះផ្សាយរបាយការណ៍នេះ បើពុំនោះទេនឹងប្រឈមមុខនឹងការបណ្តឹងតាមផ្លូវច្បាប់  ។
កាសែតនេះបានធ្វើតាម  ។

ក្នុងពេលដំណាលគ្នានេះដែរ កាសែតភាសាបារាំង *កាំបូដស្ស័រ* ត្រូវបានរាយការណ៍ថា បានបិទការផ្សាយរបស់ខ្លួន ដោយសារការក្ស័យធន ។ យោងតាមរបាយការណ៍របស់ប្រព័ន្ធឃោសនានានា រយៈពេលពីរបីថ្ងៃមុននេះ បុគ្គលិក របស់កាសែតនេះបានប្រកាសធ្វើកូដកម្ម ដោយសារតែអ្នកយកព័ត៌មានម្នាក់ ត្រូវបានបណ្តេញចេញពីការងារចំពោះការ បោះពុម្ពរឿងទាក់ទងនិងរបាយការណ៍ ហ្គាឡូបិលវឺដណិស ។ បន្ទាប់ពីបានបិទការផ្សាយអស់រយៈពេលជាច្រើនខែ មក ការសែតភាសាបារាំងនេះ បានចាប់ផ្តើមការចេញផ្សាយរបស់ខ្លួនជាប្រចាំសប្តាហ៍ឡើងវិញ ។

ក្នុងខែតុលា នាយកវិទ្យុសំបុកឃ្មុំ លោកម៉មសូណង់ដូ បានផ្អាកការផ្សាយកម្មវិធី "សំលេអ្នករាជានិយម" រយៈពេលបួនប្រាំថ្ងៃ បន្ទាប់ពីកម្មវិធីនេះបានទិទៀនដល់នាយករដ្ឋមន្ត្រី ។ អ្នកយកព័ត៌មាន មួយរូបឱ្យ RFA ត្រូវបានរាយការណ៍ថា បានចាក ចេញពីប្រទេសក្រោយពីបានទទួលនូវការគំរាមសំលាប់ ពីបទរាយការណ៍អំពី ការកាប់ឈើខុសច្បាប់នៅក្នុងខេត្តកំពង់ធំ ។ រយៈពេលប៉ុន្មានសប្តាហ៍ក្រោយមក អ្នកយកព័ត៌មានរូបនោះបាន វិលត្រលប់មកប្រទេសវិញ ហើយចាប់ផ្តើមបន្តការងារដោយ សុវត្ថិភាព ។

ក្នុងខែកុម្ភៈ ក្រសួងព័ត៌មានបានគំរាមបិទកាសែត *ខ្មែរអមតៈ* ដែលគាំទ្រដល់ ណេត្រ ពីបទបោះពុម្ពផ្សាយអត្ថបទ ដែលបានញុះ ញុងឱ្យមានភាពតានតឹងរវាង និកាយព្រះពុទ្ធសាសនាធំ១ទាំងពីរ នៅក្នុងប្រទេសកម្ពុជា ។ នៅក្នុង ខែតុលា ក្រសួងបានផ្អាកការ ផ្សាយរបស់កាសែតដដែលនេះ រយៈពេលមួយខែ ពីបទខកខានមិនបានចេញផ្សាយ "ការកែតម្រូវ" លើអត្ថបទកាលពីខែកញ្ញា ដែលក្រសួងបានស្នើ ដោយមានជាប់ទាក់ទិននិងមន្ត្រីជាន់ខ្ពស់ពីររូបរបស់ហ៊ុនស៊ីនប៉ិច ។
នៅដើមខែវិច្ឆិកា អាជ្ញាធរបានដកហូតការចេញផ្សាយអត្ថបទដ៏សំខាន់របស់ *ទស្សនាវដ្តីសារព័ត៌មានសេរី* ដែលឧបត្ថម្ភ ដោយមូលនិធិបរទេស ដោយទស្សនាវដ្តីនេះបានតិះទៀនដល់ព្រះវីរមហាក្សត្រ នរោត្តមសីហនុ នាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រមទាំងមន្ត្រីរដ្ឋាភិបាលជាច្រើនទៀត ។

ក្នុងខែឧសភា នាយករដ្ឋមន្ត្រីបានធ្វើកាទិទៀនជាសាធារណៈ ដល់អ្នកយកព័ត៌មានរបស់ RFA ថា "គ្មានសុជីវធម៌" និង "ឈ្លើយ" ចំពោះការសួរសំណួរអំពីរដ្ឋាភិបាលចំរុះ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ីនប៉ិច ។ ដោយព្រួយបារម្ភណ៍ ពី សុវត្ថិភាពផ្ទាល់ខ្លួន អ្នកយកព័ត៌មានរូបនោះបានទៅសង្ងំលាក់ខ្លួននៅប្រទេសក្រៅ ។ ពីបីសប្តាហ៍ក្រោយមក លោកបានវិល ត្រលប់មកពីបរទេសវិញដោយសុវត្ថិភាព ។

ក្នុងខែមិថុនា មានអ្នកសារព័ត៌មានបីនាក់ មកពីកាសែត *សារព័ត៌មានឯករាជ្យខ្មែរ* និង *សារព័ត៌មានទស្សនខ្មែរ* នៅខេត្តពោធិសាត់ បានចោទអង្គរក្សមន្ត្រីតុលាការខេត្តថា បានវាយដំពួកគេនិងកាណុងកាំភ្លើង ខណៈដែលពួកគេ ព្យាយាមថតរូបរថយន្តដឹកជញ្ជូនឈើខុសច្បាប់ ។

ថ្ងៃទី៤ ខែសីហា អឿនវណ្ណៈ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តពោធិសាត់ ត្រូវបានចោទប្រកាន់ថា បានបង្កឱ្យមានរបួសស្នាមលើរូបរាង្គកាយអ្នកយកព័ត៌មានម្នាក់គឺ លោក ហេង វាសនា អំឡុងពេលការស៊ើបអង្កេតរបស់លោកលើករណីប្រើប្រាស់អាវុធខ្លីខុសច្បាប់ពីសំណាក់កងរាជអាវុធហត្ថពីរនាក់ ។ ហេង វាសនា បានដាក់ពាក្យបណ្ដឹងទៅកាន់ព្រះរាជអាជ្ញាខេត្ត ប៉ុន្តែនៅដំណាច់ឆ្នាំ តុលាការមិនបានធ្វើជំនុំជំរះលើករណីនេះទេ ហើយលោក អឿនវណ្ណៈ នៅតែបន្តតួនាទីជាកងរាជអាវុធហត្ថដដែល ។

នៅក្នុងខែសីហា ផ្ទះការរបស់អ្នកយកព័ត៌មានកាសែត *ច្បាស់ការ* ត្រូវបានគេដុតចំនួនពីរដង ។ អ្នកយកព័ត៌មានបានអះអាងថា ការដុតលើកទីមួយ គឺធ្វើឡើងបន្ទាប់ពីលោកទទួលនូវការគំរាមតាមទូរស័ព្ទ ដោយមានជាប់ទាក់ទិននិងរបាយការណ៍ របស់លោកអំពីការកាប់ឈើខុសច្បាប់ នៅក្នុងខេត្តពោធិសាត់ ។ ពីរបីថ្ងៃក្រោយមក អាជ្ញាធរខេត្តបានចោទប្រកាន់ ជនជាប់សង្ស័យពីរនាក់ពីបទលួចដុតផ្ទះ ។ រឿងក្តីនេះនៅមិនទាន់ត្រូវបានលើលយកមកកាត់ទោសនៅឡើយរហូតមកដល់ដំណាច់ឆ្នាំ ។

ក្នុងខែវិច្ឆិកា បុរសម្នាក់បានចោទប្រកាន់អ្នកកាសែតបីនាក់ ដែលមកពីការសែត *សំឡេងសន្តិភាព* នៅក្នុងខេត្តកំពង់ធំពីបទលួចយកប្រាក់ចំនួន ១០៥០ ដុល្លា (៤.២ លានរៀល) នៅពេលអ្នកកាសែតទាំងបីរូបនេះបានមកផ្ទះគាត់ ដើម្បីធ្វើការស៊ើបអង្កេតលើបទចោទប្រកាន់ថា គាត់មានជាប់ទាក់ទិនរឿងចិញ្ចឹមត្រីឆ្កោខុសច្បាប់ ។ ប៉ូលីសបានចាប់ខ្លួន និងសួរចម្លើយដល់អ្នកយកព័ត៌មានទាំងបី ប៉ុន្តែទីបញ្ចប់បានដោះលែងពួកគេវិញ បន្ទាប់ពីមានអន្តរាគមពីមន្ត្រីជាន់ខ្ពស់ក្រសួងព័ត៌មាន ។

ក្នុងខែធ្នូ អ្នកយកព័ត៌មានឱ្យ VOD មួយរូបដែលយកព័ត៌មានលើការវាយកំទេសរូបបដិមាករ ក្នុងវត្តមួយកន្លែង បានអះអាង ថា លោកត្រូវបានឃុំឃាំង ដោយមន្ត្រីរាជអាវុធហត្ថ និងមន្ត្រីប៉ូលីស ហើយមន្ត្រីទាំងនោះបានលុបចោលហ្វីលរូបថតពី ម៉ាស៊ីនថតរបស់លោកទៀតផង មុនពេលដោះលែងលោកឱ្យមានសេរីភាព ។

អ្នកយកព័ត៌មាន និងនិពន្ធនាយកជាច្រើនរូប បានសារភាពជាលក្ខណៈបុគ្គលថា មិនហានចេញផ្សាយអត្ថបទរបស់ខ្លួន ដោយសារភ័យខ្លាចចំពោះតបតណាមួយពីរដ្ឋាភិបាល ។ ក្នុងខែកុម្ភៈ កាសែត ខ្មែរដែលចេញផ្សាយជាប្រចាំថ្ងៃធំៗចំនួនពីរ បានបដិសេធមិនព្រមបោះពុម្ពនូវការផ្សព្វផ្សាយ ដើម្បីទាមទារយុត្តិធម៌ឱ្យ បុរសពីរនាក់ដែលត្រូវបានគេដាក់គុក ពីបទសម្លាប់មេដឹកនាំសហជីពលោក ជា វិជ្ជា ។ អ្នកយកព័ត៌មានឱ្យ VOA, RFA និងអ្នកយកព័ត៌មានឱ្យកាសែតគណបក្សប្រឆាំងមួយចំនួន បានបម្រើការដោយមិនបញ្ជាក់ប្រាប់ពីទីតាំង ការិយាល័យរបស់ពួកគេ ហើយធ្វើសេចក្តីរាយការណ៍លើដំណើររឿងផ្សេង១ ដោយប្រើរហស្សនាមថែមទៀតផង ។

ស្ថានីយទូរទស្សន៍ និងវិទ្យុជាតិដែលគ្រប់គ្រងដោយរដ្ឋាភិបាល បានផ្សាយបន្តផ្ទាល់ ឬចាក់ផ្សាយរាល់សម័យប្រជុំ នៃកិច្ចពិភាក្សារបស់សភាជាតិ ប៉ុន្តែនៅក្នុងកាលៈទេសៈខ្លះរាល់ការផ្សព្វផ្សាយទាំងនេះ ត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ ។ ស្ថានីយទរទស្សន៍និងវិទ្យុជាតិបានផ្សព្វផ្សាយកម្មវិធីសិទ្ធិមនុស្សសកម្មភាពសង្គម សុខភាពសាធារណៈ ការអប់រំ និងសង្គមស៊ីវិល ដែលផលិតដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ។

ពេលខ្លះ រដ្ឋាភិបាលបានដាក់កំហិតដល់ប្រព័ន្ធឃោសនា មិនឱ្យចូលទៅដល់អាគាររដ្ឋាភិបាល ។ រដ្ឋធម្មនុញ្ញផ្ដល់សិទ្ធិឱ្យប្រព័ន្ធឃោសនាអាចចូលរួមយកព័ត៌មានរាល់ការប្រជុំរបស់សភាជាតិ ហើយអនុញ្ញាតឱ្យអ្នកយកព័ត៌មានចូលទៅក្នុងបរិវេណរបស់ខ្លួន តាមរយៈការិយាល័យសន្តិសុខ ។ ក្នុងឆ្នាំ២០០៥ ប្រធានតុលាការក្រុងភ្នំពេញ បានចេញបញ្ជាថា អ្នកកាសែតត្រូវមានលិខិតអនុញ្ញាត្តិ ដើម្បីយកឧបករណ៏ផ្សេង១ទៅក្នុងបន្ទប់តុលាការ និងដើម្បីធ្វើកិច្ចសំភាសន៏ មន្ត្រីតុលាការទាំងឡាយ ។ ច្បាប់អនុញ្ញាត្តិនេះ កំរមានអ្នកស្នើសុំ ហើយក៏គ្មានរបាយការណ៏ណាមួយ ចំពោះការបដិសេធរបស់តុលាការ ក្នុងការផ្ដល់ការអនុញ្ញាតនេះឡើយ ។ បទបញ្ជារបស់គណៈរដ្ឋមន្ត្រីដែលដាក់ចេញ កាលពីខែ កក្កដា ឆ្នាំ២០០៦ ហាមប្រាមមិនអោយមន្ត្រីរដ្ឋាភិបាល និងនិយោជិកទាំងអស់ និយាយពីអំពើពុករលួយរបស់រដ្ឋាភិបាល តាមរយៈប្រព័ន្ធផ្សព្វផ្សាយនិងសាជាសាធារណៈ នៅតែមានប្រសិទ្ធិភាពអនុវត្ត ។

កាលពីខែសីហា អជ្ញាធររដ្ឋាភិបាលបានរឹបអូស ថាសវីឌីអូឌីជីថល (Digital video discs) ដែលមានរូបភាពចំនែកសាកសពធ្លាក់យន្តហោះនៅខេត្តកំពត ដោយសំអាងថា រូបភាពទាំងនេះនៅតែមានលក់លើទីផ្សារក្នុងក្រុងភ្នំពេញ និងតំបន់ឯទៀតពេញផ្ទៃប្រទេស ។

**សេរីភាពលើការប្រើប្រាស់អ៊ីនធឺណិត**

ពុំមានការហាមឃាត់ណាមួយ ធ្វើឡើងដោយអាជ្ញាធររដ្ឋាភិបាល ក្នុងការប្រើប្រាស់ អ៊ីនធឺណិត រឺ របាយការណ៏ណាមួយ ស្ដីអំពីការគ្រប់គ្រង់ លើការផ្ញើរសារ E-mail និង ការនិយាយជជែកកំសាន្តតាមប្រព័ន្ធ អ៊ីនធឺណិតនោះទេ ។ ជនគ្រប់រូប រឺក្រុមនានា អាចចូលរួមក្នុងការបញ្ចេញមតិ ដោយសេរីតាមរយៈ អ៊ីនធឺណិត និងជាមួយការប្រើប្រាស់ E-mail ផងដែរ ។ បើទោះបីជាសមាគមន៏ទូរគមនាគមន៏អន្តរជាតិ បានប៉ាន់ប្រមាណថា ការប្រើប្រាស់ អ៊ីនធឺណិត មានចំនួនតែ ០.៣% ប៉ុណ្ណោះក្នុងប្រទេស កាលពីឆ្នាំ២០០៦ យ៉ាងណាក៏ដោយ ក៏បណ្ដាញសេវា អ៊ីនធឺណិតក្នុងទីប្រជុំជនធំ១ មានការផ្គត់ផ្គង់យ៉ាងច្រើន តាមរយៈហាងកាហ្វេ អ៊ីនធឺណិត និង ការប្រើប្រាស់ អ៊ីនធឺណិតតាមផ្ទះ ។

**សេរីភាពវិស័យអប់រំ និង ព្រឹត្តការណ៏វប្បធម៌**

ជាទូទៅ គ្មានការហាមឃាត់ស្របច្បាប់ណាមួយ ទៅលើសេរីភាពនៃវិស័យអប់រំនោះទេ ។ គ្រូ១ត្រូវតែប្រុងប្រយ័ត្ននៅពេលបង្រៀន ពីមុខវិជ្ជាដែលទាក់ទិន្ទទៅនឹងនយោបាយ ដោយខ្លាចប៉ះពាល់ដល់អ្នកនយោបាយមួយចំនួន ។ កាលពីខែកុម្ភៈ លោកទ្បេង ណារិទ្ធិ ជាអតីតសាស្ត្រាចារ្យ សកលវិទ្យាល័យពុទ្ធសាស្ត្រនៃរាជ្យបណ្ឌិតសភាព្រះសីហនុរាជ្យ ត្រូវបាន តុលាការក្រុងភ្នំពេញបានកាត់ទោស អោយជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ពីបទបង្រៀនសិស្សនូវអត្ថបទដែលនិពន្ធដោយលោកផ្ទាល់ ដែលមានអត្ថន័យប្រឆាំងនឹងរដ្ឋាភិបាល ។ សាលាក្រម ក៏បានពិន័យជាទឹកប្រាក់ចំនួន ១២៥០ដុល្លា ដែលស្មើនឹង ៥.២៥ លានរៀល រឺអោយគាត់ជាប់ពន្ធនាគារ ចំនួន២ឆ្នាំ បន្ថែមទៀត ។ គ្រួសាររបស់លោក ទ្បេង ណារិទ្ធិ បានអះអាងថាគាត់ជាមនុស្សវិកលចរិក ហើយនៅពេលកាត់ក្ដី តុលាការបានអោយគ្រូពេទ្យវិកលចរិក ពិនិត្យ ដោយរក្សាយ៉ាងសំងាត់នូវលទ្ធផលពិនិត្យ ។ ទោះជាយ៉ាងណាក៏ដោយ គេមិនដឹងថាលទ្ធផលនៃការពិនិត្យរបស់គ្រូពេទ្យ បានប៉ះពាល់ដល់រឿងក្ដី រឺយ៉ាងណានោះទេ ។ រឿងក្ដីនេះ ស្ថិតនៅក្រោមការប្ដឹងឧទ្ធរណ៏នាចុងឆ្នាំនេះ ។

រដ្ឋាភិបាលក៏មិនបានបានហាមឃាត់ លើព្រឹត្តិការណ៍វប្បធម៌ណាមួយទេ។

## ខ. សេរីភាពក្នុងការចូលរួមដោយសន្តិភាព និងសមាគមន៍

### សេរីភាពនៃការជួបប្រជុំ

រដ្ឋធម្មនុញ្ញបានផ្តល់នៃសេរីភាព នៃការជួបប្រជុំដោយសន្តិវិធី ក៏ប៉ុន្តែ រដ្ឋាភិបាល មិនបានគោរពនូវសិទ្ធិនេះក្នុង ការអនុវត្តនៅឡើយទេ។ រដ្ឋាភិបាល តំរូវអោយមានការសុំអនុញ្ញាតជាមុនសំរាប់ ការធ្វើព្យុហយាត្រា រឺក៏បាតុកម្មណាមួយ។ រដ្ឋាភិបាល ជានិច្ចកាល មិនផ្តល់ការអនុញ្ញាតនេះទៅអោយក្រុមសកម្មជនណាដែលរិះគន់គណបក្សកាន់អំណាច រឺ ប្រជាជាតិដែលមានសម្ព័ន្ធភាពល្អជាមួយ រដ្ឋាភិបាល។ អជ្ញាធរបានផ្អែកទៅលើហេតុផលនៃការរក្សាសន្តិសុខ និង សុវត្ថិភាពសាធារណៈ ក្នុងការបដិសេធលើការអនុញ្ញាត ទាំងនេះឡើយ។ សម្កកិច្ចបានប្រើប្រាស់កំលាំង ដែលបង្កអោយមានគ្រោះថ្នាក់បន្តិចបន្តួចដល់បាតុករ ក្នុងការបំបែកក្រុមសកម្មជន ដែលផ្តុំគ្នាដោយគ្មានការអនុញ្ញាត។ អង្គការ ADHOC រាយការណ៍ថា ក្នុងចំនោមការប្រឆាំងតវ៉ាចំនួន៩៨ករណី ដែលក្នុងនោះ មាន៥៥ករណីពាក់ព័ន្ធនឹង ជំលោះដីធ្លី និងជំលោះការងារ។ សម្កកិច្ច និងប៉ូលិសយោធា បានបំបែក ១៧ករណី ដែល៣ករណីទាក់ទិននឹង អ្នកតវ៉ាច្បាប់ ការងារ, ១០ករណី ទាក់ទិននឹងអ្នកតវ៉ាដីធ្លី, និង ៤ករណីទៀត ទាក់ទិននឹងព្រះសង្ឃខ្មែរកម្ពុជាក្រោម។ យ៉ាងណាមិញ រដ្ឋាភិបាល ក៏បានអនុញ្ញាតអោយមានការដើរដង្ហែជាក្បួន ពាក់ព័ន្ធនឹងផ្នែកសិទ្ធិមនុស្ស។ កាលពីថ្ងៃទី ១០ ធ្នូ រដ្ឋាភិបាល បានអនុញ្ញាត អោយប្រារព្ធពិធីដើងង្ហែក្បួន នៅក្នុងទីក្រុងភ្នំពេញ ស្តីពីទិវាពីសិទ្ធិមនុស្ស ដែលមានមនុស្សចូលរួម ចំនួន៥០០នាក់ ពីសំណាក់សកម្មជនសិទ្ធមនុស្ស, ព្រះសង្ឃ, និង អ្នកដទៃទៀតជាច្រើនទៀត ហើយការប្រមូលផ្តុំគ្នាក្នុងទិវាសិទ្ធមនុស្ស មានអ្នក ចូលរួម សរុបប្រមាណ ២៥០០នាក់ ក្នុងទីក្រុងភ្នំពេញ។ កាលពីពីរឆ្នាំមុន ការប្រមូលផ្តុំគ្នាបែបនេះ ដោយមិនមានការដើរដង្ហែ ក្បួន បានធ្វើឡើងត្រឹមតែនៅក្នុងបរិវេណបិទជិតណាមួយប៉ុណ្ណោះ។

កាលពីថ្ងៃទី២៧ កុម្ភៈ សម្កកិច្ចប៉ូលិស និង កងរាជអាវុធហត្ថ បានបំបែកក្រុមបាតុករជាព្រះសង្ឃខ្មែរកម្ពុជាក្រោម ចំនួន ៦០អង្គ ដែលកំពុងធ្វើបាតុកម្មមុខស្ថានទូតវៀតណាម ខណៈពេលដែលប្រធានាធិបតីវៀតណាមមកធ្វើទស្សនកិច្ចផ្លូវរដ្ឋ។ ក្រុមបាតុករ បាននាំគ្នាគាំទ្រ និងជំរុញអោយមានការដោះលែង និង បំបួសឡើងវិញ ចំពោះ សង្ឃកម្ពុជាក្រោមមួយចំនួនដែលត្រូវបានគេ ផ្សឹកនិងចាប់ខ្លួនក្នុងប្រទេសវៀតណាម។ ព្រឹកថ្ងៃបន្ទាប់ មានព្រះសង្ឃដែលបានចូលរួមក្នុងការតវ៉ា ត្រូវបានគេសំលាប់ដោយ អារក។ ហើយកាលពីថ្ងៃទី ១៦ មីនា ក្រុមសម្កកិច្ចនិង អជ្ញាធរខេត្តកណ្តាល បានហាមឃាត់សមាជិកសហគមន៍ខ្មែរកម្ពុជាក្រោម របស់ព្រះសង្ឃ ដែលបានសគុត មិនអោយធ្វើបុណ្យសព។

កាលពីថ្ងៃទី ២០ មេសា សម្កកិច្ច និង អាជ្ញាធរក្រុងប៉ៃលិន បានបំបែកក្រុមបាតុករជាព្រះសង្ឃចំនួន ៨០អង្គ ដែលបានប្រមូល ផ្តុំនៅមុខស្ថានទូតវៀតណាម ដើម្បីព្យាយាមដាក់បង្ហាញនូវ បណ្តឹងដែលចោទប្រកាន់ រដ្ឋាភិបាល វៀតណាមទៅនឹង ការបំពារសិទ្ធិ របស់ព្រះសង្ឃខ្មែរកម្ពុជាក្រោម រស់នៅក្នុងប្រទេស វៀតណាម។

បាតុករបានសំរេចទៅកាន់ស្ថានទូតមួយផ្សេងទៀត ដើម្បីដាក់ពាក្យបណ្តឹង។ នៅតាមផ្លូវ ព្រះសង្ឃដែលមិនមែនខ្មែរកម្ពុជាក្រោម និង ក្រុមមិនស្គាល់អត្តសញ្ញាណមួយក្រុម បានបង្អាក់ដំណើរបាតុករ យ៉ាងកំរោល និងបំបែកហ្វូងបាតុករផងដែរ។ ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយអង្គ ត្រូវរងរបួសនៅក្នុងព្រឹត្តិការណ៍ ឈ្លោះទាស់ទែងនេះ។ អាជ្ញាធរមិនបានធ្វើ អន្តរាគមក្នុងជំលោះនេះទេ ថែមទាំងមិនបានធ្វើការស៊ើបអង្កេត ផងដែរ។ ថ្ងៃ ១៧ ធ្នូ ព្រះសង្ឃ ៤០អង្គបានប្រឹងប្រែងដាក់ពាក្យបណ្តឹងសារជាថ្មី ទៅកាន់មន្ត្រីការទូត វៀតណាម អោយដោះលែង លោក ទឹម សាខន និងព្រះសង្ឃខ្មែរកម្ពុជាក្រោមផ្សេងទៀត ដែលត្រូវបានឃុំឃាំងក្នុងប្រទេសវៀតណាម រួមទាំងទាមទារយកដីធ្លីមកវិញ ដោយព្រះសង្ឃទាំងនោះបានអះអាងថា រដ្ឋាភិបាលវៀតណាម បានរឹបអូសយកដីក្នុងតំបន់បែកខាងត្បូងនៃប្រទេសវៀតណាម ទាំងនោះពីជនជាតិខ្មែរកម្ពុជាក្រោម។ ក្រុមសម្ថកិច្ចបានធ្វើការប៉ុនប៉ងបំបែក ក្រុមបាតុករ ប៉ុន្តែព្រះសង្ឃទាំនោះបដិសេធរំសាយក្រុមបាតុករ ហើយបន្ទាប់មកមានជំលោះកើតឡើងរវាងព្រះសង្ឃនិង ភាគីសម្ថកិច្ច។ អង្គការក្រៅ រដ្ឋាភិបាល នៅក្នុងស្រុកបានអោយដឹងថា ព្រះសង្ឃ ៦ អង្គបានរងរបួសរីឯខាងភាគីសម្ថកិច្ច ក៏បញ្ជាក់ដែរថា មានសម្ថកិច្ចមួយចំនួនរងរបួសបន្តិចបន្តួចដែរ។

កាលពីថ្ងៃទី ២៦ វិច្ឆិកា ក្រុមសម្ថកិច្ចទីរួមខេត្តរតនគីរី បានហាមឃាត់ អង្គការ CCHR មិនអោយធ្វើវេទិកាសាធារណៈ ក្នុងភូមិគង់ យូ (Kong Yu) ដែលអ្នកភូមិមួយចំនួនកំពុងមានជំលោះដីធ្លី ជាមួយឈ្មោះ គៀត កុល្យនី ដោយលើកហេតុផលជំលោះនេះដើម្បីបញ្ឈប់វេទិកានេះ។

សម្តេចសង្ឃ នួនង៉ែត និង ឯកឧត្តម ឃុន ហាង ជារដ្ឋមន្ត្រីនៃក្រសួងវប្បធម៌ និងកិច្ចការ សាសនា បានចុះហត្ថលេខាលើបទបញ្ជាហាមឃាត់ មិនអោយព្រះសង្ឃចូលរួម ក្នុងការប្រឆាំង តវ៉ា កុបកម្ម រឺការដើរដង្ហែជាក្បួន កាលពីថ្ងៃទី ៨ មិថុនា។ ដោយយោងតាមរបាយការណ៍ របស់ ប្រព័ន្ធផ្សព្វផ្សាយនានា បានអោយដឹងថា សមាជិកក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ មួយរូបបានបញ្ជាក់ថា ការហាមឃាត់នេះគឺផ្ទុយនឹងច្បាប់រដ្ឋធម្មនុញ្ញ។

**សេរីភាពនៃការបង្កើតសមាគមន៍**

រដ្ឋធម្មនុញ្ញ បានផ្តល់នូវសិទ្ធិសេរីភាពសំរាប់បង្កើតសមាគមន៍ ហើយរដ្ឋភិបាល ក៏បានគោរពលើការអនុវត្ត សិទ្ធិនេះដែរ ប៉ុន្តែរដ្ឋាភិបាលមិនបានពង្រឹងសិទ្ធិនេះដោយប្រសិទ្ធភាព ដូចដែលមានចែងក្នុងច្បាប់ការងារនោះទេ។

ភាពជាសមាជិកនៃកង កំលាំងយោធាខ្មែរក្រហម គ្រប់គ្រងប្រទេសក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ និងបន្ទាប់ពីការដួលរលំ ហើយធ្វើសកម្មភាពប្រឆាំងរដ្ឋាភិបាល គឺជាអំពើខុសច្បាប់។

**គ. សេរីភាពនៃសាសនា**

រដ្ឋធម្មនុញ្ញ ផ្តល់អោយមាននូវ សិទ្ធិសេរីភាពសៃាសនា ហើយជាទូទៅ រាល់ការអនុវត្តរបស់រដ្ឋាភិបាលគឺបង្ហាញអោយឃើញមានការគោរពសិទ្ធិនេះ។ រដ្ឋធម្មនុញ្ញ ក៏បានលុបបំបាត់នូវការរើសអើងក្នុង រង្វង់សាសនាផងដែរ ដែលក្នុងនោះមានសាសនាតូចៗមួយចំនួនទទួលរងបន្តិចបន្តួច រឺស្ទើរតែគ្មានទាំងស្រុង ចំពោះការរើសអើងជាសាធារណៈ។ ពុទ្ធសាសនាជាសាសនារដ្ឋ

ដែលមានអ្នកប្រតិបត្តិជាពុទ្ធសាសនិក លើសពី ៩៣% នៃចំនួនប្រជាជន។ ក្រៅពីនោះនៅមាន ជនជាតិចាម កាន់សាសនាម៉ូស្លីម ស្ទើរតែទាំងអស់នៃចំនួនប្រជាជនដែលនៅសល់។

ច្បាប់តំរូវអោយគ្រប់និកាយសាសនាទាំងអស់ រួមទាំងពុទ្ធសាសនា ធ្វើសិខិតស្នើសុំការអនុញ្ញាត សាងសង់កន្លែងសំរាប់ គោរពបូជា រឺរៀបចំសកម្មភាពសាសនាផ្សេងៗ ពីក្រសួងវប្បធម៌ ធម្មការនិងសាសនា។ យ៉ាងណាមិញ មិនមានការដាក់ទោសចំពោះការខកខានក្នុងការចុះឈ្មោះចូលទេ។ កាលពីខែកក្កដា ក្រសួងវប្បធម៌ ធម្មការនិងសាសនា បានចេញ ដីកាទប់ស្កាត់ការបញ្ចុះបញ្ចូលជាសាធារណៈ ក្រោមធម្មនុញ្ញដែលបានអនុម័តកាលពីឆ្នាំ ២០០៧ដែលធម្មនុញ្ញនេះ ស្ទើរតែបាត់បង់អស់ការជំរុញអោយប្រើប្រាស់។ នៅថ្ងៃទី ១០កក្កដា អាជ្ញាធរក្រុងភ្នំពេញបានបំបែកដារប្រមូលផ្តុំ គ្រិស្តជន ប្រមាណជា ៣,០០០នាក់ ដោយអះអាងថា អ្នករៀបចំការប្រមូលផ្តុំនេះមិនមានការអនុញ្ញាតច្បាប់គ្រប់គ្រាន់ទេ។ នៅមុនពេលធ្វើការប្រមូលផ្តុំអ្នករៀបចំទទួលបានការអនុញ្ញាតពីក្រសួងពត៌មាន MOI ប៉ុន្តែមិនទាន់ទទួលបានការឆ្លើយតបលើ សំនើរនេះនៅឡើយ ដែលដាក់ទៅក្រសួងវប្បធម៌ធម្មការនិងសាសនាឡើយ។

### ការរំលោភបំពានជាសហគមន៍ និងការរើសអើង

សាសនាតូចៗនានាទទួលរងការរើសអើងក្នុងសង្គម តែបន្តិចបន្តួចប៉ុណ្ណោះ រឺស្ទើរតែគ្មានតែម្តង។ មិនមានការដឹងថាមានសហគមន៍ ជនជាតិ Jewish នៅក្នុងប្រទេសឡើយ ហើយក៏មិនមានរបាយការណ៍ណាមួយស្តីពីការប្រឆាំង និងជនជាតិនេះ Jewish ដែរ។

សំរាប់របាយពត៌មានបន្ថែម សូមបើកមើលរបាយការណ៍ស្តីអំពីសាសនាឆ្នាំ២០០៧ 2007 International Religious Freedom Report

### ឃ. សេរីភាពក្នុងការធ្វើបំលាស់ទី ជនគ្មានទីជំរក ការគាំពារជនភៀសខ្លួន និង ជនអរដ្ឋ

រដ្ឋាភិបាលផ្តល់នូវសេរីភាពក្នុងការបំលាស់ទីនៅក្នុងប្រទេស ការធ្វើដំនើរទៅបរទេសការ ធ្វើអន្តោប្រវេសន៍វិលត្រលប់ មក ប្រទេសកំនើតវិញដែលជាទូទៅសិទ្ធិទាំងនេះក៏ត្រូវបានគោរពក្នុងការអនុវត្តផងដែរ។

រដ្ឋធម្មនុញ្ញហាមប្រាមការធ្វើនិរទេសដោយដោយបង្ខិតបង្ខំហើយរដ្ឋាភិបាលក៏មិនធ្លាប់បានធ្វើអ្វីដែរ។

### ការការពារជនភៀសខ្លួន

ច្បាប់ទាំងឡាយបានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬស្ថានភាពជនភៀសខ្លួនដោយអនុលោមទៅតាមអនុសញ្ញាអង្គការ សហប្រជាជាតិឆ្នាំ ១៩៥១ ដែលទាក់ទងនឹងស្ថានភាពជនភៀសខ្លួននិងពិធីសាររបស់អនុសញ្ញាឆ្នាំ១៩៦៧ហើយរដ្ឋាភិបាលបាន បង្កើតប្រព័ន្ធមួយដើម្បីផ្តល់ការការពារដល់ជនភៀសខ្លួនទាំងអស់។ អនុសញ្ញានិងពិធីសារនោះមានកម្លាំងពេញលេញខាងផ្នែក ច្បាប់នៅក្នុងប្រសេចាប់តាំងពីការធ្វើឧបគមន៍ឆ្នាំ១៩៩២។ យោងតាមការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួល បន្ទុក ជនភៀសខ្លួន (UNHCR) រដ្ឋាភិបាលបានអនុវត្តតាមអនុសញ្ញានិងទំនៀមទំលាប់ច្បាប់អន្តរជាតិស្តីពីជនភៀសខ្លួន។ រដ្ឋាភិបាលបានអនុញ្ញាឱ្យ (UNHCR) រៀបចំចាត់ចែងផ្តល់សិទ្ធិជ្រកកោនដល់អ្នកស្វែងរកសិទ្ធិជ្រកកោនអស់ទាំងនោះនិង

អនុញ្ញាតឱ្យជួយជនភៀសខ្លួនក្នុងខណៈដែលគេកំពុងស្ថិតនៅក្នុងប្រទេស ។ អនុសារណៈយោគយល់មួយដែលរដ្ឋាភិបាលបានចុះហត្ថលេខានៅឆ្នាំ ២០០៥ ជាមួយនឹងឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួល បន្ទុកជនភៀសខ្លួន (UNHCR) និងរដ្ឋាភិបាលវៀតណាម ដើម្បីដោះស្រាយស្ថានភាពពួកកុលសម្ព័ន្ធភ្នំ ម៉ុងតាញ៉ា ដែលស្ថិតនៅក្រោមការការពាររបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) នៅតែមានប្រសិទ្ធិភាពនៅឡើយ ។

អ្នកស្វែងរកសិទ្ធិជ្រកកោនណាដែលបានមកដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅភ្នំពេញត្រូវបានគេរៀបចំបែបបទដោយមានកិច្ចសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាលផងដែរ ។ នៅក្នុងអំឡុងឆ្នាំនោះ មានអ្នកមកដល់ថ្មីចំនួន ៤៤៩ នាក់ដែលស្វែងរកសិទ្ធិជ្រកកោនជាមួយនឹងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ។ យោងតាមឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានឱ្យដឹងថា ពួកកុលសម្ព័ន្ធភ្នំ ( ម៉ុងតាញ៉ា) ចំនួន៩៧នាក់ និង ជនភៀសខ្លួនដែលមិនមែនកុលសម្ព័ន្ធភ្នំចំនួន ២០ នាក់បានចាកចេញទៅប្រទេសទីបី ។ ក្នុងខណៈនោះដែរ អាជ្ញាធរបាននិរទេសអ្នក ស្វែងរក សិទ្ធិជ្រកកោនកុលសម្ព័ន្ធភ្នំ ដែលត្រូវបានគេបដិសេធចំនួន ៣០ នាក់ឱ្យត្រឡប់ទៅ ប្រទេសវៀតណាមវិញ ហើយពួកកុល សម្ព័ន្ធភ្នំចំនួន៣៣នាក់បានស្ម័គ្រចិត្ត ត្រឡប់ទៅកាន់ប្រទេសដើមកំណើតរបស់គេវិញ ។ នៅចុងឆ្នាំនោះមានកុលសម្ព័ន្ធភ្នំចំនួន ៤៦៧ នាក់ស្ថិតនៅក្នុងទីកន្លែងការពាររបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅទីក្រុងភ្នំពេញដែលរួមមានពួកកុលសម្ព័ន្ធភ្នំចំនួន១០១នាក់បានមកដល់ប្រទេសកម្ពុជាកាលពីឆ្នាំមុនផងដែរ ។ យោងតាមឧត្តម ស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) បានឱ្យដឹងថាក្នុងកំឡុងឆ្នាំនោះគ្មានជនភៀសខ្លួនណាម្នាក់បានស្នើសុំឱ្យមានការធ្វើសមាហរណកម្មនៅក្នុងប្រទេសទេ ។

ជាទំលាប់រាជរដ្ឋាភិបាលបានផ្តល់ការការពារខ្លះៗប្រឆាំងនឹងការតាមធ្វើបាបដោយសារតែការវិលត្រឡប់របស់ជនទាំងនោះមកកាន់ប្រទេសខ្លួនវិញដែលមានហេតុផលជឿថាពួកគេមានការភ័យខ្លាចចំពោះ ការតាមធ្វើបាបនេះ ។ តាមរយៈជំនួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅក្នុងអំឡុងពេលនោះរាជរដ្ឋាភិបាលបានផ្តល់ការការពារបណ្តោះអាសន្នចំពោះបុគ្គលទាំងឡាយណាដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាជនភៀសខ្លួន ដោយអនុលោមតាមអនុសញ្ញាឆ្នាំ ១៩៥១ និងពិធីសារឆ្នាំ១៩៦៧អ្នកដែលទទួលបានការការពារបែបនេះមានចំនួនប្រហែលជា១៥០នាក់ ។ទោះជាយ៉ាងនេះក្តីអង្គការក្រៅរដ្ឋាភិបាលមួយដែលប្រចាំការនៅខេត្តរតនៈគិរីបានរាយការណ៍ថាប៉ូលីសមូលដ្ឋានបានបញ្ជូនក្រុមកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ាក្រៅផ្លូវការដែលស្វែងរកសិទ្ធិជ្រកកោនចំនួន៩៩នាក់ឱ្យវិលត្រឡប់ទៅប្រទេសវៀតណាមវិញដោយគ្មានការត្រួតពិនិត្យឡើងវិញពីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនឡើយ ។នៅថ្ងៃទី២០ខែមេសាស្នងការប៉ូលីសខេត្តរតនៈគិរីបានចាប់ខ្លួនមនុស្សពីរនាក់ពីបទជួញដូរមនុស្សចំពោះតួនាទីរបស់គេដែលជួយដល់ក្រុមកុលសម្ព័ន្ធភ្នំទាំងនេះ ។អង្គការក្រៅរដ្ឋាភិបាលនានាបានអះអាងថាជនសង្ស័យទាំងពីរនេះបានផ្តល់ឱ្យអ្នកស្វែងរកសិទ្ធិជ្រកកោននូវចំណីអាហារជំរកនិងការដឹកជញ្ជូនទៅកាន់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅទីក្រុងភ្នំពេញនៅពេលដែលពួកគេបានឆ្លងកាត់ព្រំដែនពីប្រទេសវៀតណាម ។នៅចុងឆ្នាំនោះ  ជនសង្ស័យទាំងពីរនេះត្រូវបានដោះលែងតាមការលើកលែងបទចោទប្រកាន់ប្រឆាំងពួកគេ ។ អង្គការក្រៅរដ្ឋាភិបាលមួយបានអះអាងថាអាជ្ញាធរមូលដ្ឋាននៅច្រកព្រំដែនរួមជាមួយប្រទេសវៀតណាមបានបន្តការរុករកពួកកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ានៅពេលណាដែលពួកគេទទួលបានពត៌មានអំពីការមកដល់ថ្មីរបស់ពួកកុលសម្ព័ន្ធភ្នំទាំងនោះ ។

គ្មានរបាយការណ៍ណាដែលបញ្ជាក់ថាអាជ្ញាធរវៀតណាមផ្តល់រង្វាន់លើកទឹកចិត្តដល់ប៉ូលីសព្រំដែនកម្ពុជាដែលបានបញ្ជូនជនភៀសខ្លួនវៀតណាមឱ្យវិលត្រឡប់មកវៀតណាមវិញទេហើយថាប៉ូលីសសំងាត់របស់វៀតណាមបានធ្វើការរុករកជនភៀសខ្លួនវៀតណាមជាចំហរនៅលើទឹកដីព្រំដែនខាងកម្ពុជាឡើយ ។

## ជនគ្មានរដ្ឋ

ប្រទេសកម្ពុជាមានអ្នករស់នៅជាទំលាប់ដែលគ្មានរដ្ឋពិតប្រាកដ ហើយរដ្ឋាភិបាលមិនបានចាត់វិធានការណ៍អនុវត្តច្បាប់ មានប្រសិទ្ធិភាព ឬមានគោលការណ៍ណាមួយដើម្បីផ្តល់ឱ្យជនទាំងនោះនូវឱកាសទទួលបានសញ្ជាតិឡើយ ។
ដោយអនុលោមតាមច្បាប់សញ្ជាតិប្រជាពលរដ្ឋត្រូវបានគេផ្តល់សញ្ជាតិតាមរយៈកំណើតពីម្តាយនិងឪពុក ជាជនបរទេសដែលបានកើតនិងកំពុងរស់នៅដោយស្របច្បាប់លើប្រទេសនេះ ឬ ពីម្តាយឪពុកដែលមានសញ្ជាតិជាពលរដ្ឋកម្ពុជា ។ ការសិក្សាដែលបានកំណត់ដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានប៉ាន់ប្រមាណថា ជនដែលគ្មានរដ្ឋពិប្រាកដជារាប់ពាន់នាក់បានរស់នៅ ក្នុងប្រទេសនេះ ។ ប៉ុន្តែការសិក្សានេះក៏បានប៉ាន់ស្មានដែរថា ចំនួននៃជនទាំងនោះបានមកពីភស្តុតាងមិនជាក់លាក់របស់អង្គការ ក្រៅរដ្ឋាភិបាលមួយចំនួន ដែលបានផ្តល់សេវាកម្មទៅកាន់សហគមន៍ដែលគ្មានសិទ្ធិបោះឆ្នោតរួមទាំងជនដែលគ្មានការបញ្ជាក់ពីសញ្ជាតិផងហើយមិនមែនបានមកពីការស្ទង់មតិនៃជនដែលគ្មានរដ្ឋច្បាស់លាស់នោះទេ ។ អាស្រ័យហេតុនេះ អ្នកតំណាងរបស់ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនប្រចាំប្រទេស មិនបានពិចារណាតួលេខប្រាកដរបស់ប្រជាជននោះទេ ។
ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានថ្លែងថាចំនួនប្រជាពលរដ្ឋដែលគ្មានរដ្ឋច្បាស់លាស់ជាសក្តានុពលរបស់ប្រទេសនោះរួមមានទាំងជនជាតិភាគតិចវៀតណាមភាគច្រើនផងដែរ ។ យោងតាមអង្គការក្រៅរដ្ឋាភិបាលមួយដែលបានធ្វើការជាមួយជនជាតិភាគតិចវៀតណាមបានឱ្យដឹងថាបុគ្គលមួយចំនួនដែលគ្មានការបញ្ជាក់ពីសញ្ជាតិជារឿយៗមិនទទួលបានការងារការអប់រំការចុះឈ្មោះអាពាហ៍ពិពាហ៍ប្រព័ន្ធតុលាការនិងទទួលបានជាម្ចាស់កម្មសិទ្ធិដីធ្លីជាផ្លូវការទេ ។ ហេតុផលជាធម្មតាភាគច្រើនចំពោះការគ្មានរដ្ឋច្បាស់លាស់ គឺបណ្តាលមកពីការខ្វះខាតឯកសារត្រឹមត្រូវពីប្រទេសកំណើតរបស់ខ្លួន ។

## ផ្នែកទី ៣ៈ គោរពសិទ្ធិនយោបាយ ៖ សិទ្ធិពលរដ្ឋក្នុងការផ្លាស់ប្តូររដ្ឋាភិបាលរបស់គេ ។

រដ្ឋធម្មនុញ្ញផ្តល់ឱ្យប្រជាពលរដ្ឋគ្រប់រូបនូវសិទ្ធិផ្លាស់ប្តូររដ្ឋាភិបាលរបស់គេដោយសន្តិវិធី ហើយជាទូទៅ ប្រជាពលរដ្ឋអនុវត្តសិទ្ធិនេះជាទំលាប់តាមរយៈការបោះឆ្នោតដែលមានកាលកំណត់ ដោយផ្អែកទៅលើសិទ្ធិបោះឆ្នោតជាសាកល ។ សិទ្ធិបោះឆ្នោតនេះ គឺជាការស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋគ្រប់រូបដែលមានអាយុ ១៨ឆ្នាំ និងលើសអាយុ ១៨ឆ្នាំ ។

## ការបោះឆ្នោត  និងការចូលរួមក្នុងវិស័យនយោបាយ

នៅថ្ងៃទី ១ ខែមេសា ប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទីមួយ ទីពីរចំនួន ១១,៣៥៣រូប និងក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន ១,៦២១នាក់ ។  គណបក្សប្រជាជនកម្ពុជា បានឈ្នះតំណែង ៧០.៤ភាគរយ  គណបក្សសម រង្ស៊ី ២៣.៤ ភាគ រយគណបក្សនរោត្តមរណឫទ្ធិ ៣.៧ ភាគរយ និងគណបក្សហ៊្វុនស៊ិនប៉ិច ២.៤ ភាគរយ ។ អ្នកអង្កេតការណ៍ភាគច្រើនបានយល់ស្របថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ កើតមានអំពើហឹង្សាតិចតួច និងជាការបោះ ឆ្នោតដែលបានរៀបចំ

ឡើងល្អបំផុតមិនធ្លាប់បានធ្វើកន្លងមកនៅក្នុងប្រទេសទេ។ នៅពេលដែលមានបញ្ហាមួយចំនួននៅមណ្ឌលបោះឆ្នោតខ្លះៗអង្គការក្រៅរដ្ឋាភិបាលគណបក្សប្រឆាំងអ្នកអង្កេតការណ៍ និងក្រុមនុស្សដទៃទៀតមិនយល់ស្របចំពោះបញ្ហាទាំងនោះដែលថាមានការប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតទាំងស្រុងនោះទេ។ អង្គការក្រៅរដ្ឋាភិបាលបីបានរាយការណ៍ថាមន្ត្រីបោះឆ្នោតមិនអនុញ្ញាតឱ្យអ្នកបោះឆ្នោតខ្លះដែលបានចុះឈ្មោះរួច បោះឆ្នោតឡើយ ដោយសារតែភាពមិនស៊ីគ្នានៃ ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត ដូចជាការវាយឈ្មោះច្រឡំ និងការប្រកបឈ្មោះខុស ឬអវត្តមានឈ្មោះពីបញ្ជីអ្នកបោះឆ្នោត ជាដើមដែលជារឿយៗបណ្តាលមកពីការផ្ទេរឈ្មោះទៅកាន់មណ្ឌលបោះឆ្នោតផ្សេងទៀត ដោយមិនបានជូនដំណឹងដល់អ្នកបោះឆ្នោត ជាមុន។ លើសពីនេះអង្គការក្រៅរដ្ឋាភិបាល និងគណបក្សប្រឆាំងបានត្អូញត្អែរថាគណបក្សប្រជាជនកម្ពុជា បានចាប់ផ្តើមឃោសនាជាច្រើនសប្តាហ៍ ឬជាច្រើនខែជាមុន តាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មានគ្របដណ្តប់ដោយគណបក្សប្រជាជនកម្ពុជាច្រើនលើសលុបភាគច្រើន ដោយគ្មានការផ្តល់ជូនស្មើភាពគ្នាឡើយ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានរាយការណ៍ថា នៅថ្ងៃបោះឆ្នោតមន្ត្រីកាន់តំណែងរបស់គណបក្សកាន់អំណាចខ្លះបានចេញឯកសារចុះឈ្មោះអ្នកបោះឆ្នោតដោយខុសច្បាប់ និងបានឈរមើលនៅមណ្ឌលបោះឆ្នោតខ្លះ ដែលអាជ្ញាធរមូលដ្ឋានហាមឃាត់មិនឱ្យចូល  និងបានផ្តល់ជំនួយដល់អ្នកបោះឆ្នោតនៅទីកន្លែងដែល បានហាមឃាត់ទាំងនោះ ។  គណបក្ស និងបុគ្គលទាំងឡាយមានសេរីភាពឈរឈ្មោះជាបេក្ខជនដោយគ្មានការដាក់កំហិត។ នៅថ្ងៃទី១៣ មិនា តុលាការក្រុងភ្នំពេញ បានកាត់ទោសព្រះអង្គម្ចាស់នរោត្តមរាណឬទ្ធិ ប្រធានគណបក្សនរោត្តមរាណឬទ្ធិដោយកំបាំងមុខជាប់ពន្ធនាគារ ១៨ខែ និងពិន័យជាប្រាក់១៥០.០០០ដុល្លា ត្រូវជា (៦០០ លានរៀល) ពីបទរំលោភលើសេចក្តីទុកចិត្ត។ ព្រះអង្គបានភាសព្រះកាយក្នុងអំឡុងយុទ្ធនាការបោះឆ្នោតនិងនៅថ្ងៃបោះឆ្នោតជាជាងប្រឈមមុខនឹងការចោទប្រកាន់នេះ។ នៅថ្ងៃទី ៣ តុលា សាលាឧទ្ធរណ៍បាន ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ព្រះអង្គចំពោះសេចក្តីសំរេចរបស់តុលាការក្រុងភ្នំពេញ។ ផែនការនានាដែលប្តឹងតវ៉ាចំពោះសេចក្តីសំ រេចនេះ មិនត្រូវបានគេដឹងនៅចុងឆ្នាំនោះទេ។ អង្គការក្រៅរដ្ឋាភិបាល និងគណបក្សនយោបាយមួយចំនួនបានចោទប្រកាន់ថា សមាជិកនៅក្នុងគណបក្សប្រជាជនកម្ពុជាដ៏ច្រើន លើសលប់បានផ្តល់ការយកចំណេញផ្នែកនយោបាយ ដូចជាអំណោយ ឬការទទួលបានអ្វីមួយដែលជាជំនួយបន្ទាន់ពីរដ្ឋាភិបាល។ វប្បធម៌ទំនៀមទំលាប់ បានកំណត់តួនាទីរបស់ស្ត្រីក្នុងជួររដ្ឋាភិបាល តែទោះជាយ៉ាងនេះក្តី ស្ត្រីបានចូលរួមយ៉ាងសកម្មនៅក្នុងការបោះឆ្នោតជាតិឆ្នាំ ២០០៣។ ចំនួនស្ត្រីបានកើនឡើងនៅក្នុងរដ្ឋសភា ព្រឹទ្ធសភា និងតំណែងជាន់ខ្ពស់របស់រដ្ឋាភិបាល។ មានស្ត្រីចំនួន ២២រូបនៅក្នុងអាសនៈរដ្ឋសភាចំនួន ១២៣ ស្ត្រី ៩រូប នៅក្នុងអាសនៈព្រឹទ្ធសភាចំនួន ៦១ និងស្ត្រី ២៤រូបមានតំណែងជារដ្ឋមន្ត្រីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងធ្វើជាមន្ត្រីគណៈកម្មការរៀបចំការបោះឆ្នោតជាតិ។   ស្ត្រីខ្លះក៏មានតួនាទីជាទីប្រឹក្សា និងមាន ចៅក្រមជាស្ត្រីចំនួន ១៣រូបនៅតាមតុលាការខេត្ត-ក្រុង   សាលាឧទ្ធរណ៍ និងតុលាការកំពូលផងដែរ។   ក្នុងការបោះឆ្នោតក្រុម ប្រឹក្សាឃុំ-សង្កាត់នៅខែមេសា  ១៤.៦ ភាគរយនៃក្រុមប្រឹក្សាបោះឆ្នោតឃុំ/សង្កាត់ជាស្ត្រី ដែលក្នុងចំណោមនោះ ៦៧រូបត្រូវបាន ជ្រើសតាំងឱ្យធ្វើជាប្រធាន។ នេះគឺជាការកើនឡើងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ ២០០២ នៅពេលដែលស្ត្រីបានឈ្នះ ត្រឹមតែ ៩ ភាគរយនៃតំណែងសារុបទាំងអស់។ មានសមាជិកជនជាតិភាគតិច ៤នាក់--ពីរនាក់ជាជនជាតិចាម និងពីរនាក់ផ្សេងទៀតជាជនជាតិដើមភាគតិចនៅក្នុងស្ថាប័នរដ្ឋសភា ហើយក៏មានសមាជិកជនជាតិដើមភាគតិចចំនួន ៦រូបទៀតនៅក្នុងព្រឹទ្ធសភា។ យ៉ាងហោចណាស់ក៏មានមន្ត្រី៨រូបដែលមានតំណែងខ្ពស់នៅក្នុងជួររាជរដ្ឋាភិបាលមកពីក្រុមជនជាតិដើមភាគតិចផងដែរ។

## អំពើពុករលួយ  និងតម្លាភាពរបស់រដ្ឋាភិបាល

មិនមានច្បាប់ប្រឆាំងអំពើពុករលួយទេ មានតែបញ្ញត្តិមួយចំនួនតូចប៉ុណ្ណោះនៃច្បាប់ដទៃទៀតដែលចែងពីទោសបញ្ញត្តិព្រហ្មទណ្ឌចំពោះអំពើពុករលួយជាផ្លូវការ ។ ជារឿយៗ មន្ត្រីទាំងឡាយដែលពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តអំពើពុករលួយមាននិទណ្ឌភាព ។ សូចនករអភិបាលកិច្ចទូទាំងពិភពលោករបស់ធនាគារពិភពលោក បានឆ្លុះបញ្ចាំងឱ្យឃើញថា អំពើពុករលួយគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ។នៅឆ្នាំ ២០០៥ នាយករដ្ឋមន្ត្រីបានចេញសេចក្តីណែនាំដល់រដ្ឋមន្ត្រីទំនាក់ទំនងព្រឹទ្ធសភា-រដ្ឋសភា និងអធិការកិច្ចឱ្យរៀបចំសេចក្តី ព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ។ រហូតដល់ចុងឆ្នាំនេះអ្នកអង្កេតការណ៍ទាំងឡាយ មិនបានឃើញសេចក្តីព្រាងដែលបានកែប្រែ នេះតាំងពីខែកញ្ញា ឆ្នាំ ២០០៦ ម្ល៉េះហើយបញ្ហានេះបានកំពុងរង់ចាំនៅទីស្តីការគណៈរដ្ឋមន្ត្រី ។ អំពើពុករលួយត្រូវបានគេចាត់ទុកថាជាលក្ខណៈដោយអន្លើ និងរីករាលដាលពាសពេញផ្នែកនានានៅក្នុងសង្គម រួមទាំងស្ថាប័ននីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការរបស់រដ្ឋាភិបាល ។ ទស្សនាទានសាធារណៈអំពីអំពើពុករលួយរាលដាល ។ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាដែលធ្វើការប៉ាន់ប្រមាណនៅឆ្នាំ ២០០៦ បានរកឃើញថា វិស័យឯកជនបានដឹងថាប្រព័ន្ធតុលាការគឺជាស្ថាប័នពុករលួយខ្លាំងជាងគេបង្អស់នៅក្នុងប្រទេស បន្ទាប់មកសេវាកម្មគយនិងពន្ធដារ វិស័យថែរក្សាសុខភាពសាធារណៈ និងស្ថាប័នប៉ូលីស ។ ការទទួលបានប្រាក់ខែតិចតួច នាំឱ្យមានអំពើពុករលួយកើតឡើងក្នុងចំណោមមន្ត្រីសាធារណៈថ្នាក់ទាប រីឯវប្បធម៌និទណ្ឌភាពអាចឱ្យអំពើពុករលួយរីកដុះដាលក្នុងចំណោមមន្ត្រីជាន់ខ្ពស់ទាំងឡាយ ។ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាដែលធ្វើការប៉ាន់ប្រមាណអំពើពុករលួយនៅឆ្នាំ២០០៦ ក្នុងវិស័យឯកជន បានប្រមាណទៀតថា នៅឆ្នាំ ២០០៥ការបង់ប្រាក់មិនផ្លូវការរបស់វិស័យឯកជនចំពោះមន្ត្រីសាធារណៈមានចំនួនសារុប ៣៣០លានរៀល ។ ការប្រមាណនេះ ក៏បានរកឃើញថា ក្រុមហ៊ុនឯកជនធំកាលណាការបង់ប្រាក់ដែលមន្ត្រី រដ្ឋាភិបាលតំរូវក៏កាន់តែមានច្រើនកាលនោះដែរ ។ ការសិក្សាដដែលបានឱ្យដឹងថាពន្ធសក្តានុពលប្រហែល ២៥ភាគរយត្រូវបានប្រមូលពីវិស័យឯកជននៅឆ្នាំ ២០០៥ ជាការបង្ហាញឱ្យឃើញនូវការបាត់បង់របស់រដ្ឋាភិបាលចំនួនប្រហែល ៤០០លានរៀល ។ នៅខែមិថុនា អង្គការ Global Witness បានផ្សព្វផ្សាយរបាយការណ៍មួយចោទប្រកាន់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ពីបទពុក រលួយទាក់ទងនឹងការកាប់ព្រៃឈើខុសច្បាប់ ។ អ្នកអង្កេតការណ៍ខ្លះ និងមន្ត្រីរដ្ឋាភិបាលជាច្រើន បានរិះគន់របាយការណ៍នោះថា មិនគួរឱ្យជឿបានហើយថា របាយការណ៍នោះយោងទៅតាមការពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រភពអានាមិក ។ ច្បាប់ប័ណ្ណសារជាតិអនុញ្ញាតឱ្យទទួលឯកសារព័ត៌មានដោយឥតព្រំដែននៅក្នុងប័ណ្ណសារសាធារណៈ ។ យ៉ាងណាក្តីច្បាប់ផ្តល់ឱ្យទទួលបាននូវឯកសាររដ្ឋាភិបាលដទៃទៀតដែលមិនបានបញ្ជាក់ ក្រោយរយៈពេល២០ឆ្នាំប៉ុណ្ណោះ និងដោយឡែកឯកសារផ្សេងទៀតដែល ប៉ះពាល់ដល់សន្តិសុខជាតិ និងការការពារជីវិតផ្ទាល់ខ្លួន នឹងអាចត្រូវបានចេញផ្សាយក្រោយរយៈពេល ៤០ និង១២០ឆ្នាំ ។ ជាទំលាប់ រដ្ឋាភិបាលយូរៗម្តង បានបដិសេធចំពោះការទទួលព័ត៌មាន ដោយលើកយកហេតុផលនៃការលាក់ការ សំងាត់ និងសន្តិសុខប្រទេសជាតិ ។ ផ្នែកទី ៤ ឥរិយាបថរបស់រដ្ឋាភិបាលចំពោះការស៊ើបអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការ ក្រៅរដ្ឋាភិបាលអំពីការចោទប្រកាន់ការ រំលោភសិទ្ធិមនុស្ស ការប្រែប្រួលការងាររបស់ក្រុមសិទ្ធិមនុស្សអន្តរជាតិ និងនៅក្នុង ស្រុកជាទូទៅធ្វើប្រតិបត្តិការដោយគ្មានការដាក់កំហិតពីរដ្ឋាភិបាល ឡើយ ដូចជាការស៊ើបអង្កេត និងការបោះពុម្ពផ្សាយគំហើញ របស់ពួកគេស្តីពីបញ្ហាសិទ្ធិមនុស្សជាដើម ។ ជាញឹកញាប់ មន្ត្រី រដ្ឋាភិបាលធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងបុគ្គលិកសិទ្ធិមនុស្សក្នុងការស៊ើបអង្កេតរបស់ពួកគេ តែទោះជាយ៉ាងណាក្តី មានរបាយការណ៍ជាច្រើនអំពីការខ្វះខាតកិច្ចសហប្រតិបត្តិការ ហើយសូម្បីតែការបំភិតបំភ័យដែលធ្វើឡើងពាសពេញប្រទេសដោយអាជ្ញាធរ មូលដ្ឋានក៏មានផងដែរនៅក្នុងរបាយការណ៍នោះ ។ មានអង្គការសិទ្ធិមនុស្សប្រហែលជា ៤០ អង្គការនៅក្នុងប្រទេស ប៉ុន្តែមានតែ អង្គការមួយផ្នែកតូចប៉ុណ្ណោះនៃអង្គការទាំងនោះដែលពាក់ព័ន្ធយ៉ាងសកម្មនៅក្នុងការរៀបចំកម្មវិធីហ្វឹកហ្វឺន ឬស៊ើបអង្កេតការរំលោភបំពានទាំងឡាយ ។ អង្គការសិទ្ធិមនុស្សអន្តរជាតិ

និងនៅក្នុងស្រុក ប្រឈមមុខនឹងការគំរាមកំហែង និងយាយអំពីមន្ត្រីអាជ្ញាធរមូលដ្ឋាន។ បញ្ហាអស់ទាំងនេះបានបង្កើតជាទ្រង់ទ្រាយនៃការរិតបន្តឹង និងការរំខាន ដូចជាការបំភិតបំភ័យជាពាក្យសំដី ការគំរាមកំហែងប្តឹង និងការរារាំងការិយាល័យធិបតេយ្យក្នុងកំឡុងពេលជួបប្រជុំដែលឧបត្ថម្ភរ៉ាប់រងដោយអង្គការក្រៅរដ្ឋាភិបាលទាំងឡាយ។ នៅថ្ងៃទី ១៥ ឧសភា អ្នកសម្របសម្រួលសំរួលអង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស បានរត់គេចខ្លួន ដោយអះអាងថា អាជ្ញាធរក្រុងព្រះសីហនុ បានគំរាមចាប់ខ្លួនគាត់ ពីបទបង្កើតកងកម្លាំងប្រដាប់អាវុធខុសច្បាប់ចំពោះតួនាទីរបស់ខ្លួន ក្នុងការរៀបចំប្រឹងប្រែងតស៊ូនឹងការបណ្តេញចេញដោយបង្ខំនៅក្នុងខ័ណ្ឌមិត្តភាពក្រុងព្រះសីហនុ។ រយៈពេល២-៣សប្តាហ៍ក្រោយមកគាត់បានវិលត្រឡប់មកធ្វើការវិញដោយគ្មានឧប្បត្តិហេតុអ្វីឡើយ។ មិនមានការវិវឌ្ឍន៍ណាមួយនៅក្នុងករណីខែឧសភាឆ្នាំ២០០៦ ស្តីពីសកម្មជនរបស់អង្គការអាដហុកម្នាក់ដែលត្រូវបានគេឃុំខ្លួនបណ្តោះ អាសន្ននៅខេត្តកោះកុងពីបទថតរូបភាពស្តីពីការប្រឈមមុខដាក់គ្នារវាងអ្នកភូមិនិងមន្ត្រីរដ្ឋាភិបាល។ នៅខែមករា អ្នកតំណាងពិសេសនៃអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្សនៅកម្ពុជា លោក យ៉ាស ហ្គាយ បាន ដាក់របាយការណ៍ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិស្តីពីទស្សនកិច្ចរបស់គាត់នៅខែមិនា ឆ្នាំ២០០៦ដែល បង្ហាញឱ្យឃើញនូវក្តីកង្វល់ជាច្រើនអំពីការរំលោភបំពានចាប់យកដី និងសម្បទានដីរបស់រដ្ឋាភិបាល។ បន្ទាប់មកលោកនាយករដ្ឋ មន្ត្រីបានហៅអ្នកតំណាងពិសេសនោះដោយប្រើឈ្មោះមាក់ងាយ ហើយបដិសេធមិនព្រមជួបជាមួយគាត់ម្តងទៀតតាំងពីពេលនោះ មក។ នៅខែធ្នូ លោកយ៉ាស់ ហ្គាយ បានធ្វើទស្សនកិច្ចវាយតម្លៃមួយរយៈពេល ១០ថ្ងៃមកកាន់ប្រទេសកម្ពុជាដែលក្នុងកំឡុងពេលនោះលោកនាយករដ្ឋមន្ត្រីបានបញ្ជាក់មតិរបស់លោកថែម ទៀតក្រោយមក គ្មានមន្ត្រីរដ្ឋាភិបាលណាម្នាក់ផ្តល់ឱ្យគាត់ធ្វើការជួប ប្រជុំឡើយ។ គណៈកម្មការជាតិសិទ្ធិមនុស្សកម្ពុជាស្ថិតនៅដោយគ្មានសកម្មភាពអ្វីទាំងអស់។ គណៈកម្មាធិការមិនមានការប្រជុំទៀងទាត់ ឬមាន ដំណើរការប្រតិបត្តិការដែលមានតម្លាភាពទេ។

**ផ្នែកទី ៥ ការរើសអើងការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស**

រដ្ឋធម្មនុញ្ញហាមឃាត់ការរើសអើងដែលផ្អែកទៅលើពូជសាសន៍ ភេទ ពណ៌សម្បុរ ឬភាសាតែទោះជាយ៉ាងណាក្តី រដ្ឋាភិបាលជាទូទៅមិនបានការពារសិទ្ធិអស់ទាំងនេះទេ។

**ស្ត្រី**

ច្បាប់ហាមឃាត់ការរំលោភផ្លូវភេទនិងការរំលោភបំពាននានា ទោះជាយ៉ាងនេះក្តី អង្គការអន្តរជាតិ និងអង្គការនៅក្នុងស្រុកជាច្រើន បានរាយការណ៍ថា អំពើហឹង្សាប្រឆាំងនឹងស្ត្រី រួមទាំងអំពើហឹង្សាក្នុងគ្រួសារ និងការរំលោភផ្លូវភេទ គឺកើតមានជាទូទៅ។ អំពើរំលោភគឺជាបទល្មើសព្រហ្មទណ្ឌនិងត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររវាងពី ៥ទៅ ១០ឆ្នាំ យោងតាមច្បាប់អ៊ុនតាក់។ ការរំលោភបំពានទៅលើសហព័ទ្ធ និងអំពើហឹង្សាក្នុងគ្រួសារមិនត្រូវបានគេទទួលស្គាល់ថាជាបទល្មើសដាច់ដោយឡែកទេ។ ករណីនៃការរំលោភបំពានទៅលើសហព័ទ្ធអាចត្រូវបានកាត់ទោសថាជាការ "រំលោភផ្លូវភេទ" "ការបង្ករបួសស្នាម" ឬ "ការបៀតបៀនកេរ្តិ៍ខ្មាស" ប៉ុន្តែបទចោទបែបនោះកំរធ្វើការចោទប្រកាន់ណាស់។ អំពើហឹង្សាក្នុងគ្រួសារជាបទឧក្រិដ្ឋ ប៉ុន្តែមិនទាន់បានកំណត់ទោសបញ្ញត្តិឱ្យបានជាក់លាក់នៅឡើយ ។ ទោះជា យ៉ាងណាក៏ដោយ ច្បាប់របស់អុនតាក់ "UNTAC" ស្តីអំពីការវាយតប់គ្នា និងការបង្ករបួសស្នាម អាចយកមកប្រើ ដើម្បីកំណត់ទោសបញ្ញត្តិ លើបទល្មើសអំពើហឹង្សាក្នុងគ្រួសារដោយមានជម្ងន់ទោសដាក់ពន្ធនាគាររយៈពេលចាប់ពី ពីរទៅប្រាំឆ្នាំ ។

យោងតាមអង្គការក្រៅរដ្ឋាភិបាលមួយបានឱ្យដឹងថា មានអំពើហិង្សាក្នុងគ្រួសារចំនួន ១.០២៥ករណី និងបទល្មើសចាប់រំលោភសេពសន្ថវៈចំនួន ២២១ករណី នៅក្នុងខេត្តចំនួនបី ។ តុលាការបានជុំនុំជំរៈអំពើហឹង្សា ១០៤ករណី និង បទល្មើសចាប់រំលោភ ២៨ករណី ក្នុងចំណោមករណីសរុបខាងលើ ដោយសម្រេចបាននូវការជុំនំជំរៈដ៏ជោគជ័យ លើអំពើហឹង្សាក្នុងគ្រួសារ ៥ករណី និង អំពើរំលោភផ្លូវភេទ ២០ករណី ។ អង្គការលីកាដូ "LICADHO" បានបញ្ចេញ ឯកសារទាក់ទិននិងអំពីអំពើហឹង្សាក្នុងគ្រួសារចំនួន ២០៩ករណី ដែលបង្កឱ្យមានជនរងគ្រោះ ដោយសារអំពើហឹង្សា នេះចំនួន ២១៣ នាក់ នៅក្នុង ១២ខេត្តក្នុងពេលអំឡុងពេលតែ មួយ ។ នាយកដ្ឋានប្រឆាំងនឹងការជួញដូរមនុស្សរបស់ ក្រសួងមហាផ្ទៃ MOI បានស៊ើបអង្កេតលើអំពើហឹង្សាចំនួន ៥២៥ករណី ប្រឆាំងលើស្ត្រី និងកុមារ ជាលទ្ធផលឈាន ទៅចាប់បានជនល្មើស ៥៨២នាក់ និងសង្គ្រោះជនរងគ្រោះបាន ៧៧១នាក់ ។ ក្នុងចំណោមការចាប់ខ្លួនចំនួន ៥៨២ ករណី មាន៤៥៨ករណីជាប់ទាក់ទិននិងបទល្មើសចាប់រំលោភ និងការរំលោភដោយការគ្រោងទុក ។ បទល្មើស ចាប់រំលោភ ១២ករណីបានបណ្តាលឱ្យជនរងគ្រោះស្លាប់ ។ ការតស៊ូមតិរបស់អង្គការក្រៅរដ្ឋាភិបាលមួយបានរាយការណ៍ថា បានទទួលនូវពាក្យបណ្តឹងលើអំពើហឹង្សាក្នុងគ្រួសារចំនួន ៨៤ករណី ដោយក្នុងនោះមាន ៣៤ករណីបានបញ្ជូនទៅតុលាការ ដើម្បីជំនុំជំរៈនៅអំឡុងឆ្នាំនោះ ។ មានជាច្រើនករណី ទំនងជាមិនបានរាយការណ៍អំពីបញ្ហា ឱ្យបានច្បាស់លាស់ ដោយសារតែគ្មានប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងដោយសារតែស្ត្រីដែលជាជនរងគ្រោះខ្លាច មិនហ៊ានប្តឹងប្រឆាំងនឹងជនល្មើស ។ អង្គការក្រៅរដ្ឋាភិបាលនានា បានឱ្យដឹងថាការអនុវត្តច្បាប់ប្រឆាំងនឹង អំពើហិង្សានៅទន់ខ្សោយ អាជ្ញាធរបន្តបញ្ជាសការជាប់ទាក់ទិននឹងជម្លោះក្នុងគ្រួសារ រួមទាំងជនរងគ្រោះផ្ទាល់ ជារឿយៗស្ទាក់ស្ទើរក្នុងការ ស្វះស្វែងរៀបចំពាក្យបណ្តឹងជាផ្លូវការ ។

រដ្ឋាភិបាលបានគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលទាំងឡាយណា ដែលបានផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីក្រីក្រ ដែលងាយរងគ្រោះដោយសារការបំពានពីប្តី អំពើពេស្យាចារ និងការជួញដូរមនុស្ស ។ មជ្ឈមណ្ឌលប្រព័ន្ធឃោសនាក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាល និងក្រសួងកិច្ចការនារី បានផលិតកម្មវិធីស្តីអំពីបញ្ហាស្ត្រី ។ អង្គការក្រៅរដ្ឋាភិបាលក៏បាន ផ្តល់ជម្រកដល់ស្ត្រីដែលមានវិបត្តិផងដែរ ។
រដ្ឋធម្មនុញ្ញហាមឃាត់មិនឱ្យមានអំពើពេស្យាចារ ទោះជាយ៉ាងនេះក៏ដោយ មិនមាននីតិវិធីស្របច្បាប់ណាមួយប្រឆាំង នឹងការប្រកបការងារជាស្ត្រីរកស៊ីផ្លូវភេទឡើយ ។ ការជួញដូរស្ត្រីក្នុងគោលបំណងប្រព្រឹត្តពេស្យាកម្មគឺជាបញ្ហាធ្ងន់ធ្ងរបើទោះបីជាមានច្បាប់ប្រឆាំងនឹងការផ្តល់សេវាផ្លូវភេទ និងការចាប់ជំរិតក្នុងបំណងកេងប្រវ័ញ្ចផ្លូវភេទក៏ដោយ ។ មានរបាយការណ៍ជាច្រើនដែលអះអាងថា ប៉ូលីសបានបំពានលើស្ត្រីរកស៊ីផ្លូវភេទ ។ បើទោះបីជាមានការបង្រ្កាបម្តងម្កាលលើផ្ទះមេបននៅទីក្រុងភ្នំពេញ ក៏ដោយ អំពើពេស្យាចារ និងការជួញដូរមនុស្សដោយខុសច្បាប់នៅតែមាន ។ ចំនួនស្ត្រីរកស៊ីផ្លូវភេទមានប្រមាណពី ១៤.៧២៥ ទៅ ១៨.២៥០ ។ ទេសចរណ៍ផ្លូវភេទជាបញ្ហាមួយដែលកើតឡើង ដោយសារភាពក្រីក្រនៅគ្រប់ទិសទី និងទស្សនៃនិទណ្ឌភាព ។ ច្បាប់ការងារផ្តល់នូវការការពារប្រឆាំងនឹងការយាយីផ្លូវភេទនៅកន្លែងធ្វើការ ប៉ុន្តែមិនបានបញ្ជាក់ឱ្យបានច្បាស់អំពី ស្ថានទម្ងន់ទោស ។ អង្គការពលកម្មអន្តរជាតិ ILO បានរាយការណ៍ថា កម្រមានការយាយីផ្លូវភេទនៅខាងផ្នែកឧស្សាហ៍កម្មណាស់ ។ រដ្ឋធម្មនុញ្ញចែងច្បាស់លាស់ អំពីការផ្តល់សិទ្ធិស្មើគ្នាសំរាប់ស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ។ ក្នុងការអនុវត្តជាក់ស្តែង ស្ត្រីមានសិទ្ធិស្មើគ្នាលើទ្រព្យសម្បត្តិ មានឋានៈស្របច្បាប់ដូចគ្នាក្នុងការធ្វើនីតិវិធីលែងលះ និងមានសិទ្ធិដូចគ្នានិងបុរសដែរក្នុងការទទួលបាននូវការអប់រំ និងមុខរបរ ផ្សេងៗ ។ ប៉ុន្តែទោះបីជាយ៉ាង

ណាក៏ដោយ ប្រពៃណីវប្បធម៌នៅតែបន្តរារាំងស្ត្រីក្នុងការឈានទៅដល់មុខតំណែងជាន់ ខ្ពស់ក្នុងអាជីវកម្ម និងវិស័យផ្សេងៗទៀត ។ ស្ត្រីភាគច្រើន ត្រូវបានគេរំពឹងគិតលើការងារដែលទទួលបានប្រាក់កម្រៃ ទាប និងត្រូវបានគេដកហូតពីតំណែងជាអ្នកគ្រប់គ្រង ។ បុរសភាគច្រើន មានសំលេងលើសលប់ខាងផ្នែកយោធា ប៉ូលីស និងស៊ីវិល ។

ក្រសួងកិច្ចការនារីត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បីការពារសិទ្ធិស្ត្រី និងលើកស្ទួយនូវសមធម៌រវាងបុរស និងស្ត្រីនៅក្នុងសង្គម ដោយបន្តកម្មវិធីនារីរតនៈរបស់ខ្លួន ។ កម្មវិធីនេះមានគោលបំណងដើម្បីបង្កើន វត្តមានស្ត្រីតាមរយៈការ តម្រង់ទិសនៃសមធម៌រវាងបុរស និងស្ត្រី ដោយជំរុញឱ្យស្ត្រីចូលរួមក្នុងជីវិតសេដ្ឋកិច្ច និងនយោបាយ និងបង្កើនការ ការពារសិទ្ធិស្ត្រី ។

**កុមារ**

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់កុមារ ហើយរដ្ឋាភិបាលបានធ្វើឱ្យសុខមាលភាពកុមារក្លាយជាគោលដៅដ៏ជាក់លាក់មួយ ។ រដ្ឋាភិបាលបានពឹងផ្អែកលើមូលនិធិអន្តរជាតិ ដើម្បីឧបត្ថម្ភកម្មវិធីជាច្រើនដែលទាក់ទិនសុខមាលភាពកុមារ ហើយជាលទ្ធផលមានតែមូលនិធិដ៏សមស្របប៉ុណ្ណោះសំរាប់ដោះស្រាយនូវបញ្ហាផ្សេងៗ ដែលមានឥទ្ធិពលលើកុមារ ។

ក្នុងឆ្នាំ២០០២ រដ្ឋាភិបាលបានបង្កើតប្រព័ន្ធចុះសំបុត្រកំណើតទំនើបមួយ ដែលគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ដោយបានរាយការណ៍ឱ្យដឹងថា កម្មវិធីនេះបានចុះសំបុត្រកំណើត ៩១ភាគរយដោយជោគជ័យ ក្នុងឆ្នាំ២០០៦ ។ ប្រព័ន្ធនេះមិនបានរាប់បញ្ចូលនូវការជ្រាបចូលជាពិសេសទៅដល់សហគមន៍ជនជាតិភាគតិចទេ ។ រដ្ឋាភិបាលខកខាន មិនបានចុះសំបុត្រកំណើតនោះទេដែលនាំឱ្យមានការរើសអើង រួមទាំងការច្រានចោលនូវសេវាសាធារណៈជាដើម ។ ការសិក្សាមួយស្តីពីអ្នកដែលមិនមែនជាប្រជាពលរដ្ឋរបស់ប្រទេស ដែលធ្វើឡើងដោយ ឧត្តមស្នងការជាន់ខ្ពស់បន្ទុក ជនភាសខ្លួនរួ ណះជះ បានបញ្ជាក់ថា នីតិវិធីចុះសំបុត្រកំណើតជារឿយៗ មិនរាប់បញ្ចូលកុមារជនជាតិភាគតិច និង អ្នកទាំងឡាយដែលមិនមែនជាពលរដ្ឋកម្ពុជា ។ អង្គការក្រៅរដ្ឋាភិបាលដែលផ្តល់សេវាដល់សហគមដែលគ្មានសិទ្ធិក្នុង ការបោះឆ្នោត បានរាយការណ៍ថា កុមារដែលមិនបានចុះសំបុត្រកំណើតជារឿយៗមិនទទួលបាននូវការអប់រំ និងការ ថែទាំសុខភាព ។ អង្គការទាំងនោះបន្ថែមទៀតថា ពេលអនាគតបុគ្គលដដែលនោះប្រហែលជាមិនអាចទទួលបាននូវ ឱកាសការងារ កម្មសិទ្ធិផ្ទាល់ខ្លួន ការបោះឆ្នោត និងប្រើប្រព័ន្ធច្បាប់ ។ កុមារបានរងគ្រោះផ្សេងៗគ្នាដោយសារប្រព័ន្ធ អប់រំមិនទាន់សមស្រប ។ ការអប់រំគឺមិនគិតប្រាក់ ប៉ុន្តែមិនទាន់ក្លាយជាកាតព្វកិច្ចចាំបាច់ រហូតដល់ថ្នាក់ទី៩ ។ កុមារជាច្រើនបានបោះបង់ចោលការសិក្សាដើម្បីជួយដល់គ្រួសាររបស់ពួកគេក្នុងការប្រកបរបរកសិកម្មចិញ្ចឹមជីវិត ខ្លះទៀតបានចូលសាលានៅពេលមានអាយុច្រើន ឬមិនបានចូលសាលាសោះក៏មានដែរ ។ ក្នុងឆ្នាំ២០០៥ ក្រសួងអប់រំបានឱ្យ ដឹងថមានកុមារដែលមានសិទ្ធិចូលរៀន ៩១ភាគរយ ត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះចូលរៀននៅបឋមសិក្សា ប៉ុន្តែតួ លេខនេះមិនបានឆ្លុះបញ្ចាំងអំពីការចូលរៀនទេ ។ បន្ទាប់ពីសាលាបឋមសិក្សាមក មានសិស្ស ២៦ភាគរយដែលមាន សិទ្ធិបានចូលអនុវិទ្យាល័យ និង៩ភាគរយបានចូលវិទ្យាល័យ ។ បើទោះបីជាមានកម្មវិធីស្ថាបនាសាលារៀនក៏ដោយ ថ្នាក់រៀនភាគច្រើនមានចំនួនសិស្សច្រើនលើសលុប និងមិនមានបរិក្ខាសិក្សាគ្រប់គ្រាន់ និងសមស្រប ។ តាមជនបទ សាលាជារឿយៗផ្តល់ការបណ្តុះបណ្តាលត្រឹមតែពីបីឆ្នាំប៉ុណ្ណោះ ។ តាមរយៈទិន្នន័យរបស់ក្រសួងអប់រំ មានសាលារៀន ៤៦ភាគរយខ្វះទឹកស្អាតសំរាប់បរិភោគ និងគ្មានបង្គន់ ។ ប្រាក់ខែគ្រូបង្រៀនមិនត្រូវបានបើកឱ្យបានទៀងទាត់ និងមិន គ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ជីវភាពឱ្យបានសមរម្យ ដែលតម្រូវឱ្យឪពុកម្តាយបង់ប្រាក់ក្រៅ

ផ្លូវការ ដែលគ្រួសារក្រីក្រជាច្រើន មិនមានលទ្ធភាព ។ រដ្ឋាភិបាលផ្តល់សិទ្ធិដល់កុមារីស្មើគ្នានិងកុមារាដែរ ក្នុងការទទួលបាននូវការអប់រំ ប៉ុន្តែគ្រួសារ ដែលមានធនធានខ្សត់ខ្សោយ ជារឿយៗផ្តល់អាទិភាពដល់កុមារា ។ នៅក្នុងតំបន់ជាច្រើនសាលារៀនឋិតនៅឆ្ងាយពីផ្ទះ ហើយមធ្យោបាយធ្វើដំណើរគឺជាបញ្ហាចោទ ។ កត្តានេះបានជះឥទ្ធិពលពិសេសដល់កុមារី ដោយសារតែការព្រួយបារម្ភណ៍ពីសុវត្ថិភាពក្នុងការធ្វើដំណើររវាងផ្ទះ និងសាលារៀន ។ កុមារា និងកុមារីមាន សិទ្ធិស្មើគ្នា ក្នុងការទទួលបាននូវការថែទាំសុខភាពពីរដ្ឋ ។
ការបំពានលើកុមារជារឿងសាមញ្ញ បើទោះបីជាគ្មានស្ថិតិជាក់លាក់ក៏ដោយ ។ ការរំលោភកុមារនៅតែជាបញ្ហាដ៏ ធ្ងន់ធ្ងរ ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក បានរាយការណ៍ថា មានការចាប់រំលោភ និងការរំលោភដែលប៉ុនប៉ងទុក មុន ចំនួន ១៩៩ករណី ដែលប្រព្រឹត្តលើកុមារមានអាយុក្រោម ១៨ឆ្នាំ ដែលក្នុងនោះមានពីរករណីស្លាប់ ។ ២៩ករណី ទាក់ទិននិងកុមារមានអាយុក្រោម ៥ឆ្នាំ ។ ការរួមភេទជាមួយកុមារក្រោម ១៥ឆ្នាំ ជារឿងខុសច្បាប់ ទោះជាយ៉ាងនេះ ក៏ដោយនៅតែមានពេស្យាចារលើកុមារ និងការជួញដូរកុមារ ។ អំឡុងពេលការសំរុកចូលផ្ទះបនប៉ុន្មានឆ្នាំមកនេះ សង្គ្រោះបានក្មេងស្រីមិនទាន់គ្រប់អាយុជាច្រើន ដែលត្រូវបានជួញដូរដើម្បីធ្វើពេស្យាចារ ។ ក្រសួងមហាផ្ទៃបាន រាយការណ៍ឱ្យដឹងថា ចាប់បានជនភេទទីបីបរទេសចំនួន ប្រាំពីរនាក់ ។ កុមារខ្លះទៀតបានប្រឡូកក្នុងពេស្យាចារ ដើម្បី រកប្រាក់កម្រៃចិញ្ចឹមជីវិត ដោយមិនមានជាប់ទាក់ទិននិង ភាគីទីបីទេ ។

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយបានប៉ាន់ស្មានថា មានកុមារតាមចិញ្ចើមថ្នល់ជាង ១.២០០ នាក់ នៅក្នុងទីក្រុង ភ្នំពេញដែលគ្មានទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ ហើយមានកុមារជាង ១០.០០០ នាក់បានធ្វើការងារតាម ដងផ្លូវ ដោយមិនត្រឡប់ទៅគ្រួសារនៅពេលល្ងាច ។ មានកុមារប្រមាណជា ៥០០ ទៅ ១.៥០០ នាក់បានរស់នៅជាមួយក្រុមគ្រួសាររបស់ពួកគេនៅតាម ចិញ្ចើមថ្នល់ ក្នុងតំបន់ទីប្រជុំជនទីរួមខេត្តនានា ។ ក្រសួងសង្គមកិច្ច និងស្តារយុវ នីតិសម្បទាបានផ្តល់ស្ថិតិទាបជាងនេះដោយរាយការណ៍ថា មានកុមារតាមចិញ្ចើមថ្នល់ ៣.០៨៤ នាក់ទូទាំងប្រទេសក្នុងឆ្នាំ២០០៥ ។

ការសិក្សាមួយដែលធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកបានបញ្ជាក់ថា ក្នុងខែកញ្ញា ២០០៦ មានកុមារក្រោមអាយុ ប្រាំមួយឆ្នាំ ៣៧នាក់ កំពង់រស់នៅជាមួយម្តាយរបស់គេក្នុងពន្ធនាគារ ហើយកុមារទាំងនោះរងនូវការធ្វើ បាបពីឆ្មាំគុក និងប្រឈមមុខទៅនឹងការរងរបួសរាង្គកាយពីក្រុមឧក្រិដ្ឋជនពេញវ័យដែលស្នាក់នៅក្នុងបន្ទប់ជាមួយ ។ ជាទូទៅកុមារខ្វះជីវជាតិអាហារ និងការអប់រំឱ្យបានសមស្រប ។ ពលកម្មកុមារជាបញ្ហាក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ ។

**ការជួញដូរមនុស្ស**

ច្បាប់ហាមឃាត់មិនឱ្យមានការជួញដូរមនុស្ស ប៉ុន្តែប្រទេសកម្ពុជាជាប្រភព ជាទិសដៅ និងជាកន្លែងឆ្លងកាត់ដែល បុរស ស្ត្រី និងកុមារត្រូវបានគេធ្វើចរាចរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម ។ ការសិក្សាមួយនៅ ឆ្នាំ២០០៣ បាន ប៉ាន់ប្រមាណថា មានជនរងគ្រោះដែលត្រូវបានជួញដូរក្នុងឧស្សាហកម្មផ្លូវភេទចំនួន ២.០០០ នាក់ ក្នុងនោះមាន ៨០ ភាគរយ ជាស្ត្រី និងក្មេងស្រីជនជាតិវៀតណាម ។ កុមារត្រូវបានគេធ្វើចរាចរណ៍ក្នុងស្រុក ដើម្បី កេងប្រវ័ញ្ចផ្លូវភេទ និងពលកម្ម ។ មាន ស្ត្រី និងកុមារីជនជាតវៀតណាមខ្លះត្រូវបានគេជួញដូរតាមរយៈប្រទេសនេះ ក្នុងអាជីវកម្មពាណិជ្ជកម្មផ្លូវភេទនៅក្នុងប្រទេស

ផ្សេងៗ ទៀតនៅអាស៊ី ។ កុមារត្រូវបានគេចរាចរចូលទៅកាន់ប្រទេសថៃ និងវៀតណាម ដើម្បីឱ្យសុំទាន រែអង្គាសប្រាក់លក់ដូរតាមចិញ្ចើម ថ្នល់ និងលក់ផ្កាជាដើម ។ កុមារជារឿយៗត្រូវបានក្លាយទាសករនៃបំណុល ដែលត្រូវគេបង្ខំឱ្យសុំទានលក់ដូរ អីវ៉ាន់ ឬគេបង្កើតជាផ្នែកមួយនៃសមាជិកក្រុមអ្នកសុំទានដែលចាត់តាំងឡើង សូមបីនៅពួកគេមិនមានជាប់ទាក់ទិននឹង បំណុល ឬផលលំបាកខាងសេដ្ឋកិច្ចក៏ដោយ ។ ស្ត្រី និងកុមារត្រូវបានជួញដូរទៅប្រទេស ម៉ាឡេស៊ី និងថៃក្នុងបំណង ទាញផលចំណេញខាងផ្លូវភេទ និងបង្ខំឱ្យធ្វើការក្នុងរោចចក្រ ឬជាអ្នកបំរើតាមផ្ទះ ខណៈដែលបុរសត្រូវបានជួញដូរ ដើម្បីបង្ខំឱ្យធ្វើការខាងផ្នែកកសិកម្ម នេសាទ និងសំណង់ ។

ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជាពិសេសអ្នកដែលត្រូវបានគេជួញដូរដើម្បីកេងប្រវ័ញ្ចផ្លូវភេទ ប្រឈមទៅនឹងគ្រោះថ្នាក់នៃការឆ្លងកាមរោគ រួមមានមេរោគអេដស៍ជាដើម ។ ក្នុងករណីខ្លះទៀត ជនរងគ្រោះត្រូវបានគេបង្ខំ រួមទាំងត្រូវគេធ្វើបាបទាំងផ្លូវចិត្ត និងផ្លូវកាយពីសំណាក់ក្រុមជួញដូរមនុស្ស មេបន និងភ្ញៀវ ។

អ្នកជួញដូរមនុស្សក្នុងស្រុកបានក្តោបតំបន់ភូមិសាស្ត្រតូចៗជាក់លាក់មួយចំនួន និងដើរតួជាឈ្មួញកណ្តាលសំរាប់ប្រព័ន្ធជួញដូរទ្រង់ទ្រាយធំៗ ។ ក្រុមឧក្រិដ្ឋកម្មដែលបានរៀបចំទុក ភ្នាក់ងារជួយរកការងាររួមទាំងមេអណ្តើកផងដែរ ត្រូវបានគេជឿថាមានជាប់ទាក់ទិនក្នុងអំពើជួញដូរមនុស្សនេះ ។ ជនល្មើសបានប្រើវិធីសាស្ត្រច្រើនយ៉ាង ដើម្បីទទួល បានជនរងគ្រោះ ។ ក្នុងករណីជាច្រើន ជនរងគ្រោះត្រូវបានលោងលោមទៅតាមការសន្យារកការងារស្របច្បាប់ ឬឯកសារធ្វើដំណើរ ។ ម្យ៉ាងវិញទៀត អ្នកដែលស្គាល់គ្នាមិត្តភ័ក្រ និងសមាជិកគ្រួសារបានលក់ជនរងគ្រោះ ឬទទួលបានប្រាក់កំរៃចំពោះការជួយបោកប្រាស់ពួកគេ ។ កុមារក្មេងៗភាគច្រើននៃពួកគេជាក្មេងស្រី ជារឿយៗត្រូវបានឪពុក-ម្តាយដែលក្រីក្រអស់សង្ឃឹមក្នុងឆាកជីវិត កំណត់ថាជារបស់មួយដែលបញ្ចាំទុកសំរាប់ជាការដោះបំណុល ហើយកូនៗទាំងនោះត្រូវទទួលខុសត្រូវចំពោះការសងបំណុល និងការប្រាក់ដែលកើនឡើង ។ របាយការណ៍មួយក្នុងខែ កញ្ញាដែលធ្វើ ឡើងដោយអង្គការអន្តោប្រវេសន៍អន្តរជាតិ (IOM) បានថ្លែងថាកម្មករដែលជាកុមារនៅក្នុងស្រុក ជាពិសេសក្មេងដែលត្រូវបាន គេប្រើជាមនុស្សបញ្ចាំ ឬផ្ញើទុកដើម្បីលោះបំណុល ភាគច្រើនទំនងជាត្រូវបានគេជួញដូរ និងស្ថិតក្នុងសកម្មភាពកេងប្រវ័ញ្ច អាជីវកម្មផ្លូវភេទ ។ ច្បាប់បានចែងកាត់ទោសដាក់ពន្ធនាគារ ពី១៥ ទៅ២០ឆ្នាំចំពោះជនដែលត្រូវបានគេកាត់ទោសពីបទជួញដូរ មនុស្សដែលមានអាយុ ក្រោម១៥ឆ្នាំទោសបញ្ញត្តិគឺពី ១០ទៅ១៥ ឆ្នាំចំពោះការជួញដូរមនុស្សដែលមានអាយុ១៥ឆ្នាំ ឬលើស ។ យោងតាមក្រសួងមហាផ្ទៃបានឱ្យដឹងថា ប៉ូលីសបានធ្វើការស៊ើបអង្កេតចំនួន ៥២៩ករណីអំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីនិងកុមារ រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ការរំលោភ អំពើអនាចារ និងការជួញដូរមនុស្ស ។ ការស៊ើបអង្កេតនេះ នាំឱ្យមានការចាប់ខ្លួនជនល្មើសចំនួន ៥៨២នាក់ដែលក្នុងចំណោមជនទាំងនោះ ៨៦នាក់ត្រូវបានចាប់ខ្លួនពីបទជួញដូរមនុស្សឆ្លង ដែននិងនៅក្នុងប្រទេស ។ ទោះជាយ៉ាងណាក្តី អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានបន្តរាយការណ៍អំពីការខកខានមិនបានអនុវត្ត ច្បាប់ជាទូទៅ និងអំពីមន្ត្រីរដ្ឋាភិបាល ដទៃទៀតដែលដើរតួជាអ្នកផ្តល់ដំណឹង ។ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារីក្រសួង យុត្តិធមិមានការទទួលខុសត្រូវជាចំបង ដើម្បីប្រឆាំងនឹងការជួញដូរមនុស្ស ។ នៅខែមេសា រដ្ឋាភិបាលបានបង្កើតក្រុមការងារ ជាតិឱ្យធ្វើជាស្ថាប័នសំរបសំរួលអន្តរក្រសួងប្រឆាំងនឹងការជួញដូរមនុស្ស ។ ក្រុមការងារនេះ រួមមានស្ថាប័នត្រួតពិនិត្យពាក់ព័ន្ធ នឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ទៀតផង ។ មាននាយកដ្ឋានមួយប្រឆាំងនឹងការជួញដូរមនុស្ស និងការពារអនីតិជនហើយក្រសួង មហាផ្ទៃបានធ្វើប្រតិបត្តិការបែងចែកតាមឯកទេសប្រឆាំងនឹងការជួញដូរមនុស្សនៅ

គ្រប់ខេត្ត-ក្រុងទាំងអស់។ ក្នុងខណៈដែល រដ្ឋាភិបាល បានចាប់ខ្លួន និងកាត់ទោសអ្នកជួញដូរមនុស្ស និងបន្តធ្វើការគាំទ្រកម្មវិធីរបស់ខ្លួន ទប់ស្កាត់ និងការការពារបញ្ហាទាំង នេះតាមរយៈធ្វើកិច្ចសហការជាមួយនឹងអង្គការក្នុងស្រុកអង្គការបរទេស និងអង្គការអន្តរជាតិ។ ការប្រឹងប្រែងប្រឆាំងនឹងការជួញដូរមនុស្សរបស់ក្រសួង បានបន្តដោយមានការរារាំងដោយអំពើពុករលួយ និងប្រព័ន្ធតុលា ការដែលចុះខ្សោយ។ គេជឿជាក់ដោយ ទូលំទូលាយថា ការអនុវត្តច្បាប់ខ្លះ និងមន្ត្រីរដ្ឋាភិបាលដទៃទៀតបានទទួលសំណូកដែល សំរួលដល់ការជួញដូរផ្លូវភេទ និងការ ជួញដូរមនុស្ស។នៅថ្ងៃទី ១៦ខែមិនា តុលាការក្រុងព្រះសីហនុបានឱ្យម្ចាស់ផ្ទះសំណាក់ អូរ ២ និងនិយោជិតទាំងអស់រួចខ្លួនពីបទ ចោទប្រកាន់ទាំងឡាយ និងបានកាត់ទោសនិយោជិតផ្សេងទៀតពីបទល្មើសរងនៃសញ្ចារកម្ម និងបានកាត់ទោសឱ្យជាប់ពន្ធនាគារ រយៈពេល២ ឆ្នាំ បូកបន្ថែមនឹងទោសព្យួររយៈពេល៣ឆ្នាំទៀត។ អាកប្បកិរិយាប្រែប្រួលរបស់មន្ត្រីក្នុងអំឡុងពេលសវនាការ និងទោស បញ្ញត្តិដែលស្រាល បានធ្វើឱ្យមានការបារម្ភថា មានការដោះដូរសំណូកជាថ្នូរនឹងការវិនិច្ឆ័យរឿងក្តីនោះឱ្យបានស្រាល។

នៅថ្ងៃទី២១ ខែមិនា តុលាការក្រុងភ្នំពេញបានឱ្យម៉េង សាយ អតីតប្រធានអង្គភាពនគរបាលក្រុងភ្នំពេញប្រឆាំងការជួញដូររួចខ្លួន ដែលត្រូវបានគេព្យួរទោសនៅឆ្នាំ ២០០៦ ពីបទជំរិតទារប្រាក់ពីជនជាតិកូរេខាងត្បូង។ មន្ត្រីប៉ូលីសម្នាក់ស្ថិតនៅក្នុងពន្ធនាគារ ដោយសារជាប់ពាក់ព័ន្ធនឹងករណីតុលាការក្រុងភ្នំពេញឆ្នាំ ២០០៦អំពីនាយប៉ូលីស ៣រូបត្រូវបានតុលាការកាត់ទោសជាប់ពន្ធនាគាររយៈពេលពី ៥ ទៅ៧ឆ្នាំចំពោះអំពើពុករលួយទាក់ទងនឹងការជួញដូរមនុស្ស។ មន្ត្រី២រូបក្នុងចំណោមពួកគេ បានប្តឹងឧទ្ធរណ៍ចំពោះរឿងក្តីរបស់គេ។ គ្មានសកម្មភាពរបស់តុលាការចំពោះការប្តឹងឧទ្ធរណ៍នេះទេ ហើយមន្ត្រី២រូបនេះទៀតសោត ក៏មិនទាន់បានចាប់ផ្តើមជាប់ទោសនៅឡើយដែរ។

នៅថ្ងៃទី១ សីហា តុលាការក្រុងព្រះសីហនុ បានបើកសវនាការរឿងក្តីសញ្ចារកម្ម ក៏ប៉ុន្តែឱ្យជនសង្ស័យរួចខ្លួន ដោយផ្អែកលើភស្តុតាងមិនគ្រប់គ្រាន់។ អ្នកអង្កេតការណ៍ បានរាយការណ៍អំពីភាពមិនប្រក្រតីនៅក្នុងសវនាការរឿងក្តីនេះ ហើយរឿងក្តីនេះស្ថិតនៅក្រោមការប្តឹងឧទ្ធរណ៍នៅចុងឆ្នាំនោះ។

នៅថ្ងៃទី ៩សីហា ព្រះរាជក្រឹត្យ បានបង្គាប់មកឧត្តមក្រុមប្រឹក្សាអង្គចៅក្រមបណ្តេញប្រធានសាលាឧទ្ធរណ៍ លី វួច ឡេង។ សេចក្តីសំរេចនោះ ត្រូវបានចេញដោយសារមានការចោទប្រកាន់ថា ប្រធានសាលាឧទ្ធរណ៍នោះ បានទទួលសំណូកជាថ្នូរ នឹងការដោះលែងជនល្មើសជួញដូរមនុស្សដែលបើកផ្ទះបនឆាយ ហ៊ូ ២នៅទីក្រុងភ្នំពេញ។ មន្ត្រីនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រមចំនួន ៣រូបក៏ត្រូវបានគេដកចេញដោយសារការជាប់ទាក់ទងនឹងរឿងក្តីនោះដែរ ហើយចៅក្រមសាលាឧទ្ធរណ៍ ៣រូប និងព្រះរាជអាជ្ញារងម្នាក់បានទទួលលិខិតស្តីបន្ទោសជា ផ្លូវការ។ លី វួចឡេងត្រូវបានគេផ្ទេរទៅកាន់តំណែងដែលគេមិនបានដឹងនៅក្រសួងយុត្តិធម៌។ គ្មានបទចោទណា មួយត្រូវបានធ្វើប្រឆាំងនឹងរូបអ្នកស្រីទេ។ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ បានរាយការណ៍ថា ការស៊ើបអង្កេតរបស់គេ បាន បន្ត។ អង្គការក្រៅរដ្ឋាភិបាលតស៊ូមតិផ្នែកច្បាប់មួយ បានរាយការណ៍ថា ករណីជួញដូរមនុស្សចំនួន៥បានបញ្ជូនទៅបើកសវនា ការក្នុង អំឡុងឆ្នាំនេះ ដែលនាំឱ្យមានការកាត់ទោសមនុស្ស២នាក់។ នៅពេលដំណាល គ្នានេះដែរ ក្រសួងមហាផ្ទៃ បានរាយការណ៍ ថាការកាត់ទោសមនុស្ស ៥នាក់ពីបទចោទជួញដូរមនុស្សដែលមានការកាត់ឱ្យជាប់ពន្ធនាគារចាប់ពី ៤ ទៅ ១៥ឆ្នាំ។ តុលាការ ក្រុងភ្នំពេញ បានរាយការណ៍អំពីការកាត់ទោសជនល្មើសជួញដូរមនុស្ស ៤៩នាក់ពីខែមករាមកទល់ខែ តុលា។ ជារឿយៗ ប៉ូលីស មន្ត្រីតុលាការ និងចៅក្រមមិនបានបំបែកជនរងគ្រោះពីជនល្មើសក្នុងកំឡុងការឆ្លក់ចូលការចាប់ខ្លួន និងនៅពេលសវនាការនោះទេ។ នៅក្នុងករណីខ្លះមន្ត្រីទាំងនោះ បាននិយាយនិងដើរតួ ហាក់បីដូចជាជនរងគ្រោះនោះជាជនល្មើសវិញ។ នៅកំឡុង ថ្ងៃទី ៩ខែមិនា សវនាការជួញដូរមនុស្សនៅក្រុងព្រះសីហនុ

ចៅក្រមជំនុំជំរះបាននិយាយសំដីខ្លាំងទៅកាន់ជនរងគ្រោះដោយ សារការជួញដូរដែលមិនទាន់គ្រប់អាយុនៅក្នុងបន្ទប់តុលាការ និងបានឱ្យជនល្មើស២រូបដែលបានចោទប្រកាន់នោះរួចខ្លួន ។

ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា (MOSAVY) បានបញ្ជូនជនរងគ្រោះនៃការជួញដូរទៅអង្គការក្រៅរដ្ឋាភិបាលនានា ដែលផ្តល់ជំនួយយ៉ាងច្រើនបំផុតដល់ជនរងគ្រោះ ។  រាជរដ្ឋាភិបាល បានចូលរួមជាដៃគូរក្នុងកិច្ចប្រឹងប្រែងលើបញ្ហាមួយចំនួន តែទោះជាយ៉ាងណាក្តី ការវិភាគទានរបស់រដ្ឋាភិបាល ត្រូវបានរារាំងយ៉ាងធ្ងន់ធ្ងរដោយសារធនធានមានកំណត់ ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនផ្តល់សេវាកម្មសំរាំងយកជនដែលមានអត្តសញ្ញាណជាជនរងគ្រោះនៃការជួញដូរពិតប្រាកដ ។ ជនរងគ្រោះខ្លះត្រូវបានអង្គការក្រៅរដ្ឋាភិបាលជាច្រើន និងក្រសួងយុត្តិធម៌ ជំរុញលើកទឹកចិត្តដើម្បីឱ្យពួកគេដាក់ពាក្យ បណ្តឹងប្រឆាំងនឹងជនល្មើសក៏ប៉ុន្តែនៅក្នុងបរិយាកាសទូទៅនៃនិទណ្ឌភាព ការការពារជនរងគ្រោះគឺជាបញ្ហា ហើយជនរងគ្រោះ ត្រូវបានគេដឹងថាទទួលរងនូវការគំរាមកំហែងឱ្យលះបង់ចោលរឿងក្តីរបស់ខ្លួន ។  ស្លាកស្នាមទុរយស៍ក្នុងសង្គមប្រឆាំងនឹងស្ត្រីដែល ជាស្រីពេស្យាជនរងគ្រោះនៃការបំពានផ្លូវភេទ ឬជនរងគ្រោះនៃការជួញដូរផ្លូវភេទ ធ្វើឱ្យមានការលំបាកដល់ជនរងគ្រោះក្នុងការចូលរួមជាមួយគ្រួសារសហគមន៏ និងសង្គមជាតិវិញ ។ ច្បាប់ប្រឆាំងនឹងការជួញដូរ មិនមានបញ្ញត្តិណាការពារជនរងគ្រោះបរទេសពីការដែលត្រូវបានចោទប្រកាន់តាមច្បាប់អន្តោប្រវេ សន៏ទេ  ប៉ុន្តែក្នុងកំឡុងឆ្នាំនោះ គ្មានករណីណាដែលត្រូវបានរាយការណ៏អំពីជនរងគ្រោះនៃការជួញដូរនោះថាជាជនអន្តោប្រវេសន៏ ខុសច្បាប់នោះទេ ។   ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទាបានធ្វើការជាមួយនឹងអង្គការអន្តោប្រវេសន៏អន្តរជាតិ (IOM) ដើម្បី ធ្វើមាតុភូមិនិវត្តន៏ជនរងគ្រោះនៃការជួញដូរទាំងនោះពីប្រទេសថៃ និងវៀតណាមមកកាន់ប្រទេសកម្ពុជា និងពីកម្ពុជាទៅវៀត ណាមវិញ ។  តែទោះជាយ៉ាងនេះក៏ដោយ ការធ្វើមាតុភូមិនិវត្តន៏ទៅកាន់ប្រទេសវៀតណាមនៅតែឱ្យមានដំណើរការយូរ និងមានការលំបាក ។ ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទាបានធ្វើមាតុភូមិនិវត្តន៏ជនរងគ្រោះជាកុមារ និងក្មេងជំទង់ចំនួន៨៤៥នាក់ និងជនទន់ខ្សោយដទៃទៀតដែលក្លាយជាជនរងគ្រោះផងដែរពីប្រទេសថៃ  វៀតណាម និងប្រទេសម៉ាឡេស៊ី និងធ្វើសមាហរ័ណកម្មដល់ពួក គេឱ្យចូលទៅរួមរស់ជាមួយនឹងគ្រួសាររបស់គេវិញ ។ ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការអន្តោប្រវេសន៏ អន្តរជាតិ  (IOM) និង (MOSAVY) បានធ្វើមាតុភូមិនិវត្តន៏ក្មេងស្រីវៀតណាមដែលត្រូវបានគេជួញដូរចំនួន ៨នាក់ឱ្យត្រឡប់ ទៅវៀតណាមវិញ ។ ទាំងម្ចាស់ជំនួយរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិ មានកម្មវិធីទប់ស្កាត់ពលកម្មកុមារ ឬក៏រំដោះកុមារពីពលកម្ម ។  ប្រទេសកម្ពុជា គឺជាប្រទេសដែលបានចុះហត្ថលេខីទៅលើគំនិតផ្តួចផ្តើមសំរបសំរួលតាមទន្លេមេគង្គរបស់ក្រសួងប្រឆាំងនឹងការជួញ ដូរដែលសកម្មភាពរបស់ខ្លួន រួមមានការធានានូវការការពារផ្នែកច្បាប់ នៅក្នុងសង្គម និងសហគមន៏ដល់ជនរងគ្រោះនៃការជួញដូរពង្រឹងសមត្ថភាពនៃការអនុវត្តន៏ច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងបង្កើតនូវការឆ្លើយតបដែលមានការយល់ដឹងមួយ
ទាក់ទិនដល់ក្រសួងដែលពាក់ព័ន្ធទាំងអស់ ។   ក្រសួងមួយចំនួន រួមទាំងក្រសួងកិច្ចការនារី និងក្រសួងទេសចរណ៏ដែលមានគំនិតផ្តួចផ្តើមប្រឆាំងនឹងការជួញដូរមនុស្ស ដើម្បីកាត់បន្ថយពលកម្មកុមារ ។   ម្យ៉ាងវិញទៀត ម្ចាស់ជំនួយបានគាំទ្រកម្មវិធីទាំងឡាយដើម្បីប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារដែលត្រូវបានអនុវត្តដោយអង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការអប់រំពិភពលោក (World Education) ។ ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា បានធ្វើការជាមួយនឹងអង្គការមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF) និង អង្គក្រៅរដ្ឋាភិបាលនៅក្នុងស្រុកជាច្រើនទៀត ដើម្បីគ្រប់គ្រងបណ្តាញការងារដែលមានមូលដ្ឋាននៅតាមសហគមន៏ក្នុងគោលបំ ណងទប់ស្កាត់ការជួញដូរមនុស្ស ។

**ជនពិការ**

គ្មានច្បាប់ណាដែលហាមឃាត់ដាក់លាក់ចំពោះការរើសអើងប្រឆាំងនឹងជនពិការនោះទេ ។ រដ្ឋាភិបាលមិនបានតំរូវឱ្យមានការបង្កើត ឬផ្តល់សេវាកម្មរបស់រដ្ឋាភិបាលទៅឱ្យជនពិការនោះឡើយ ។ រដ្ឋាភិបាល ហាមឃាត់ជនពិការ ពីការធ្វើជាគ្រូបង្រៀននៅក្នុងសាលាសាធារណៈ ។ នៅថ្ងៃទី ១ខែតុលា រដ្ឋាភិបាលបានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ ។ កម្មវិធីដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បាននាំមកនូវការកែលំអដ៏ច្រើនគួរសមនៅក្នុងការប្រព្រឹត្ត និងការស្តារឡើងវិញចំពោះជនដែលបានបាត់បង់អវៈយវៈប៉ុន្តែពួកគេបានប្រឈមមុខនឹងការរើសអើងក្នុងសង្គមដ៏ច្រើនសន្ធឹកសន្ធាប់ ជាពិសេស នៅក្នុងការទទួលបាននូវការងារជំនាញ ។ មិនមានការកំណត់ផ្នែកច្បាប់ទៅលើសិទ្ធិរបស់ជនពិការចំពោះការបោះឆ្នោត ឬការចូលរួមនៅក្នុងកិច្ចការរបស់ពលរដ្ឋនោះទេ  ប៉ុន្តែផ្ទុយទៅវិញ រដ្ឋាភិបាលមិនបានធ្វើការប្រឹងប្រែងរួមដើម្បីជួយពួកគេឱ្យក្លាយទៅជាពលរដ្ឋដែលមានការចូលរួមចំនែកច្រើន ថែមទៀតនោះឡើយ ។  ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទាទទួលខុសត្រូវចំពោះការធ្វើគោលការណ៍ ដើម្បីការពារសិទ្ធិរបស់ជនពិការ និងទទួលខុសត្រូវចំពោះការស្តារឡើងវិញការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈសំរាប់ជនពិការទាំងនេះ ។

**ជាតិ/ពូជសាសន៍/ជនជាតិដើមភាគតិច**

សិទ្ធិរបស់ជនជាតិដើមភាគតិច តាមច្បាប់សញ្ជាតិឆ្នាំ ១៩៩៦ មិនបានចែងច្បាស់ទេ ។ ការការពារតាមរដ្ឋធម្មនុញ្ញគ្របដណ្តប់ទៅលើតែប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះ ។ ចំនួនប្រជាពលរដ្ឋដែលជាជនជាតិភាគតិចចិន និងវៀតណាម បង្កើតបានជាជនជាតិដើមភាគតិចក្នុងចំនួនដ៏ធំរបស់ខ្លួន ។ ប្រជាពលរដ្ឋដែលជាជនជាតិចិនភាគតិច ត្រូវបានគេទទួលរាប់អាននៅក្នុងសង្គម ប៉ុន្តែការគុំគួនបានបន្តទៅលើជនជាតិភាគតិចវៀតណាមដែលត្រូវបានគេឃើញថាជាការគំរាមមួយដល់ប្រទេសជាតិ និងវប្បធម៌ ។ ក្រុមខ្លះនៅតែបន្តធ្វើសេចក្តីថ្លែងការណ៍ប្រឆាំងនឹងជនជាតិវៀតណាម ។ ពួកគេបានត្អូញត្អែរអំពីការគ្រប់គ្រងនយោបាយរបស់គណបក្សប្រជាជនកម្ពុជាដោយរដ្ឋាភិបាលវៀតណាម  ដូចជាបញ្ហាស្តីពីការទន្ទ្រានយកដីព្រំដែន និងបញ្ហាដទៃទៀតបញ្ហាទាំងនោះបង្ហាញថា យ៉ាងហោចណាស់ក៏ពួកគេឱ្យជនជាតិវៀតណាមភាគតិចនោះ ទទួលខុសត្រូវមួយចំណែកដែរ ។

**ជនអន្តោប្រាម**

ជារឿយៗ រដ្ឋាភិបាលតែងតែព្រងើយកន្តើយនឹងកិច្ចប្រឹងប្រែងដែលសហគមន៍អន្តោប្រាមបានខិតខំធ្វើដើម្បីការពារទឹកដីកំណើតដូនតា និងធនធានធម្មជាតិរបស់ពួកគេ ។ ថ្វីត្បិតតែមានច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលអំពាវនាវឱ្យមានការចុះបញ្ជីដីរួមរបស់ប្រជាជនអន្តោប្រាមក្តី ក៏ការអំពាវនាវនេះ ត្រូវបានធ្វើតិចតួចក្នុងការអនុវត្តន៍ផ្តល់ប័ណ្ណកម្មសិទ្ធិដីរួមនេះដែរ ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានអំពាវនាវឱ្យបញ្ឈប់ជាបណ្តោះអាសន្នចំពោះការលក់ដី និងការសម្បទានដីដែលមានការប៉ះពាល់ដល់សហគមន៍ជនអន្តោប្រាមទាំងនេះ ។ អង្គការជាតិនិងអន្តរជាតិ បានធ្វើសកម្មភាពយ៉ាងក្លៀវក្លាក្នុងការអប់រំសហគមន៍ជនអន្តោប្រាមអំពីសិទ្ធិកាន់កាប់ដីធ្លីរបស់គេ និងផ្តល់តំណាងការពារតាមផ្លូវច្បាប់នៅក្នុងជំលោះ ។ នៅថ្ងៃទី ៩ ខែមីនា ជនអន្តោប្រាមដែលរស់នៅក្នុងភូមិទាំងឡាយនៅខេត្តស្ទឹងត្រែងដែលមានចំនួនច្រើនជាង ២០០នាក់ បានធ្វើការតវ៉ាប្រឆាំង នឹងការឈូសឆាយដីព្រៃរបស់សហគមន៍ធ្វើឡើងដោយក្រុមហ៊ុនចំនួនបួន ដែលរដ្ឋាភិបាលត្រូវបានចោទប្រកាន់ថាបានផ្តល់សម្បទានព្រៃឈើ ឱ្យក្រុមហ៊ុនទាំងនោះដោយខុសច្បាប់ ។ ដីទាំងនោះត្រូវបានអ្នកភូមិជនអន្តោប្រាមប្រើជាយូរមកហើយសំរាប់ការដាំដុះចិញ្ចឹមជីវិត ធ្វើការ

បរបាញ់ និងយកផលិតផលជ័រឈើ ។ នៅខែឧសភា អាជ្ញាធរខេត្ត បានបង្កើតគណៈកម្មាធិការពិសេស ដើម្បីដោះស្រាយបញ្ហា ប៉ុន្តែគណៈកម្មាធិការនេះ មិនបានចាត់វិធានការណ៍ណាមួយទេ ។

នៅថ្ងៃទី ១៥ ខែមិនា គ្រួសារជនអន្តោប្រាមដើមកំណើតចារ៉ៃចំនួនជាង ៥០០គ្រួសារ នៅខេត្តរតនៈគិរី បានទាមទារឱ្យដកមន្ត្រីមូលដ្ឋានមួយចំនួនដែលតាមការចោទប្រកាន់ថាបានពាក់ព័ន្ធនៅក្នុងការលក់ដីបោកបញ្ឆោតឱ្យលក់ដី ដែលមានទំហំ ៣.០០០ ពាន់អានៃដី រួមរបស់ពួកគេ។ នៅខែកញ្ញា ឆ្នាំ ២០០៦ អ្នកភូមិទាំងនោះ បានដឹងថា ដីរបស់ពួកគេត្រូវបានលក់ នៅពេលដែលពួកគេបានឃើញកម្មករ ជីកកំណត់ព្រំដីទុកសំគាល់ជាទ្រព្យសម្បត្តិឯកជន ។ អ្នកភូមិទាំងនោះ ក៏បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរខេត្ត ប៉ុន្តែ អាជ្ញាធរមិនបានធ្វើការឆ្លើយតបនឹងបណ្តឹងរបស់គេទេ ។

នៅដើមខែសីហា មន្ត្រីខេត្តរតនៈគិរីបានរារាំងអ្នកភូមិជនអន្តោប្រាមដើមកំណើតទំពួន មិនឱ្យកប់សាកសពរបស់គ្នាគេនៅលើដីដែលបានយកមកធ្វើជាទីកន្លែងកប់សាកសពតាមប្រពៃណីជាយូរមកហើយតាំងពីឆ្នាំ ១៩៧៩ម្ល៉េះ ។ តុលាការខេត្តបានថ្លែងថាគេនឹងចាប់ខ្លួនជនណាដែលព្យាយាមកប់សាកសពនៅទីនោះ ដោយអះអាងថា ដីនេះជាកម្មសិទ្ធិរបស់ប្រធាននាយកដ្ឋានហិរញ្ញវត្ថុខេត្ត ។ អាជ្ញាធរបានដាក់កំណត់កន្លែងកប់សាកសពថ្មីមួយដែលមានទំហំប្រហែលជា ៥០០ យ៉ា ឆ្ងាយពីទីកប់សាកសពចាស់ដែលធ្លាប់មានតាមទំនៀមទំលាប់ប្រពៃណី ។ អ្នកភូមិទាំងនោះ បានទទូចសុំឱ្យអង្គការមិនរដ្ឋាភិបាលជួយខ្លួន និងមានផែនការដាក់ពាក្យបណ្តឹងទៅតុលាការខេត្ត ។

ក្នុងកំឡុងពេលរំឭកខួប ទិវាអន្តរជាតិសំរាប់ប្រជាជនអន្តោប្រាម នៅថ្ងៃទី៩ ខែសីហា ឧត្តមស្នងការអង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្ស បានកត់សំគាល់នូវការខកខានរបស់រាជរដ្ឋាភិបាល ក្នុងការការពារនិងអនុវត្តសិទ្ធិរបស់ជនអន្តោប្រាមដែលត្រូវទទួលបានដីរបស់ពួកគេ បូរណភាពដែនដី និងធនធានធម្មជាតិ ។ ឧត្តមស្នងការអង្គការសហប្រជាជាតិ បានអំពាវនាវសុំឱ្យមានការចាត់វិធានការណ៍ជាបន្ទាន់ ដើម្បីបញ្ឈប់ការចាប់យកដីនៅក្នុងតំបន់កុលសម្ព័ន្ធ ជាពិសេសការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលមានការរាលដាលយ៉ាងខ្លាំង និងការផ្តល់អាជ្ញាប័ណ្ណជិកយករ៉ែដោយគ្មានការពិគ្រោះយោបល់ពីសហគមន៍ ។

**ការរំលោភបំពានដ៏ទៃទៀតនៅក្នុងសង្គម និងការរើសអើង**

ការរើសអើងនៅក្នុងសង្គមប្រឆាំងនឹងអ្នកឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ នៅតែជាបញ្ហាមួយក្នុងតំបន់ជនបទ តែទោះជាយ៉ាងណាក្តី ការរើសអើងនេះ ត្រូវបានកាត់បន្ថយដោយកម្មវិធីយល់ដឹងមេរោគអេដស៍/ជម្ងឺអេដស៍ ។ មិនមានការរើសអើងជាផ្លូវការណាមួយប្រឆាំងនឹង អ្នកឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ទេ ។ គ្មានករណីណាដែលត្រូវបានគេរាយការណ៍ អំពីការរើសអើងទាក់ទងនឹងភេទដែលបង្ហាញឱ្យ ឃើញនៅក្នុងការងារ ផ្ទះសំបែង ភាពគ្មានរដ្ឋ ឬទទួលបានការអប់រំ ឬថែរក្សាសុខភាពឡើយ ។ ប៉ុន្តែការរួមភេទដូចគ្នាជាតួយ៉ាង ត្រូវបានគេប្រព្រឹត្តដោយមានការភ័យខ្លាច និងមន្ទិលសង្ស័យ ហើយមានក្រុមគាំទ្រមួយចំនួនតូចផ្តែកលើការបង្ហាញឱ្យឃើញទាក់ទងនឹងផ្លូវភេទ ដែលរឿងបែបនោះ អាចត្រូវបានគេរាយការណ៍ ។

**ផ្នែកទី ៦ សិទ្ធិកម្មករ**

**ក) សិទ្ធិបង្កើតសមាគម**

ច្បាប់ការងារ ផ្តល់ឱ្យកម្មករក្នុងវិស័យឯកជនដែលមានលក្ខណៈសេដ្ឋកិច្ចជាផ្លូវការពីសិទ្ធិចូលរួមក្នុងសហជីពកម្មករតាមការជ្រើសរើសរបស់គេ ដោយមិនចាំបាច់មានការអនុញ្ញាតជាមុននោះទេ។ ប៉ុន្តែ ការអនុវត្តសិទ្ធិ របស់រដ្ឋាភិបាលនេះ គឺគ្រាន់តែមានដោយ

អន្ទើប៉ុណ្ណោះ។  សមាជិកភាពនៅក្នុងសហជីពកម្មករ ឬសមាគមនិយោជិត មិនអាចបង្ខិតបង្ខំបានទេ ហើយកម្មករមានសេរីភាព ដកខ្លួនចេញពីអង្គការបែបនោះ ទោះជាយ៉ាងណាក៏សហជីពមួយចំនួនប៉ុនប៉ងគំរាមកម្មករដែលចង់ដកខ្លួនចេញក៏ដោយ ។ សហជីព អាចទាក់ទងគ្នាដោយសេរី  ប៉ុន្តែច្បាប់មិនបានចែងយ៉ាងជាក់លាក់អំពីសិទ្ធិរបស់គេដែលអាចទាក់ទងគ្នាជាអន្តរជាតិនោះទេ ។ ក្នុងខណៈដែលច្បាប់នេះ អនុវត្តចំពោះកម្មករបរទេស  វាមិនអនុវត្តចំពោះមន្ត្រីរាជការ រួមទាំងលោកគ្រូ-អ្នកគ្រូ ចៅក្រម និង បុគ្គលិកយោធា ឬចំពោះកម្មករក្នុងវិស័យក្រៅផ្លូវការឡើយ ។  បុគ្គលិកធ្វើការតាមឧស្សាហកម្មដឹកតាមអាកាសចរ និងនាវា មិនមានសិទ្ធិទទួលបានការការពារពេញលេញពីច្បាប់ទេ ប៉ុន្តែមានសេរីភាពក្នុងការបង្កើតសហជីព ។ ប្រជាពលរដ្ឋភាគច្រើនបំផុត របស់ប្រទេសកម្ពុជា បានធ្វើការនៅក្នុងវិស័យក្រៅផ្លូវការ ជាចំបងធ្វើជាកសិករដាំស្រូវសំរាប់ចិញ្ចឹមជីវិត អ្នកលក់ដូរឬធ្វើជា កម្មករមានជំនាញ ឬគ្មានជំនាញ ។ មានតែមួយភាគតូចប៉ុណ្ណោះ តាមការប្រមាណ គឺតិចជាង១ភាគរយនៃកម្មករដែលប្រើកម្លាំង បានបង្កើតជាសហជីព ។ សហជីពត្រូវបានប្រមូលផ្តុំនៅតាមឧស្សាហកម្មកាត់ដេរសំលៀក បំពាក់ និងធ្វើស្បែកជើងដែលមាន ប្រហែលពី ៤០ ទៅ ៥០ ភាគរយនៃកម្មករចំនួន ៣៥០.០០០នាក់ ចូលជាសមាជិកសហជីព ។ វិស័យទេសចរកម្ពុជា និងសហព័ន្ធ កម្មករផ្តល់សេវាកម្ម បង្ហាញឱ្យឃើញមានកម្មករ ៤.០០០នាក់ដែលធ្វើការនៅតាមសណ្ឋាគារ កាស៊ីណូ និងអាកាសយានដ្ឋាន ។ ក្នុងចំណោមសហព័ន្ធជាតិ និងសហជីពកម្មករចំនួន ៣១    ២៦មានសម្ព័ន្ធភាពជាមួយរដ្ឋាភិបាលចំនួន ៤រូបជាសហជីពនិង សហព័ន្ធ ឯករាជ្យ និង១រូបមានទំនោរគាំទ្រការប្រឆាំង។

សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ហៅកាត់ថា (CITA) មានឈ្មោះថាជា "សមាគម" ដោយមូលហេតុមានការហាមប្រាមក្នុង ការប្រមូលផ្តុំនៅតាមទីសាធារណៈ ហើយសមាគមនេះតំណាងឱ្យគ្រូបង្រៀនចំនួន ៨១៥០នាក់ ក្នុងចំណោមគ្រូបបង្រៀនទាំង អស់  ៨៩០០០នាក់ទូទាំងប្រទេស ។ ព្យុហៈយាត្រា និងការតវ៉ាដែលធ្វើឡើងដោយសមាគមនេះ ត្រូវបានគេហាមឃាត់ញឹកញាប់ ទោះបីជាគេរាយការថាការប្រមូលផ្តុំនេះមិនមានការពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងរដ្ឋាភិបាលទៅលើសកម្មភាពប្រចាំ-ថ្ងៃក៏ ដោយ ។ ផ្អែកលើមន្ត្រីសមាគមនេះបានឱ្យដឹងថា បុគ្គលិកមួយចំនួនរបស់សមាគមនេះមានការភ័យខ្លាចថាការពាក់ព័ន្ធជាមួយនឹង សមាគមនេះអាចមានការរាំងស្ទះដល់ឱកាសក្នុងការអភិវឌ្ឍការងាររបស់ពួកគេ។ សមាគមសាធារណៈមួយទៀតដែលមានឈ្មោះ ថា សមគមមន្ត្រីរាជការឯករាជ្យកម្ពុជា ហៅកាត់ថា (CICA) គឺជាសមាគមមួយដែលតំណាងឱ្យមន្ត្រីរាជការចំនួន ៥០០នាក់ មក ពីតាមបណ្តាក្រសួង មន្ទីរ ក្រុមប្រឹក្សាឃុំនានា ក្នុងចំណោមមន្ត្រីរាជការទាំងអស់ចំនួន ១០០.០០០នាក់ទូទាំងប្រទេស ។ ប្រធាន សមាគមនេះបានទទួលស្គាល់ថាការយាយី ឬការទំលាក់បុណ្យស័ក្តិ បានក្លាយជាបញ្ហាដែលធ្វើឱ្យមន្ត្រីរាជការទាំងនោះភ័យខ្លាចមិន ហ៊ានចូលរួមជាមួយនឹងសមាគម ។

មានសហជីព និងសហព័ន្ធឯករាជ្យ និងនិមយធ្វើការប្រឆាំងតវ៉ាមួយចំនួនមានការត្អូញត្អែយ៉ាងខ្លាំងទៅនឹងការពន្យាពេលដែលមិន មានការចាំបាច់ ព្រមទាំងការយកថ្លៃខ្ពស់ក្នុងការចុះបញ្ជីជាមួយនឹងរដ្ឋាភិបាល ។

ជាទូទៅគេសង្កេតឃើញថា សហជីពទាំងអស់នោះកសាងសមត្ថភាពរបស់ខ្លួនបានយឺតជាទីបំផុត ប៉ុន្តែមានសហជីពមួយចំនួនមិន អាចតំណាងចំណាប់អារម្មណ៍សមាជិករបស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយឡើយ ដោយសារតែមានកង្វះខាតទៅលើធនធានបណ្តុះ បណ្តាល និងបទពិសោធន៍ ។ ម្យ៉ាងវិញទៀត អំពើពុករលួយបានបង្កឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សហជីព និយោជក មន្ត្រីរាជការ និងទំនាក់ទំនងឧស្សាហកម្មស្របច្បាប់នានា។ អំពើហឹង្សា ការយាយី ព្រមទាំងការគំរាមកំហែងរវាងសហជីពដែល ជាគូប្រជែងតែងតែកើតមានឡើងញឹកញាប់ ។

កាលពីថ្ងៃទី១៤ ខែកុម្ភៈ កន្លងទៅនេះ មានបុរសមិនស្គាល់អត្តសញ្ញាណពីរនាក់បានបាញ់សម្លាប់ប្រធានសហជីពក្នុងស្រុកម្នាក់ គឺលោក ហ៊ឺ វុទ្ធី ខណៈពេលដែលលោកចេញពីធ្វើការវេណយប់ក្នុងរោងចក្រ Suntex ។ ចាប់តាំងពីឆ្នាំ២០០៥ មក រោងចក្រ Suntex និងរោងចក្រ Bright Sky ដែលជារោងចក្រស្ថិតនៅក្នុងបរិវេណជាមួយគ្នា បានក្លាយទៅជាទីតាំងបង្កជម្លោះ និងអំពើហឹង្សាររវាងសហជីព និងសហជីព ។ លោក ហ៊ឺ វុទ្ធី គឺជាសមាជិកម្នាក់នៅក្នុងសហជីពដ៏ធំមួយក្នុងប្រទេស គឺសហជីពសេរីកម្មករក្នុងព្រះរាជាណាចក្រកម្ពុជា ដែលហៅកាត់ថា (FTUWKC) ហើយការស្លាប់របស់លោកត្រូវបានគេគិតថាបណ្តាលមកការជាប់ពាក់ព័ន្ធជាមួយនឹងការងារសហជីពនេះឯង ។ ជនសង្ស័យមិនត្រូវបានរកឃើញឡើយ ។ ក្នុងឆ្នាំ ២០០៤ មានប្រធានសហជីពពីរនាក់ផ្សេងទៀតដែលមកពីសហជីព FTUWKC ដដែលត្រូវបានគេសម្លាប់ គឺលោក ជា វិជ្ជា និងលោក រស់សុននិរ៉េត ។

នៅក្នុងរោងចក្រមួយចំនួន បុគ្គលិកនៅក្នុងជួរគ្រប់គ្រង តែងតែបង្កើតសហជីពផ្ទាល់ខ្លួន ដើម្បីគាំទ្រសហជីពក្នុងជួរគ្រប់គ្រង ឬដើម្បីសម្របសម្រួលប្រធានសហជីព ។ ប្រធានសហជីពដែលស្ថិតក្នុងជួរនយោបាយតែងតែត្អូញត្អែថា សហព័ន្ធយុវជនខ្មែរនៃសហជីពរោងចក្រកាត់ដេរតែងតែគំរាមកំហែងធ្វើកូដកម្មដើម្បីទាមទាប្រាក់ពីអ្នកគ្រប់គ្រង ព្រមទាំងគំរាមកំហែង និងយាយីកម្មករមកពីសហជីពដទៃទៀតផងដែរ ។ ប្រធានសហជីពឯករាជមានការត្អូញត្អែថាសម្ព័ន្ធសហជីពកម្មករកម្ពុជាដែលនិយមខាងរដ្ឋាភិបាល បានធ្វើអន្តរាគមន៏ញជាញឹកញាប់ទៅក្នុងកិច្ចការរបស់សហជីពផ្សេងៗ ដោយទាមទាប្រាក់ពីអ្នកគ្រប់គ្រងជាថ្នូរនឹងការបញ្ចុះបញ្ចូលកម្មករកុំឱ្យធ្វើកូដកម្មនិងបាតុកម្មស្របច្បាប់ និងគំរាមកំហែងប្រធានសហជីពដែលជាគូប្រជែង ។

ការអនុវត្តសិទ្ធិសមាគម និងសេរីភាពមិនឱ្យមានការរើសអើងទៅលើសហជីពនៅមានភាពទន់ខ្សោយនៅឡើយ ។ ការអនុវត្តរបស់រដ្ឋាភិបាលត្រូវរាំងស្ទះដោយសាតែកង្វះខាតឆន្ទះនយោបាយ និងភាពចម្រូងចម្រាស់ផ្នែកហិរញ្ញវត្ថុ និងទំនាក់ទំនងផ្នែកនយោបាយជាមួយនឹងនិយាជិត និងប្រធានសហជីព ។ ក្នុងនោះរដ្ឋាភិបាលក៏ជួបប្រទះនូវកង្វះខាតធនធានផងដែរ ដែលរួមមាន : មន្ត្រីអធិការកិច្ចការងារគ្មានបទពិសោធន៍ និងមិនធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាល ហើយម្យ៉ាងទៀតរដ្ឋាភិបាលមិនផ្តល់ប្រាក់បៀវត្សរ៍ឱ្យបានគ្រប់គ្រាន់ ។ ជាញឹកញាប់ ក្រសួងការងារ ដែលបណ្តុះបណ្តាលខាងវិជ្ជាជីវៈ តែងតែឯកភាពទៅតាមការទាមទាររបស់កម្មករ ប៉ុន្តែក្រសួងនេះកម្រប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួនដើម្បីកាត់ទោសលើនិយាជក ដែលជាអ្នករំលោភលើបទបញ្ជារបស់ក្រសួងឡើយ ដោយតែងតែរុញបញ្ហាដែលកើតឡើងទៅឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជំនួសវិញ ។

មានរបាយការណ៍ដែលគួរឱ្យជឿជាក់ជាច្រើន ដែលបានរាយការអំពីការយាយីប្រឆាំងនឹងសហជីព ដែលមានដូចជា ការបណ្តេញប្រធានសហជីពចោល ពីរោងចក្រកាត់ដេរ និងសហគ្រាសផ្សេងៗ ។ ពេលខ្លះនិយោជកបានប្តឹងប្តល់ដល់តុលាការ ដើម្បី បណ្តេញ ឬ កាត់ទោសប្រធានសហជីព ។ នៅក្នុងរឿងក្តីចំនួនពីរករណី តុលាការបានចោទប្រកាន់ប្រធានសហជីពពីបទញុះញង់កម្មករឱ្យធ្វើកូដកម្ម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និងពីបទប៉ុនប៉ងញុះញង់កម្មករឱ្យប្រព្រឹត្តិអំពើហឹង្សា ។ នៅចុងឆ្នាំ តុលាការបាន ព្យួររឿងក្តីទាំងពីរនេះ ។ ពេលខ្លះប្រធានសហជីពដែលត្រូវគេបណ្តេញចោលទាំងនោះបានទទួលយកសំណងជាប្រាកដើម្បីបញ្ចប់ជម្លោះ បន្ទាប់ពីអំពាវនាវមិនបានសម្រេច ដើម្បីឱ្យរដ្ឋាភិបាលជួយដោះស្រាយឱ្យពួកគេបានចូលធ្វើការងារវិញ ។ នៅពេលខ្លះទៀត រដ្ឋាភិបាលមានការលើកកម្ពស់សិទ្ធិការងារខ្លះដែរ ។ ឧទាហរណ៍ : ក្រសួងករងារបានធ្វើការប្រមានក្រុមហ៊ុន ចំនួន ១០៣២ ពីបទរំលោភច្បាប់ ធ្វើការផាកពិន័យក្រុមហ៊ុនចំនួន ១០ និងបានចោទប្រកាន់ក្រុមហ៊ុនចំនួន ៥ ពីបទរំលោភច្បាប់ និងបទប្បញ្ញាការងារ ។ ក្នុងនោះក្រសួងការងារបានបញ្ជូនរឿងក្តីជំលោះការងារចំនួន ៨៣ករណី ដែលមិនអាចដោះស្រាយចេញទៅឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាដើម្បីធ្វើការដោះស្រាយ ។

## ខ. សិទ្ធិរៀបចំ និងចរចារួម

ច្បាប់បានផ្តល់សិទ្ធិក្នុងការរៀបចំ និងចរចារួម ប៉ុន្តែរដ្ឋាភិបាលមិនបានអនុវត្តច្បាប់ទាំងនោះឱ្យបានរលូនឡើយ ។ ជាទូទៅគេរៀបចំប្រាក់បៀវត្សរ៍យោងទៅតាមតម្លៃពលកម្មទីផ្សារ លើកលែងតែប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការ ដែលរដ្ឋាភិបាលជាអ្នកឱ្យរៀបចំ ។ ប្រាក់បៀវត្សរ៍អប្បបរមារបស់កម្មកររោងចក្រកាត់ដេរមានចំនួន ៥០ ដុល្លារក្នុងមួយខែ (ស្មើនឹង ២១០០០០រៀល) ។ ក្នុងអំឡុងពេលមួយឆ្នាំនេះ មានកិច្ចព្រមព្រៀងចរចារួមចំនួន ១៩ ដែលបានចុះបញ្ជីជាមួយនឹងក្រសួងការងារ ។ ភាគច្រើនគឺកិច្ចព្រមព្រៀងសម្រុះសម្រួលដែលមិនសមស្របទៅនឹងស្តង់ដារចរចារួមអន្តរជាតិ ។ មានតែកិច្ចព្រមព្រៀងចរចារួមចំនួនតែ ៦ ប៉ុណ្ណោះដែលមាននៅក្នុងរោងចក្រកាត់ដេរ មានចំនួន ១០ នៅក្នុងសណ្ឋាគារ និងមានចំនួន ១ គ្រប់ដណ្តប់ទៅលើកម្មករចុះកិច្ចសន្យាបម្រើការងារនៅក្នុងអាកាសយានដ្ឋានអន្តរជាតិ ។

បទបញ្ញត្តិមួយនៅក្នុងឆ្នាំ ២០០១ បានបង្កើតនិតិវិធី ដើម្បីអនុញ្ញាតឱ្យសហជីពតំណាងកម្មករក្នុងគោលបំណងចរចារួម ។ បទញ្ញត្តិទាំងនោះក៏បានបង្កើតលក្ខខណ្ឌជាច្រើនផងដែរសំរាប់និយោជក និងសហជីពពាក់ព័ន្ធទៅនឹងការចរចារួម និងបានផ្តល់លក្ខខណ្ឌការពារបន្ថែម ដើម្បីការពារប្រធានសហជីពពីការបណ្តេញចោល ។ ការិយាល័យទំនាក់ទំនងការងារមានភារកិច្ចសម្រប-សម្រួលដំណើរការចុះបញ្ជីសហជីព និងការបញ្ជាក់ពី "ឋានៈអ្នកតំណាងភាគច្រើនបំផុត" សំរាប់សហជីព ដែលបានផ្តល់ឈ្មោះថាជាសហជីពតំណាងឱ្យកម្មករភាគច្រើនបំផុតនៅក្នុងសហគ្រាស ដើម្បីតំណាងឱ្យកម្មករនៅក្នុងគ្រឹស្ថាននោះ ។ ប៉ុន្តែគេមើលឃើញថាដំណើរការចុះបញ្ជីអ្នកតំណាងភាគច្រើនមានភាពរញ៉េរញ៉ៃ ហើយអ្នកអង្កេតការណ៍អន្តរជាតិបានរាយការណ៍ថាបញ្ជីឈ្មោះ "សហជីពតំណាងភាគច្រើន" របស់រដ្ឋាភិបាល ដោយរួមទាំងសហជីពគ្រប់គ្រងដោយជួរអ្នកគ្រប់គ្រង និងសហជីពដែលមាន "តំណាងភាគច្រើន" គួរត្រូវផុតកំណត់ប៉ុន្មានមុននេះ ។ រដ្ឋាភិបាលបានចាប់ផ្តើមត្រួតពិនិត្យលើដំណើរការបញ្ជាក់ "តំណាងភាគច្រើន" ដោយមានការឧបត្ថម្ភពីអង្គការអន្តរជាតិ និងបេសកកម្មការទូត ។

ច្បាប់បានផ្តល់សិទ្ធិឱ្យធ្វើកូដកម្ម និងការពារអ្នកធ្វើកូដកម្មពីការវាយប្រហារតបត ។ ច្បាប់បានចែងថា ការធ្វើកូដកម្មអាចប្រព្រឹត្តិទៅបានដរាបណាមានការសមស្របទៅនឹងលក្ខខណ្ឌ ដែលរួមមានបរាជ័យលើយុទ្ធសាស្ត្រដោះស្រាយជម្លោះ (ដែលមានដូចជាការចចារ សម្របសម្រួល និងការសម្រេចដោយអាជ្ញាកណ្តាល) ការបោះឆ្នោតដោយសម្ងាត់របស់សមាជិកសហជីព និងមានការផ្តល់តំណឹង ៧ ថ្ងៃជាមុនដល់និយោជក និងក្រសួងការងារ ។

ក្រសួងការងារបានរាយការណ៍ឱ្យដឹងថាមានកូដកម្មចំនួន ៨២ លើកបានកើតឡើងរយៈពេលមួយឆ្នាំ ។ អ្នកអង្កេតការណ៍អន្តជាតិ និយោជក និងប្រធានសហជីពជាច្រើនបានទទួលស្គាល់ថា ស្ទើរតែគ្រប់កូដកម្មទាំងអស់មិនបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់ធ្វើកូដកម្មឡើយ ។ សហជីពផ្សេងទៀតបានតវ៉ាញថា ដោយសារតែគ្មានការចូលរួមពីក្រសួងការងារទើបណ្តាលឱ្យកូដកម្មនៅតាមរោងចក្រកាត់ដេរកើតមានឡើងដូច្នេះ ។

រដ្ឋាភិបាលបានអនុញ្ញាតឱ្យកម្មករធ្វើបាតុកម្មនៅតាមរោងចក្រ ប៉ុន្តែបានហាមមិនឱ្យកម្មករធ្វើការតវ៉ាប្រឆាំងនានានៅក្រៅតំបន់ដែលរោងចក្រស្ថិតនៅឡើយ ។ ជាទូទៅមានអន្តរាគមន៍តិចតួចបំផុតពីនគរបាល

ទោះបីជាក្នុងករណីខ្លះមានការបំផ្លិចបំផ្លាញទ្រព្យ- សម្បត្តិក៏ដោយ ។ ពេលខ្លះ វត្តមានរបស់នគរបាលក្នុងការធ្វើអន្តរាគមន៍ទៅលើកូដកម្មហាក់មានភាពហួសហេតុ ហើយជាញឹក- ញាប់ គេបានបញ្ចូលកងកម្លាំងអន្តរាគមន៍ពិសេសទៀតផងក្នុងការធ្វើការអន្តរាគមន៍លើកូដកម្ម ។

នៅថ្ងៃទី៤ ខែឧសភា មានកម្មករចំនួន ៤ នាក់ និងសន្តិសុខចំនួន ៥ នាក់បានរងរបួសនៅពេលដែលសន្តិសុខនៅក្នុងរោងចក្រកាត់ដេរ L.A. បានព្យាយាមរារាំងកម្មករមិនឱ្យចាកចេញពីរោងចក្រដើម្បីធ្វើកូដកម្ម។ កម្មករចំនួន ៤000 នាក់បានចូលរួមធ្វើកូដកម្មពីរថ្ងៃមុនពេលដែលពួកគេទាមទារសុំឱ្យបណ្តេញអ្នកគ្រប់គ្រងចោល ដោយសារតែមូលហេតុអ្នកគ្រប់គ្រងរូបនោះបានប្រមាទមើលងាយកម្មករ ។

នៅថ្ងៃទី ២១ ខែ ឧសភា មានកងកម្លាំងនគរបាលខេត្តចំនួនជាង ១00 នាក់បានប្រើអំពើហឹង្សាដើម្បីបំបែកហ្វូងបាតុករចំនួន ២00 នាក់ដែលបម្រើការងារនៅក្នុងរោងចក្រកាត់ដេរ River Rich ស្ថិតនៅក្នុងខេត្តកណ្តាល ។ កម្មករជាច្រើនបាននិយាយថានគរបាលបានវាយក្រុមបាតុករជាច្រើននាក់ ប៉ុន្តែនគរបាលបានបដិសេធន៍ថាមិនបានបង្កឱ្យមានរបួសស្នាមឡើយ ។ កូដកម្មបានកើតឡើង នៅពេលដែលអ្នកគ្រប់គ្រងមិនគោរពតាមពាក្យសន្យាអនុញ្ញាតឱ្យកម្មករចំនួន ១0 នាក់ចូលបម្រើការងារវិញខណៈពេលកិច្ចសន្យាការងារមិនត្រូវបានបង្ក ។ បន្ទាប់ពីការធ្វើកូដកម្ម អ្នកគ្រប់គ្រងបានគំរាមប្តឹងតំណាងសហជីព ៣ នាក់ពីបទញុះញង់ កម្មករឱ្យធ្វើបាតុកម្មខុសច្បាប់ និងពីបទរើសអើង ប៉ុន្តែបន្ទាប់មកបានញប់ការប្តឹងប្តល់នោះវិញ ។

នៅថ្ងៃ ២៩ ខែវិច្ឆិកា មានកងកម្លាំងនគរបាលប្រមាណជា ២00 នាក់បានប្រើអំពើហឹង្សាដើម្បីបំបែកហ្វូងបាតុករចំនួន ២000 នាក់ ដែលបម្រើការងារនៅក្នុរោងចក្រកាត់ដេរ Fortune ដែលតវ៉ាទៅនឹងការកាត់ប្រាក់ឧបត្ថម្ភ និងកិច្ចសន្យាការងារមានរយៈ-ពេលខ្លី ។ នគរបាលបានចោទប្រកាន់បាតុករទាំងនោះពីបទធ្វើឱ្យកកស្ទះផ្លូវ បង្កភាពឥតសណ្តាប់ធ្នាប់ ចោលដំថ្ម និងបង្ករបួសស្នាមដល់នគរបាល ។ កម្មករបាននិយាយថា នេះជាកូដកម្មអហឹង្សា ហើយការបង្ក្រាបរបស់នគរបាល ដោយមានទាំងពីបាញ់កាំភ្លើងឡើងជាការគំរាម និងការប្រើប្រាស់ឧស្ម័នបង្ហូរទឹកភ្នែក បានធ្វើឱ្យកម្មករចំនួន ៣ នាក់មានរបួស។ នគរបាលបានចាប់ខ្លួនកម្មករចំនួន ៤ នាក់ ប៉ុន្តែបានដោះលែងមកវិញនៅថ្ងៃដដែល ។

ពុំមានការវិវត្តន៍ណាមួយឡើយនៅក្នុងរឿងក្តី ខែ កក្កដា ឆ្នាំ ២00៦ របស់ប្រធានសហជីពរោងចក្រកម្រិតបីពាក់ព័ន្ធទៅនឹងសហជីព FTUWKC ដែលត្រូវបានកាត់ទោសពីបទឃុំឃាំងមនុស្សដោយខុសច្បាប់។ បន្ទាប់ពីការឃុំឃាំងចំនួន ១ ខែ ៤ ថ្ងៃនៅក្នុងពន្ធនាគារ គេបានដោះលែងកម្មករទាំងនោះឱ្យមានសេរីភាពវិញ ។

ក្រៅពីមានបញ្ញត្តិច្បាប់ការពារបាតុករពីការប្រឆាំងតបត មានរបាយការណ៍ដែលគួរឱ្យជឿជាក់ជាច្រើនបានរាយការណ៍ថា គេបានបណ្តេញកម្មករចោលដោយគ្មានមូលហេតុត្រឹមត្រូវ ក្រោយពេលដែលកម្មករទាំងនោះបានរៀបចំ ឬចូលរួមនៅក្នុងកូដកម្ម ។ ខណៈពេល ដែលមានកូដកម្មមិនស្របច្បាប់កើតឡើង
ការចូលរួមរបស់កម្មករក្នុងកូដកម្មនោះក៏មិនគួរយកមកធ្វើជាហេតុផលក្នុងការ បណ្តេញកម្មករចោលឡើយ ។ ក្នុងករណីខ្លះទៀត និយោជកត្រូវបានគៀបសង្កត់កម្មករឱ្យទទួលយកប្រាក់សំណង ហើយបានបញ្ឈប់ពីការងារ ។ មានមធ្យោបាយល្អៗជាច្រើនក្នុងការដោះស្រាយបញ្ហាបណ្តេញបុគ្គលិកនេះ ទោះបីជាមធ្យាបាយទាំងនោះ គ្មានប្រសិទ្ធ ភាពក៏ ដោយ ។ ក្រសួងការងារអាចចេញបទបញ្ជាដោយឱ្យកម្មករចូលបម្រើការងារដូចធម្មតាវិញ ប៉ុន្តែការធ្វើដូច្នេះហាក់ជំរុញឱ្យអ្នកគ្រប់គ្រងគៀបសង្កត់កម្មករឱ្យលាលែងចេញពីការងារជាថ្នូរនឹងប្រាក់សំណង ។ ជម្លោះរួម ដូចជានៅពេលដែលគេបាន បណ្តេញនិយោជិតចេញពីការងារ គេអាចដោះស្រាយជម្លោះនោះដោយការសម្រេចចិត្តដាច់ពីគ្នា នៅមុនពេលបញ្ជូនទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចំពោះជម្លោះបុគ្គលិកគេអាចដោះស្រាយនៅមុនតុលាការ ទោះបីជាប្រព័ន្ធយុត្តិធម៌មានភាពលំអៀង និងមិនមានតម្លាភាពក៏ដោយ ។ សហជីពខ្លះបានជំរុញឱ្យរដ្ឋាភិបាលពង្រីក តួនាទីក្រុមប្រឹក្សាអាជ្ញារកណ្តាល ដើម្បីបញ្ចូលវិវាទដែលមានផលប្រយោជន៍រួមនិងដល់បុគ្គល និងធ្វើសេចក្តីសំរេចរបស់ខ្លួនជាស្ថាពរ ។

នៅតែបន្តការភាន់ច្រឡំអំពីតួនាទីត្រួតត្រារបស់សហជីពកម្មករ និងអ្នកបំរើនៅតាមហាងដែលបានជ្រើសរើស ។ យោងតាមបទបញ្ជា ប្រធានសហជីពមានតួនាទីប្រដូចទៅនឹងអ្នកបំរើនៅតាមហាង ហើយមន្ត្រីសហជីពទាំងអស់ ទទួលបានការការពារពីការបណ្តេញចេញពីសហគ្រាស ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី និយោជក ជារឿយៗមិនបានគោរពការការពារទាំងអស់នេះទេ ។មិនមានច្បាប់ពិសេស ឬការលើកលែងណាមួយពីច្បាប់ការងារដែលជាក់លាក់នៅក្នុងតំបន់ដំណើរការនាំផលិតផលចេញទេ (ដែលត្រូវបានគេដឹងថាជាតំបន់សេដ្ឋកិច្ចពិសេស) ។

### គ) ការហាមឃាត់ពលកម្មបង្ខិតបង្ខំ និងប្រើកម្លាំងហួសហេតុ

ច្បាប់ហាមឃាត់ពលកម្មបង្ខិតបង្ខំ និងប្រើកម្លាំងហួសហេតុ រួមទាំងពលកម្មកុមារផង ប៉ុន្តែមានរបាយការណ៍ជាច្រើនរាយការណ៍ថា ការអនុវត្តនៅតែកើតមាន ស្ទើរតែនៅគ្រប់វិស័យក្រៅផ្លូវការទាំងស្រុង ។

មានរបាយការណ៍នៃករណីដាច់ដោយឡែកអំពីពលកម្មប្រើ កម្លាំងដោយកម្មករធ្វើការនៅក្នុងស្រុក ។ ពលកម្មបង្ខិតបង្ខំលើកុមារគឺជាបញ្ហាមួយធ្ងន់ធ្ងរនៅក្នុងឧស្សាហកម្មជំនួញផ្លូវភេទ ។

ការធ្វើការលើសម៉ោងដោយមិនស្ម័គ្រចិត្ត មានស្ទើរគ្រប់ទីកន្លែង ។ តាមច្បាប់ការងារ ការធ្វើការលើសម៉ោងស្របច្បាប់គឺ មិនអាចលើសពី ២ម៉ោងក្នុងមួយថ្ងៃ និងត្រូវតែមានការស្ម័គ្រចិត្តទៀតផង។ ប៉ុន្តែជាទំលាប់ ការងារលើសម៉ោង ជារឿយៗបន្ទាយហួសពីព្រំដែននៃ ច្បាប់ ហើយនិយោជកប្រើការគាបសង្កត់បង្ខំនិយោជិតឱ្យធ្វើការ។ កម្មករតែងតែប្រឈមមុខនឹងការផាកពិន័យការបណ្តេញចេញ ឬបាត់បង់ប្រាក់បន្ថែម ប្រសិនបើគេបដិសេធមិនធ្វើការងារលើសម៉ោងទេ។

### ឃ) ការហាមឃាត់ពលកម្មកុមារ និងអាយុអប្បបរិមាសំរាប់ប្រកបការងារ

រដ្ឋាភិបាលបានអនុម័តច្បាប់ ដើម្បីការពារកុមារពីការកេងប្រវ័ញ្ចនៅកន្លែងធ្វើការ ប៉ុន្តែជារឿយៗការអនុវត្តនេះមិនបានខ្លាំងក្លានោះទេ ។ ច្បាប់បានចែងថា អាយុ១៥ឆ្នាំដែលជាអាយុអប្បបរិមាសំរាប់ប្រកបការងារ និង១៨ឆ្នាំជាអាយុអប្បបរិមាសំរាប់ការងារណា ដែលប្រកបដោយគ្រោះថ្នាក់ ។ ច្បាប់អនុញ្ញាតឱ្យកុមារដែលមានអាយុចាប់ពី ១២ឆ្នាំ ទៅដល់១៥ឆ្នាំ អាចចូលរួមធ្វើការងារណាដែលស្រាល មិនមែនជាការងារដែលប្រកបទៅដោយគ្រោះថ្នាក់ដល់សុខភាពរបស់ពួកគេទេ និងមិនឱ្យប៉ះពាល់ដល់ការសិក្សានៅសាលាឡើយ ។ ការសិក្សា មួយនៅក្នុងឆ្នាំ ២០០៦ដោយធនាគារពិភពលោក អង្គការពលកម្មអន្តរជាតិ (ILO) អង្គការមូលនិធិកុមារអន្តរជាតិរបស់អង្គការសហប្រ ជាជាតិ (UNICEF) បានធ្វើការប៉ាន់ប្រមាណថា មានកុមារចំនួន ១,៥ លាននាក់ដែលជាប់ពាក់ព័ន្ធទៅនឹងពលកម្មខុសច្បាប់ រួមមានទាំងកុមារៗដែលមានអាយុក្រោម១២ឆ្នាំចំនួន ៧៥០,០០០នាក់ និងកុមារអាយុពី១២ ទៅដល់១៤ឆ្នាំចំនួន៥០០,០០០នាក់ដែលពាក់ព័ន្ធនៅក្នុងសកម្មភាពសេដ្ឋកិច្ចដែលមិនមែនជាការងារស្រាល និងកុមារច្រើនជាង ២៥០,០០០នាក់អាយុពី១៥ ទៅ១៧ឆ្នាំធ្វើការនៅក្នុងវិស័យប្រកបទៅដោយគ្រោះថ្នាក់និងហាមឃាត ឬធ្វើការលើសពី៤៣ម៉ោងក្នុងមួយសប្តាហ៍ ។

គ្មានទស្សនៈណាមួយចំពោះច្បាប់ដែលហាមឃាត់ពលកម្មកុមារនោះ ត្រូវបានអនុវត្តដោយគ្រប់គ្រាន់នៅក្នុងវិស័យការងារជាផ្លូវការ នោះទេ ។ គ្មាននិយោជកណាម្នាក់ត្រូវបានកាត់ទោសដោយសារការរំលោភច្បាប់ប្រឆាំងទៅនឹងពលកម្មកុមារឡើយ ។ ក្រសួងការងារ សង្គមកិច្ច អតីតយុទ្ធជន (MOLVT) មានការទទួលខុសត្រូវចំពោះបញ្ហាពលកម្មកុមារក្នុងវិស័យសេដ្ឋកិច្ចទាំងក្រៅផ្លូវការនិងក្នុងផ្លូវការ ប៉ុន្តែអធិការកិច្ចការងាររបស់ក្រសួង មិនបានបំពេញតួនាទីនៅក្នុងវិស័យក្រៅផ្លូវការ

ឬក្នុងការអនុវត្តច្បាប់នៅតាមឧស្សាហកម្មខុស ច្បាប់ឡើយ ។ នៅក្នុងវិស័យផ្លូវការ អធិការកិច្ចការងារបានធ្វើការត្រួតពិនិត្យ ឧស្សាហកម្មខ្លះៗជាធម្មតា ដូចជារោងចក្រកាត់ដេរ ជាដើម (ដែលការកើតឡើងនៃពលកម្មកុមារមានស្ទួចស្តើង) ប៉ុន្តែនៅតាម ឧស្សាហកម្មខ្លះដែលមានចំនួនគ្រោះថ្នាក់ខ្ពស់បំផុត ចំពោះពលកម្មកុមារគឺ ការធ្វើអធិការកិច្ចការងារត្រូវបានគេជំរុញទាំងស្រុង តាមរយៈការដាក់ពាក្យបណ្តឹង ។

រដ្ឋធម្មនុញ្ញបានហាមឃាត់ពលកម្មកុមារដោយបង្ខំ ឬដោយចំណងធានា តែទោះជាយ៉ាងណាក្តី ពលកម្មកុមារដោយការបង្ខំគឺជា បញ្ហាមួយ ដ៏ធ្ងន់ធ្ងរនៅក្នុងឧស្សាហកម្មជំនួញផ្លូវភេទ ។

ភ្នាក់ងារអនុវត្តច្បាប់ខកខានមិនបានទប់ស្កាត់ពេស្យាចារកុមារនៅក្នុងលក្ខណៈមួយប្រកប ទៅដោយចីរភាពនិងស៊ីសង្វាក់គ្នា ។ ការរាលដាលនៃអំពើពុករលួយ ការខ្វះខាតតម្លាភាព ប្រភពធនធានមិនគ្រប់គ្រាន់ និងការខ្វះខាត បុគ្គលិកស្ថិតនៅជាឧបសគ្គ មួយដែលត្រូវប្រឈមមុខច្រើនជាទីបំផុត ។

**ង) ស្ថានភាពការងារដែលអាចទទួលយកបាន**

ច្បាប់តំរូវឱ្យក្រសួងការងារ សង្គមកិច្ច និងអតីតយុទ្ធជន (MOLVT) បង្កើតនូវប្រាក់កំរៃជាអប្បបរិមាក្នុងវិស័យកាត់ដេរដោយ ផ្អែក ទៅលើអនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាការងារ ។ គ្មានប្រាក់កំរៃអប្បបរិមាចំពោះឧស្សាហកម្មដទៃទៀតទេ ។ ប្រាក់កំរៃជា អប្បបរិមាសំរាប់វិស័យនេះ គឺមានចំនួន ពី ៤៥ ទៅដល់ ៥០ដុល្លា ស្មើនឹង (១៨៩.០០០ ទៅ ២១០.០០០រៀល) ក្នុងមួយខែ ។ និយោជក ស្ទើតែទាំងអស់នៅក្នុងវិស័យកាត់ដេរ បានផ្តល់ប្រាក់កំរៃដល់កម្មករ យ៉ាងហោចណាស់ក៏មានកំរិតជា អប្បបរិមានោះផងដែរ តែបើទោះជា យ៉ាងណាក៏កម្មករធម្មតាខ្លះ ជារឿយៗ ត្រូវបានគេផ្តល់ប្រាក់ឱ្យតិចជាងនេះក៏ដោយ ។ កម្មករកាត់ដេរ ទទួលបានប្រាក់កំរៃជាមធ្យមចំនួន ពី ៧០ ទៅ ៨០ដុល្លា ស្មើនឹង (២៩៤.០០០ ទៅ ៣៣៦.០០០រៀល) ក្នុងមួយ ខែ រួមទាំងប្រាក់ការងារលើសម៉ោង និងប្រាក់បន្ថែមទៀត ។ ប្រាក់ខែជាទូទៅនៅក្នុងវិស័យកាត់ដេរ និងវិជ្ជាជីវៈជាច្រើនផ្សេងៗ ទៀត មិន គ្រប់គ្រាន់ចំពោះកម្មករ និងគ្រួសាររបស់គេឱ្យមានជីវភាពរស់នៅដោយថ្លៃថ្នូរឡើយ បើទោះជាប្រាក់ខែក្នុងវិស័យកាត់ ដេរ ជាទូទៅ ខ្ពស់ជាងប្រាក់ខែនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការនោះក៏ដោយ ។ ប្រាក់ខែរបស់មន្ត្រីរាជការក៏មិនគ្រប់គ្រាន់ដើម្បី ផ្តល់ឱ្យកំរិតជីវភាពរស់នៅរបស់គេឱ្យបានថ្លៃថ្នូរ ដែលជាហេតុតំរូវឱ្យមន្ត្រីរដ្ឋាភិបាលស្វែងរកប្រភពចំណូលពីខាងក្រៅ ដោយ ករណីជាច្រើន តាមរយៈរកការងារទីពីរ ឬទទួលសំណូកជាដើម ។

នៅថ្ងៃទី ៨ មិថុនា កន្លងមកនេះ ថ្វីត្បិតតែមានការតវ៉ាយ៉ាងខ្លាំងក្លាពីសហជីពខ្លះ រដ្ឋសភាបានធ្វើវិសោធនកម្មច្បាប់ការងារដើម្បី បង្កើតឱ្យមានអត្រាប្រាក់កំរៃផ្លាស់ប្តូរវេនយប់ដែលមាន ១៣០ភាគរយនៃប្រាក់កំរៃពេលថ្ងៃ ។ មុនការធ្វើវិសោធនកម្មនេះ ការអនុវត្តន៍ជាទំលាប់ គឺផ្តល់ប្រាក់ឱ្យកម្មករផ្លាស់ប្តូរវេនយប់ ២០០ភាគរយនៃប្រាក់កំរៃពេលថ្ងៃហើយរោងចក្រមួយចំនួន ប្រតិបត្តិ ការងារផ្លាស់ប្តូរវេនយប់ ដោយសារតែមានការចំណាយទៅលើប្រាក់ខែខ្ពស់ពេក។

ច្បាប់មានចែងចំពោះរយៈពេលធ្វើការងារប្រចាំសប្តាហ៍ដោយស្របតាមបទដ្ឋានច្បាប់មានចំនួន ៤៨ម៉ោងក្នុងមួយសប្តាហ៍ដោយ មិនឱ្យ លើសពី ៨ម៉ោងក្នុងមួយថ្ងៃឡើយ ។ ច្បាប់ចែងសំរាប់ការងារលើសម៉ោងក្នុងមួយម៉ោងទទួលបានប្រាក់កំរៃមួយម៉ោងកន្លះ និងទទួល បាន២ម៉ោងនៅពេល ធ្វើការយប់ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យឈប់សំរាក។ និយោជិតទាំងអស់ត្រូវបានគេអនុញ្ញាតឱ្យ ធ្វើការងារលើស ម៉ោងរហូតដល់២ម៉ោងជារៀងរាល់ថ្ងៃ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាល មិនបានអនុវត្តបទដ្ឋានទាំងនេះឱ្យមាន

ប្រសិទ្ធិភាពទេ។ កម្ម ករបានរាយការណ៍ថា ការងារលើសម៉ោង ជារឿយៗ ច្រើនហួសហេតុ និងជួនកាលមានការបង្ខំផង ។ ស្រដៀងគ្នានោះដែរ ក្រៅពី វិស័យឧស្សាហកម្មកាត់ដេរ បទបញ្ញត្តិអំពីម៉ោងការងារ កំរនឹងត្រូវបានគេអនុវត្តតាមណាស់ ។ ច្បាប់ចែងថា ទីកន្លែងធ្វើការ ត្រូវតែមានបទដ្ឋានសុវត្ថិភាព និងសុខភាពឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសុខុមាលភាពរបស់កម្មករ ។ រដ្ឋា ភិបាល បានអនុវត្តបទដ្ឋានដែលមានស្រាប់នោះតែដោយអន្លើប៉ុណ្ណោះ ជាផ្នែកមួយគឺដោយសារតែមានការខ្វះខាតបុគ្គលិក ដែលមានការហ្វឹកហ្វឺន និងសំភារៈ ។ ការរងគ្រោះទាក់ទងនឹងបញ្ហាការងារ និងបញ្ហាសុខភាព គឺជាការធម្មតា ។ រោងចក្រកាត់ដេរធំៗ ភាគច្រើនដែលផលិតសំលៀកបំពាក់សំរាប់ទីផ្សារនៅប្រទេសអភិវឌ្ឍន៍ទាំងឡាយ មិនសូវជាជួបបញ្ហាផ្នែកសុខភាព និងសុវត្ថិភាពប៉ុ ន្មានទេ ដោយសារតែមានល័ក្ខខ័ណ្ឌនៃកិច្ចសន្យារបស់គេជាមួយអ្នកទិញ ។ ស្ថានភាពការងារនៅតាមរោងចក្រខ្នាតតូចៗខ្លះ និង ឧស្សាហកម្មធុនតូចមានលក្ខណៈមិនសូវល្អ និងជារឿយៗមិនត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិទេ ។ ទោសបញ្ញត្តិមានចែងនៅក្នុងច្បាប់ ប៉ុន្តែមិនមានបញ្ញត្តិណាជាក់លាក់ ដើម្បីការពារកម្មករដែលប្តឹងអំពីស្ថានភាពគ្មានសុវត្ថិភាពឬគ្មានសុខភាពឡើយ ។ កម្មករដែលព្យា យាមគេចចេញដោយខ្លួនឯងពីស្ថានភាពការងារគ្មានសុវត្ថិភាពប្រថុយនឹងការបាត់បង់ការងារ ។